# ប្រវត្តិពុទ្ធឧបាសិកា

# ភាគទី ៣



ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ :..២២៥ សជណ

រាជធានីភ្នំពេញ,ថ្ងៃទី..០៤...ខែ..កុម្ភៈ..ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- សាលាខេត្តបាត់ដំបង
  " ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

*សៀវភៅប្រវត្តិពុទ្ធឧបាសិកា ឬប្រវត្តិឧបាសិកា* ភាគ ៣ នេះ *មានប្រវត្តិរបស់ឧបាសិកាជាឯតទគ្គៈក៏មាន មិនមែនជាឯតទគ្គៈក៏មាន មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវរបស់ឧបាសិកា នាសម័យពុទ្ធកាល ដែលបានទទួលតំណែងជាឯតទគ្គៈ ហើយមានឈ្មោះល្បីល្បាញ នាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរុងរឿងចម្រើន ដល់ពុទ្ធបរិស័ទ នៅក្នុងសម័យនោះផងដែរ ។*

*ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែង ឬភាពអស្ចារ្យ នៃឧបាសិកាទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្តាប់ព្រះធម៌របស់ឧបាសិកា អ្នកខ្លះបានធ្វើធម្មសាកច្ឆាជាដើម ។ប៉ុន្តែ ឥឡូវនេះ ភាពអស្ចារ្យរបស់ឧបាសិកាខ្លះៗ ពុទ្ធបរិស័ទក្នុងសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវភាពអស្ចារ្យ តួនាទី ចរិយាអធ្យាស្រ័យ វត្តបដិបត្តិ និងការសម្តែងព្រះធម៌ផ្សេងៗ របស់ឧបាសិកាទាំងអស់នោះ ដែលមានសម្តែងទុកនៅក្នុង* គម្ពីរព្រះត្រៃបិដក *និងក្នុង*

**អដ្ឋកថា** ជាដើម ព្រោះថា ព្រះពុទ្ធសាសនា ដែលចម្រើនរុងរឿងនោះ ក៏អាស្រ័យមានអ្នកចងចាំ បដិបត្តិតាម និងចេះសម្ដែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្ដាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ឧបាសិកាទាំងអស់នោះ ជាសក្ខីភាព បញ្ជាក់ឲ្យដឹងបានថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារឧបាសិកាផងដែរ ទើបខ្ញុំព្រះករុណាអាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចងក្រង ទុកជាពន្លឺដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចដាក់ភាសាបាលីផងបានទេ ព្រោះថាមានសេចក្ដីពិស្ដារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើរជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត

ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ដូនដោយចេះមិនដល់ ដូនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិតជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

**សូមអស់មិត្តអ្នកអាន** បានទទួលនូវការចេះដឹង ជាកេរ្តិ៍មរតកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់ព្រះនិព្វាន ដែលជាបរិយោសាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤**

**សែន ៩ ម៉ឺន ៥ ពាន់រៀល) និងប្រាក់ដុល្លារ ៦៤៥ ដុល្លារសហរដ្ឋអាមេរិក ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅប្រមាណ ៦៥ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ* **ថ្វាយបង្គំបាន ៥១ កន្លែង** *បានការឧបត្ថម្ភអំពីឧបាសក* **ឡាយ សុខុម** *និងឧបាសិកា* **ឱម លក្ខណា** *នៅក្នុង* **ព.ស. ២៥៥០** *( ១០.០២.២០០៧ ) ។*

## **ទឹកឃើញស្រុកព្រះ**

*ទឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា*
*សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា*
*ជ្រះថ្លាក្រៃលែង ។*
*៦៥ អង្គា គាល់ព្រះកគវា ៥១ កន្លែង*
*នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក*
*ក្នុងព.ស.២៥៥០ ។*

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល) និង ប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិប ចណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

នឹកឃើញលង្កា នឹកឃើញកាលណា ជ្រះថ្លាក្រៃលែង
នៅពុទ្ធស្ថាន ១៩ កន្លែង ដែលខ្ញុំបានស្វែង
ទៅថ្វាយបង្គំ ។

១២១ អង្គា　　គាល់ព្រះបាទា　នាស្ថានមនោរម
លើសុមនកូដ　　ជេស្ឋាឧត្តម　ជាកំពូលភ្នំ
ក្នុងប្រវត្តិពុទ្ធ ។
ទឹកដីលង្កា　　ទឹកដីអស្ចារ្យ　ពេញពោរដោយឫទ្ធិ
នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត　ធម្មយាត្រាប្រណីត
ក្នុង ព.ស. ២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥២** ផ្នែកខាងសម្តេចព្រះធម៌ ដូចគ្នានឹង **ព.ស. ២៥៥១** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល ) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ២** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុធារត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥**

**ព្រះអង្គផងដែរ** បានការឧបត្ថម្ភពីឧបាសក **យឹត សុខណារ៉ត** ឧបាសិកា **ហ៊ិន ម៉ៅរ៉ាវិនី** M. SU SOKUNORA et Mme INN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងពីឧបាសិកា **អ៊ីវ រិទ្ធារី** ឧបាសិកា **ស្នួន គល្យាណៈ** ឧបាសិកា **ស្នួន ចរណៃ** នៅក្នុង **ព.ស. ២៥៥២** ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់   ព្រះពុទ្ធជាម្ចាស់   គុណធំក្រៃលែង
ច្រើនពុទ្ធសកករាជ   សាសនាអង្វែង   ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។

នៅស្រុកឥណ្ឌា   ៦៧ អង្គា   រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន   ព្រមចិត្តផង់ថ្លា   បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុខផារ៉ត** ជាប្រធាន ( ក្នុងឆ្នាំដែលគេបើកព្រះចង្កូមកែវស្តាំខាងក្រោម ខ្ញុំព្រះករុណា បានទៅ

ថ្វាយបង្គំព្រះចន្ទមកែវបាន ៥-៦ ដង ឃើញហើយជ្រះថ្លាណាស់ មនុស្ស ដែលទៅថ្វាយបង្គំពេលនោះ មានរាប់លាន រាប់សែននាក់ មានសភាពគួរឲ្យជ្រះថ្លាចំពោះចិត្តចេតនាដែលកើតឡើង ពីព្រោះ ព្រះចន្ទមកែវនៅក្នុងប្រទេសស្រីលង្កា ៥ ឆ្នាំ ទើបបើកម្តង ) ក្នុងការ ដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៣៦ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៣ ព្រះអង្គផងដែរ បានការ ឧបត្ថម្ភមកអំពីឧបាសក ឆាយ អ៊ិចសាវ ឧបាសិកា ហ្វង គីមសែ ក្រោមការជ្រោមជ្រែងពីឧបាសក យន្ត សួន នៅក្នុង ព.ស. ២៥៥២ ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៣ ផ្នែកខាងសម្តែង ព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥២ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( ១៣ លាន ០ សែន ៨ ម៉ឺន) និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន

ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៣** ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ញប់ស្ញែងអស្ចារ្យ
ឱះឱ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង **ព.ស. ២៥៥៤** ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង **ព.ស. ២៥៥៣** ដែរ ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល** ( **៣១ លាន ៩ សែន ៩ ម៉ឺន**) **និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល

ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ៤** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងពីឧបាសក **ឡាយ សុខុម** នៅក្នុង **ព.ស. ២៥៥៤** ( ២៧.០២.២០១១ ) ។

## គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាន
ប្រៀបបានព្រៃស្ងាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាំដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. **២៥៥៥** ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. **២៥៥៤** ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស.

**២៥៥៥** ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( **៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់**រៀល ) និងប្រាក់ដុល្លារ **២៧៥៨** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាលើកទី ៥** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅ ប្រមាណ **៦៨ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គ**ផងដែរ ដោយទៅថ្វាយបង្គំបាន **១៤** កន្លែងធំៗ បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង **ព.ស. ២៥៥៥** ( ០២.០២.២០១២ ) ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាលើកទី ៣** មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១៤០ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ១៥** ព្រះ

អង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩ កន្លែងធំៗ បានការឧបត្ថម្ភមក អំពីឧបាសិកា **អ៊ុង រិទ្ធារី** នៅក្នុង ព.ស. ២៥៥៥ (២៧.០៣.២០១២)។

## បានយល់ស្រុកព្រះ

| | | |
|---|---|---|
| ប្រទេសខ្លាំងណាស់ | បានយល់ស្រុកព្រះ | ជាតិភូមិសាស្តា |
| ១៤ កន្លែង | ៦៨ អង្គ | បានក្រាបវន្ទា |
| | បូជាគ្រប់ប្រាណ ។ | |
| សិរីលង្កា | ១៤០ អង្គា | ៩ ពុទ្ធស្ថាន |
| ប្រទេសខ្លាំងណាស់ | ដែលពួកខ្ញុំបាន | នមស្ការពុទ្ធស្ថាន |
| | ក្នុងពុទ្ធសករាជ ២៥៥៥ ។ | |

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យង់ សុង** (ស្លាប់) និងញោមស្រី **ឈឹម ហាយ** (ស្លាប់) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត

រស់ សុផាត លោកគ្រូធម្មាចារ្យ គាំ អ៊ីច ឧបាសិកា គួ ប៊ុនគាង បងស្រី ឈុំ គីមហួយ និងឧបាសិកា ង៉ែត យូអេង ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវ័កបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះ

ឃ

*សក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា* **នត្ថិ សន្តិ បរំ សុខំ** *ពុំមានសេចក្ដីសុខដទៃក្រៅអំពីសេចក្ដីស្ងប់ឡើយ ។*

*អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៦*

*ត្រូវនឹងថ្ងៃអង្គារ ទី ៣០ ខែតុលា ឆ្នាំ ២០១២*

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត*

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ម៉ូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ុម សុខាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន ចណ្ណា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ុម វីយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការងារធម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក បួ ស៊ីផួ ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ុច ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រិម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

# សមាជិកសមាគមធម្មទានអរិយវង្សយង់សុផាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ **យង់ សុផាត** ជាប្រធានសមាគម

លោកអភិបាលស្រុក **ស្រេង ស្រ៊ាង** ជាទីប្រឹក្សាសមាគម

ឧបាសក **អ៊ឹម វ៉ៃយ៉ា** ជាអនុប្រធានសមាគម

ឧបាសិកា **ង៉ែត យូអេង** ជាអនុប្រធានសមាគម

សាមណេរ **ម៉ី សាលួន** ជាលេខាធិការ

ឧបាសក **ឡាន សុខុម** ជាលេខាធិការរង

ឧបាសិកា **តាំង ប៉ោងជីង** ជាហេរញ្ញិក

ឧបាសិកា **ជា នាង** ជាបេឡា

លោកគ្រូធម្មបណ្ឌិត **អឿ សៅ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **គួ ប៊ុនគាង** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ឈុំ គីមហួយ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក **ឡាយ សុខុម** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **អ៊ុង រិទ្ធារី** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ហោ ភាព** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ប៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស ម៉ូនីតា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹក ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀក ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែង កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហ៊ុង សុវណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង


ល.រ ទំព័រ

១- ឈ្មោះរបស់ឧបាសិកា ............................................ ន

២- ជីវប្រវត្តិរបស់ឧបាសិកាសុប្បិយា ............................ ១

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកបម្រើជំងឺ

៣- ជីវប្រវត្តិរបស់ឧបាសិកាកាតិយានី ............................ ២១

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកជ្រះថ្លាមិនកម្រើក

៤- ជីវប្រវត្តិរបស់ឧបាសិកានកុលមាតាគហបតានី ......... ២៩

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល

៥- ជីវប្រវត្តិរបស់ឧបាសិកាកាឡី .................................. ៥០

ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗ គ្នា

៦- ជីវប្រវត្តិរបស់ព្រះនាងមល្លិកាទេវី ............................ ៩៦

ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

៧- ជីវប្រវត្តិរបស់ព្រះនាងចុន្ទីរាជកុមារី ........................ ១៦៣

ដែលជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

៨- ជីវប្រវត្តិរបស់ព្រះនាងរោហិណី .............................. ១៧១

ដែលជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

៩- ជីវប្រវត្តិរបស់ព្រះនាងសុមនារាជកុមារី .................. ១៨៣

ដែលជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១០- ជីវប្រវត្តិរបស់ឧបាសិកាចូឡសុភទ្ទា ..................... ២០៦

ដែលជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

១១- ជីវប្រវត្តិរបស់នាងបតិបូជិកា ............................... ២៣២

ដែលជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ

ន

# ជីវប្រវត្តិពុទ្ធឧបាសិកា ឬជីវប្រវត្តិរបស់ឧបាសិកា

មានឈ្មោះ ឧបាសិកា សុជាតា និងឧបាសិកា វិសាខា ជាដើម សុទ្ធសឹងតែជាឧបាសិកាដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រដូចបាន បាលីហៅថា **ឯតទគ្គៈ** គឺបានដល់ភាពប្រសើររបស់ឧបាសិកាម្នាក់ៗ ដូចជាឧបាសិកា សុជាតា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងអ្នកដល់សរណៈជាបឋម ឧបាសិកា វិសាខា ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងការឲ្យទានដូច្នេះជាដើម ។

ដូច្នេះ ពុទ្ធឧបាសិការបស់ព្រះបរមគ្រូនៃយើងនេះ មានឈ្មោះរបស់លោកដូចខាងក្រោមនេះ គឺ

១- ឧបាសិកា សុជាតា ២- ឧបាសិកា វិសាខា

៣- ឧបាសិកា ខុជ្ជុត្តរា ៤- ឧបាសិកា ឧត្តរា

៥- ឧបាសិកា សុប្បវាសា ៦- ឧបាសិកា សុប្បិយា

៧- ឧបាសិកា កាតិយានី ៨- ឧបាសិកា កុលមាតាគហបតានី

ប

៩- ឧបាសិកា កាឡី

១០- ឧបាសិកា មល្លិកាទេវី

១១-ឧបាសិកា សាមាវតី

១២- ឧបាសិកា ចុន្ទីរាជកុមារី

១៣- ឧបាសិកា រោហិណី

១៤- ឧបាសិកា សុមនារាជកុមារី

១៥- ឧបាសិកា ចូឡសុភទ្ទា

១៦- ឧបាសិកា បតិបូជិកា

១៧- ឧបាសិកា បុណ្ណទាសី

១៨- ឧបាសិកា បេសការធិតា

១៩- ឧបាសិកា បេសការី

២០- ឧបាសិកា មល្លិកា

២១- ឧបាសិកា មាតិកមាតា

២២- ឧបាសិកា សុត្តរា

២៣- ឧបាសិកា វដ្ឍមាលា

២៤- ឧបាសិកា លខុមា

២៥- ឧបាសិកា លតា

២៦- ឧបាសិកា សារីព្រាហ្មណី

២៧-ឧបាសិកា សិរិមា

២៨- ឧបាសិកា សុជាតា

២៩- ឧបាសិកា សុន្ទរា

៣០- ឧបាសិកា សុភទ្ទា

៣១- ឧបាសិកា សេសវតី

# ✍ ជីវប្រវត្តិរបស់ឧបាសិកាសុប្បិយា ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកបម្រើជំងឺ "

នាងសុប្បិយា ជាឧបាសិកាម្នាក់ ដែលបានទទួលការលើកតម្កើងពីព្រះពុទ្ធអង្គឲ្យជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយផ្នែកខាងជាអ្នកបម្រើជំងឺ នៅក្នុងព្រះពុទ្ធសាសនានេះ មិនមែនត្រឹមតែប៉ុណ្ណោះទេ នាងក៏ជាអ្នកទ្រទ្រង់នូវគុណធម៌ដ៏យ៉ាងវិសេសវិសាលទៀត ចំណែកជីវប្រវត្តិក៏មានសម្ដែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់នាងសុប្បិយាឧបាសិកា មានសម្ដែងប្រាកដនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិនយបិដក** នៃ **ភេសជ្ជក្ខន្ធកៈ** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៅ **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

**នាងសុប្បិយា** បានមកកើតនៅក្នុងត្រកូលមួយ ដែលនៅក្នុងក្រុងពារាណសី ។ហេតុដែលនាងសុប្បិយាមានសេចក្ដីជ្រះថ្លា នៅក្នុង

ព្រះពុទ្ធសាសនា រហូតដល់នាងបានជាឧបាសិកា ជាអ្នកមានការជឿ យ៉ាងមាំទាំ ដែលចូលដល់អចលសទ្ធា សំដៅដល់មានសទ្ធាយ៉ាង ពិតប្រាកដ មិនមានការស្ទាក់ស្ទើរសង្ស័យចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឬរឿងបុណ្យបាប នរក និងសួគ៌ ជរាបដល់រឿងលោកនេះ និងលោកខាងមុខទៀតផង ។ ទាំងនេះទាក់ទងក្នុងសម័យមួយ ព្រះមុនី ព្រមដោយភិក្ខុសង្ឃជាច្រើនរូប ទ្រង់បានយាងទៅកាន់ក្រុងពារាណសី ។ នាងសុប្បិយា ក៏បានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ ហើយនាងក៏បានសម្រេចព្រះសោតាបត្តិផល ឬហៅម្យ៉ាងទៀតថា ជាព្រះសោតាបន្ន គឺបានជាព្រះអរិយបុគ្គលថ្នាក់ដំបូង នៅក្នុងព្រះពុទ្ធ សាសនានេះ ដោយនាងបានឃើញព្រះសាស្តាជាគ្រាដំបូងប៉ុណ្ណោះ ។ គ្រានោះ ព្រះមុនីគង់នៅក្នុងក្រុងរាជគ្រឹះ សមគួរតាមព្រះអធ្យាស្រ័យ ហើយ ទ្រង់យាងចេញចារិកទៅកាន់ក្រុងពារាណសី កាលទ្រង់យាង ទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ទៅក្រុងពារាណសីនោះ ។ បានឮថា ព្រះសាស្តា គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុង

ពារាណសីនោះ ។ គ្រានោះឯង ក្នុងក្រុងពារាណសីមានជនពីរនាក់ គឺឧបាសកឈ្មោះសុប្បិយ: ១ ឧបាសិកាឈ្មោះសុប្បិយា ១ ជាអ្នកមានសេចក្ដីជ្រះថ្លា ជាអ្នកឲ្យទាន ជាអ្នកធ្វើការបម្រើព្រះសង្ឃ ។ លំដាប់នោះ សុប្បិយាឧបាសិកាបានទៅកាន់វត្ត ហើយដើរចូលទៅគ្រប់វិហារ គ្រប់ទីបរិវេណ ហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ មានលោកម្ចាស់អង្គណាឈឺខ្លះដែរ លោកម្ចាស់អង្គណាត្រូវការឲ្យខ្ញុំព្រះករុណាយករបស់អ្វីមកប្រគេនដែរឬ ? វេលានោះឯង ភិក្ខុ ១ រូប បានផឹកថ្នាំបញ្ចុះ ។ ភិក្ខុនោះ បាននិយាយនឹងសុប្បិយាឧបាសិកាដូច្នេះថា នែនាង អាត្មាឆាន់ថ្នាំបញ្ចុះ អាត្មាត្រូវការដោយសាច់ដែលមានឱជារស ។ សុប្បិយាឧបាសិកានិយាយថា ល្អហើយលោកម្ចាស់ ខ្ញុំនឹងឲ្យគេយកមកប្រគេន និយាយដូច្នេះហើយ បានទៅដល់ផ្ទះ ហើយក៏បង្គាប់កូនក្មួយថា នែនាយ អ្នកចូរទៅទិញនូវសាច់សត្វដែលស្លាប់ស្រាប់ ។ បុរសនោះ បានទទួលពាក្យសុប្បិយាឧបាសិកាថា បាទអ្នកម្ចាស់ ហើយក៏ដើររកសាច់អស់ទាំងក្រុងពារាណសី មិនបានឃើញ

សាច់សត្វដែលស្លាប់ស្រាប់ឡើយ ។ បុរសនោះ បានចូលទៅរក សុប្បិយាឧបាសិកា លុះចូលទៅដល់ហើយ បាននិយាយដូច្នេះនឹង សុប្បិយាឧបាសិកាថា បពិត្រអ្នកម្ចាស់ គ្មានសាច់សត្វដែលស្លាប់ ស្រាប់ទេ ព្រោះថ្ងៃនេះគ្មានគេសម្លាប់សត្វសោះ ។ លំដាប់នោះ សុប្បិយាឧបាសិកា មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើភិក្ខុឈឺ នោះឯង មិនបានសាច់ដែលមានឱជារសទេ អាពាធក៏រឹងរឹតតែចម្រើន ឡើង ឬមួយនឹងធ្វើកាលកិរិយាទៅមិនខាន ឥឡូវអាត្មាអញ បានទទួល បេ្តជ្ញាថា នឹងប្រគេនសាច់ បើត្រឡប់ជាមិនបានឲ្យគេយកទៅប្រគេនវិញ កិច្ចនោះមិនសមគួរដល់អញសោះ ។ សុប្បិយាឧបាសិកា ក៏ចាប់យក កាំបិតសម្រាប់ហាន់សាច់មកអារសាច់ភ្លៅរបស់ខ្លួន ហើយហុចឲ្យទៅ ទាសីថា ហ៏ា ហងឯង ចូរយកសាច់នេះទៅចាត់ចែង ហើយយកទៅ ប្រគេនដល់ភិក្ខុឈឺក្នុងវិហារឯណោះចុះ មួយទៀត បើមានភិក្ខុណា សួររកអញ នាងឯងចូរទូលលោកថា អញឈឺ លុះនិយាយផ្តាំដូច្នេះ ហើយ បានរុំភ្លៅដោយសំពត់សម្រាប់បង់-ក ហើយចូលទៅក្នុងបន្ទប់

ដេកលើគ្រែ ។ លំដាប់នោះ សុប្បិយឧបាសកបានទៅកាន់ផ្ទះហើយ សួរទាសីថា នាងសុប្បិយាទៅណា ? ទាសីនោះប្រាប់ថា បពិត្រអ្នកម្ចាស់ៗ នោះ សម្រាន្តនៅក្នុងបន្ទប់ ។ លំដាប់នោះ សុប្បិយឧបាសកបានចូលទៅរកសុប្បិយាឧបាសិកា ចូលទៅដល់ហើយ សួរសុប្បិយាឧបាសិកាយ៉ាងនេះថា ព្រោះហេតុអ្វីបានជានាងដេក ?សុប្បិយាឧបាសិកាឆ្លើយថា ខ្ញុំឈឺ ។ សុប្បិយឧបាសកសួរថា នាងឈឺអ្វី ? ទើបសុប្បិយាឧបាសិកាប្រាប់សេចក្តីនោះ ដល់សុប្បិយឧបាសកដោយសព្វគ្រប់ ។ លំដាប់នោះ សុប្បិយឧបាសក គិតថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ចម្លែកពេកណាស់ សុប្បិយាឧបាសិកានេះ ជាស្រីមានសទ្ធាជ្រះថ្លាមែន អម្បាលសាច់របស់ខ្លួន គង់លះបង់បាន ចំណង់បើវត្ថុតិចតួចឯទៀត ឧបាសិកានឹងមិនឲ្យដូចម្តេចបាន គិតដូច្នេះហើយ ក៏មានចិត្តរីករាយខ្ពស់ឡើង បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះសុប្បិយឧបាសក អង្គុយនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះសម្ពុទ្ធ

យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសម្មាសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃនិមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ។ ព្រះលោកនាថទ្រង់ទទួលនិមន្តដោយការៈស្ងៀម ។

លំដាប់នោះ សុប្បិយឧបាសកបានដឹងថា ព្រះមានជោគ ទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះលោកនាយកធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ លុះកន្លងរាត្រីនោះទៅហើយ សុប្បិយឧបាសក បានតាក់តែងខាទនីយ ភោជនីយាហារដ៏ឧត្តមហើយ ឲ្យមនុស្សទៅក្រាបបង្គំទូល កាលសមគួរចំពោះព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន ពេលសមគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះវេលាព្រឹក ព្រះមហាវីរៈ ទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរយាងទៅកាន់ផ្ទះសុប្បិយឧបាសក លុះយាងទៅដល់ហើយ គង់លើអាសនៈដែលគេរៀបចំថ្វាយ មួយអន្លើដោយភិក្ខុសង្ឃ ។ វេលានោះ សុប្បិយឧបាសកបានចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះសាស្តា ហើយឈរនៅក្នុងទីដ៏សមគួរ ។ លុះសុប្បិយ

ឧបាសកឈរនៅក្នុងទីដ៏សមគួរហើយ ព្រះមានជោគ ទ្រង់មានបន្ទូលសួរដូច្នេះថា នាងសុប្បិយានៅទីណា ? សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងសុប្បិយាឈឺ ។ ព្រះអង្គទ្រង់មានបន្ទូលថា បើដូច្នោះ ចូរឲ្យនាងសុប្បិយាមក ។ សុប្បិយឧបាសកក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ នាងសុប្បិយាមិនអាចនឹងមកបានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយចូរគ្រាហ៍នាំយកមក ។ លំដាប់នោះ សុប្បិយឧបាសក បានគ្រាហ៍សុប្បិយាឧបាសិកានាំមកថ្វាយ ។ និមិត្តតែព្រះជិនស្រី ទ្រង់ទតឃើញកាលណាដំបៅរបស់នាងដែលធំដល់ម៉្លោះ ក៏ដុះសាច់សះជា មានសម្បុរល្អ មានរោមដុះពេញឡើងវិញមួយរំពេច ។ លំដាប់នោះ សុប្បិយឧបាសកនិងសុប្បិយាឧបាសិកា បាននិយាយគ្នាថា អើហ្ន៎ អស្ចារ្យពេកណាស់ អើហ្ន៎ ចម្លែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើន មានអានុភាពច្រើន គ្រាន់តែព្រះអង្គ ទ្រង់បានទតឃើញមួយរំពេច ដំបៅដែលធំដល់ម៉្លោះ ក៏ដុះសាច់សះជា មានសម្បុរល្អ មានដុះរោមឡើងវិញ អ្នកទាំងអស់នោះ

មានចិត្តរីករាយខ្ពស់ឡើង ក៏អង្គាសខាទនីយ និងភោជនីយាហារ ដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯង ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែដល់លោកប្រកែកលែងទទួលទៀត លុះព្រះមានជោគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏នាំគ្នាអង្គុយនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះសាស្តាបានញុំាង សុប្បិយឧបាសក និងសុប្បិយាឧបាសិកា ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

សុប្បិយាឧបាសិកា អារសាច់ភ្លៅថ្វាយភិក្ខុឈឺ ជាមូលហេតុឲ្យព្រះសក្យមុនីទ្រង់បញ្ញត្តសិក្ខាបទ ហាមមិនឲ្យភិក្ខុឆាន់សាច់មនុស្ស និងសត្វផ្សេងៗ មានសម្តែងទុកនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិនយបិដក** នៃ **ភេសជ្ជក្ខន្ធកៈ** ដូចមានសេចក្តីថា ៖

ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានជោគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា

សូមសាច់អំពីសុប្បិយាឧបាសិកា ? កាលបើព្រះទសពលត្រាស់សួរយ៉ាងនេះហើយ ភិក្ខុនោះក្រាបទូលព្រះជិនវរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសូមសាច់អំពីសុប្បិយាឧបាសិកា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបានឲ្យគេនាំយកសាច់មកហើយឬនៅ ? ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យគេនាំយកសាច់មកហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបានឆាន់ហើយឬនៅ ? ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឆាន់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មុននឹងអ្នកឆាន់ អ្នកបានពិចារណាដែរឬទេ ? ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានពិចារណាទេ ។ ព្រះលោកនាយកទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងមិនពិចារណាហើយហ៊ានឆាន់សាច់ដូច្នេះសោះ នែមោឃបុរស អ្នកឯងឆាន់សាច់មនុស្សពិតហើយ នែមោឃបុរស អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ល។ ទ្រង់តិះដៀលរួចហើយ ទ្រង់ធ្វើធម្មីកថា

ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស ដែលមានសទ្ធា មានសេចក្តីជ្រះថ្លា មនុស្សទាំងនោះ សូម្បីតែសាច់របស់ខ្លួនឯង ក៏គង់លះប្រគេនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់មនុស្សទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិថុល្លច្ច័យ ។ មួយាងទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានពិចារណាជាមុនហើយ មិនត្រូវឆាន់សាច់ទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។ ( ក្នុង **អដ្ឋកថា គម្ពីរតតិយសមន្តប្បសាទិកា** ថា បើភិក្ខុដឹងថា សាច់យ៉ាងនេះៗ ដែលព្រះសាស្តាទ្រង់ហាម មិនចាំបាច់សួរទេ ប្រសិនបើមិនដឹងការពិត គប្បីសួរជាមុនហើយឆាន់ ទើបគួរ ) ។

***ព្រះពុទ្ធប្បញ្ញត្តិហាមឆាន់សាច់ដំរី***... សម័យនោះឯង មានដំរីស្តេចស្លាប់ច្រើន ។ ជួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ដំរី ក៏បានប្រគេនសាច់ដំរីដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់ដំរី ។ ពួកមនុស្សពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើនឹង

ហាមឆាន់សាច់ដំរីសោះ ដំរីក៏ជាយានរបស់ស្តេច បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបបង្គំទូលដំណើរនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ដំរីទេ ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ ។

*ព្រះពុទ្ធបញ្ញត្តិហាមឆាន់សាច់សេះ...* សម័យនោះឯង មានសេះរបស់ស្តេចស្លាប់ច្រើន ។ ជួនជាវេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់សេះ ក៏បានប្រគេនសាច់សេះដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយក៏នាំគ្នាឆាន់សាច់សេះ ។ ពួកមនុស្សពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើនឹងហាមឆាន់សាច់សេះទេ ព្រោះសេះជាយានរបស់ស្តេចដែរ បើស្តេចទ្រង់ជ្រាប មុខជាខ្ញាល់នឹងភិក្ខុទាំងនោះមិនខាន ។ ពួកភិក្ខុក្រាបទូលដំណើរនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សេះទេ ភិក្ខុណាឆាន់ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

ព្រះពុទ្ធប្បញ្ញត្តិហាមឆាន់សាច់ឆ្កែ... សម័យនោះឯង វេលាស្រុកអត់បាយ មនុស្សទាំងឡាយនាំគ្នាស៊ីសាច់ឆ្កែ ក៏បានប្រគេនសាច់ឆ្កែដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឆាន់សាច់ឆ្កែ ។ ពួកមនុស្សបានពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើនឹងហ៊ានឆាន់សាច់ឆ្កែសោះ ព្រោះឆ្កែជាសត្វគួរខ្ពើមរអើម ។ ភិក្ខុទាំងឡាយបានក្រាបបង្គំទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ឆ្កែទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

ព្រះពុទ្ធប្បញ្ញត្តិហាមឆាន់សាច់ពស់... សម័យនោះឯង ពេលស្រុកអត់បាយ មនុស្សទាំងឡាយស៊ីសាច់ពស់ ក៏បានប្រគេនសាច់ពស់ដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុទាំងឡាយ ក៏នាំគ្នាឆាន់សាច់ពស់ ។ ពួកមនុស្សបានពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនសមបើនឹងហ៊ានឆាន់សាច់ពស់សោះ ព្រោះពស់ជាសត្វគួរខ្ពើមរអើម ។ ចំណែកខាងស្តេចនាគ ឈ្មោះសុបស្សបាន

ចូលទៅគាល់ព្រះមានព្រះភាគ ។ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។ លុះសុបស្សនាគរាជស្ថិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នាគទាំងឡាយ ជាសត្វគ្មានសទ្ធា គ្មានសេចក្តីជ្រះថ្លាទេ ក្រែងពួកនាគទាំងនោះ បៀតបៀនភិក្ខុទាំងឡាយខ្លះមិនខាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមកុំឲ្យលោកម្ចាស់ទាំងឡាយឆាន់សាច់ពស់ឡើយ ។ លំដាប់នោះ ព្រះមានព្រះភាគញុំាងសុបស្សនាគរាជ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ។ លុះសុបស្សនាគរាជ ដែលព្រះមុនីទ្រង់ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ថ្វាយបង្គំព្រះភគវា ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយមិនត្រូវឆាន់សាច់ពស់ទេ ភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ ។

*ព្រះពុទ្ធប្បញ្ញត្តិហាមឆាន់សាច់សីហៈ...* សម័យនោះឯង ពួកព្រាន សម្លាប់សត្វសីហៈ ហើយស៊ីសាច់សីហៈ ក៏បានប្រគេនសាច់សីហៈ ដល់ពួកភិក្ខុដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុក៏នាំគ្នាឆាន់សាច់សីហៈ ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វសីហៈធុំក្លិនសាច់សីហៈ ក៏សម្លាប់ភិក្ខុជាច្រើន ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ចំពោះព្រះមុនី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់សីហៈទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

*ព្រះពុទ្ធប្បញ្ញត្តិហាមឆាន់សាច់ខ្លាធំ...* សម័យនោះឯង ពួកព្រាន សម្លាប់ខ្លាធំ ហើយស៊ីសាច់ខ្លាធំ ក៏បានប្រគេនសាច់ខ្លាធំដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុនាំគ្នាឆាន់សាច់ខ្លាធំ ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វខ្លាធំធុំក្លិនសាច់ខ្លាធំ ក៏សម្លាប់ភិក្ខុជាច្រើន ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ចំពោះព្រះទសពល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាធំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

**ព្រះពុទ្ធបញ្ញត្តិហាមឆាន់សាច់ខ្លាដំបង...** សម័យនោះឯង ពួកព្រានសម្លាប់សត្វខ្លាដំបង ហើយស៊ីសាច់ខ្លាដំបង ក៏បានប្រគេនសាច់ខ្លាដំបងដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុក៏នាំគ្នាឆាន់សាច់ខ្លាដំបង ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វខ្លាដំបងបានធុំក្លិនសាច់ខ្លាដំបង សម្លាប់ភិក្ខុជាច្រើន ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាដំបងទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

**ព្រះពុទ្ធបញ្ញត្តិហាមឆាន់សាច់ខ្លាឃ្មុំ...** សម័យនោះឯង ពួកព្រានសម្លាប់សត្វខ្លាឃ្មុំ ហើយស៊ីសាច់ខ្លាឃ្មុំ បានប្រគេនសាច់ខ្លាឃ្មុំដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុនាំគ្នាឆាន់សាច់ខ្លាឃ្មុំ ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វខ្លាឃ្មុំបានធុំក្លិនសាច់ខ្លាឃ្មុំ ក៏សម្លាប់ភិក្ខុជាច្រើន ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ចំពោះព្រះភគវា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាឃ្មុំទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

ព្រះពុទ្ធបញ្ញត្តិហាមឆាន់សាច់ខ្លាព្រៃ... សម័យនោះឯង ពួកព្រានសម្លាប់សត្វខ្លាព្រៃ ហើយស៊ីសាច់ខ្លាព្រៃ ក៏បានប្រគេនសាច់ខ្លាព្រៃដល់ពួកភិក្ខុ ដែលត្រាច់ទៅបិណ្ឌបាត ។ ពួកភិក្ខុក៏នាំគ្នាឆាន់សាច់ខ្លាព្រៃ ហើយក៏ទៅនៅក្នុងព្រៃ ។ ពួកសត្វខ្លាព្រៃបានធុំក្លិនសាច់ខ្លាព្រៃ ហើយក៏សម្លាប់ភិក្ខុជាច្រើន ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់ខ្លាព្រៃទេ ភិក្ខុណាឆាន់ ត្រូវអាបត្តិទុក្កដ ។

ព្រះមានបុណ្យទ្រង់បញ្ញត្តិសិក្ខាបទហាមភិក្ខុមិនឲ្យឆាន់សាច់ ១០ យ៉ាងដូចពោលមកនេះ មានសេចក្តីអត្ថាធិប្បាយនៅក្នុង **គម្ពីរសមន្តបាសាទិកា** ដូចមានសេចក្តីថា ៖

សាច់មនុស្សដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនឲ្យឆាន់ ព្រោះហេតុថា មានជាតិជាមនុស្សដូចគ្នា ។ សាច់ដំរី និងសាច់សេះ ដែលព្រះមុនីទ្រង់ហាមមិនឲ្យឆាន់ ព្រោះហេតុថា ជាសត្វដែលជាពាហនៈរបស់ព្រះរាជា ។ សាច់សុនខ និងសាច់ពស់ដែលព្រះភគវា ទ្រង់ហាម

មិនឲ្យឆាន់ ព្រោះហេតុថា ជាសត្វដែលបដិកូល គឺកខ្វក់ គួរឲ្យខ្ពើមរអើម ៗសត្វ ៤ ជំពូកទៀត បានដល់ សត្វសីហៈ ១ ខ្លាធំ ១ ខ្លាដំបង ១ ខ្លាឃ្មុំ ១ ដែលព្រះមហាវីរៈទ្រង់ហាមមិនឲ្យឆាន់ ដើម្បីមិនឲ្យកើតឧបទ្វន្តរាយ ( អន្តរាយកើតពីឧបទ្រព ) ដល់ភិក្ខុសង្ឃទាំងឡាយ ៗ មូលហេតុដែលនឹងកើតមានព្រះពុទ្ធប្បញ្ញត្តិសិក្ខាបទហាម មិនឲ្យភិក្ខុទាំងឡាយឆាន់សាច់ទាំង ១០ យ៉ាងនេះ ព្រះពុទ្ធអង្គទ្រង់បញ្ញត្តិសិក្ខាបទជាគ្រាដំបូង ក៏ទាក់ទងមកពីសុប្បិយាឧបាសិកា ជាអ្នកមានសទ្ធាខ្ជាំងក្លារឹងមាំ បានអារសាច់របស់នាងប្រគេនដល់ភិក្ខុអាពាធ ក្នុងឋានៈដែលនាងជាអ្នកតាំងចិត្ត ប្រគេននូវភាពបម្រើភិក្ខុអាពាធទាំងឡាយ កាលបើនាងបវារណា ( គឺការបើកឱកាស ឲ្យនិយាយ ឲ្យសូមតាមកាលគួរ ឬតាមសេចក្តីត្រូវការ ) ហើយ លុះភិក្ខុមានសេចក្តីត្រូវការវត្ថុណានីមួយទើបត្រូវឲ្យរកយកមកប្រគេន ៗ

គុណគឺសេចក្តីល្អរបស់សុប្បិយាឧបាសិកា ដែលបានតាំងចិត្តប្រតិបត្តិបម្រើភិក្ខុសាមណេរទាំងឡាយមកដោយល្អ លុះក្រោយមក

កាលព្រះមហាមុនីទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ព្រះអង្គទ្រង់បានប្រកាសតែងតាំងឧបាសិកាទាំងឡាយ ទុកក្នុងតំណែងជាឯតទគ្គៈផ្សេងៗ សមតាមសេចក្តីប្រាថ្នា ហើយព្រះអង្គទ្រង់ប្រកាសតែងតាំងសុប្បិយាឧបាសិកា ទុកក្នុងតំណែងជាឯតទគ្គៈដែរ មានសម្តែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ គិលានុបដ្ឋាកីនំ យទិទំ សុប្បិយាឧបាសិកា** ម្នាលភិក្ខុទាំងឡាយ សុប្បិយាឧបាសិកាជាអ្នកប្រសើរជាងពួកឧបាសិកាទាំងឡាយ ដែលជាឧបាសិការបស់តថាគត ផ្នែកខាងជាអ្នកបម្រើជំងឺ ។

តំណែងជាឯតទគ្គៈ ដែលសុប្បិយាឧបាសិកា បានទទួលការតែងតាំងពីព្រះមហាវីរៈនេះ ក្រៅអំពីសេចក្តីល្អក្នុងបច្ចុប្បន្ននេះហើយ នៅមានផលនៃសេចក្តីល្អ ដែលនាងបានកសាង ទាំងដែលបានតាំងសេចក្តីប្រាថ្នាក្នុងទីចំពោះព្រះភក្ត្រនៃព្រះពុទ្ធក្នុងអតីតកាល តាមដែលមានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចតទៅថា ៖

ក្នុងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ដោយរាប់ពីកប្បនេះទៅមួយសែនកប្ប ។ សុប្បិយាឧបាសិកា បានកើតនៅក្នុងត្រកូលមួយក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ កាលនាងចម្រើនវ័យធំដឹងក្តីហើយ នាងបានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ ហើយបានឃើញព្រះអង្គទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកបម្រើជំងឺ ។ លុះនាងកុលធីតាបានឃើញដូច្នេះហើយ ក៏មានការពេញចិត្តនៅក្នុងតំណែងនោះ ទើបបានតាំងចិត្តធ្វើបុណ្យកុសលផ្សេងៗ ហើយប្រាថ្នាឲ្យបានតំណែងនោះ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះបទុមុត្តរៈ ជាពិសេសនាងបានធ្វើសេចក្តីល្អតជាប់គ្នា រហូតដល់អស់ជីវិត ។ អំណើះពីនោះមកកាលបើនាងអស់ជីវិតទៅហើយ នាងបានទៅកើតជាទេវតាខ្លះ កើតជាមនុស្សខ្លះ រហូតកន្លងទៅបានមួយសែនកប្ប ទើបនាងបានត្រឡប់មកកើតក្នុងផ្ទះអ្នកមានធនធានម្នាក់ នៅក្នុងក្រុងពារាណសី ក្នុងពុទ្ធកាលនេះមាតាបិតា និងពពួកញាតិបានដាក់ឈ្មោះឲ្យនាងថា **សុប្បិយា** ប្រែថា

ជាទីស្រឡាញ់ក្រៃលែង ។ ក្នុងពេលខាងក្រោយមក ព្រះមានបុណ្យ ដែលមានភិក្ខុទាំងឡាយ ចោមរោមជាបរិវារ ទ្រង់យាងមកដល់ក្រុង ពារាណសី ។ សុប្បិយាឧបាសិកា បានទៅស្តាប់ព្រះធម៌របស់ព្រះជិនស្រី ក៏បានសម្រេចព្រះសោតាបត្តិផល ក្នុងកាលដែលបានឃើញព្រះភគវា ជាលើកដំបូងតែប៉ុណ្ណោះ ។ ទើបចាត់បានថា សុប្បិយាឧបាសិកា ជាព្រះអរិយសាវិកាក្នុងព្រះសាសនានេះ តាំងពីថ្ងៃនោះមក ចាប់ផ្តើម អំពីថ្ងៃនោះមក នាងបានបម្រើភិក្ខុសាមណេរ ដោយតាំងចិត្តបម្រើភិក្ខុឈឺ រៀងមក ដូចរឿងដែលបានពោលមកហើយ ក្នុងវគ្គខាងដើមនោះ ។ល។

( ជីវប្រវត្តិរបស់សុប្បិយាឧបាសិកា ចប់ )

8888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ឧបាសិកាកាតិយានី ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកជ្រះថ្លាមិនកម្រើក "

*ឧបាសិកាកាតិយានី ជាអ្នកទ្រទ្រង់នូវគុណធម៌ ជាព្រះអរិយៈ និងជាឯតទគ្គៈប្រៀបដូចគ្នានឹងការទទួលបាននូវបរិញ្ញាបត្រផ្នែកខាងវេជ្ជបណ្ឌិត កិត្តិយសរបស់អ្នកដែលមានចំណេះដឹង ក្នុងសង្គមទូទៅ កាពជាអ្នកប្រសើរ ដោយសេចក្តីល្អរបស់ឧបាសិកា បានទទួលជំនឿពីពុទ្ធបរិស័ទថា ជាអ្នកមាននូវគុណធម៌ពិតមែន ។*

*ជីវប្រវត្តិរបស់* **ឧបាសិកាកាតិយានី** *ទាំងដែលប្រព្រឹត្តទៅក្នុងចំណែកអតីតជាតិ និងបច្ចុប្បន្នជាតិនោះ មានរឿងតំណាលទុកនៅក្នុង* **អដ្ឋកថាមនោរថបូរណី** *ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង* **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** *ដូចមានសេចក្តីថា ៖*

*ក្នុងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធ ដោយរាប់ពីភទ្ទកប្បនេះទៅមួយសែនកប្ប ។ ឧបាសិកាកាតិយានី បានកើតនៅក្នុងត្រកូលអ្នកមាន*

ធនជានម្នាក់ នៅក្នុងក្រុងហង្សវតី ។ គ្រាមួយ នាងកុលធីតា (កាតិយានី) បានទៅស្តាប់ព្រះធម៌ ថែមទាំងបានឃើញព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់បាន ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាឯតទគ្គៈ គឺជាអ្នក ប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកមានសេចក្តីជ្រះថ្លា មិនកម្រើក ឃើញដូច្នោះហើយ ក៏នឹកពេញចិត្តក្នុងតំណែងដ៏ប្រសើរនោះ ទើបបានធ្វើកុសលផ្សេងៗ ជាច្រើន ហើយតាំងសេចក្តីប្រាថ្នា ដើម្បី ឲ្យបានតំណែងនោះ ក្នុងអនាគតកាល ។ កាលតមក នាងកុលធីតានោះ អស់ជីវិតទៅហើយ នាងបានកើតជាមនុស្ស និងទេវតា អស់កាល មួយសែនកប្ប ។ លុះមកដល់ពុទ្ធកាល ព្រះពុទ្ធបរមគ្រូនៃយើងនេះ នាងបានមកកើតនៅក្នុងត្រកូលមួយ នៅក្នុងក្រុងកុររឃរៈ ដែនអវន្តី ពួកញាតិទាំងឡាយបានដាក់ឈ្មោះឲ្យនាងថា **កាតិយានី** ។ អំណឹះ ពីនោះមក នាងកាតិយានី កាលបើចម្រើនវ័យធំដឹងក្តីហើយ នាងបាន ជាសម្លាញ់យ៉ាងស្និទ្ធស្នាល ជាមួយនឹងឧបាសិកាកាឡី អ្នកក្រុងកុររឃរៈ ដែលជាញោមស្រីរបស់ព្រះសោណកុដិកណ្ណៈ ។ គ្រាមួយ ឧបាសិកា

កាឡី បានទៅអារាធនាព្រះសោណកុដិកណ្ណៈ ( លោកកូន ) ឲ្យលោកមកសម្ដែងធម៌ថា សូមលោកម្ចាស់សម្ដែងធម៌ឲ្យដល់ញោមបានស្ដាប់តាមទំនងដែលលោកម្ចាស់ បានសម្ដែងធម៌ថ្វាយព្រះភគវារួចហើយ ។ ដល់ពេលយប់ ដែលត្រូវវេលាកំណត់នឹងសម្ដែងព្រះធម៌នោះ ព្រះសោណកុដិកណ្ណៈ បានឡើងគង់លើធម្មាសនៈ ដែលបានរៀបចំហើយខាងក្នុងព្រះនគរ ដោយមានញោមស្រី ជាអ្នកចាត់ចែងក្នុងការរៀបចំសម្ដែងព្រះធម៌នោះ ។ គ្រានោះ ឧបាសិកាកាតិយានី បានទៅជាមួយនឹងឧបាសិកាកាឡី ដើម្បីនឹងស្ដាប់ព្រះធម៌ទេសនា តែបានទៅឈរស្ដាប់ព្រះធម៌ខាងចុងនៃបរិស័ទ ។ ក្នុងគ្រានោះ ពួកចោរមានចំនួនប្រមាណ ៩០០ នាក់ បាននាំគ្នាជីកឧម្មង្គ ដោយពួកចោរផ្ដើមជីកតាំងពីខាងក្នុងក្រុងទៅ រហូតដល់ផ្ទះរបស់ឧបាសិកាកាតិយានី ។ ចំណែកមេចោរ មិនបានចូលទៅជាមួយនឹងពួកកូនចោរទាំងនោះទេ គេបានទៅកន្លែងដែលព្រះសោណកុដិកណ្ណៈ សម្ដែងព្រះធម៌ទេសនាប្រោសដល់ញោមស្រី ដើម្បីពិនិត្យមើលថា ប្រជាជនដែលទៅប្រជុំគ្នាក្នុងទីនោះ

ធ្វើអ្វី ដោយគេចូលទៅឈរពីខាងក្រោយឧបាសិកាកាតិយានី ។

ក្នុងគ្រានោះ ឧបាសិកាកាតិយានី បាននិយាយជាមួយនឹងទាសីថា នាងចូរត្រឡប់ទៅផ្ទះវិញ ទៅយកប្រេងសម្រាប់បន្ថែមចាក់អុជប្រទីបមក យើងនឹងអុជប្រទីបឲ្យឆេះសន្ធោសន្ធៅ ហើយនឹងស្តាប់ព្រះធម៌ទេសនា ។ នាងទាសីបានត្រឡប់ទៅផ្ទះ លុះទៅដល់ផ្ទះ នាងបានអុជប្រទីបឡើង នាងបានឃើញពួកចោរជីកឧមង្គចូលទៅក្នុងផ្ទះ នាងមិនបានកាន់យកប្រេងសម្រាប់មកបន្ថែមប្រទីបឡើយ បានប្រញាប់ទៅជម្រាបឧបាសិកាកាតិយានី ម្ចាស់របស់ខ្លួនថា បពិត្រអ្នកម្ចាស់ ពួកចោរកំពុងតែជីកឧមង្គចូលទៅក្នុងផ្ទះ ចាំះ ។ មេចោរបានស្តាប់ឮពាក្យប្រាប់របស់នាងទាសីហើយ គិតថា ប្រសិនបើស្រីនេះ ជឿពាក្យសម្តីរបស់នាងទាសី យើងនឹងត្រឡប់ទៅផ្ទះវិញ យើងនឹងយកដាវកាប់នាងឲ្យដាច់ជាពីរកំណាត់ តែប្រសិនបើនាងនៅស្តាប់ព្រះធម៌ តាមដែលខ្លួនតាំងចិត្តទ្រព្យដែលពួកចោរនាំយកទៅហើយ យើងក៏នឹងនាំមកជូនដល់នាងវិញ ។ ចំណែកឧបាសិកាកាតិយានី បានស្តាប់ពាក្យរបស់នាងទាសី ដែល

ជម្រាបនោះហើយ ទើបនិយាយថា នាងកុំបញ្ចេញសំឡេងឲ្យឮខ្លាំង កាលបើពួកចោរនាំយកទ្រព្យទៅ ក៏នឹងនាំយកតែទ្រព្យដែលពួកចោរស្វែងរកឃើញប៉ុណ្ណោះ ចំណែកយើងបានស្តាប់ព្រះធម៌ទេសនា ដែលកើតឡើងដោយកម្រក្នុងថ្ងៃនេះ នាងកុំមកធ្វើឲ្យខូចការស្តាប់ព្រះធម៌ទេសនារបស់យើងឡើយ ។ មេចោរដែលនៅឈរចាំកន្លែងនោះ កាលបើបានស្តាប់ពូពាក្យឧបាសិកាកាតិយានី ជាមួយនឹងទាសីដូច្នេះហើយ ទើបជញ្ជឹងគិតថា ប្រសិនបើលួចទ្រព្យក្នុងផ្ទះរបស់ស្រីនេះ ដែលជាអ្នកតាំងមាំនៅក្នុងធម៌ដូចនេះ ផែនដីដ៏ធំ គង់នឹងស្រូបពួកយើងចុះទៅប្រាកដ លុះមេចោរ បានគិតឃើញដូច្នេះហើយ ទើបបានទៅប្រាប់ពួកចោរឲ្យលះបង់ទ្រព្យទាំងឡាយ ដែលពួកចោរកាន់យកហើយ នាំពួកចោរទាំងនោះមកស្តាប់ព្រះធម៌ដោយឈរនៅខាងក្រោយបរិស័ទ ។ ក្នុងពេលដែលព្រះសោណកុដិកណ្ណៈបានសម្តែងព្រះធម៌ទេសនាចប់ ឧបាសិកាកាតិយានី ក៏បានសម្រេចព្រះសោតាបត្តិផល គឺបានជាព្រះអរិយបុគ្គលថ្នាក់ដំបូង នៅក្នុងព្រះសាសនានេះ ដែលហៅថា ព្រះសោតាបន្ន ។

លុះដល់ពេលព្រះអរុណរះឡើង មេចោរបានចូលទៅក្រាបទៀបបាតជើងរបស់ឧបាសិកាកាតិយានី ថែមទាំងពោលថា បពិត្រអ្នកម្ចាស់ សូមអ្នកម្ចាស់អត់ទោសឲ្យដល់ខ្ញុំបាទទាំងអស់គ្នាផង ។ ឧបាសិកាកាតិយានីបានឃើញអំពើរបស់ពួកចោរដូច្នោះហើយ ក៏នឹកសង្ស័យ ទើបសួរថា ពួកអ្នកបានធ្វើខុសអ្វីចំពោះយើង ? មេចោរបានពោលរៀបរាប់អំពីទោសកំហុស ដែលខ្លួនបានធ្វើរួចហើយទាំងអស់ឲ្យនាងបានស្តាប់ ។ កាលឧបាសិកាកាតិយានីបានជ្រាបរឿងទាំងអស់នោះហើយ ទើបបានពោលថា នែអ្នកទាំងអស់គ្នា បើដូច្នោះ យើងអត់ទោសឲ្យដល់អ្នកទាំងអស់គ្នា ។ មេចោរកាលបានទទួលការអភ័យទោសឲ្យហើយ ទើបពោលអង្វរថា បពិត្រអ្នកម្ចាស់ កាលបើអ្នកម្ចាស់អត់ទោសឲ្យដល់ពួកខ្ញុំទាំងអស់គ្នាហើយ សូមឲ្យពួកខ្ញុំម្ចាស់បានបួស នៅក្នុងសម្នាក់លោកម្ចាស់សោណកុដិកណ្ណៈ ជាបុត្រនៃសម្លាញ់របស់អ្នកម្ចាស់ផងចុះ ។ ឧបាសិកាកាតិយានី ក៏បាននាំចោរទាំងនោះទៅបួស នៅក្នុងសម្នាក់របស់ព្រះសោណកុដិកណ្ណៈ ។ កាលពួកចោរទាំងនោះ បានបួសនៅ

ក្នុងសម្នាក់របស់ព្រះថេរៈ ហើយក៏បានតាំងចិត្តប្រតិបត្តិធ្វើសមណធម៌ រហូតដល់បានសម្រេចជាព្រះអរហន្តទៅ ។

អំណើះពីនោះមក ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ព្រះពុទ្ធអង្គទ្រង់បានប្រកាសតែងតាំងឧបាសិកាទាំងឡាយ ទុកក្នុងតំណែងជាឯតទគ្គៈផ្សេងៗ ថែមទាំងបានតែងតាំងឧបាសិកាកាតិយានី ទុកក្នុងតំណែងជាឯតទគ្គៈផងដែរ តាមដែលមានសម្ដែងទុកនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ អវេច្ចប្បសន្នានំ យទិទំ កាតិយានី** ម្នាលភិក្ខុទាំងឡាយ ឧបាសិកាកាតិយានី ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ អ្នកជាឧបាសិការបស់តថាគត ផ្នែកខាងជាអ្នកមានសេចក្ដីជ្រះថ្លាមិនកម្រើក ។

តំណែងជាឯតទគ្គៈ ដែលឧបាសិកាកាតិយានីបានទទួលនេះ ដោយអាស្រ័យហេតុ ២ ប្រការ ប្រការទី ១ ហេតុក្នុងអតីតជាតិ ដែលឧបាសិកាកាតិយានី មានសេចក្ដីពេញចិត្តក្នុងតំណែងនេះ ហើយ

ឧបាសិកាបានតាំងចិត្តធ្វើបុណ្យកុសល ប្រាថ្នាឲ្យបានតំណែងនេះ ។ ប្រការទី ២ ហេតុក្នុងបច្ចុប្បន្នជាតិនេះ ដោយឧបាសិកាបានតាំងចិត្តធ្វើសេចក្តីល្អ ដោយចិត្តស្អាតបរិសុទ្ធ ទើបបានជាបច្ច័យជួយឲ្យសម្រេចតាមសេចក្តីប្រាថ្នា ។៚

( ជីវប្រវត្តិរបស់ឧបាសិកាកាតិយានី ចប់ )

88888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ឧបាសិកានកុលមាតាគហបតានី ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកចេះធ្វើឱ្យអ្នកដទៃស្និទ្ធស្នាល "

នកុលមាតាគហបតានី ជាឧបាសិកាមាននូវគុណសម្បត្តិផ្នែកខាងឯតទគ្គៈ ជាគ្រឿងជានាសេចក្តីល្អ ដោយព្រះលោកនាថទ្រង់លើកតម្កើងកិត្តិគុណរបស់ឧបាសិកា ឲ្យប្រាកដច្បាស់ដល់ពុទ្ធបរិស័ទថា ជាឧបាសិកា អ្នកបានធ្វើសេចក្តីល្អទុកមកហើយ គឺជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល ។

ជីវប្រវត្តិរបស់នកុលមាតាគហបតានីឧបាសិកា មានរឿងពោលរួមជាមួយនឹងជីវប្រវត្តិរបស់នកុលបិតាគហបតី អ្នកជាស្វាមីរបស់នាងតាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** ថា ៖

នកុលមាតាគហបតានី ជាភរិយារបស់នកុលបិតាគហបតី អ្នកនៅក្នុងក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ នាងបានជាមាតារបស់នកុលដូច្នេះ ទើបនាងមានឈ្មោះថា **នកុលមាតា** ។ សម័យមួយ ព្រះសាស្តា

ព្រមដោយភិក្ខុសង្ឃហែហម ស្ដេចបានយាងទៅកាន់ក្រុងសុំសុមារគិរៈ ហើយគង់នៅក្នុងដែន **ភេសកឡាវ័ន** ។ លំដាប់នោះ នកុលមាតាគហបតានី បានរួមធ្វើដំណើរជាមួយនឹងនកុលបិតាគហបតីស្វាមី ព្រមដោយអ្នកក្រុងបាននាំគ្នាទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ កាលបានឃើញព្រះសម្ពុទ្ធ ក្នុងគ្រាដំបូងប៉ុណ្ណោះ បុគ្គលទាំងពីរនាក់ គឺនកុលមាតាគហបតានី និងស្វាមីរបស់នាង ក៏កើតការទ្រទ្រង់ចាំបានថា ព្រះពុទ្ធជាបុត្ររបស់ខ្លួន ទើបក្រាបទៀបព្រះយុគលបាទក្រាបទូលថា បពិត្រលោកកូន ព្រះអង្គទ្រង់លះបង់ចោលមាតាអស់កាលយូរដល់ត្រឹមនេះ ហើយស្ដេចយាងទៅទីណា ព្រះករុណាម្ចាស់ ។ មានរឿងតំណាលថា នកុលមាតាគហបតានីនេះ ធ្លាប់បានជាមាតារបស់ព្រះសាស្ដាមក ៥០០ ជាតិ ធ្លាប់បានជាម្ដាយមីង ៥០០ ជាតិ ធ្លាប់បានជាម្ដាយធំ ៥០០ ជាតិ និងធ្លាប់ជាបងស្រី ៥០០ ជាតិ ។ ចំណែកនកុលបិតាគហបតី ក៏ធ្លាប់បានជាបិតារបស់ព្រះពុទ្ធ ៥០០ ជាតិ និងធ្លាប់បាននៅក្នុងឋានៈដទៃៗ ទៀត ដូចគ្នា ។ ព្រោះហេតុនេះ បុគ្គល

ទាំង ២ នាក់នេះ ជាអ្នកមានសេចក្តីស្រឡាញ់ បន្តជាប់គ្នាមកហើយ អស់កាលដ៏យូរអង្វែង លុះបានឃើញព្រះលោកនាយក ទើបចេះធ្វើឲ្យកើតមានការស្និទស្នាលយល់ថា ព្រះពុទ្ធជាបុត្ររបស់យើង ទើបក្រាបទូលឡើងយ៉ាងនោះ ហើយលោកទាំង ២ នាក់ មិនអាចទ្រទ្រង់ស្មារតីបាន ។ ព្រះមហាវីរៈ ក៏ទ្រង់មិនបានដេញបុគ្គលទាំង ២ នាក់នោះ ឲ្យចៀសចេញទៅគ្រប់វេលា ដែលចិត្តរបស់បុគ្គលទាំង ២ នាក់នោះ នៅមិនទាន់ដឹងខ្លួន ព្រះអង្គទ្រង់ជ្រាបអធ្យាស្រ័យរបស់បុគ្គលទាំង ២ នាក់ កាលបើព្រះអង្គទ្រង់ជ្រាបថា បុគ្គលទាំង ២ នាក់នេះ មានស្មារតីវិញហើយ ជាអ្នកមានចិត្តជាកណ្តាលហើយ ទើបព្រះអង្គទ្រង់សម្តែងធម៌ប្រោស ។ ក្នុងវេលាព្រះសាស្តា ទ្រង់សម្តែងព្រះធម៌ទេសនាចប់ បុគ្គលទាំង ២ នាក់នោះ បានសម្រេចព្រះសោតាបត្តិផល បានជាព្រះអរិយបុគ្គល ។ ចាប់តាំងអំពីបុគ្គលទាំង ២ នាក់នោះ បានជាព្រះសោតាបន្នហើយ ក៏បានរៀបចំអាសនៈក្នុងផ្ទះរបស់ខ្លួនទុក ៥០០ អាសនៈ សម្រាប់ជាកន្លែងគង់របស់ភិក្ខុសង្ឃ ៥០០ រូប ដែលនិមន្ត

មកជាប្រចាំរាល់ថ្ងៃ ។

មានព្រះពុទ្ធវាទ ដែលព្រះមហាមុនី ទ្រង់ទេសនាប្រោសដល់នកុលមាតាគហបតានី ដែលមានសម្ដែងនៅក្នុងព្រះបាលី **នកុលសូត្រ** នៃ **ឧបោសថវគ្គ** ក្នុង **គម្ពីរអង្គុត្តរនិកាយ អដ្ឋកនិបាត** ថា៖

សម័យមួយ ព្រះមានព្រះភាគ កាលគង់នៅក្នុងភេសកឡាវ័នជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះ នកុលមាតាគហបតានី ( នាងគហបតានីឈ្មោះនកុលមាតា ) ចូលទៅគាល់ព្រះមុនី លុះចូលទៅដល់ហើយ ។ល។ ក៏អង្គុយនៅ ។ លុះនកុលមាតាគហបតានី អង្គុយនៅក្នុងទីដ៏សមគួរហើយ ព្រះភគវាទ្រង់ត្រាស់ដូច្នេះថា នែនកុលមាតា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយទៅ តែងតែទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ? នែនកុលមាតា មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតា មានប្រាថ្នាសេចក្ដីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវ

សេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្ត្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ ចំពោះស្វាមីនោះ ១ ។ល។ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ មានទាន បរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ នៃនកុលមាតា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមីនោះ សព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែលនាំមកនូវសេចក្តី ប្រាថ្នាគ្រប់យ៉ាងនោះ ជាស្ត្រីល្អ មិនបានធ្វើស្វាមីឲ្យក្តៅក្រហាយ ដោយ ពាក្យប្រណែន ជាស្ត្រីមានបញ្ញា តែងបូជាស្វាមី និងបុគ្គលដែលជា ទីគោរពទាំងអស់ ជាស្ត្រីមានសេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះ ជនជាបរិស័ទ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ថែទាំសម្បត្តិ

ដែលស្វាមីរកបានមក នារីណាជាស្ត្រី លុះក្នុងអំណាចសេចក្ដីប្រាថ្នា របស់ស្វាមី ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតា ឈ្មោះមនាបកាយិកា ។

មានរឿងរបស់នកុលមាតាគហបតានី ដែលសម្ដែងដល់ភាពជាអ្នកមានចំណេះដឹង ឬមានភាពអង់អាចក្នុងការពោលណែនាំស្វាមី មិនឲ្យមានការអាល័យ ឬព្រួយបារម្ភ សូម្បីព្រះមានជោគ ក៏ព្រះអង្គទ្រង់ត្រាស់ជានាគុណ ដែលជាសេចក្ដីល្អរបស់គហបតានី តាមដែលមានសម្ដែងនៅក្នុងព្រះបាលី **នកុលសូត្រ** នៃ **សារាណីយាទិវគ្គ** ក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់នៅក្នុងភេសកឡាវន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះ **សុំសុមារគិរៈ** ក្នុង **ភគ្គជនបទ** ។ សម័យនោះឯង នកុលបិតាគហបតី មានអាពាធដល់នូវទុក្ខ ឈឺធ្ងន់ ។ គ្រានោះ នកុលមាតាគហបតានី បាននិយាយនឹងនកុលបិតាគហបតី ដូច្នេះថា បពិត្រគហបតី អ្នកកុំធ្វើមរណកាលទាំងសេចក្ដីអាល័យឡើយ

បពិត្រគហបតី ព្រោះកាលកិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ ព្រះសាស្តាទ្រង់តិះដៀលផង បពិត្រគហបតីអ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណឹះអត់ពីអញទៅនកុលមាតាគហបតានីនឹងមិនអាច ដើម្បីចិញ្ចឹមនូវទារកទាំងឡាយទាំងគ្រប់គ្រងនូវឃរាវាសបានឡើយ បពិត្រគហបតី ដំណើរនោះអ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី ខ្ញុំជាស្ត្រីប៉ិនប្រសប់រវៃកប្បាស ធ្មៀវធ្មាសបួងក្នុងសក់ បពិត្រគហបតី អំណឹះអត់ពីអ្នកទៅ ខ្ញុំអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ទាំងគ្រប់គ្រងនូវឃរាវាសបាន បពិត្រគហបតី ព្រោះហេតុដូច្នោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី កាលកិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ ព្រះមុនីទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណឹះ

អំពីអញទៅ នកុលមាតាគហបតានី ចប់តែយកប្តីទៀត បពិត្រគហបតី ដំណើរនោះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី អ្នកក្តី ខ្ញុំក្តី ក៏ដឹងថា ព្រហ្មចរិយធម៌របស់គ្រហស្ថ យើងធ្លាប់សន្សំមកអស់ ១៦ ឆ្នាំហើយ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ព្រោះកាល-កិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះមានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណឹះអំពីអញទៅ នកុលមាតាគហបតានី ចប់តែមិនចង់ឃើញព្រះមានព្រះភាគ មិនចង់ឃើញភិក្ខុសង្ឃ បពិត្រគហបតី ដំណើរនោះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតីជឿចុះ អំណឹះអំពីអ្នកទៅ ខ្ញុំនឹងរឹងរឹតតែចង់ឃើញព្រះភគវាផង នឹងរឹងរឹតតែចង់ឃើញភិក្ខុសង្ឃផង បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ព្រោះ

កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ រមែង
នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តី
អាល័យ ព្រះសាស្តាទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែល
ជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណើះអំពីអញទៅ នកុលមាតា-
គហបតានី ឋប់តែលែងបំពេញសីលទាំងឡាយ បពិត្រគហបតី
ដំណើរនោះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី
ពួកស្ត្រីគ្រហស្ថ ជាសាវិការបស់ព្រះសាស្តាអង្គនោះ ទាំងប៉ុន្មានទនាក់
ជាស្ត្រីស្លៀកដណ្តប់សំពត់.ស បំពេញសីលទាំងឡាយ បណ្តាពួក
សាវិកាទាំងនោះ ខ្ញុំជាសាវិកាមួយដែរ រឿងនេះបើបុគ្គលណាមាន
សេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះភគវាជាព្រះអរហន្ត
សម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅភេសកឡាវ័ន ជាទីឲ្យអភ័យដល់
ម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះគប្បីចូលទៅ
គាល់ព្រះមានព្រះភាគនោះហើយ សួរល្បងចុះ បពិត្រគហបតី ព្រោះ
ហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រ

គហបតី ព្រោះកាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្ដីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្ដីអាល័យ ព្រះមានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្ដីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានី ជាស្ត្រីបាននូវចេតោសមថកម្មដ្ឋាន បពិត្រគហបតី ដំណើរនោះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី ពួកស្ត្រីគ្រហស្ថជាសាវិការបស់ព្រះភគវាទាំងប៉ុន្មានទាក់ ជាស្ត្រីស្លៀកដណ្ដប់សំពត់.ស បាននូវចេតោសមថៈក្នុងសន្ដាន បណ្ដាសាវិកាទាំងនោះខ្ញុំជាសាវិកាមួយដែរ រឿងនេះបើបុគ្គលណាមានសេចក្ដីសង្ស័យក្ដីមានសេចក្ដីងឿងឆ្ងល់ក្ដី ព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះ ចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយសួរល្បងចុះ ។ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាល ទាំងសេចក្ដីអាល័យឡើយ បពិត្រ

គហបតី ព្រោះកាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្ដីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបសេចក្ដីអាល័យ ព្រះមានព្រះភាគ ទ្រង់តិះដៀលផង ។ ម្នាលគហបតី ប្រហែលជាអ្នកមានសេចក្ដីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានី មិនទាន់ដល់នូវការចុះចិត្តស៊ប់ មិនទាន់ដល់នូវទីពឹង មិនទាន់ដល់នូវការកក់ក្ដៅ មិនទាន់ធ្លងផុតសេចក្ដីសង្ស័យ មិនទាន់ប្រាសចាកសេចក្ដីងឿងឆ្ងល់ មិនទាន់ដល់នូវសេចក្ដីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនទាន់លែងជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្ដា បពិត្រគហបតី ដំណើរនោះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី ពួកស្ត្រីគ្រហស្ថជាសាវិការបស់ព្រះមានព្រះភាគទាំងប៉ុន្មាននាក់ ជាស្ត្រីស្លៀកដណ្ដប់សំពត់.ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹង ដល់នូវការកក់ក្ដៅ មានសេចក្ដីសង្ស័យធ្លងផុតហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ ដល់នូវសេចក្ដីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្ដា បណ្ដាសាវិកាទាំងនោះ ខ្ញុំជា

សាវិកាមួយដែរ រឿងនេះបើបុគ្គលណា មានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះ គប្បីចូលទៅគាល់ព្រះមានព្រះភាគអង្គនោះ ហើយសួរល្បងចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ព្រោះកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះមានព្រះភាគ ទ្រង់តិះដៀលផង ។

លំដាប់នោះ នកុលបិតាគហបតី ដែលនកុលមាតាគហបតានីទូន្មានដោយឱវាទនេះ អាពាធនោះ ក៏ស្ងប់រម្ងាប់ដោយឋានៈ ទាំងនកុលបិតាគហបតី ក៏សះស្បើយចាកអាពាធនោះ ។ អាពាធនោះជាស្រឡះអំពីនកុលបិតាគហបតីហើយ ។ លុះនកុលបិតាស្បើយចាកជំងឺក្រោកចាកជំងឺមិនយូរប៉ុន្មាន ក៏ច្រត់នូវឈើច្រត់ចូលទៅគាល់ព្រះមុនី

លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះប្រាថ្នានូវប្រយោជន៍ ជាអ្នកទូន្មានប្រៀនប្រដៅ ។ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថជាសាវិកាបេស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់.ស បំពេញសីលទាំងឡាយ បណ្តាពួកសាវិកាទាំងនោះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថជាសាវិការបស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់.ស បាននូវចេតោសមថៈក្នុងសន្តាន បណ្តាពួកសាវិកាទាំងនោះ នកុលមាតាគហបតានីជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថជាសាវិការបស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់.ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹងមាំ ដល់នូវភាពកក់ក្តៅ មានសេចក្តីសង្ស័យ

ធ្ងន់ផុតហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បណ្តាពួកឧបាសិកាទាំងនោះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះប្រាថ្នានូវប្រយោជន៍ ទូន្មានប្រៀនប្រដៅ ។

ពាក្យពោលជាសំតៀនរបស់នកុលមាតាគហបតានី មានសេចក្តីអត្ថាធិប្បាយទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

នកុលមាតាគហបតានី បានព្យាយាមរក្សានកុលបិតាគហបតីហើយ តែមិនអាចធ្វើឲ្យជំងឺស្ងប់រម្ងាប់បាន ទើបនាងអង្គុយនៅក្នុងទីជិតជំណោកនៃស្វាមី នាងប្រាថ្នាដើម្បីរម្ងាប់ជំងឺរបស់ស្វាមី ដែលនៅរស់ដោយចរិយា គឺការតាំងពាក្យសច្ចៈចំពោះមុខស្វាមី ដោយគុណ គឺសេចក្តីល្អរបស់ខ្លួនយ៉ាងអង់អាច ដោយអង្គ ៣ ប្រការ ទាំងបានពោលអាងដល់ព្រះពុទ្ធជាសក្ខី ហើយបានធ្វើសច្ចកិរិយា ដោយអាងដល់

គុណធម៌ទាំងឡាយ មានសីលជាដើមរបស់ខ្លួន ដោយពាក្យសច្ចៈនេះ សូមឲ្យជមងឺក្នុងសរីរកាយ របស់នកុលគហបតីវិនាសទៅ សេចក្ដីសុខសប្បាយកើតឡើងវិញមកចុះ ។ ក្នុងទីបំផុតនកុលបិតាគហបតីក៏ជាស្បើយអំពីជំងឺ ដែលមានអាការធ្ងន់នោះ ។

នកុលបិតាគហបតី និងនកុលមាតាគហបតានី បានចូលទៅគាល់ក្រាបបង្គំទូលនូវសេចក្ដីប្រាថ្នា ដែលនឹងឲ្យបានជួបគ្នាក្នុងជាតិនេះ និងជាតិខាងមុខទៀត ហើយព្រះមានព្រះភាគត្រាស់គោលធម៌ ដែលធ្វើឲ្យស្វាមីភរិយាបានជួបគ្នា តាមដែលមានសម្ដែងទុកនៅក្នុងព្រះបាលី **សមជីវិសូត្រ** ក្នុង **គម្ពីរអង្គុត្តរនិកាយ** **ចតុក្កនិបាត** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្ដីថា ៖

អំណើះអំពីនោះមក បុគ្គលទាំងពីរនាក់នោះមានភាពចាស់ជរាណាស់ទៅហើយ ព្រះសាស្ដា ស្ដេចបានមកកាន់ដែនភគ្គៈម្ដងទៀត ។ គ្រានោះឯង ទ្រង់ចូលទៅកាន់និវេសន៍ របស់គហបតីឈ្មោះនកុលបិតា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។

លំដាប់នោះ នកុលបិតាគហបតី និងនកុលមាតាគហបតានី បាននាំគ្នាចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់បានថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយនៅក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំព្រះអង្គបានប្រសប់គ្នានឹងនកុលមាតាគហបតានី តាំងពីកំលោះក្រមុំមក មិនមែនប្រព្រឹត្តកន្លងចិត្តនៃនកុលមាតាគហបតានីសូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបក្នុងបរលោកផង ។ ចំណែកនកុលមាតាគហបតានី ក៏ក្រាបបង្គំទូលព្រះមហាវីរបុរសដូច្នេះដែរថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមពីខ្ញុំម្ចាស់បានប្រសប់គ្នានឹងនកុលបិតាគហបតី តាំងពីកំលោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្ត នៃនកុលបិតាគហបតី សូម្បីដោយចិត្តម្តងទេ មិនបាច់ពោលដល់ទៅ ការធ្វើដោយកាយឡើយ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឲ្យជួបគ្នា

ក្នុងបរលោកផង ។ ព្រះភគវាត្រាស់ថា ម្នាលគហបតី និងគហបតានី ទាំងឡាយ បើជនទាំងពីរនាក់ប្តីប្រពន្ធប្រាថ្នាឲ្យជួបគ្នាក្នុងបច្ចុប្បន្នជាតិ នេះផង ឲ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធា ស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា មានបញ្ញាស្មើគ្នា ទើបជួបគ្នា ក្នុងបច្ចុប្បន្ននេះផង ជួបគ្នាក្នុងបរលោកផង ។ ហើយព្រះលោកនាថ ទ្រង់ត្រាស់សម្តែងព្រះគាថាយ៉ាងនេះថា

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាអ្នកដឹងនូវពាក្យពេចន៍ នៃស្មូម ជាអ្នកសង្រួមក្នុងសីល អ្នកចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធ និងប្តីទាំងនោះ ពោលពាក្យផ្អែមល្ហែមមករកគ្នានិងគ្នា រមែងមានសេចក្តី ចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានិងគ្នា ពួកសត្រូវ រមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ មានសីលស្មើគ្នា ជនទាំងពីរនាក់មានសីល និងវត្តស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះ ហើយ បើមានបំណងក្នុងកាម ក៏រមែងជាអ្នកត្រេកអររីករាយ ក្នុង ទេវលោកបាន ។

នៅក្នុងព្រះគាថានេះ មានពាក្យអធិប្បាយនៅក្នុងព្រះអដ្ឋកថាចារ្យថា ពាក្យថា **មានសទ្ធាស្មើគ្នា** បានដល់ ជាអ្នកមានការជឿស្មើគ្នា ដូចការជឿបុណ្យបាប គុណទោសដូចគ្នា ឬជឿចំពោះព្រះពុទ្ធសាសនានេះដូចគ្នា ។ ពាក្យថា **មានសីលស្មើគ្នា** បានដល់ មានការរក្សាសីល គឺសង្រួមរវាំងកាយវាចាឲ្យរៀបរយជាប្រក្រតី ទាំងភរិយា និងស្វាមី ។ ពាក្យថា **មានការបរិច្ចាគស្មើគ្នា** បានដល់ មានការពេញចិត្តក្នុងការឲ្យទាន ឬធ្វើបុណ្យដូចគ្នា ។ ពាក្យថា **មានបញ្ញាស្មើគ្នា** បានដល់ បន្ទោបង់បាប និងអំពើដែលជាទោសដូចគ្នា ដោយដឹងថា បាបជាវត្ថុនាំមកនូវទោស ទាំងដែលដឹងថា បុណ្យកុសលជាវត្ថុដែលនាំមកនូវប្រយោជន៍ទាំងពីរ គឺខ្លួនឯង និងអ្នកដទៃ ។ កាលបើធ្វើឲ្យបានទាំង ៤ ប្រការនេះ ទាំងស្វាមី និងភរិយា រមែងជួបគ្នាបានហើយ ក៏ជាវត្ថុដែលធ្វើបានដោយកម្រ ប្រសិនបើធ្វើបាន រមែងតែងតែទទួលផលល្អចំពោះស្វាមី និងភរិយា គឺឲ្យបានជួបគ្នាក្នុងបច្ចុប្បន្ននេះផង និងក្នុងបរលោកផង ។

កិត្តិយសដែលនកុលមាតាគហបតានី ទទួលបានពីព្រះមុនីនោះ ដោយព្រះអង្គទ្រង់គង់នៅក្នុងវត្តជេតពន ហើយព្រះអង្គទ្រង់បានប្រកាសតែងតាំងឧបាសិកាទុកក្នុងតំណែងជាឯតទគ្គៈផ្សេងៗ ថែមទាំងបានប្រកាស តែងតាំងនកុលមាតាគហបតានីទុកក្នុងតំណែងជាឯតទគ្គៈដែរ តាមដែលមានសម្ដែងនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ វិស្សាសិកានំ យទិទំ នកុលមាតាគហបតានី** ម្នាលភិក្ខុទាំងឡាយ នកុលមាតាគហបតានី ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ អ្នកជាឧបាសិការបស់តថាគត ផ្នែកខាងជាអ្នកបេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល ។

មួយទៀត កាលដែលនកុលមាតាគហបតានី បានទទួលតំណែងជាឯតទគ្គៈដូចនេះ ក្រៅអំពីសេចក្ដីល្អដែលបានធ្វើហើយក្នុងបច្ចុប្បន្នជាតិនេះរបស់នាង ក៏នៅមានសេចក្ដីល្អដែលនាងធ្លាប់បានធ្វើមកហើយក្នុងអតីតជាតិ ដោយនាងបានតាំងសេចក្ដីប្រាថ្នា ដើម្បីឲ្យបានឋានៈ

បែបនេះ តែការធ្វើសេចក្ដីល្អរបស់នាង បានធ្វើរួមគ្នាជាមួយនឹងនកុលបិតាគហបតីដែលជាស្វាមីនោះ ក៏មានរឿងពោលទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៅក្នុង **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្ដីថា ៖

ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ដោយរាប់ថយក្រោយពីកប្បនេះទៅមួយសែនកប្ប នកុលមាតាគហបតានី បានកើតនៅក្នុងត្រកូលមួយ នៅក្នុងក្រុងហង្សវតី ថ្ងៃមួយ នាងបានទៅស្ដាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ ហើយនាងបានឃើញព្រះអង្គទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ទុកក្នុងតំណែងជាអ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល ក៏កើតការពេញចិត្តក្នុងតំណែងនោះ ហើយទើបបានបំពេញបុណ្យកុសលផ្សេងៗ ដោយប្រាថ្នាថា សូមឲ្យអាត្មាអញក្នុងអនាគតកាលបាននូវតំណែងនេះ ក្នុងសាសនាព្រះពុទ្ធអង្គណាទីមួយ ថែមទាំងបានធ្វើកុសលផ្សេងៗ រហូតដល់អស់ជីវិត ។ កាលនាងអស់ជីវិតពីជាតិនោះទៅហើយ បានកើតជាមនុស្ស និងទេវតាអស់មួយសែនកប្ប ។

លុះមកដល់ព្រះពុទ្ធសាសនាបរមគ្រូនៃយើងនេះ នាងបានមកកើតជាមនុស្ស ថែមទាំងបានជាភរិយារបស់នកុលបិតាគហបតីទៀត ក្រោយពីនាងបានស្តាប់ព្រះធម៌ទេសនារបស់ព្រះពុទ្ធអង្គហើយ បានសម្រេចជាព្រះសោតាបន្ន ។ នកុលមាតាគហបតានី ជាព្រះអរិយសាវិកាបានតំណែងជាឯតទគ្គៈ ក្នុងព្រះពុទ្ធសាសនាបរមគ្រូនៃយើងនេះ ។l៚

( ជីវប្រវត្តិរបស់នកុលមាតាគហបតានីឧបាសិកា ចប់ )

88888888888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ឧបាសិកាកាឡី ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗ គ្នា "

ឧបាសិកាកាឡី ជាអរិយសាវិកា ដែលជាអ្នកសម្បូរទៅដោយគុណធម៌ ថែមទាំងបានទទួលការលើកតម្កើងពីព្រះសាស្ដា ឲ្យជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកជ្រះថ្លាតាមពាក្យដែលឮតគ្នា ការបានសម្រេចមគ្គផលរបស់ឧបាសិកាកាឡី ស្រដៀងគ្នានឹងបរិភោគអាហារដែលគេត្រៀមទុកសម្រាប់អ្នកដទៃ មិនមែនជាអាហារដែលគេរៀបចំទុកឲ្យដល់ខ្លួន ចំណែកឧបាសិកាកាឡីនេះ ជាមាតារបស់ព្រះសោណកុដិកណ្ណៈ ដែលលោកជាឯតទគ្គៈផ្នែកខាងជាអ្នកពោលវាចាពីរោះ ។ ជីវប្រវត្តិរបស់ឧបាសិកាកាឡី ជារឿងមួយដែលគួរឲ្យចាប់អារម្មណ៍ផងដែរ ។

ជីវប្រវត្តិរបស់ឧបាសិកាកាកាឡី មានសម្ដែងទុកនៅក្នុង **គម្ពីរអដ្ឋកថាមនោរថបូរណី** ដូចមានសេចក្ដីថា ៖

ឧបាសិកាកាឡីក្នុងអតីតកាល កើតនៅក្នុងក្រុងហង្សវតីដែលត្រូវនឹងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្ពុទ្ធ ដែលព្រះអង្គបានឧប្បត្តិឡើងក្នុងលោក ដោយរាប់បានមួយសែនកប្បពីកប្បនេះទៅ ។ សម័យមួយនាងកុលធីតា ( កាឡី ) បានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះបទុមុត្តរសម្ពុទ្ធ ក៏បានឃើញព្រះអង្គទ្រង់ប្រកាសតែងតាំងឧបាសិកាម្នាក់ ឲ្យជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ផ្នែកខាងជាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗ គ្នា កាលបើនាងបានឃើញដូច្នេះហើយ ក៏ពេញចិត្តចង់បាននូវតំណែងនោះ នាងទើបបានធ្វើបុណ្យកុសល ថែមទាំងបានតាំងសេចក្តីប្រាថ្នា ឲ្យបាននូវតំណែងនោះ ក្នុងអនាគតកាល នៅក្នុងសាសនាព្រះពុទ្ធអង្គណាមួយ ។ លុះនាងកុលធីតានោះអស់ជីវិតពីជាតិនោះទៅហើយ ក៏បានត្រាច់រង្គាត់អន្ទោលក្នុងសង្សារវដ្តនេះ កើតជាមនុស្សនិងទេវតា រហូតដល់អស់កាលមួយសែនកប្ប ។ លុះមកដល់ពុទ្ធកាលគឺកាលដែលព្រះមុនីទ្រង់ឧប្បត្តិឡើងក្នុងលោកនេះ នាងកុលធីតានោះបានមកកើតក្នុងក្រុងរាជគ្រឹះ ។ ពួកញាតិបានដាក់ឈ្មោះឲ្យនាងថា **កាឡី**

( ពាក្យថា កាឡី ឬកាឡៈ មានសេចក្តីថា ខ្មៅ ឬស្នាមខ្មៅជាកន្លែងៗ នាងគង់នឹងមានសម្បុរកាយខ្មៅ ទើបបានដាក់ឈ្មោះនេះដូច្នេះ ) ។ កាលបើនាងកាឡី មានវ័យចម្រើនធំដឹងក្តីហើយ នាងក៏បានជាកិរិយារបស់មហាសេដ្ឋី ( តែមិនប្រាកដឈ្មោះ ) នាងបានទៅនៅក្រុងកុររឃរៈក្នុងដែនអវន្តីជនបទ កាលតមក នាងក៏តាំងគភ៌ឡើង ។ សម័យនោះឯងនាងកាឡីមានគភ៌ចាស់ជិតនឹងប្រសូតបុត្រហើយ នាងទើបបានគិតថា ការប្រសូតិបុត្រក្នុងផ្ទះរបស់អ្នកដទៃ ជាការមិនសមរម្យ នាងទើបសូមការអនុញ្ញាតពីស្វាមី វិលត្រឡប់មកត្រកូលរបស់ខ្លួន ដែលនៅក្នុងក្រុងរាជគ្រឹះ ។ ក្នុងពេលដែលនាងកាឡីត្រឡប់មកដល់ផ្ទះរបស់ខ្លួននៅក្នុងក្រុងរាជគ្រឹះហើយ ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងជាព្រះពុទ្ធហើយ ព្រះអង្គទ្រង់ប្រកាសសម្តែងធម្មចក្រ នៅឯព្រៃឥសិបតនមិគទាយវ័នប្រោសដល់ពួកបញ្ចវគ្គិយ ។ ទេវតាក្នុងម៉ឺនចក្រវាល បានទៅប្រជុំគ្នានៅកន្លែងដែលព្រះលោកនាយក ទ្រង់សម្តែងព្រះធម្មចក្កប្បវត្តនសូត្រនៅឯព្រៃឥសិបតនមិគទាយវ័ននោះ ។ ក្នុងបណ្តាពួកទេវតាទាំងនោះ

មានយក្សមួយឈ្មោះថា **សាតាគិរីយក្ស** ដែលចាត់នៅក្នុងពួកយក្សសេនាបតីចំនួន ២៨ នាក់ បានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះមុនីដែរ ផលដែលសាតាគិរីយក្ស បានតាំងចិត្តស្តាប់ព្រះធម៌ដោយគោរពនោះ ក៏ធ្វើឲ្យសាតាគិរីយក្សបានសម្រេចនូវព្រះសោតាបត្តិផល ឬហៅថាព្រះសោតាបន្ន ។

ក្រោយពីសាតាគិរីយក្សបានជាព្រះសោតាបន្នហើយ មានគំនិតប្រាថ្នាល្អចំពោះសម្លាញ់ថា ហេមវតយក្សដែលជាសម្លាញ់របស់យើងបានមកស្តាប់ព្រះធម៌ទេសនានេះដែរឬទេហ្ន៎ កាលបើគិតឃើញដូច្នេះហើយ ទើបរកមើលក្នុងរវាងពួកទេវតាចំពោះសម្លាញ់របស់ខ្លួន លុះរកមើលមិនឃើញហេមវតយក្ស ក៏គិតថា សម្លាញ់របស់យើងគង់នឹងមិនដឹងថា ព្រះរតនត្រ័យកើតឡើងហើយក្នុងលោក គួរយើងទៅរកសម្លាញ់ ហើយពណ៌នាអំពីគុណធម៌របស់ព្រះលោកនាថ ថែមទាំងប្រាប់ធម៌វិសេសដែលយើងបានហើយដល់ហេមវតយក្ស ដែលជាសម្លាញ់របស់យើង គិតឃើញដូច្នេះហើយ ទើបនាំបរិវាររបស់ខ្លួន ហោះឆ្លងកាត់

ក្រុងរាជគ្រឹះទៅរកហេមវតយក្សក្នុងមួយរំពេចនោះឯង ។ ចំណែកហេមវតយក្ស បានឃើញព្រៃហិមពាន្តដ៏ធំទូលំទូលាយប្រមាណ ៣០០០ យោជន៍ ដើមឈើទាំងឡាយបញ្ចេញផ្ការីកស្គុសស្គាយខុសរដូវកាល ឃើញដូច្នេះហើយក៏នឹកដល់សាតាគិរីយក្ស ដែលជាសម្លាញ់របស់ខ្លួន ដោយចង់ទៅបបួលសម្លាញ់មកដើរមើលក្នុងព្រៃហិមពាន្ត ដែលមានផ្ការីកស្គុសស្គាយនេះជាមួយគ្នា ។ ( យក្សទាំងពីរនាក់នេះជាសម្លាញ់នឹងគ្នា មានចេតនាល្អចំពោះគ្នា សូម្បីនឹងមានហេតុផលផ្សេងៗ គ្នា តែចេតនាដែលបានតាំងទុកល្អចំពោះគ្នា បង្ហាញឲ្យឃើញថា ជាមិត្រពិតប្រាកដ មិនមែនជាមិត្រក្លែងក្លាយ ដែលមានឧបាយកល មិត្រពិតកាលបើគប់រកគ្នាហើយ មានតែភាពស្មោះស្ម័គ្រជាមួយគ្នា ) ។ អ្នកមានចេតនាល្អ រមែងបានប្រសព្វផលល្អ សាតាគិរីយក្សព្រមទាំងបរិវារ បានមកជួបគ្នានឹងហេមវតយក្សព្រមទាំងបរិវារ នៅលើដំបូលផ្ទះរបស់ឧបាសិកាកាឡី ។ ជាបឋមយក្សបរិវារទាំងពីរពួកនោះ ហោះមកប្រឈមមុខគ្នា ចំណែកម្នាក់ៗ សួរដល់អ្នកជាប្រមុខរបស់គ្នានឹងគ្នា

លុះបានជ្រាបហើយ ព្រមគ្នាក៏សម្តែងនូវកាពរីករាយ តពីនោះ ទើបជម្រាបឲ្យយក្សសេនាបតី អ្នកជាប្រមុខរបស់ខ្លួនឲ្យជ្រាប ។ សាតាគិរីយក្ស កាលបានជួបហេមវតយក្ស ទើបសួរឡើងថា នែសម្លាញ់ អ្នកទៅណា ? ហេមវតយក្សតបថា យើងមករកសម្លាញ់ហ្នឹងឯង ។ សាតាគិរីយក្ស សួររកមូលហេតុថា អ្នករកយើងមានការអ្វី ? ហេមវតយក្ស ទើបប្រាប់នូវមូលហេតុដែលខ្លួនមករកឲ្យជ្រាបថា នែសម្លាញ់ យើងបានឃើញព្រៃហិមពាន្ត ដើមឈើទាំងឡាយ បានបញ្ចេញផ្ការីកស្គុសស្គាយច្រើនណាស់ ទើបមកបបួលសម្លាញ់ទៅមើលផ្ការីកស្គុសស្គាយទាំងនោះជាមួយគ្នា ។ សាតាគិរីយក្សសួរតទៅទៀតថា នែសម្លាញ់ នេះអ្នកមិនជ្រាបឬថា ព្រៃហិមពាន្តដែលដើមឈើបញ្ចេញផ្កាខុសរដូវកាល ព្រោះហេតុអ្វី ? ហេមវតយក្សទទួលតបតាមការពិតថា ហេតុក្នុងរឿងនេះយើងមិនជ្រាបទេ ចុះសម្លាញ់ដឹងហេតុនេះឬទេ ? សាតាគិរីយក្សពោលថា នែសម្លាញ់ ព្រះសិទ្ធត្ថរាជកុមារ ទ្រង់ជាឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ

ហើយ ដោយទ្រង់បានត្រាស់ដឹងជាព្រះពុទ្ធ ឥឡូវនេះ ទ្រង់បានសម្តែង **បឋមទេសនា** គឺព្រះធម៌ទេសនាជាលើកដំបូង ដែលហៅឈ្មោះថា ធម្មចក្កប្បវត្តនសូត្រ ដែលមានពួកទេវតាទាំងម៉ឺនចក្រវាលមកស្តាប់ ដោយព្រះអង្គសម្តែងប្រោសដល់ពួកបញ្ចវគ្គិយ ដោយហេតុនេះអ្នក មិនជ្រាបឬ ? ហេមវតយក្សឆ្លើយថា យើងមិនដឹងហេតុនេះឡើយ សម្លាញ់ ។ សាតាគិរីយក្ស បានពោលតទៅទៀតថា នៃសម្លាញ់ ការយល់របស់អ្នក ដែលឃើញដើមឈើទាំងឡាយ បញ្ចេញផ្កាខុស រដូវកាល រីកស្គុសស្គាយក្នុងព្រៃហិមពាន្តនោះ មិនទាន់ត្រឹមត្រូវ ការពិតនោះថ្ងៃនេះ ទាំងម៉ឺនចក្រវាលដើមឈើទាំងឡាយ បានបញ្ចេញ ផ្ការីកទាំងអស់ ដូចកម្រងផ្កាដែលក្រងទុកទាំងអស់ ដើម្បីជាគ្រឿងសក្ការ គោរពបូជាចំពោះព្រះមហាវីរបុរស ។ ហេមវតយក្សបានពោលថា នៃសម្លាញ់ រឿងដើមឈើបញ្ចេញផ្កាខុសរដូវកាល លើកទុកសិនចុះ ព្រះមានព្រះភាគ ទ្រង់ជាបរមគ្រូនៃជនក្នុងលោកនោះ អ្នកបានឃើញ ដោយខ្លួនឯង ឬថាមាននរណាប្រាប់ដល់អ្នក ហេមវតយក្សសួរដោយ

ការចាប់អារម្មណ៍យ៉ាងក្រៃលែង ។ សាតាគិរីយក្សបានពោលថា នែសម្លាញ់ ព្រះសម្ពុទ្ធនោះ យើងបានឃើញដោយខ្លួនឯង មិនមានអ្នកណាប្រាប់យើងទេ ក្រៃលែងជាងនោះនៅមានទៀត គឺយើងបានស្តាប់ព្រះធម៌ទេសនារបស់ព្រះអង្គ ព្រមទាំងបានផឹកនូវអមតធម៌ គឺធម៌ដែលមិនស្លាប់ទៀតផង កាលដែលយើងមករកសម្លាញ់ក្នុងពេលនេះ មានបំណងនឹងឲ្យសម្លាញ់របស់យើងបានផឹកនូវអមតធម៌ ដូចគ្នានឹងយើងដែរ ។

ខណៈដែលយក្សទាំងពីរនោះកំពុងសន្ទនានឹងគ្នា មិនខ្វះមិនលើសពេលដែលឧបាសិកាកាឡីក្រោកឡើងពីដំណេក ក៏បានឮនូវសំឡេងនៃការសន្ទនាគ្នានោះ ទើបពិចារណាថា សំឡេងនេះឮមកពីទីណា ហើយជ្រាបថា សំឡេងនេះឮមកពីលើដំបូលផ្ទះ ថែមទាំងមិនមែនជាសំឡេងរបស់មនុស្សទេ ប្រាកដជាសំឡេងរបស់អមនុស្ស កាលឧបាសិកាកាឡី បានពិចារណាដឹងយ៉ាងច្បាស់ពិតប្រាកដហើយ ទើបអង្គុយតាំងចិត្តស្តាប់ នូវការសន្ទនាធម៌រវាងយក្សទាំងពីរនោះតទៅ ។

លំដាប់នោះ សាតាគិរីយក្សទើបពោលឡើងថា ថ្ងៃនេះជាថ្ងៃ ឧបោសថ ១៥ កើត យប់នេះជាយប់ដ៏ប្រសើរ យើងទាំងពីរនាក់ទៅគាល់ព្រះមុនីដ៏ប្រសើរជាមួយគ្នា ។ ហេមវតយក្សទើបសួរថា ព្រះទ័យរបស់ព្រះសមណគោតមតាំងមាំល្អឬ សេចក្តីត្រិះរិះរបស់ព្រះសមណគោតមយ៉ាងណា ក្នុងឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលជាទីប្រាថ្នា ឬក្នុងអនិដ្ឋារម្មណ៍ គឺអារម្មណ៍ដែលមិនជាទីប្រាថ្នា ។ សំណួររបស់ហេមវតយក្សបានសួរដល់ការប្រព្រឹត្តតាមផ្លូវកាយ តាមផ្លូវចិត្ត និងការចិញ្ចឹមជីវិតរបស់ព្រះទសពលជាលំដាប់ទៅ ។ សាតាគិរីយក្ស បានពោលដោះស្រាយឲ្យហេមវតយក្សអស់សេចក្តីសង្ស័យគ្រប់ប្រការ ទាំងពោលបង្ហាញអំពីព្រះសរីរសម្បត្តិ គឺភាពល្អស្អាតនៃព្រះវរកាយ និងគុណសម្បត្តិរបស់ព្រះសាស្តាឲ្យហេមវតយក្សបានស្តាប់ ដោយសព្វគ្រប់ប្រការ ។ ចំណែកហេមវតយក្សបានតាំងចិត្តស្តាប់ ថែមទាំងបានបញ្ជូនក្រសែចិត្តទៅតាមព្រះធម៌ទេសនា ក៏បានសម្រេចព្រះសោតាបត្តិផល ដែលហៅថាព្រះសោតាបន្ន ។ រីឯឧបាសិកាកាឡីបានស្តាប់ព្រះធម៌ ដែលសាតាគិរីយក្ស

បានសម្តែងទៅដោយលំដាប់ ធ្វើឲ្យកើតសេចក្តីជ្រះថ្លា ចំពោះព្រះមុនី ទាំងដែលខ្លួន នៅមិនទាន់បានជួបឃើញសោះនោះឡើយ នាងក៏បាន សម្រេចព្រះសោតាបត្តិផល ដូចគ្នាបានទទួលអាហារដែលអ្នកដទៃ គេរៀបចំទុកដើម្បីអ្នកណាម្នាក់ដូច្នោះ ។ សរុបសេចក្តីថា ក្នុងបណ្តា ស្រ្តីទាំងអស់ ឧបាសិកាកាឡី បានសម្រេចជាព្រះសោតាបន្នមុនស្រ្តី ទាំងពួង ។ ការណ៍ដែលឧបាសិកាបានសម្រេចជាព្រះសោតាបន្ន និង ការប្រសូតិបុត្រនោះ បានកើតឡើងក្នុងខណៈជាមួយគ្នា ដោយកើត ឡើងក្នុងយប់ថ្ងៃនោះឯង ក្នុងថ្ងៃដែលដាក់ឈ្មោះឲ្យកូនប្រុស នាងបាន កាន់និមិត្តដែលបុត្រជាអ្នកមានសម្បុរល្អស្អាត ទើបដាក់ឈ្មោះឲ្យថា **សោណៈ** ប្រែថា **មាស** ។ តមកឈ្មោះរបស់លោកមានពាក្យតខាង ចុងថា **កុដិកណ្ណៈ** សំដៅយកថា អ្នកមានប្រដាប់ត្រចៀកតម្លៃមួយកោដិ ព្រោះដូច្នោះ ឈ្មោះរបស់លោកទើបប្រាកដថា **សោណកុដិកណ្ណៈ** សំដៅដល់ សោណៈអ្នកមានប្រដាប់ត្រចៀកតម្លៃមួយកោដិ ។ លុះ ឧបាសិកាកាឡីប្រសូតបុត្ររួចហើយ ក៏ស្នាក់នៅក្នុងផ្ទះ ក្នុងត្រកូល

របស់ខ្លួន សមគួរដល់ការសម្រាលហើយ នាងទើបនាំបុត្រទៅកាន់ដែនអវន្តី ដែលជាគេហដ្ឋានត្រកូលខាងស្វាមី ។ នាងបានតាំងចិត្តចិញ្ចឹមថែរក្សាសោណកុដិកណ្ណៈ រហូតដល់មានវ័យចម្រើនធំដឹងក្តី ។

រឿងរបស់ព្រះសោណកុដិកណ្ណៈ ដែលមានសេចក្តីពាក់ពន្ធទំនាក់ទំនងជាមួយនឹងឧបាសិកាកាឡី ជាមូលហេតុឲ្យនាងបានថ្វាយសំពត់ចំពោះព្រះមានជោគ ដែលមានសម្តែងប្រាកដនៅក្នុងព្រះបាលី **សោណត្ថេរ ក្នុងគម្ពីរខុទ្ទកនិកាយ ឧទាន និងក្នុង គម្ពីរមហាវគ្គ ព្រះវិន័យបិដក** ប៉ុន្តែក្នុងទីនេះ សូមតំណាលនៅក្នុង **គម្ពីរមហាវគ្គ ព្រះវិន័យបិដក** ដូចមានសេចក្តីថា ៖

សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅលើភ្នំបបាតៈ ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ ។ សម័យនោះឯង ឧបាសកឈ្មោះសោណកុដិកណ្ណៈ ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈដ៏មានអាយុ ។ វេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ បានចូលទៅរកព្រះមហាកច្ចានៈ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហា

កច្ចាន: រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះឧបាសកឈ្មោះសោណ-កុដិកណ្ណៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌ដែលលោកម្ចាស់មហាកច្ចានៈសម្តែងហើយយ៉ាងណាៗ ខ្ញុំករុណាក៏ដឹងច្បាស់ តែបុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឲ្យបរិបូណ៌ពេញលេញ ឲ្យស្អាតរលីងដូចជាស័ង្ខ ដែលបុគ្គលដុសខាត់ឡើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវខ្ញុំករុណា ចង់កោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាវៈទាំងឡាយ ហើយចេញចាកផ្ទះទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈបំបួសខ្ញុំផង ។ កាលបើឧបាសកនោះនិយាយយ៉ាងនេះហើយ ព្រះមហាកច្ចានៈក៏បាននិយាយពាក្យនេះនឹងសោណ-កុដិកណ្ណឧបាសកថា នែសោណៈ ការប្រព្រឹត្តនូវការដេកនៅតែម្នាក់ឯង បរិភោគនូវភត្តតែមួយពេល និងប្រព្រឹត្តព្រហ្មចរិយធម៌ ដរាបអស់មួយជីវិត មិនងាយនឹងធ្វើបានឡើយ នែសោណៈ ណ្ហើយចុះ អ្នកឯង

គួរតែនៅជាគ្រហស្ថ ប្រកបតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺការដេកតែម្នាក់ឯង ការបរិភោគភត្តតែម្តង និងការប្រព្រឹត្តព្រហ្មចរិយធម៌សមគួរតាមកាល ក្នុងភេទជាគ្រហស្ថនោះចុះ ។ ការប្រុងប្រៀបទីងបួសរបស់សោណកុដិកណ្ណឧបាសកនោះ ក៏បានស្ងប់រំងាប់ទៅក្នុងពេលនោះឯង ។ សោណកុដិកណ្ណឧបាសកបានចូលទៅរកព្រះមហាកច្ចានៈជាគម្រប់ពីរដងផង ។ល។ សោណកុដិកណ្ណៈបានចូលទៅរកព្រះមហាកច្ចានៈជាគម្រប់ ៣ ដងផង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះសោណកុដិកណ្ណឧបាសក អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈថា បពិត្រលោកម្ចាស់ដ៏ចម្រើនធម៌ដែលលោកម្ចាស់មហាកច្ចានៈសម្តែងហើយ យ៉ាងណាៗ ខ្ញុំករុណាក៏ដឹងច្បាស់ តែបុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌នេះ តែជាបុគ្គលដែលឲ្យបានពេញអស់ជើង ឲ្យបានស្អាតអស់ជើង ដូចជាស័ង្ខដែលគេដុសខាត់ហើយទេ បពិត្រលោកម្ចាស់

ដ៏ចម្រើន ឥឡូវខ្ញុំករុណាចង់កោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាវៈទាំងឡាយ ហើយចេញចាកផ្ទះទៅបួសក្នុងភេទរបស់បុគ្គលគ្មានផ្ទះ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈបំបួសខ្ញុំផង ។ ព្រះមហាកច្ចានៈក៏បានបំបួសសោណកុដិកណ្ណឧបាសកក្នុងវេលានោះឯង ។ សម័យនោះឯង អវន្តិទក្ខិណាជនបទ មានភិក្ខុតិចណាស់ ។ វេលានោះ ព្រះមហាកច្ចានៈឲ្យប្រជុំភិក្ខុសង្ឃ មានពួក ១០ ដែលមកពីទិសនោះៗ ហើយឲ្យឧបសម្បទាដល់សោណៈ ដោយក្រលំបាកពេកណាស់ លុះតែកន្លង ៣ ឆ្នាំទៅ ទើបរកគណៈសង្ឃបានគ្រប់ ១០ ។ លំដាប់នោះ កាលសោណៈនៅចាំវស្សារួចហើយ នៅក្នុងទីស្ងាត់លាក់ខ្លួនសំងំ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា អាត្មាអញគ្រាន់តែបានឮថា ព្រះមានព្រះភាគនោះ បែបយ៉ាងនេះៗ តែអាត្មាអញមិនដែលឃើញព្រះទសពលចំពោះមុខសោះ ។ បើឧបជ្ឈាយ៍អនុញ្ញាតឲ្យអាត្មាអញទៅ អាត្មាអញគួរតែទៅ ឲ្យបានឃើញព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ ។

គ្រានោះ ព្រះសោណៈដ៏មានអាយុ លុះវេលាថ្ងៃរសៀល ក៏ចេញអំពីទីលាក់ខ្លួនពួនសំងំហើយ ចូលទៅរកព្រះមហាកច្ចានៈ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកច្ចានៈ រួចក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈអង្គុយនៅក្នុងទីដ៏សមគួរហើយ បាននិយាយពាក្យនេះនឹងព្រះមហាកច្ចានៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណានៅក្នុងទីស្ងាត់ លាក់ខ្លួនពួនសំងំក្នុងទីនេះ ក៏កើតការត្រិះរិះក្នុងចិត្តយ៉ាងនេះថា អាត្មាអញគ្រាន់តែបានឮថា ព្រះសម្ពុទ្ធនោះ បែបយ៉ាងនេះៗ តែអាត្មាអញមិនដែលឃើញព្រះមានព្រះភាគ ក្នុងទីចំពោះមុខបានម្តងសោះ បើឧបជ្ឈាយ៍អនុញ្ញាតឲ្យអាត្មាអញទៅ គួរតែអាត្មាអញទៅឲ្យបានឃើញព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ បពិត្រលោកម្ចាស់ដ៏ចម្រើន បើឧបជ្ឈាយ៍អនុញ្ញាតឲ្យខ្ញុំទៅ ខ្ញុំករុណាគួរនឹងទៅឲ្យបានឃើញព្រះមានព្រះភាគនោះ ។ ព្រះមហាកច្ចានៈក៏និយាយតបវិញថា នែសោណៈ ប្រពៃពេកណាស់ហើយ នែសោណៈ លោកចូរទៅគាល់ព្រះមានព្រះភាគនោះចុះ នែសោណៈ លោកមុខជានឹង

បានឃើញព្រះមានព្រះភាគនោះ ជាទីនាំឲ្យកើតសេចក្តីជ្រះថ្លា គួរឲ្យជ្រះថ្លា មានឥន្ទ្រិយរំងាប់ហើយ មានព្រះទ័យរំងាប់ហើយ បានដល់នូវបញ្ញាសម្រាប់ទូន្មាន និងសមាធិសម្រាប់រំងាប់ដ៏ឧត្តម បានទូន្មានព្រះអង្គហើយ បានរក្សាព្រះអង្គហើយ បានឈ្នះឥន្ទ្រិយហើយ បានប្រាសចាកកិលេសហើយ នៃសោណៈ បើដូច្នោះ លោកចូរថ្វាយបង្គំព្រះបាទាទាំងគូរបស់ព្រះមានព្រះភាគ ដោយសិរសាតាមពាក្យខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ឧបជ្ឈាយ៍របស់ខ្ញុំឈ្មោះមហាកច្ចានៈ សូមក្រាបថ្វាយបង្គំចំពោះព្រះបាទទាំងគូរបស់ព្រះមានព្រះភាគ ដោយសិរសារួចហើយចូរ លោកក្រាបបង្គំទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ដែនអវន្តិទក្ខិណាជនបទ មានភិក្ខុតិចណាស់ ខ្ញុំព្រះអង្គប្រជុំភិក្ខុសង្ឃ មានពួក ១០ អំពីប្រទេសនោះៗ ហើយបានឧបសម្បទាដោយលំបាកពេកណាស់ លុះតែកន្លង ៣ ឆ្នាំទៅហើយ ទើបសម្រេចធ្វើម្តងហ្នឹ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាតនូវឧបសម្បទាក្នុងដែនអវន្តិទក្ខិណាជនបទ ដោយគណៈសង្ឃឲ្យតិចល្មមទៅ បពិត្រព្រះអង្គ

ដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ មានផែនដីខ្មៅស្អិត គ្រោតគ្រាត រឹងរដិបរដុបដោយស្នាមជើងគោ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់ អនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាជនបទ បពិត្រ ព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ ពួកមនុស្សរាប់អានការ ងូតទឹកណាស់ ប្រកបដោយសេចក្តីស្អាតព្រោះទឹក ធ្វើម្តេចហ្ន៎ ព្រះ មានព្រះភាគ គួរទ្រង់អនុញ្ញាតការងូតទឹកឲ្យបានជានិច្ច ក្នុងដែនអវន្តិ-ទក្ខិណាជនបទ បពិត្រព្រះអង្គដ៏ចម្រើន ដែនអវន្តិទក្ខិណាជនបទ មាន កម្រាលស្បែកច្រើន គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រ ព្រះអង្គដ៏ចម្រើន ក្នុងមជ្ឈិមជនបទ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះ មោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ ( **តាមអដ្ឋកថា** ស្មៅទាំង ៤ នេះ គេតែងយកមកធ្វើកន្ទេលរឹងខ្លះ កន្ទេលទន់ខ្លះ ឯស្មៅឈ្មោះឯរគុ មានសម្ផស្សរឹងគ្រោតគ្រាត ស្មៅឈ្មោះមោរគុនោះ មានចុងក្រហម មានសាច់ល្អិតទន់ មានសម្ផស្សស្រួល គេតែងយកមកធ្វើកន្ទេលទន់ សម្រាប់ដេក កាលបើដេកសន្ធត់ទៅហើយ លុះក្រោកចេញក៏ប៉ោង

ឡើងវិញ ឯស្មៅឈ្មោះមជ្ជារុនោះ គេយកធ្វើជាសំពត់សាដកក៏បាន ស្មៅឈ្មោះជន្តុ មានពណ៌ដូចកែវមណី ) យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ មានកម្រាលស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគដូច្នោះដែរ ធ្វើម្ដេចហ្ន៎ ព្រះមានព្រះភាគគួរទ្រង់អនុញ្ញាតកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគក្នុងដែនអវន្តិទក្ខិណាជនបទ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ មនុស្សទាំងឡាយប្រគេនចីវរ ដើម្បីភិក្ខុដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះដល់ភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះបានប្រគេនចីវរ ដើម្បីលោកហើយ ភិក្ខុទាំងនោះក៏រង្កៀសមិនត្រេកអរ ព្រោះយល់ឃើញថា កុំឲ្យត្រូវនិស្សគ្គិយដល់យើងឡើង ធ្វើម្ដេចហ្ន៎ ព្រះមានព្រះភាគទ្រង់ប្រាប់របៀបប្រតិបត្តិក្នុងចីវរ ។ ឯព្រះសោណៈ បានទទួលស្ដាប់ពាក្យព្រះមហាកច្ចានៈដោយពាក្យថា ករុណាលោកម្ចាស់ រួចហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមហាកច្ចានៈដ៏មានអាយុ ធ្វើប្រទក្សិណ

ហើយទុកដាក់គ្រឿងសេនាសនៈរួចកាន់យកបាត្រ និងចីវរ ចេញដើរ (បានចៀងចូលទៅប្រាប់លាញោមស្រី គឺឧបាសិកាកាឡីឲ្យជាប ។ ចំណែកឧបាសិកាកាឡី ទើបនិយាយពាក្យនេះនឹងលោកម្ចាស់ថា ល្អហើយ កាលនឹងទៅគាល់ព្រះមានព្រះភាគ សូមកាន់យកសំពត់កម្ពលមួយផ្ទាំងនេះ ទៅថ្វាយព្រះមានព្រះភាគក្នុងព្រះគន្ធកុដិផង ពោលដូចនេះហើយ នាងក៏ប្រគេនសំពត់កម្ពលមួយផ្ទាំង ដែលមានតម្លៃថ្លៃណាស់ ដល់ព្រះសោណៈ) ។ ដោយលំដាប់ទៅក្រុងសាវត្ថី ក៏ចូលទៅរកព្រះមានព្រះភាគ ក្នុងវត្តជេតពន ក្បែរក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។

វេលានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទថា ម្នាលអានន្ទ អ្នកចូរទៅក្រាលសេនាសនៈឲ្យអាគន្តុកភិក្ខុនេះបន្តិច ។ គ្រានោះព្រះអានន្ទគិតថា ព្រះមានព្រះភាគទ្រង់បង្គាប់អញថា អានន្ទ អ្នកឯងចូរក្រាលសេនាសនៈឲ្យអាគន្តុកភិក្ខុនេះបន្តិច ចំពោះភិក្ខុណា ព្រះមុនី

ទ្រង់ប្រាថ្នាដើម្បីគង់ក្នុងវិហារ ១ ជាមួយនឹងភិក្ខុនោះ គឺថា ព្រះសម្ពុទ្ធ ប្រាថ្នាដើម្បីគង់នៅក្នុងវិហារ ១ ជាមួយនឹងព្រះសោណៈ លុះគិតដូច្នោះហើយ ក៏ក្រាលសេនាសនៈចំពោះព្រះសោណៈក្នុងវិហារ ដែលព្រះសាស្ដាគង់នៅ ។ គ្រានោះ ព្រះមានជោគ ទ្រង់គង់ក្នុងទីកណ្ដាលវាលអស់រាត្រីជាច្រើន ទើបយាងចូលទៅកាន់វិហារ ។ ចំណែកខាងព្រះសោណៈ ក៏នៅក្នុងទីវាលអស់រាត្រីជាច្រើន ទើបចូលទៅកាន់វិហារ ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី បានត្រាស់បង្គាប់ព្រះសោណៈថា នែភិក្ខុ អ្នកគួរនឹងសម្ដែងធម៌បន្តិចទៅ ។ ព្រះសោណៈបានទទួលព្រះពុទ្ធដីកាព្រះសាស្ដាដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏សម្ដែងនូវសូត្រទាំងឡាយ មាននៅក្នុងអដ្ឋកវគ្គទាំងអស់ដោយសរភញ្ញ ។ លុះចប់សរភញ្ញរបស់ព្រះសោណៈហើយ ព្រះសម្ពុទ្ធ ក៏បានអនុមោទនាក្នុងខណៈនោះថា នែភិក្ខុ ពីរោះហើយៗ នែភិក្ខុ សូត្រទាំងឡាយដែលមាននៅក្នុងអដ្ឋកវគ្គ អ្នកបានរៀនមកត្រឹមត្រូវហើយ អ្នកបានធ្វើទុកក្នុងចិត្តល្អហើយ បានពិចារណា

ល្អហើយ អ្នកប្រកបដោយសម្តីដ៏ពីរោះក្បោះក្បាយ ប្រាសចាកទោស គួរនឹងញុំាងជនឲ្យបានដឹងច្បាស់នូវសេចក្តី នែភិក្ខុ អ្នកមានវស្សាប៉ុន្មានហើយ ? ព្រះសោណៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទើបបានតែមួយវស្សាទេ ។ ព្រះមានព្រះភាគទ្រង់សួរថា នែភិក្ខុ ហេតុអ្វីបានជាអ្នកធ្វើការឲ្យយឺតយូរយ៉ាងនេះ ក្រមកបួសម្ល៉េះ ? ព្រះសោណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឯទោសក្នុងកាមទាំងឡាយ ខ្ញុំព្រះអង្គបានឃើញមកជាយូរហើយ តែថា ផម្នតាយរាវាស មានសេចក្តីចង្អៀតចង្អល់ច្រើន មានកិច្ចច្រើន មានការងារច្រើន ។ វេលានោះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនោះហើយ ទើបទ្រង់បន្លឺឡើងនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលបានឃើញទោសក្នុងលោកហើយ ដឹងនូវធម៌ដែលប្រាសចាកឧបធិក្កិលេស ជាព្រះអរិយៈ រមែងមិនត្រេកអរក្នុងបាប ជាបុគ្គលស្អាត រមែងមិនត្រេកអរក្នុងបាប ។

គ្រានោះ ព្រះសោណៈគិតថា ព្រះមានព្រះភាគទ្រង់ស្មោះសរ

នឹងអាត្មាអញដោយពិត ព្រះឧបជ្ឈាយ៍របស់អាត្មាអញបានផ្ញើពាក្យបណ្តាំណា កាលនេះជាកាលគួរនឹងក្រាបទូល តាមពាក្យបណ្តាំនោះ ទើបក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈលើស្មាម្ខាង ហើយក្រាបទៀបព្រះបាទទាំងគូរបស់ព្រះមានព្រះភាគដោយសិរសា ហើយក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ ឈ្មោះមហាកច្ចានៈ សូមឱនសិរសាក្រាបថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគជាម្ចាស់ ម្យ៉ាងទៀតលោកឲ្យខ្ញុំព្រះអង្គក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើនដែនអវន្តិទក្ខិណាជនបទមានភិក្ខុតិច (ចាប់ផ្តើមតាំងពីខ្ញុំព្រះអង្គបានបួសជាសាមណេរ ) កន្លងទៅ ៣ ឆ្នាំហើយ ទម្រាំប្រជុំសង្ឃបាន ១០ រូបដែលមកពីទិសនោះៗ ហើយទើបបានឧបសម្បទាដោយលំបាកពន់ពេកណាស់ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ គួរទ្រង់អនុញ្ញាតនូវឧបសម្បទាក្នុងដែនអវន្តិទក្ខិណាជនបទ ដោយគណៈសង្ឃតិចជាងមុន បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ មានផែនដីខ្មៅស្អិត

គ្រោតគ្រាតរឹងរជិបរជុប ដោយស្នាមជើងគោ ធ្វើម្តេចហ្ន៎ ព្រះសាស្តា គួរទ្រង់អនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ក្នុងដែនអវន្តិទក្ខិណាជនបទ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ ពួកមនុស្សរាប់អានការងូតទឹកណាស់ ប្រកបដោយសេចក្តីស្អាតព្រោះទឹក ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតការងូតទឹកឲ្យបានជានិច្ច ក្នុងដែនអវន្តិ‑ទក្ខិណាជនបទ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងមជ្ឈិមជនបទ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនអវន្តិទក្ខិណាជនបទ មានកម្រាលគេធ្វើដោយស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគក៏ដូច្នោះដែរ ធ្វើម្តេចហ្ន៎ ព្រះមានព្រះភាគគួរទ្រង់អនុញ្ញាតកម្រាលទាំងឡាយ ដែលគេធ្វើដោយស្បែក គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក្នុងដែនអវន្តិទក្ខិណាជនបទ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ មនុស្ស

ទាំងឡាយគេប្រគេនចីវរ ដើម្បីពួកភិក្ខុដែលនៅក្រៅសីមាថា យើងនឹងប្រគេនចីវរនេះ ដើម្បីភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកហើយ ប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះបានប្រគេនចីវរចំពោះលោក ភិក្ខុទាំងនោះក៏វៀសមិនត្រេកអរ ដោយគិតថា កុំឲ្យមាននិស្សគ្គិយដល់យើងឡើយ ធ្វើម្ដេចហ្ន៎ ព្រះមានព្រះភាគ ទ្រង់គួរប្រាប់របៀបប្រតិបត្តិក្នុងចីវរនោះ ។

ព្រោះនិទាននេះ ដំណើរនេះ ព្រះមានបុណ្យទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះ រួចព្រះពុទ្ធអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ ដែនអវន្តិទក្ខិណាជនបទ មានភិក្ខុតិចម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទទាំងអស់ តថាគតអនុញ្ញាតនូវឧបសម្បទាដោយគណៈសង្ឃ មានវិន័យធរជាគម្រប់ ៥ បាន (សំដៅយកគ្រុសូត្រ) ។ បណ្ដាជនបទទាំងនោះ ជនបទទាំងឡាយ ដែលជាបច្ចន្តជនបទ គឺក្នុងទិសខាងកើត មាននិគមឈ្មោះ **កជង្គល** ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះ **មហាសាលា** ខាងនាយនិគម

ឈ្មោះមហាសាលានោះ ហៅថា **បច្ចន្តជនបទ** ខាងនាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងអគ្នេយ៍ មានស្ទឹងឈ្មោះ **សល្លវតី** ខាងនាយស្ទឹងសល្លវតីនោះ ហៅថា **បច្ចន្តជនបទ** ខាងនាយចូលមក ជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះ **សេតកណ្ណិក** ខាងនាយសេតកណ្ណិកនោះហៅថា **បច្ចន្តជនបទ** ខាងនាយចូលមកជា មជ្ឈិមជនបទ ។ ក្នុងទិសខាងលិចមានស្រុកព្រាហ្មណ៍ ឈ្មោះ **ថូនគ្រាម** ខាងនាយស្រុកថូនគ្រាមនោះហៅថា **បច្ចន្តជនបទ** ខាងនាយចូលមក ជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើងមានភ្នំឈ្មោះ **ឧសីរធជ:** ខាងនាយ ភ្នំនោះហៅថា **បច្ចន្តជនបទ** ខាងនាយចូលមកជាមជ្ឈិមជនបទ ។ ម្នាល ភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទទាំងឡាយបែបនេះ តថាគតអនុញ្ញាត នូវឧបសម្បទា ដោយគណៈសង្ឃ មានវិន័យធរជាគម្រប់ ៥ បាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាជនបទ មានផែនដីខ្មៅស្អិត រឹងគ្រោតគ្រាត រដិបរដុបដោយស្នាមជើងគោ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទទាំងអស់ តថាគតអនុញ្ញាតស្បែកជើង ៤ ជាន់ឡើង

ទៅ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាជនបទ ពួកមនុស្ស ច្រើនរាប់អានការងូតទឹក ប្រកបដោយសេចក្ដីស្អាតព្រោះការងូតទឹក ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទទាំងអស់ តថាគតអនុញ្ញាតនូវការ ងូតទឹកបានជានិច្ច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាជនបទ មានកម្រាលស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ម្នាលភិក្ខុទាំងឡាយ ក្នុងមជ្ឈិមជនបទទាំងឡាយ មានស្មៅឈ្មោះឯរគុ ស្មៅឈ្មោះមោរគុ ស្មៅឈ្មោះមជ្ជារុ ស្មៅឈ្មោះជន្តុ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងដែនអវន្តិទក្ខិណាជនបទ មានកម្រាលស្បែក ទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តជនបទទាំងអស់ តថាគតអនុញ្ញាតកម្រាល ស្បែកទាំងឡាយ គឺស្បែកចៀម ស្បែកពពែ ស្បែកម្រឹគ ។ ម្នាល ភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើមានពួកមនុស្សប្រគេនចីវរដើម្បី ភិក្ខុទាំងឡាយ ដែលនៅក្រៅសីមាថា យើងប្រគេនចីវរនេះចំពោះភិក្ខុ ឈ្មោះនេះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរបាន

ចីវរមិនទាន់មកដល់ដែដរាបណាចីវរនោះ ភិក្ខុមិនត្រូវរាប់តាមកំណត់ថ្ងៃដរាបនោះដែរ ។

មូលហេតុដែលឧបាសិកាកាឡី នឹងបានឱកាសស្តាប់ធម្មិកថារបស់ព្រះសោណៈនោះ តាមដែលមានរឿងតំណាលទុកនៅក្នុង **រឿងសម្ពហុលភិក្ខុ** នៃ **ភិក្ខុវគ្គ** និងក្នុង **អដ្ឋកថាធម្មបទ** ថា ៖

កាលបើលោកត្រឡប់មកដល់អវន្តិទក្ខិណាជនបទវិញហើយ ទើបចូលទៅរកព្រះមហាកច្ចានៈ ដែលជាព្រះឧបជ្ឈាយ៍នោះ ក៏បានទូលរៀបរាប់ក្នុងដំណើររឿងរ៉ាវ ដែលខ្លួនចូលទៅគាល់ព្រះលោកនាយកឲ្យជ្រាបសព្វគ្រប់ប្រការ ។ លុះដល់ព្រឹកឡើង លោកក៏បាននិមន្តទៅបិណ្ឌបាតត្រង់ផ្ទះញោមស្រី កាលបើញោមស្រីបានក្រឡេកឃើញលោកកូនត្រឡប់មកវិញហើយ ក៏សប្បាយចិត្ត ចង់ជ្រាបរឿងរ៉ាវខ្លះៗ ទើបនិមន្តលោកកូនឲ្យឡើងគង់លើផ្ទះទទួលចង្ហាន់ ។ ពេលព្រះថេរៈឆាន់ចង្ហាន់រួចស្រេចហើយ លោកក៏បានតំណាលរឿង ដែលខ្លួនចូលទៅគាល់ព្រះសម្ពុទ្ធ ឲ្យញោមជាមាតាបានស្តាប់ពីដើមរហូតដល់ចប់ ។

ចំណែកឧបាសិកាកាឡីបានសួរទៀតថា លោកម្ចាស់បានសម្តែងធម៌ថ្វាយដល់ព្រះភគវា ហើយព្រះអង្គបានប្រទានសាធុការពិតមែនឬ ? ព្រះសោណៈសួរទៅវិញថា ញោមដឹងរឿងនេះមកពីណា ? ញោមស្រីក៏ប្រាប់ថា ដឹងមកពីទេវតាដែលអាស្រ័យនៅផ្ទះរបស់ញោមស្រីនេះឯងជាអ្នកប្រាប់ឲ្យដឹង គ្រានោះ ឧបាសិកាបាននិយាយរឿងនោះ ប្រាប់ឲ្យព្រះថេរៈបាត់ធ្វល់ នាងបានពោលដូចតទៅថា ក្រោយពីលោកម្ចាស់សម្តែងព្រះធម៌ចប់ ទេវតាដែលអាស្រ័យនៅក្នុងផ្ទះនេះ បានពោលឲ្យសាធុការ ដោយសំឡេងដ៏ខ្លាំង ញោមទើបសួរថា អ្នកជានរណាបានឲ្យសាធុការដូច្នេះ ទេវតាតបថា ខ្ញុំ ឧបាសិកា ។ នាងសួរថាលោកជានរណា ? ទេវតាតបថា ខ្ញុំជាទេវតាដែលអាស្រ័យនៅក្នុងផ្ទះរបស់ឧបាសិកា ។ ពេលនោះ ឧបាសិកាបានពោលថា បពិត្រទេវតាយូរណាស់មកហើយ លោកមិនធ្លាប់បានឲ្យសាធុការដល់យើងឡើយហេតុអ្វី ថ្ងៃនេះ លោកទើបឲ្យសាធុការ ? ទេវតាពោលតបថា ខ្ញុំមិនបានឲ្យសាធុការដល់ឧបាសិកាទេ ។ បើអ្នកមិនបានឲ្យសាធុការ

ដល់យើង ចុះឲ្យសាធុការដល់នរណាវិញ ? ទេវតាពោលតបថា ខ្ញុំបានឲ្យសាធុការដល់ព្រះសោណកុដិកណ្ណៈ ដែលជាបុត្ររបស់ឧបាសិកាទេតើ ។ តើបុត្ររបស់យើងធ្វើអ្វី ទើបអ្នកឲ្យសាធុការដូច្នេះ ? ទេវតាពោលតបថា ក្នុងថ្ងៃនេះ បុត្ររបស់ឧបាសិកានៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះសាស្តា ទាំងបានសម្តែងធម៌ថ្វាយដល់ព្រះមានជោគទៀតផង លុះព្រះភគវា ទ្រង់បានស្តាប់ព្រះធម៌ពីបុត្ររបស់ឧបាសិកាហើយ ទ្រង់សព្វព្រះទ័យ ទើបព្រះអង្គបានប្រទានសាធុការ ព្រោះហេតុនោះសូម្បីខ្ញុំក៏បានឲ្យសាធុការដល់ព្រះថេរៈនោះដែរ ជាការទទួលសាធុការរបស់ព្រះមុនី ទើបបានមានសំឡេងសាធុការខ្លាំងឡើង ជាសំឡេងដូចគ្នាទាំងអស់ ចាប់តាំងពីភូមិទេវតា រហូតដល់ព្រហ្មលោក ។

ឧបាសិកាសួរតទៅទៀតថា បពិត្រទេវតា បុត្ររបស់យើងសម្តែងធម៌ថ្វាយដល់ព្រះភគវា ឬថាព្រះសាស្តា ទ្រង់សម្តែងព្រះធម៌ឲ្យដល់បុត្ររបស់ខ្ញុំ ? ដែលនាងសួរដូច្នេះ ដោយនាងមិនទាន់ជឿក្រែងខ្លួនស្តាប់ច្រឡំ ។ ទេវតាឆ្លើយថា មិនមែនទេ បុត្ររបស់ឧបាសិកា

ទេតើ ជាអ្នកសម្ដែងធម៌ថ្វាយដល់ព្រះសម្ពុទ្ធ ។ កាលបើទេវតាពោល
បញ្ជាក់យ៉ាងនេះហើយ បីតិទាំង ៥ ក៏កើតប្រាកដចំពោះឧបាសិកា
សព្វសព៌ាង្គកាយទាំងអស់ ពេលនោះនាងមានគំនិតថា ប្រសិនបើថា
បុត្ររបស់យើងនៅក្នុងព្រះគន្ធកុដិជាមួយនឹងព្រះមុនី អាចសម្ដែងធម៌
ថ្វាយដល់ព្រះលោកនាយក ក៏គង់អាចសម្ដែងធម៌ឲ្យយើងបានស្ដាប់
ដូចគ្នាដែរ នាងទើបគិតតទៅទៀតថា ក្នុងពេលដែលកូនយើងត្រឡប់
មកដល់វិញ យើងនឹងឲ្យលោកកូនសម្ដែងធម្មិកថាឲ្យស្ដាប់ដែរ ។ កាល
ជាខាងក្រោយមក ឧបាសិកាកាឡី លុះបានសួរដឹងរឿងរ៉ាវដូច្នោះហើយ
ក៏បានពោលជាមួយនឹងព្រះសោណៈបន្តទៀតថា លោកម្ចាស់ កាល
បើលោកម្ចាស់ អាចសម្ដែងធម៌នៅចំពោះព្រះភក្ត្ររបស់ព្រះវិជិតមារ
បានហើយ ហេតុដូច្នេះ លោកម្ចាស់ក៏អាចសម្ដែងធម៌ឲ្យដល់ញោម
បានស្ដាប់ដូចគ្នាដែរ តពីនោះ ឧបាសិកា ទើបប្រាប់កំណត់ថ្ងៃសម្ដែងធម៌
ហើយព្រះថេរៈក៏ទទួលនិមន្តរបស់ញោមស្រីថា អាត្មានឹងសម្ដែងធម៌
ដែលសម្ដែងថ្វាយដល់ព្រះលោកនាយកហើយនោះ យកមកសម្ដែង

ជូនញោមស្តាប់ ។ ឧបាសិកាកាឡីកាលដឹងថា លោកកូនព្រមទទួលនិមន្តហើយ ក៏មានការរីករាយសប្បាយចិត្តយ៉ាងក្រៃលែង ។

ទើបបានត្រៀមធ្វើកុសល ឲ្យមានឡើងក្នុងថ្ងៃស្តាប់ទេសនានោះថា យើងនឹងថ្វាយទានដល់ភិក្ខុសង្ឃ ធ្វើការបូជារួចហើយ នឹងស្តាប់ធម្មឹកថាអំពីបុត្ររបស់យើង ហើយបានឲ្យទាសីតែម្នាក់ប៉ុណ្ណោះនៅចាំផ្ទះ សល់ប៉ុន្មាននាំឲ្យទៅស្តាប់ធម៌របស់ព្រះសោណកុដិកណ្ណៈនៅឯមណ្ឌលដែលនាងបានកសាងទុក សម្រាប់ប្រើប្រាស់ជាប្រយោជន៍ក្នុងការស្តាប់ធម៌ ។ ក្រោយពីរៀបចំធម្មាសនៈរួចហើយ ព្រះថេរៈក៏ឡើងកាន់ធម្មាសនៈនោះសម្តែងព្រះធម៌ ដោយមានសំឡេងដ៏ពីរោះជាប់ចិត្ត ។ ក្នុងពេលជាមួយគ្នានោះ មានពួកចោរ ៩០០ នាក់ បានចូលទៅកាន់ផ្ទះរបស់ឧបាសិកាកាឡីនោះ ។ ប៉ុន្តែផ្ទះរបស់នាងព័ទ្ធជុំវិញដោយកំពែង ៧ ជាន់ មានខ្លោងទ្វារ ៧ នាងលាមឆ្កែដែលកាចៗទុកនៅត្រង់ខ្លោងទ្វារគ្រប់ៗ ទ្វារ ធ្វើដូចបុរាណបានពោលថា ព័ទ្ធរបងដោយចង្កូមឆ្កែ ។ ក្រៅពីនោះ នៅមានជីកប្រឡាយទុកត្រង់ទីធ្លាក់

សំយាបផ្ទះជុំវិញ ហើយដាក់សំណប៉ាហាំងចុះរហូតដល់ពេញ ពេលថ្ងៃសំណប៉ាហាំងនោះ រលាយប្រាកដហាក់បីដូចទឹកកំពុងក្តៅពុះ ព្រោះត្រូវកម្តៅថ្ងៃ តែដល់ពេលយប់ សំណប៉ាហាំងនោះរឹងដូចជាដុំដែកព្រមទាំងជោតចម្រូងដែកធំៗ ទុកក្នុងចន្លោះប្រឡាយជាប់ៗ គ្នាទៅ ។ ពួកចោរទាំងនោះ មើលមិនឃើញផ្លូវចន្លោះ ព្រោះអាស្រ័យការរក្សាយ៉ាងនេះ ជាពិសេសនោះ ព្រោះឧបាសិកាកាឡីនៅផ្ទះរាល់ៗ ថ្ងៃ ។ ថ្ងៃនេះ ពួកចោរដឹងថា នាងបានចេញទៅស្តាប់ធម៌ ទើបប្រើវិធីជីកឧម្មង្គចូលទៅក្នុងផ្ទះ ដោយជីកចូលជ្រៅចុះទៅខាងក្រោមនៃសំណប៉ាហាំង និងចម្រូងដែកនោះ ។

កាលបើពួកចោរទាំងនោះ បាននាំគ្នាជីកចូលទៅដល់ក្នុងផ្ទះរួចស្រេចហើយពួកចោរទាំង ៩០០នាក់ បាននិយាយប្រាប់មេចោរថា ចូរទៅកាន់កន្លែងមណ្ឌល ដែលឧបាសិកាស្តាប់ធម៌ ដោយពាក្យថា ប្រសិនបើនាងបានដឹងថា ពួកយើងនាំគ្នាចូលទៅក្នុងផ្ទះនោះ ហើយនាងប្រាថ្នាចង់ត្រឡប់មកផ្ទះវិញ ពួកយើងចូរសម្លាប់នាងចោល ។

រីឯមេចោរក៏បានទៅឈរក្បែរឧបាសិកា ដែលកំពុងអង្គុយស្តាប់ព្រះធម៌នោះ ។ ចំណែកពួកចោរដទៃទៀត បាននាំគ្នាដុតភ្លើងឲ្យភ្លឺឡើងក្នុងផ្ទះ ហើយគាស់ទ្វារបន្ទប់ដែលទុកកហាបណៈ ។ នាងទាសីដែលនៅចាំផ្ទះនោះ កាលបើឃើញពួកចោរនាំគ្នាចូលមកក្នុងផ្ទះហើយ ទើបប្រញាប់រត់ទៅរកឧបាសិកា ដើម្បីប្រាប់រឿងរ៉ាវទាំងអស់នោះ ដោយភាពតក់ស្លុតចិត្ត និយាយទាំងត្រហេបត្រហបថា បពិត្រម៉ែម្ចាស់ៗ ពួកចោរមានចំនួនច្រើនណាស់ បាននាំគ្នាចូលទៅក្នុងផ្ទះគាស់ទ្វារបន្ទប់ដែលទុកកហាបណៈហើយ ។ ឧបាសិកាឆ្លើយថា ឲ្យពួកគេយកទៅចុះ កុំមករំខានយើងស្តាប់ធម៌ឡើយ នាងឯងចូរត្រឡប់ទៅផ្ទះវិញសិនចុះ ឧបាសិកានិយាយប្រាប់ ដោយមិនខ្វល់ចំពោះកហាបណៈទាំងនោះឡើយ គិតតែខំស្តាប់ធម៌តទៅទៀត ។ កាលបើពួកចោរទាំងនោះ នាំគ្នាជញ្ជូនកហាបណៈពីបន្ទប់អស់ហើយ ទើបនាំគ្នាគាស់បន្ទប់ដាក់ប្រាក់តទៅទៀត ។ នាងទាសីឃើញពួកចោរធ្វើដូច្នេះ ក៏បានប្រញាប់មកប្រាប់រឿងនេះ ឲ្យដល់ឧបាសិកាជ្រាបទៀត ។ ឧបាសិកានិយាយទៀតថា ពួកចោរចូរជញ្ជូន

យកប្រាក់ដែលគេប្រាថ្នាយកទៅចុះ នាងឯងកុំរំខានយើងស្តាប់ធម៌ឡើយ ហើយប្រាប់ឲ្យនាងត្រឡប់ទៅផ្ទះវិញ ។ នាងទាសីកាលត្រឡប់មកដល់ផ្ទះ ឃើញបន្ទប់ដាក់ប្រាក់ទទេ ថែមទាំងឃើញពួកចោរកំពុងគាស់បន្ទប់ដាក់មាស ក៏ប្រញាប់ត្រឡប់មកប្រាប់ដល់ឧបាសិកាទៀត ។

ឧបាសិកាកាឡី ស្តាប់ពាក្យតំណាលប្រាប់របស់ទាសីហើយ មិនបានសម្តែងអាការកង្វល់ ឬហួងហែងចំពោះទ្រព្យទាំងនោះទេ ទាំងសេចក្តីខឹងក្រោធ ក៏មិនមានចំពោះចោរនោះដែរ ហើយនិយាយប្រាប់ទាសីដែលចូលមករកដោយបន្ទោសថា យើ ! នាងល្អ នាងមករកយើងច្រើនដងហើយ សូម្បីយើងបានប្រាប់ថា ឲ្យពួកចោរជញ្ជូនទ្រព្យយកទៅតាមសេចក្តីប្រាថ្នាចុះ យើងកំពុងស្តាប់ធម្មិកថា បុត្ររបស់យើង នាងកុំមកធ្វើអន្តរាយដល់យើងឡើយ ប៉ុន្តែនាងនៅតែមិនស្តាប់ពាក្យសម្តីរបស់យើងទាល់តែសោះ នៅតែចូលមករកយើងដដែលៗ ទៀត លើកក្រោយទៀត ប្រសិនបើនាងត្រឡប់មករកយើងទៀត យើងនឹងដាក់ទោសដល់នាងមិនខាន ចូរនាងត្រឡប់ទៅផ្ទះសិនចុះ ហើយបញ្ជា

ឲ្យទាសីត្រឡប់ទៅផ្ទះវិញ ។ មេចោរបានស្តាប់ពួពាក្យនិយាយរបស់ឧបាសិកា ក៏បាននឹកភ័យឡើងថា កាលពួកយើងនាំយកទ្រព្យសម្បត្តិផ្សេងៗ របស់ស្ត្រីដែលមានសេចក្តីល្អនោះ ប្រាកដជារន្ទះនឹងបាញ់បំបែកក្បាលរបស់ពួកយើងមិនខានទេ ហើយបញ្ជូនកូនចោរឲ្យទៅប្រាប់ដល់ពួកចោរទាំងនោះថា ចូរឲ្យពួកគេជញ្ជូនទ្រព្យទាំងអស់របស់ឧបាសិកាយកទៅទុកដាក់តាមកន្លែងដើមវិញដោយឆាប់រហ័ស ។ ពួកចោរទាំងនោះ កាលបានស្តាប់ពាក្យបញ្ជាអំពីមេចោរហើយ ក៏ប្រញាប់នាំគ្នាយកកហាបណៈ មាស-ប្រាក់ចូលទៅទុកក្នុងបន្ទប់ដើមវិញ ដោយមិនខ្វះឬមិនបាត់បង់អ្វីមួយឡើយ ។ ដោយសេចក្តីថា ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ជាធម្មតា ព្រោះហេតុដូច្នោះ ទើបព្រះមុនីទ្រង់ត្រាស់ថា

**ធម៌រមែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយរមែងនាំសេចក្តីសុខមកឲ្យ នេះជាអានិសង្សក្នុងការ ដែលបុគ្គលប្រព្រឹត្តធម៌ល្អ អ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងមិនទៅកាន់ទុគ្គតិ ។**

ពួកចោរដែលនៅក្នុងផ្ទះរបស់ឧបាសិកាកាឡី កាលនាំគ្នាយក

ទ្រព្យទៅទុកកន្លែងដើម រួចហើយទើបនាំគ្នាចូលទៅស្តាប់ធម៌ដែរ ។ ចំណែកព្រះសោណកុដិកណ្ណត្ថេរ តាំងចិត្តសម្តែងធម៌ទៅតាមលំដាប់ ដូចដែលសម្តែងថ្វាយព្រះសម្ពុទ្ធនោះ ឲ្យញោមបានស្តាប់យ៉ាងត្រេកអរពេញចិត្ត រហូតអស់រាត្រី ដល់ពេលភ្លឺទើបចុះចាកធម្មាសនៈ ។ ក្នុងខណៈនោះ មេចោរដើរតម្រង់ចូលទៅក្រាបចុះទៀបជើងរបស់ឧបាសិកាកាឡី ហើយនិយាយថា ឧបាសិកា សូមអត់ទោសឲ្យដល់ខ្ញុំបាទផងចុះ ឧបាសិកាកាឡីសួរថា អ្នកមានរឿងអ្វី នាងពោលដោយប្លែកក្នុងចិត្ត ព្រោះមិនដឹងរឿងអ្វី ស្រៀមៗ ក៏មកសុំឲ្យអត់ទោសឲ្យ មេចោរនោះពោលទៀតថា ឧបាសិកា ខ្ញុំបានចងអាឃាតនឹងអ្នក ដោយមានបំណងនឹងសម្លាប់ឧបាសិកា ទើបមកឈរក្បែរឧបាសិកា ។ ប្រសិនបើរឿងនេះដូច្នេះ ខ្ញុំអត់ទោសឲ្យអ្នក នាងពោលអត់ទោសដោយការពេញចិត្ត ។ សូម្បីពួកចោរដ៏សេសទាំងអស់ ឃើញឧបាសិកាអត់ទោសឲ្យមេចោរដោយទឹកមុខញញឹមប្រិមប្រិយ ថែមទាំងមិនមានការខឹងក្រោធ ទើបនាំគ្នាទៅសូមខមាទោសឧបាសិកាដូចមេចោរដែរ ។ គ្រានោះ ឧបាសិកា

កាឡីនិយាយថា អ្នកទាំងឡាយ ខ្ញុំអត់ទោសឲ្យហើយ ។ ពួកចោរនាំគ្នាសូមអង្វរឧបាសិកាថា បើឧបាសិកាអត់ទោសឲ្យដល់ពួកខ្ញុំទាំងអស់គ្នាហើយ សូមឧបាសិកាជួយសង្គ្រោះពួកខ្ញុំផង យើងខ្ញុំទាំងអស់គ្នាចង់បព្វជ្ជាក្នុងសម្នាក់ព្រះសោណកុដិកណ្ណត្ថេរ ដែលជាបុត្ររបស់ឧបាសិកា ។ កាលបើនាងបានជ្រាបបំណងដ៏ល្អ របស់ពួកចោរទាំងនោះ ទើបបែរមុខទៅរកលោកកូន ហើយលើកដៃសំពះ និងនិយាយថា លោកម្ចាស់ ពួកចោរទាំងនេះជ្រះថ្លានឹងគុណរបស់ញោមជ្រះថ្លានឹងធម្មីកថារបស់លោកម្ចាស់ ថែមទាំងចង់បព្វជ្ជាទៀតផង ដូច្នេះ សូមលោកម្ចាស់ឲ្យពួកចោរទាំងនេះបួសផងចុះ ។ ព្រះសោណៈមានថេរវាចាថាល្អហើយ ទើបឲ្យពួកចោរទាំងនោះបព្វជ្ជា ឲ្យសមាទានសីល ។

កាលជាខាងក្រោយមក ពួកចោរបានឧបសម្បទាហើយ ព្រះថេរៈបានឲ្យកម្មដ្ឋានផ្សេងៗ ដល់ភិក្ខុទាំងនោះ មួយរយរូបឲ្យរៀនកម្មដ្ឋានមួយ ភិក្ខុទាំង ៩០០ រូបនោះ រៀនកម្មដ្ឋាន ៩ យ៉ាងផ្សេងៗ គ្នា ។ ហើយនាំគ្នាឡើងទៅលើភ្នំមួយ អង្គុយធ្វើសមណធម៌

នៅក្រោមដើមឈើតាមអធ្យាស្រ័យ ។

គ្រានោះ ព្រះសាស្ដាទ្រង់គង់ប្រថាប់នៅវត្តជេតពន ឆ្ងាយពីភិក្ខុដែលធ្វើសមណធម៌ទាំងនោះ ប្រមាណ ១២០ យោជន៍ ទ្រង់ប្រមើលមើលភិក្ខុទាំងនោះ ហើយទ្រង់កំណត់ព្រះធម៌ទេសនា ដោយអំណាចនៃការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ទ្រង់បញ្ចេញព្រះរស្មីផ្សាយទៅ ហាក់បីដូចជាព្រះសាស្ដា ទ្រង់ប្រថាប់ចំពោះមុខ ហើយទ្រង់ត្រាស់សម្ដែងព្រះគាថាទាំងនោះថា

ភិក្ខុណា មានប្រក្រតីនៅដោយមេត្តា ជ្រះថ្លាក្នុងព្រះសាសនា ភិក្ខុនោះគប្បីសម្រេចបទដ៏ស្ងប់ ( គឺព្រះនិព្វាន ) ដែលចូលទៅរំងាប់សង្ខារដ៏ជាសុខ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកបាចទឹកទូក ( គឺអត្តភាព ) នេះ ទូកដែលអ្នកបាចទឹកចេញហើយចាកទីនោះ នឹងដល់នូវព្រះនិព្វាន ( គឺរលត់កិលេស និងកងទុក្ខ ) ។ ភិក្ខុគប្បីកាត់ផ្ដាច់ធម៌ ៥ ប្រការ ( សំយោជនៈខាងក្រោម ៥ ) គប្បីលះបង់ធម៌ ៥ ប្រការ ( គឺសំយោជនៈខាងលើ ៥ ) និងគប្បីញ៉ាំងនូវគុណធម៌ ៥ ប្រការ

( គឺឥន្ទ្រិយ ៥ ) ឲ្យចម្រើនក្រៃលែងឡើង ។ ភិក្ខុរំងាប់នូវកិលេសដែលជាគ្រឿងជាប់ជំពាក់ ៥ ប្រការ ( គឺរាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ ) បានហើយ តថាគតហៅថា បុគ្គលអ្នកឆ្លងឱឃៈ គឺអន្លង់ទឹកជំ ៤ ប្រការ ( គឺអន្លង់ទឹកទី ១ កាម ២ ភព ៣ ទិដ្ឋិ ៤ អវិជ្ជា ជាអន្លង់ទឹកឆ្លងបានដោយកម្រ ) ។ ចូរអ្នកបរិកម្ម ទាំងកុំប្រមាទ ចិត្តរបស់អ្នកកុំវិលទៅក្នុងកាមគុណ អ្នកកុំជាអ្នកប្រមាទលេបដុំលោហៈ ( គឺដុំដែកក្តៅក្នុងនរក ) អ្នកកុំជាអ្នកដែលកម្មឆេះនៅក្នុងនរក យំកន្ទក់កន្ទេញថា នេះទុក្ខ ។ ឈានរមែងមិនមានដល់បុគ្គល ដែលមិនមានបញ្ញា។ រមែងមិនមានក្នុងបុគ្គល ដែលមិនមានឈាន ឈាន និងបញ្ញារមែងមានក្នុងបុគ្គលណា បុគ្គលនោះ តាំងនៅក្នុងទីជិតព្រះនិព្វាន ។ សេចក្តីត្រេកអរមិនមែនរបស់មានទៅកន្លែងមនុស្ស រមែងមានដល់ភិក្ខុចូលទៅកាន់ផ្ទះទំនេរហើយ បុគ្គលមានចិត្តស្ងប់ហើយ បុគ្គលឃើញច្បាស់នូវធម៌ដោយប្រពៃ ។ ភិក្ខុពិចារណានូវការកើតឡើង និងការវិនាសទៅនៃខន្ធទាំងឡាយ ដោយអាការណា។ រមែងបាននូវបីតិ

និងបាមោជ្ជ ដោយអាការនោះៗ ។ ការបានទូវបីតិ និងបាមោជ្ជនោះ ជាធម៌ដែលមិនស្លាប់របស់អ្នកដឹងច្បាស់ទាំងឡាយ ។ ធម៌នេះ គឺការគ្រប់គ្រងនូវឥន្ទ្រិយ ១ សេចក្ដីសន្ដោស ១ ការសង្រួមក្នុងបាតិមោក្ខ ១ ជាខាងដើមក្នុងព្រះធម៌ ដែលមិនស្លាប់នោះ នៅមានដល់ភិក្ខុដែលមានបញ្ញាក្នុងសាសនានេះ ។ អ្នកចូរគប់មិត្តដែលល្អ មានអាជីពបរិសុទ្ធ មិនខ្ជិលច្រអូស គប្បីជាអ្នកប្រព្រឹត្តក្នុងបាតិមោក្ខ ១ ជាខាងដើមក្នុងធម៌មិនស្លាប់នោះ មានដល់ភិក្ខុអ្នកមានបញ្ញានៅក្នុងព្រះសាសនានេះ ។ អ្នកចូរគប់មិត្តដែលល្អ មានអាជីពបរិសុទ្ធ មិនខ្ជិលច្រអូស គប្បីជាអ្នកប្រព្រឹត្តក្នុងបដិសណ្ឋារៈ ( មានអាមិស និងធម៌ទុកទទួលភ្ញៀវ ) គប្បីជាអ្នកឈ្លាសវៃក្នុងអាចារៈ ( មានមារយាទល្អ ) ។ ព្រោះហេតុនោះ អ្នកនឹងជាអ្នកច្រើនដោយបាមោជ្ជ ( អ្នករីករាយក្នុងធម៌ ) ធ្វើនូវទីបំផុតនៃទុក្ខបាន ។

កាលព្រះមានជោគ ទ្រង់សម្ដែងព្រះគាថានេះចប់ហើយ ភិក្ខុទាំងអស់នោះ ក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទាក្នុង

កន្លែងដែលខ្លួនអង្គុយហើយនោះឯង ហើយនាំគ្នានិមន្តហោះឡើងទៅលើអាកាស ។ ភិក្ខុទាំងអស់ បាននិមន្តហោះទៅតាមផ្លូវអាកាស ឈានរំលងផ្លូវកន្តារប្រមាណ ១២០ យោជន៍ មកកោតសរសើរនូវព្រះពុទ្ធសរីរៈ ដែលមានពណ៌ដូចមាស និងដើម្បីនិមន្តមកក្រាបថ្វាយបង្គំព្រះយុគលបាទរបស់ព្រះលោកនាថ ។

នេះជាផលល្អរបស់ឧបាសិកាកាឡី ដែលជួយឲ្យប្រជាជនបានឱកាសមករួមស្តាប់ព្រះធម៌ទេសនា ជាពិសេសបានជួយឲ្យពួកចោរមានចិត្តអាក្រក់មកធ្វើអំពើល្អវិញ ទាំងបានជួយឲ្យពួកចោរបួសនៅក្នុងព្រះពុទ្ធសាសនានេះ ក៏ស្មើគ្នានឹងការជួយផ្សព្វផ្សាយព្រះពុទ្ធសាសនាឲ្យដល់ប្រជាជនបានយល់ដឹងច្រើនផងដែរ ។

ឧបាសិកាកាឡីមានការចាប់អារម្មណ៍ក្នុងធម៌ ហើយក៏បានចូលទៅសួរព្រះមហាកច្ចានៈ ដែលមានសម្តែងប្រាកដនៅក្នុងបាលី **កាឡីសូត្រ នៃ មហាវគ្គទី ៣ ក្នុង គម្ពីរអង្គុត្តរនិកាយ ទសកនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមហាកច្ចានៈ គង់នៅវត្តបពិត ជិតក្រុងកុររឃរៈ ក្នុងដែនអវន្តី ។ គ្រានោះ ឧបាសិកាកាឡី អ្នកនៅក្នុងក្រុងឈ្មោះកុររឃរៈ ចូលទៅរកព្រះមហាកច្ចានៈ លុះចូលទៅដល់ថ្វាយបង្គំព្រះកច្ចានៈ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះឧបាសិកាកាឡីអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ទូលព្រះមហាកច្ចានៈដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់ក្នុងកុមារីបញ្ហា ( ប្រស្នាដែលព្រះលោកនាយក ទ្រង់ពោលចំពោះពួកកុមារី ជាធីតានៃមារ ) ថា

ការសម្រេចប្រយោជន៍ ជាសេចក្តីស្ងប់រំងាប់ នៃហឫទ័យតថាគតម្នាក់ឯង បានឈ្នះនូវកិលេសសេនា ជាទីស្រឡាញ់ ជាទីត្រេកអរ បានឈាន ត្រាស់ដឹងនូវព្រះនិព្វានជាសុខ ហេតុនោះ តថាគតមិនធ្វើសាក្សីដោយសារជនទេ សាក្សី ( មិត្តធម៌ ) ដោយជនណាមួយមិនសម្រេចដល់តថាគតឡើយ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តីនៃភាសិតដែលព្រះភគវា

សម្តែងដោយសង្ខេបនេះ យើងគប្បីយល់ដោយពិស្តារដូចម្តេចបាន ? នែនាង ពួកសមណព្រាហ្មណ៍ខ្លះ ចូលកាន់បឋវីកសិណដ៏ឧត្តម ហើយញុំាងបឋវីកសិណនោះឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ នែនាង ព្រះសាស្តា បានត្រាស់ដឹងនូវការចូលកាន់បឋវីកសិណដ៏ឧត្តមនោះ ហើយបានឃើញខាងដើម គឺសមុទយសច្ចៈ បានឃើញទោស គឺទុក្ខសច្ចៈ បានឃើញនូវធម៌ជាគ្រឿងរលាស់ គឺនិរោធសច្ចៈ បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ គឺមគ្គសច្ចៈ ព្រះអង្គបានជ្រាបនូវការសម្រេចប្រយោជន៍ ជាការស្ងប់នៃហឫទ័យ ព្រោះហេតុនៃការឃើញខាងដើម ព្រោះហេតុនៃការឃើញទោស ព្រោះហេតុនៃការឃើញនូវធម៌ជាគ្រឿងរលាស់ ព្រោះហេតុនៃការឃើញនូវមគ្គាមគ្គញ្ញាណទស្សនៈ ។ នែនាង... ចូលកាន់អាបោកសិណដ៏ឧត្តម នែនាង... ចូលកាន់តេជោកសិណដ៏ឧត្តម នែនាង... ចូលកាន់វាយោកសិណដ៏ឧត្តម នែនាង... ចូលកាន់នីលកសិណដ៏ឧត្តម នែនាង... ចូលកាន់បីតកសិណដ៏ឧត្តម នែនាង... ចូលកាន់លោហិតកសិណដ៏ឧត្តម នែនាង... ចូលកាន់ឱទាតកសិណ

ដ៏ឧត្តម នែនាង... ចូលកាន់អាកាសកសិណដ៏ឧត្តម នែនាង... ពួកសមណព្រាហ្មណ៍ខ្លះចូលកាន់វិញ្ញាណកសិណដ៏ឧត្តម ហើយញុំាងវិញ្ញាណកសិណនោះឲ្យកើត ដោយប្រកាន់ថាជាប្រយោជន៍ ។ នែនាងព្រះមានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណកសិណដ៏ឧត្តមនេះ លុះព្រះមានព្រះភាគ បានជ្រាបច្បាស់នូវការចូលកាន់វិញ្ញាណកសិណដ៏ឧត្តមនោះហើយ បានឃើញខាងដើម បានឃើញទោស បានឃើញធម៌ជាគ្រឿងរលាស់ បានឃើញមគ្គាមគ្គញ្ញាណទស្សនៈ ព្រះអង្គជ្រាបនូវការបានសម្រេចប្រយោជន៍ ជាការស្ងប់ហឫទ័យ ព្រោះហេតុនៃការឃើញខាងដើម ព្រោះហេតុនៃការឃើញទោស ព្រោះហេតុនៃការឃើញធម៌ជាគ្រឿងរលាស់ ព្រោះហេតុនៃការមគ្គាមគ្គញ្ញាណទស្សនៈ ។ នែនាង ព្រះមានព្រះភាគជាម្ចាស់បានត្រាស់ពាក្យណា ក្នុងកុមារីបញ្ហាទាំងឡាយថា

ការសម្រេចប្រយោជន៍ ជាសេចក្ដីស្ងប់រំងាប់ នៃហឫទ័យ តថាគតម្នាក់ឯង បានឈ្នះនូវកិលេសសេនា ជាទីស្រឡាញ់ ជាទី

ត្រេកអរ បានឈាន ត្រាស់ដឹងនូវព្រះនិព្វានជាសុខ ហេតុនោះ តថាគត មិនធ្វើសាក្សីដោយសារជនទេ សាក្សី ( មិត្តធម៌ ) ដោយសារជន ណាមួយមិនសម្រេចដល់តថាគតឡើយ ។

នៃនាង សេចក្តីនៃភាសិត ដែលព្រះលោកនាថទ្រង់សម្តែង ដោយសង្ខេបនេះឯង យើងគប្បីដឹងដោយពិស្តារយ៉ាងនេះ ។ ឧបាសិកា កាឡី ជាតួយ៉ាងនៃឧបាសិកា ដែលមានការចាប់អារម្មណ៍ ក្នុងការ ស្តាប់ធម៌យ៉ាងពិតប្រាកដ គុណសម្បត្តិប្រការនេះ ទើបជាហេតុឲ្យ នាងបានទទួលការលើកតម្កើងពីព្រះមានព្រះភាគ នាកាលព្រះសម្ពុទ្ធ គង់នៅវត្តជេតពន ទ្រង់បានតែងតាំងឧបាសិកាទាំងឡាយ ទុកក្នុង តំណែងផ្សេងៗ ហើយក៏បានប្រកាសតែងតាំងឧបាសិកាកាឡីទុកនៅ ក្នុងតំណែងជាឯតទគ្គៈដែរ ។

តាមដែលមានសម្តែងទុកនៅក្នុងព្រះបាលី **គម្ពីរអង្គុត្តរនិកាយ ឯកនិបាត** ដូចមានសេចក្តីថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ អនុស្សវប្បសន្នានំ**

យទិទំ កាឡីឧបាសិកា កុររឃរិកា ម្នាលភិក្ខុទាំងឡាយ ឧបាសិកាកាឡី ជាអ្នកប្រសើរជាងឧបាសិកាទាំងឡាយ ដែលជាឧបាសិការបស់តថាគត ផ្នែកខាងជាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗ គ្នាមក ។

ចំណែកឧបាសិកាកាឡី ជាឧបាសិកាម្នាក់ ដែលជាអ្នកទ្រទ្រង់ទៅដោយគុណ ផ្នែកខាងធម៌ជារបស់ព្រះអរិយបុគ្គល ហើយឧបាសិកាកាឡី ជាអ្នកមានឧបការគុណចំពោះព្រះពុទ្ធសាសនានេះទៀតផង ។៚

( ជីវប្រវត្តិរបស់ឧបាសិកាកាឡី ចប់ )

888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនាងមល្លិកាទេវី ✍

## “ ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ព្រះនាងមល្លិកាទេវី ទ្រង់ជាស្ត្រីដែលមានរូបឆោមស្រស់ គួរឲ្យជាទីពិចពិលរមិលមើល ទាំងជាអ្នកឈ្លាសវៃ មានបញ្ញាស្រួចស្រាល់ ទាំងជាអ្នកមានព្រះទ័យក្នុងការធ្វើសេចក្ដីល្អជានិច្ច ទ្រង់ក៏ជាអ្នកត្រិះរិះផ្ដើមធ្វើ **អសទិសទាន** គឺទានដែលឥតមានទានដទៃណាមួយប្រដូចបាន ហើយជាពិសេសនោះ មានត្រឹមតែម្ដងគត់នៅក្នុងព្រះពុទ្ធសាសនារបស់ព្រះមានព្រះភាគនៃយើងនេះ និងផលនៃការធ្វើបុណ្យនំកុម្មាសចំពោះព្រះលោកនាថ បានបណ្ដាលឲ្យនាងជាមនុស្សសាមញ្ញ ក្លាយទៅជាអគ្គមហេសីនៃព្រះបាទបសេនទិកោសលបាន ។

ជីវប្រវត្តិរបស់ព្រះនាងមល្លិកា ដែលពោលនៅក្នុងវគ្គ ដែលទ្រង់នៅជាមនុស្សសាមញ្ញ និងការធ្វើបុណ្យរបស់ព្រះនាង មានរឿងសម្ដែងទុកនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដី

ព្រះបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយជាតក** នៃ **សត្តកនិបាតជាតក** ក្នុង **រឿងកុម្មាសបិណ្ឌជាតក** និងក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ ឧទាន** ក្នុងរឿង **រាជសូត្រ** និងក្នុង **អដ្ឋកថាសារត្ថប្បកាសិនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** ក្នុងរឿង **មល្លិកាសូត្រ** ដូចមានសេចក្តីថា ៖

កាលព្រះសម្មាសម្ពុទ្ធ គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ដោយទ្រង់ត្រាស់ព្រះធម៌ទេសនា ប្រារព្ធចំពោះព្រះនាងមល្លិកាទេវីថា ព្រះនាងមល្លិកាទេវីនោះ មុននឹងបានមកជាព្រះរាជទេវី ព្រះនាងជាធីតារបស់នាយមាលាការ ( អ្នកក្រងផ្កា ) ម្នាក់ ដែលនៅក្នុងក្រុងសាវត្ថី នាងជាស្ត្រីមានរូបឆោមល្អស្អាត ទាំងជាអ្នកមានបញ្ញាច្រើន ។ ក្នុងពេលដែលនាងមល្លិកាមានអាយុ ១៦ ឆ្នាំ ថ្ងៃមួយ នាងបានទៅលេងសួនផ្កាជាមួយនឹងស្ត្រីជាច្រើន តែមុននឹងចេញពីផ្ទះទៅ នាងបានយកនំកុម្មាស ( នំសណ្តែក ) ៣ ដុំដាក់ទៅក្នុងកំប្រោង សម្រាប់ដាក់ផ្កាដើរទៅ ក្នុង

ខណៈដែលនាងដើរចេញពីក្រុងទៅ នាងបានឃើញព្រះលោកនាយក ទ្រង់បញ្ចេញព្រះឆព្វណ្ណ ( រស្មីទាំង ៦ ពណ៌ គឺខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេក ) នៃព្រះវរកាយ ស្តេចយាងចូលទៅបិណ្ឌបាត ព្រមដោយភិក្ខុសង្ឃជាបរិវារ គ្រានោះ នាងមល្លិកាក៏កើតសេចក្តីជ្រះថ្លាឡើង ទើបនាំយកនំកុម្មាស ៣ ដុំ ទៅដាក់បាត្រថ្វាយព្រះសាស្តា ។ ចំណែកព្រះមហាវីរៈ ទ្រង់យកបាត្រដែលស្តេចចាតុម្មហារាជថ្វាយនោះ ទទួលនំកុម្មាសរបស់នាងមល្លិកា ។ នាងមល្លិកាក្រោយពីបានថ្វាយនំកុម្មាស បានក្រាបសិរសោចុះ ក្រាបថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមហាមុនី ហើយបានកាន់យកសេចក្តីត្រេកអរក្នុងចិត្ត មានព្រះពុទ្ធជាអារម្មណ៍ ហើយដើរទៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះមហាវីរៈទ្រង់ទតមើលនាងមល្លិកាហើយ ទ្រង់បានសម្តែងអាការញញឹមឲ្យប្រាកដ ដើម្បីនឹងបង្ហាញអំពីអានិសង្ស ដែលនាងមល្លិកាបានថ្វាយនំកុម្មាសឲ្យជាក់ច្បាស់ ។ ពេលនោះ ព្រះអានន្ទដ៏មានអាយុ បានឃើញអាការញញឹមនោះ ក៏បានដឹងមួយរំពេចថា នឹងមានបំណាងយ៉ាងណានីមួយ

ទើបក្រាបទូលសួរព្រះមានបុណ្យថា មានហេតុយ៉ាងណាឬ ក្នុងការដែលព្រះមុនីទ្រង់បានធ្វើការញញឹម ព្រះអង្គ ? ព្រះសម្ពុទ្ធទ្រង់ត្រាស់នូវហេតុនៃការញញឹមថា ម្នាលអានន្ទ ថ្ងៃនេះឯង ក្មេងស្រីនេះនឹងបានជាអគ្គមហេសីនៃព្រះបាទបសេនទិកោសល ព្រោះផលនៃទានដែលនាងបានថ្វាយនំកុម្មាសនេះ ព្រះលោកនាថត្រាស់ដូច្នេះហើយ ទើបស្តេចចារិកទៅតាមធម្មតា មួយអន្លើដោយភិក្ខុសង្ឃជាបរិវារ ។

ចំណែកឯនាងមល្លិកា កាលបើថ្វាយនំកុម្មាសចំពោះព្រះភគវាហើយ បានដើរៗ ទៅ រហូតដល់សួនផ្កា ថែមទាំងនាងបានច្រៀងនៅក្នុងសួនផ្កានោះទៀតផង ។ ក្នុងថ្ងៃនោះឯង ព្រះបាទបសេនទិកោសលទ្រង់បានធ្វើចម្បាំងជាមួយនឹងព្រះបាទអជាតសត្តុ ទ្រង់បានបរាជ័យក្នុងការធ្វើចម្បាំង ហើយទ្រង់ជិះសេះរត់ចូងកាត់ មកតាមផ្លូវសួនផ្កានោះ ទ្រង់ក៏បានឮសំឡេងនាងមល្លិកាកំពុងតែច្រៀង ក៏ទ្រង់សព្វព្រះរាជហឫទ័យក្នុងសំនៀងនោះ ទើបទ្រង់ទាញខ្សែបង្ហៀរសេះព្រះទីន័ងតម្រង់ទៅសួនផ្កានោះ ។ នាងមល្លិកា ជាស្ត្រីដែលដល់ព្រមដោយ

បុណ្យវាសនា កាលជួបនឹងព្រះរាជាហើយ ក៏មិនរត់គេចទៅណា តែនាងត្រឡប់ដើរចូលទៅចាប់ខ្សែបង្ហៀរសេះរបស់ព្រះរាជាទៀតផង ។ គ្រានោះព្រះបាទបសេនទិកោសលត្រាស់សួរ ទាំងដែលទ្រង់ប្រថាប់នៅលើខ្នងសេះថា នាងមានស្វាមីហើយឬនៅ ? នាងមល្លិកាក្រាបទូលថា នៅមិនទាន់មានស្វាមីទេ ព្រះអង្គ ? ទើបចុះចាកខ្នងសេះ មកផ្ទំលើភ្លៅរបស់នាងមល្លិកា ព្រោះទ្រង់ហត់នឿយមកដោយខ្យល់ និងកំដៅថ្ងៃ ទ្រង់សម្រាកបានមួយស្របក់ហើយ សុំឲ្យនាងឡើងអង្គុយលើសេះព្រះទីន័ង ហែហមដោយពួកពលយោធា ស្តេចយាងចូលទៅក្នុងព្រះនគរ ហើយចាត់ចែងបញ្ជូននាង ឲ្យត្រឡប់មកដល់មាតាបិតារបស់នាងវិញ លុះដល់វេលាល្ងាច ទើបបញ្ជូនព្រះរាជយាន ព្រមដោយគ្រឿងសក្ការៈ និងគ្រឿងរាជឥស្សរិយយសជាច្រើន ហើយឲ្យនាងអង្គុយលើគំនររតនៈ ទើបទ្រង់ធ្វើការអភិសេក តាំងនាងជា **ឯកអគ្គមហេសី** ។ ចាប់ផ្តើមអំពីនោះមក ព្រះនាងមល្លិកាទេវី ទ្រង់ជាទីស្នេហារបស់ព្រះបាទបសេនទិកោសលយ៉ាងក្រៃលែង ព្រោះព្រះនាងទ្រង់ជាអ្នកប្រកបដោយ

កល្យាណធម៌ ៥ ប្រការនៃស្ត្រី ទ្រង់គោរពចំពោះព្រះរាជស្វាមីណាស់ ទាំងទ្រង់ជាទីស្និទ្ធស្នាលជាមួយនឹងព្រះភគវាដែរ ។ ការដែលព្រះនាងទ្រង់ថ្វាយនំកុម្មាស ៣ ដុំចំពោះព្រះទសពលហើយ ព្រះនាងទ្រង់បានជាអគ្គមហេសីនៃស្តេចក្នុងបច្ចុប្បន្នទាន់ភ្នែកនេះ ដំណឹងទាំងអស់នេះក៏បានឮទូទៅទាំងក្រុងសាវត្ថី ។ ខាងក្រោយថ្ងៃមួយ ភិក្ខុទាំងឡាយបានអង្គុយសន្ទនាគ្នានៅក្នុងសាលាធម្មសភាថា ព្រះនាងមល្លិកាទេវីទ្រង់ថ្វាយនំកុម្មាស ៣ ដុំចំពោះព្រះលោកនាថ ហើយបានអភិសេកជាឯកអគ្គមហេសី នៅក្នុងថ្ងៃនោះឯង ព្រោះផលរបស់ទាននោះ ។ គ្រានោះ ព្រះលោកនាយកស្តេចយាងមកត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុអ្នកប្រជុំសន្ទនាគ្នាពីរឿងអ្វី ? កាលទ្រង់ជ្រាបពីការក្រាបទូលរបស់ភិក្ខុទាំងឡាយហើយ ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនអស្ចារ្យទេ ដែលនាងមល្លិកាទេវីទ្រង់ថ្វាយនំកុម្មាស ៣ ដុំចំពោះព្រះសព្វញ្ញុពុទ្ធមួយអង្គហើយ បានជាអគ្គមហេសីរបស់ព្រះបាទបសេនទិកោសល ព្រោះហេតុអ្វី ព្រោះព្រះពុទ្ធទាំងឡាយមានគុណច្រើន

តែថា បណ្ឌិតទាំងឡាយពីបុរាណថ្វាយនំកុម្មាស ៤ ដុំដែលសាបឈឹង គ្មានខ្លាញ់ គ្មានផ្អែម ដល់ព្រះបច្ចេកពុទ្ធ ក៏បានសិរីរាជសម្បត្តិក្នុងដែនកាសិករដ្ឋ មានបរិវេណប្រមាណ ៣ រយយោជន៍ ក្នុងអត្តភាពទី ២ ( គឺជាតិបន្ទាប់មក បានកើតជាព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី ដែលមានដែនដីធំទូលំទូលាយបរិបូណ៌ដោយសម្បត្តិគ្រប់យ៉ាង ) ព្រោះផលនៃការថ្វាយនំកុម្មាស ៤ ដុំចំពោះព្រះបច្ចេកពុទ្ធ ៤ រូបដោយដៃរបស់ខ្លួនឯង ។

ផលល្អរបស់ព្រះនាងមល្លិកាទេវី ទ្រង់ចូលទៅគាល់ព្រះភគវាដើម្បីទ្រង់ក្រាបទូលសួរមូលហេតុ ដែលធ្វើឲ្យមាតុគ្រាមមានរូបរាងនិងសម្បុរស្អាត គួរឲ្យជាទីស្រឡាញ់ និងមិនស្អាត គួរឲ្យស្អប់ ព្រោះអ្វីជាហេតុ អ្វីជាបច្ច័យ ទាំងព្រះនាងទ្រង់បានប្ដេជ្ញាជាព្រះពុទ្ធមាមិកជនមានរឿងពោលទុកនៅក្នុងបាលី **មល្លិកាសូត្រ** ក្នុង **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត** ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះបរមគ្រូ ទ្រង់គង់នៅក្នុងវត្តជេតពន ជិតក្រុង

សាវត្ថី ។ គ្រានោះ ព្រះនាងមល្លិកាទេវី ក៏ចូលទៅគាល់ព្រះសាស្តា លុះចូលទៅដល់ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះនាងមល្លិកាទេវីអង្គុយនៅក្នុងដ៏សមគួរ ហើយបានក្រាបបង្គំទូលព្រះសាស្តាដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលណាស់ ជាមនុស្សកម្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានសក្តិតូចផង ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលផង តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្តិធំ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ជាអ្នកប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង តែជាអ្នកកម្សត់ មានទ្រព្យតិច

មានភោគៈតិច មានសក្តិតូច ។ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកមាតុគ្រាមខ្លះក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានសក្តិធំផង ។ នៃនាងមល្លិកាទេវី មាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តីចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹងព្យាបាទ រឹងត្អឹងធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ មាតុគ្រាមនោះ មិនដែលឲ្យបាយ ទឹក សំពត់ យានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអន្ទុយ គ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ឡើយ ជាអ្នកមានចិត្តឫស្យា តែងឫស្យាប្រទូស្ត ចងសេចក្តីឫស្យាក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អានសំពះ និងការបូជារបស់ជនទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ចុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ

កើតក្នុងត្រកូលឯណានីមួយ ជាអ្នកមានសម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលផង ជាអ្នកកម្សត់ផង មានទ្រព្យតិចផង មានភោគៈតិចផង មានសក្តិតូចផង ។ នែនាងមល្លិកាទេវី មួយទៀត មាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនក្រោធ មានសេចក្តីចង្អៀតចង្អល់ច្រើន ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹងព្យាបាទ រឹងត្អឹងធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើង ។ តែមាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអន្ទ្រុយ គ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ទាំងមិនមានចិត្តប្រកបដោយឫស្យា ទាំងមិនមានចិត្តប្រកបដោយឫស្យា រមែងមិនមានឫស្យា មិនប្រទូស្ត មិនចងសេចក្តីឫស្យាក្នុងលាភសក្ការៈ សេចក្តីគោរពកោតអាន សំពះ និងការបូជារបស់ជនទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង

អាក្រក់មើលផង ប៉ុន្តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្តិធំផង ។ នែនាងមល្លិកាទេវី មួយទៀត មាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្តខឹង មិនព្យាបាទមិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ តែមាតុគ្រាមនោះ មិនដែលឲ្យបាយ ទឹក សំពត់យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអន្ទុយ គ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ឡើយ ទាំងជាអ្នកមានចិត្តប្រកបដោយឫស្យា តែងឫស្យាប្រទូស្ត ចងសេចក្តីឫស្យាក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អានសំពះ និងការបូជារបស់ជនទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណាទីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផងប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់

មានទ្រព្យតិច មានភោគៈតិច មានសក្តិតូច ។ នែនាងមល្លិកា មួយទៀត មាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើង ។ មាតុគ្រាមនោះ ធ្លាប់ឲ្យបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអន្ទយ និងគ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ទាំងជាអ្នកមានចិត្តមិនប្រកបដោយឫស្យា តែងមិនឫស្យា មិនប្រទូស្ត មិនចងសេចក្តីឫស្យាក្នុងលាភសក្ការៈ សេចក្តីគោរពកោតក្រែង និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ ប្រសិនបើមាតុគ្រាមនោះ ច្យុតអំពីអត្តភាពនោះទៅហើយ មកកាន់អត្តភាពនេះវិញ មាតុគ្រាមនោះ កើតក្នុងត្រកូលឯណានីមួយ តែងជាអ្នកមានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ទាំងជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង

មានសក្តិធំផង ។ នែនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានសម្បុរអាក្រក់ផង អាក្រក់មើលផង ជាអ្នកខ្សត់ផង មានទ្រព្យតិចផង មានសក្តិតូចផង ។ នែនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានពណ៌សម្បុរអាក្រក់ផង មានរូបអាក្រក់ផង អាក្រក់មើលផង ប៉ុន្តែជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានសក្តិធំផង ។ នែនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ ជាអ្នកមានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ប៉ុន្តែជាអ្នកខ្សត់ មានទ្រព្យតិច មានភោគៈតិច មានសក្តិតូចផង ។ នែនាងមល្លិកា នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមាតុគ្រាមពួកខ្លះក្នុងលោកនេះ មានរូបល្អផង គួរជាទីពិចពិលរមិលមើលផង គួរជាទីជ្រះថ្លាផង ប្រកបដោយពណ៌សម្បុរ និងទ្រង់ទ្រាយដ៏ឧត្តមផង ជាអ្នកស្តុកស្តម្ភផង មានទ្រព្យច្រើនផង មានភោគៈច្រើនផង មានសក្តិធំ

ផង ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះនាងមល្លិកាទេវី ក៏ក្រាបបង្គំព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយបន្តិចបន្តួច ក៏ចងចិត្តខឹង ព្យាបាទ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើងក្នុងជាតិមុនដោយពិត បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានពណ៌សម្បុរអាក្រក់ រូបអាក្រក់ អាក្រក់មើលផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអន្ទុយ និងគ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ក្នុងជាតិមុនដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកមិនមានចិត្តឫស្យា មិនប្រណែន មិនប្រទូស្ត មិនចងសេចក្តីប្រណែនក្នុងលាភសក្ការៈ សេចក្តីគោរព រាប់អានសំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃអំពីជាតិមុន ។

បពិត្រព្រះអង្គដ៏ចម្រើន បានជាឥឡូវនេះ ខ្ញុំព្រះអង្គមានសក្តិធំដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ខត្តិយកញ្ញាខ្លះ ព្រាហ្មណកញ្ញាខ្លះ គហបតីកញ្ញាខ្លះ ដែលមានក្នុងរាជត្រកូលនេះ កញ្ញាទាំងនោះ ខ្ញុំព្រះអង្គតែងធ្វើជាធំ ជាអធិបតីលើកញ្ញាទាំងនោះ បពិត្រព្រះអង្គដ៏ចម្រើន តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំព្រះអង្គជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេនិយាយច្រើន ក៏មិនចងចិត្ត មិនខឹង មិនព្យាបាទ មិនរឹងត្អឹង មិនធ្វើនូវសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនត្រេកអរ ឲ្យកើតប្រាកដឡើង ខ្ញុំព្រះអង្គនឹងឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអង្គុយ និងគ្រឿងប្រទីបដល់សមណៈ ឬព្រាហ្មណ៍ ខ្ញុំព្រះអង្គមិនមានចិត្តឫស្យា មិនប្រណែន មិនប្រទូស្ត មិនចងនូវសេចក្តីប្រណែនក្នុងលាភសក្ការៈ សេចក្តីគោរពរាប់អានសំពះ និងការបូជារបស់បុគ្គលទាំងឡាយដទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ល។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះលោកនាថ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសិកា អ្នកដល់

នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

ព្រះនាងមល្លិកាទេវី ទ្រង់បានសម្តែងភាពជាបណ្ឌិតឲ្យប្រាកដដល់ព្រះបាទបសេនទិកោសល ដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ ក្នុងរឿងមល្លិកាសូត្រ** ថា ៖

ជិតក្រុងសាវត្ថី... សម័យនោះឯង ព្រះបាទបសេនទិកោសលគង់ក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើ ជាមួយនឹងព្រះនាងមល្លិកាទេវី ។ គ្រានោះ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលនឹងព្រះនាងមល្លិកាទេវី ដូច្នេះថា នែនាងមល្លិកា បុគ្គលដទៃណា ដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួននាងទៅទៀត មានដែរឬ ? ព្រះនាងមល្លិកាទេវី ក្រាបទូលថា បពិត្រមហារាជ បុគ្គលដទៃណាដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួនខ្ញុំម្ចាស់មិនមានទេ បពិត្រមហារាជ ចុះបុគ្គលណានីមួយដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួនព្រះអង្គទៅទៀត មានដែរឬ ? ព្រះបាទបសេនទិកោសលតបថា នែនាងមល្លិកា បុគ្គលដទៃណានីមួយដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួនយើងទៅទៀតមិនមានទេ ។

លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ចុះអំពីប្រាសាទ ហើយស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះសាស្តាដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើជាមួយនឹងនាងមល្លិកាទេវី ក្នុងទីឯណោះ បានសួរនាងមល្លិកាទេវីដូច្នេះថា នែនាងមល្លិកា បុគ្គលដទៃណាដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួននាងទៅទៀត មានដែរឬ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ នាងមល្លិកាទេវី ក៏ពោលតបមកនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រមហារាជ បុគ្គលដទៃណាដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួនខ្ញុំម្ចាស់ទៅទៀត មិនមានទេ បពិត្រមហារាជ ចុះបុគ្គលណានីមួយ ដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួនព្រះអង្គទៅទៀត មានដែរឬ ? បពិត្រព្រះអង្គដ៏ចម្រើន កាលបើនាងមល្លិកាទេវីសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គឆ្លើយតបនឹងនាងមល្លិកា

ទេវីទៅវិញដូច្នេះថា នែនាងមល្លិកា បុគ្គលដទៃណានីមួយ ដែលជាទីស្រឡាញ់ ដែលវិសេសជាងខ្លួន យើងទៅទៀត មិនមានទេ ។ លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏ត្រាស់នូវគាថានេះ ក្នុងពេលនោះថា

**បុគ្គលមានចិត្តរំពឹងគិតសព្វទិស រមែងរកមិនឃើញនូវបុគ្គលជាទីស្រឡាញ់ជាងខ្លួនក្នុងទីណាមួយទេ ខ្លួនទើបជាទីស្រឡាញ់ច្រើនជាងបុគ្គលដទៃយ៉ាងនោះឯង ព្រោះហេតុនោះ បុគ្គលដែលស្រឡាញ់ខ្លួនឯង មិនគប្បីបៀតបៀនបុគ្គលដទៃឡើយ ។**

ព្រះនាងមល្លិកាទេវី ទ្រង់សម្តែងដល់នូវភាពជាអ្នកមានបញ្ញា ទ្រង់ដឹងទាន់ហេតុការណ៍ដែលកើតឡើងបានត្រឹមត្រូវ ទ្រង់មិនវង្វេងជឿពាក្យរបស់រាជបុរោហិត អ្នកគិតឃើញដល់លាភសក្ការៈ ក្រាបបង្គំទូលបោកបញ្ឆោតព្រះបាទបសេនទិកោសល ឲ្យទ្រង់វង្វេងជឿក្នុងអំពើដែលខុស ដោយព្រះនាងទ្រង់ជាអ្នកជួយឲ្យព្រះបាទបសេនទិកោសលរួចផុតពីការបោកបញ្ឆោត និងរួចផុតពីការទ្រង់ធ្វើអំពើបាប ទាំងជួយ

ឲ្យទ្រង់ដោះលែងសត្វទាំងឡាយទៀតផង តាមដែលមានសម្ដែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ពាលវគ្គ** និង **អដ្ឋកថាបរមត្ថទីបនី** ថា៖

កាលបើរាជបុរោហិត ក្រាបបង្គំទូលកុហកនូវទំនាយព្រះសុបិនរបស់ព្រះបាទបសេនទិកោសលថា ជាព្រះសុបិននិមិត្តអាក្រក់ មានអន្តរាយដល់ព្រះជន្មរបស់ព្រះរាជា ។ ព្រះរាជាត្រូវធ្វើការបូជាយញ្ញដោយជីវិតសត្វគ្រប់យ៉ាង សត្វម្យ៉ាងៗ ១០០ ទើបទ្រង់អាចរួចផុតអំពីមរណភ័យនោះបាន ។ ព្រះបាទបសេនទិកោសល ទ្រង់វង្វេងជឿក្នុងពាក្យក្រាបបង្គំទូលរបស់រាជបុរោហិតនោះ ទើបមានព្រះរាជតម្រាស់អនុញ្ញាតឲ្យចាប់សត្វទាំងពួងដោយឆាប់រហ័ស ។ រាជបុរោហិតនោះកាលនឹងឲ្យមនុស្សចាប់សត្វមានជីវិតបែបណាមួយ ឲ្យបានមួយមុខៗ ១០០ គឺដំរី សេះ គោឧសភៈ កូនគោឈ្មោល មេគោ កូនគោញីពពែ ចៀម មាន់ ជ្រូក ក្មេងប្រុស ក្មេងស្រី គេក៏គិតជញ្ជឹងថាប្រសិនបើយើងនឹងឲ្យចាប់យកតែសត្វ ឬម្រឹគដែលជាអាហារប៉ុណ្ណោះជនទាំងឡាយនឹងនិយាយបានថា បុរោហិតឲ្យចាប់យកតែសត្វដែល

ជារបស់អាចស៊ីបានប៉ុណ្ណោះ ព្រោះដូច្នោះ ទើបឲ្យចាប់ទាំងជ័រី សេះ និងមនុស្សផង ។

ផលប្រាកដថា ពួកមនុស្សដែលបុរោហិតនោះបញ្ជាឲ្យចាប់ ក៏ធ្វើការចាប់ច្រើនហួសដែលបញ្ជានោះ សេចក្ដីក្នុងវគ្គនេះមានប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **កោសលសំយុត្ត** ថា ៖

ជិតក្រុងសាវត្ថី... សម័យនោះ ព្រះបាទបសេនទិកោសល តាំងផ្ដើមធ្វើមហាយញ្ញ ( បូជាធំ ) ។ ពួកគោឧសភៈ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ គេចងភ្ជាប់នឹងសសរយញ្ញដើម្បីបូជា ។ ពួកជនណា ដែលជាខ្ញុំប្រុសក្ដី ជាអ្នកបម្រើក្ដី ជាអ្នកធ្វើការងារក្ដី ជនទាំងនោះត្រូវអាជ្ញាគំរាម ហើយត្រូវភ័យគំរាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ ( ការរំពឹងគិត ) ។ កាលបើមហាជនស្រែកយំដល់ពួកញាតិរបស់ខ្លួនរៀងៗ ខ្លួន មានសំឡេងខ្លាំង ហាក់បីដូចសំឡេងផែនដីស្រុត ។ គ្រានោះ ព្រះនាងមល្លិកាទេវី ទ្រង់ព្រះសណ្ដាប់សំឡេង

នោះហើយ ទើបស្តេចទៅកាន់រាជសម្នាក់ ចូលគាល់ព្រះរាជាក្រាបទូលសួរថា បពិត្រមហារាជ មានហេតុអ្វីឬ ? ឥន្ទ្រិយព្រះអង្គមិនប្រក្រតីប្រាកដដូចព្រះអង្គអស់កម្លាំង ព្រះពរម្ចាស់ ។ ព្រះបាទបសេនទិកោសលទើបត្រាស់ថា នាងមល្លិកា មិនដឹងឬថា អាសិរពិសលូននៅក្បែរត្រចៀករបស់យើង ( សំដៅដល់ មានប្រាប់ប្រផ្នូលអាក្រក់ដល់យើង ) ។ ព្រះនាងមល្លិកាទើបក្រាបទូលសួរថា មានហេតុអ្វី ព្រះអង្គ ?ព្រះរាជាត្រាស់តបថា កាលពីយប់មិញនេះ យើងបានឮសំឡេងចម្លែក យើងទើបសួរបុរោហិត ក៏បានជ្រាបថា អន្តរាយនៃជីវិតនឹងប្រាកដដល់យើងៗត្រូវបូជាយញ្ញ ដោយសត្វម្យ៉ាងៗ ១០០ ទើបនឹងរួចជីវិតបាន យើងទើបគិតថា ការដែលយើងមានជីវិតរស់នៅនោះឯង ជាលាភរបស់យើងៗទើបឲ្យចាប់សត្វទាំងនោះ ។ ព្រះនាងមល្លិកាទេវី ទ្រង់ក្រាបទូលថាបពិត្រមហារាជ ព្រះអង្គជាមនុស្សអន្ធពាល ( មនុស្សល្ងង់ សោយព្រះក្រយាហារច្រើនឥតអំពើ ព្រះអង្គសោយម្ហូបៗ មួយនាឡិធំ មានសម្ល និងអ្វីៗ ផ្សេងៗ ជាច្រើន ព្រះអង្គទ្រង់គ្រងរាជ្យសម្បត្តិពីរដែនក៏ពិត

តែបញ្ញារបស់ព្រះអង្គនៅល្ងង់ខ្លៅម៉្លេះ ។ ព្រះបាទបសេនទិកោសល ទើបត្រាស់សួរថា ព្រោះហេតុអ្វី នាងទើបនិយាយយ៉ាងនេះ? ព្រះនាងមល្លិកាទេវីទ្រង់ក្រាបទូលថា ព្រះអង្គទ្រង់ឃើញទីណា ដែលមនុស្សម្នាក់មានជីវិតរស់នៅ ព្រោះការសម្លាប់របស់មនុស្សដទៃទៀត ព្រោះហេតុអ្វីបានជាទ្រង់ជឿពាក្យរបស់ព្រាហ្មណ៍ជាមនុស្សអន្ធពាល ហើយទម្លាក់ទុក្ខទៅឲ្យដល់មហាជន និងពួកសត្វទៅវិញ ព្រះលោកនាយកទ្រង់ជាអគ្គបុគ្គលនៃមនុស្ស និងទេវតាទាំងឡាយ មានព្រះប្រាជ្ញាមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ សូមព្រះអង្គទ្រង់ក្រាបទូលសួរព្រះមានជោគ ទ្រង់ធ្វើតាមឱវាទរបស់ព្រះពុទ្ធចុះ ព្រះអង្គ ។

លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់យាងទៅកាន់វត្តជាមួយនឹងព្រះនាងមល្លិកាទេវីដោយព្រះរាជរថ ព្រះអង្គត្រូវមរណភ័យគំរាមហើយ ទ្រង់មិនអាចក្រាបទូលអ្វីៗ បានឡើយ លុះទ្រង់ក្រាបថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយ ទ្រង់គង់ប្រថាប់នៅក្នុងទីដ៏សមគួរ ។ គ្រានោះព្រះលោកនាថ ទ្រង់សាកសួរព្រះរាជាមុនថា បពិត្រមហារាជ ព្រះអង្គ

ស្តេចយាងមកពីណា ទាំងកណ្តាលថ្ងៃដូចនេះ ? ប៉ុន្តែព្រះបាទបសេនទិ-កោសល ក៏ទ្រង់ប្រថាប់គង់នៅស្ងៀមដដែល ។ ពេលនោះ ព្រះនាងមល្លិកាទេវីទ្រង់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានជ្រាបថា ព្រះរាជាទ្រង់បានព្រះសណ្តាប់នូវសំឡេងដ៏ចម្លែក ក្នុងវេលានៃមជ្ឈិមយាម ហើយព្រះអង្គត្រាស់ប្រាប់ហេតុនោះដល់បុរោហិត ចំណែកឯបុរោហិតក្រាបបង្គំទូលថា អន្តរាយនៃជីវិត នឹងមានដល់ព្រះអង្គ កាលបើព្រះអង្គចាប់សត្វមួយមុខ ១០០ សម្រាប់ បូជាយញ្ញ ដោយលោហិតហូរពីបំពង់-កនៃសត្វនោះ ទើបដើម្បីកម្ចាត់អន្តរាយ ព្រះអង្គនឹងរួចជីវិតបាន ព្រះអង្គឲ្យគេចាប់សត្វទុកជាច្រើន ព្រះករុណាព្រះអង្គ ។ ព្រះសាស្តាទើបត្រាស់សួរថា យ៉ាងនោះ មែនឬមហារាជ ? ព្រះបាទបសេនទិកោសលទ្រង់ក្រាបទូលថា យ៉ាងនោះពិតមែន ព្រះអង្គ ។ ព្រះលោកនាថត្រាស់សួរតទៅទៀតថា ព្រះអង្គ ទ្រង់ឮសំឡេងនោះថាយ៉ាងណា ? ព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលតបតាមសំឡេងដែលទ្រង់បានឮមក ( ទុ. ស. ន. សោ. ) ។ ព្រះមហាវីរៈ

ទ្រង់បានព្រះសណ្ដាប់សេចក្ដីដែលព្រះរាជាទ្រង់ក្រាបទូលនោះ ។ លំដាប់នោះ ព្រះមហាមុនីត្រាស់នឹងព្រះរាជាថា មហាបពិត្រ ព្រះអង្គកុំភ័យខ្លាចអ្វីឡើយ អន្តរាយមិនមានដល់ព្រះអង្គទេ តែពួកសត្វដែលធ្វើបាបកម្ម កាលនឹងប្រកាសទុក្ខរបស់ខ្លួន រៀងៗ ខ្លួនឲ្យច្បាស់ ទើបពោលយ៉ាងនោះ ។ ព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលសួរថា សត្វទាំងនោះធ្វើកម្មអ្វី ព្រះអង្គ ? ព្រះភគវា កាលនឹងទ្រង់សម្ដែងកម្មរបស់សត្វនរកទាំងនោះ ទើបត្រាស់ថា

ក្នុងអតីតកាល យុគសម័យនោះ មនុស្សមានអាយុពីរម៉ឺនឆ្នាំ ព្រះកស្សបសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោក ស្ដេចចារិកទៅក្នុងទីកន្លែងផ្សេងៗ ព្រមដោយព្រះអរហន្តសាវកពីរម៉ឺនរូប ស្ដេចបានទៅដល់ក្រុងពារាណសី ។ អ្នកក្រុងពារាណសីរួមគ្នាថ្វាយអាគន្តុកទាន ពួកខ្លះក៏ថ្វាយពីររូប ពួកខ្លះក៏ថ្វាយបីរូប ឬពួកខ្លះក៏ថ្វាយច្រើនរយរូប ។ ក្នុងកាលនោះ ក្នុងក្រុងពារាណសី មានសេដ្ឋីបុត្រ ៤ នាក់ ម្នាក់ៗ មានទ្រព្យសម្បត្តិ ៤០ កោដិ ជាសម្លាញ់នឹងគ្នា សេដ្ឋីទាំងនោះប្រឹក្សា

គ្នាថា ក្នុងផ្ទះរបស់ពួកយើងមានទ្រព្យសម្បត្តិច្រើនណាស់ តើពួកយើងចំណាយទ្រព្យនេះយ៉ាងណា ។ កាលព្រះកស្សបសម្មាសម្ពុទ្ធទ្រង់ព្រះគុណដូចនោះស្តេចកំពុងចារិកទៅ បណ្តាសេដ្ឋីបុត្រទាំងនោះ មិនមាននរណាម្នាក់និយាយថា ពួកយើងនឹងថ្វាយទាន ធ្វើការបូជា រក្សាសីល តែមានម្នាក់ពោលឡើងថា ពួកយើងនឹងផឹកសុរា បរិភោគសាច់ក្លែម ទៅដើរលេងសប្បាយ ជីវិតរបស់ពួកយើងនេះ ប្រាកដជាល្អមិនខានឡើយ ។ ម្នាក់ទៀតពោលថា ពួកយើងបរិភោគបាយស្រូវសាលីក្រអូប ដែលរក្សាទុក ៣ ឆ្នាំហើយ និងអាហារដែលមានរសឆ្ងាញ់ផ្សេងៗ ត្រាច់ទៅ ។ មួយទៀត ពោលថា ពួកយើងនឹងឲ្យគេជ្រើសរកភោជនីយាហារប្លែកៗមក ហើយត្រាច់ទៅ ។ ឯម្នាក់ទៀតពោលថា នែសម្លាញ់ ពួកយើងមិនធ្វើកិច្ចអ្វីយ៉ាងដទៃ ស្ត្រីទាំងឡាយ កាលបើយើងប្រាប់ថានឹងឲ្យទ្រព្យឯស្រីដែលមិនត្រូវការទ្រព្យនោះ មិនមានឡើយ ព្រោះដូច្នោះ ពួកយើងប្រមូលទ្រព្យទុកហើយ យកទ្រព្យទៅបញ្ឆោតដើម្បីលួងលោមស្រីធ្វើបរទារកម្ម ( គឺអំពើដែលបុរសប្រព្រឹត្តខុស ចំពោះភរិយារបស់

អ្នកដទៃ គឺអំពើលួចប្រពន្ធគេ) ។សេដ្ឋីបុត្រទាំង ៤នាក់នោះយល់ព្រម ក្នុងការយល់ឃើញរបស់អ្នកចុងក្រោយថា ល្អហើយៗ និងធ្វើតាមពាក្យ ណែនាំរបស់អ្នកទី ៤ នោះ ។ ចាប់ផ្តើមពីពេលនោះមក សេដ្ឋីបុត្រ ទាំងនោះ បានជញ្ជូនទ្រព្យទៅឲ្យដល់ស្រ្តីដែលមានរូបស្អាត ដើម្បីការ សប្បាយតាមបំណងរបស់ខ្លួនអស់ពីរម៉ឺនឆ្នាំ កាលចុតិហើយ ក៏បានទៅ កើតក្នុងអវិចីនរក ព្រោះតែទោសនៃអំពើប្រព្រឹត្តបរទារកម្ម ។សេដ្ឋីបុត្រ ទាំងនោះត្រូវឆេះក្នុងនរកអស់មួយពុទ្ធន្តរ កើតស្លាប់ៗ កើតនៅក្នុង អវិចីនរកនោះ ដោយអំណាចបាបកម្មនៅមិនទាន់អស់ ទើបបានទៅកើត ក្នុងលោហកុម្ភីទៀត ដែលមានជម្រៅ ៦០ យោជន៍ លិចចុះទៅដល់ បាតខាងក្រោមត្រូវចំណាយពេលអស់ ៣ ម៉ឺនឆ្នាំ ងើបឡើងមកដល់ ខាងលើមាត់ខ្ទះ ៣ម៉ឺនឆ្នាំ ពួកគេត្រូវការពោលនូវគាថាម្នាក់ៗ ១ គាថា តែមិនអាចនឹងពោលបាន ក៏ពោលម្នាក់ៗ បានត្រឹមតែមួយព្យញ្ជនៈ ហើយត្រឡប់លិចចុះទៅក្នុងខ្ទះទង់ដែងដូចដើមវិញ ។បពិត្រមហារាជ ព្រះអង្គឮសំឡេងនោះយ៉ាងណា ? ព្រះបាទបសេនទិកោសល ទ្រង់

ក្រាបទូលថា សំឡេងថា ទុ ព្រះអង្គ ។ ព្រះលោកនាយក កាលនឹងទ្រង់សម្តែងគាថា ដែលសត្វនរកពោលនៅមិនទាន់ពេញ ឲ្យពេញ ទើបព្រះពុទ្ធអង្គត្រាស់ថា

ពាក្យថា ទុ មានសេចក្តីថា **យើងមិនបានឲ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ពួកយើងជាអ្នករស់នៅដោយលំបាក ។**

លុះព្រះមានជោគ ទ្រង់ប្រកាសសេចក្តីនេះដល់ព្រះរាជាហើយ ទើបត្រាស់សួរថា បពិត្រមហារាជ សំឡេងទី ២-៣-៤ ព្រះអង្គទ្រង់ឮថាយ៉ាងណា ? ព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលថា ឮថាយ៉ាងនេះ ទី ២ ស ទី ៣ ន ទី ៤ សោ ព្រះអង្គ ។ ព្រះសក្យមុនីទ្រង់សម្តែងពាក្យដ៏សេសឲ្យបរិបូណ៌ ទើបត្រាស់គាថានោះតាមលំដាប់ថា

ពាក្យថា ស មានសេចក្តីថា **ពួកយើងឆេះនៅក្នុងនរកពេញ ៦ ម៉ឺនឆ្នាំគ្រប់គ្រាន់ តើទីបំផុតនឹងមានក្នុងវេលាណា ។**

ពាក្យថា ន មានសេចក្តីថា **ពួកយើងមិនមានទីបំផុតទេ ពួក**

យើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាកដដល់យើងឡើយ នៃអ្នកដ៏ចម្រើន ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។

ពាក្យថា សោ មានសេចក្តីថា ប្រសិនបើខ្ញុំបានដោះរួចចាកនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើតែកុសលឲ្យច្រើន តាំងតែអំពីកាលដឹងក្តីទៅ ។

លុះព្រះសក្យមុនី ត្រាស់ព្រះគាថានេះដោយលំដាប់ ប្រកាសសេចក្តីទាំងនោះ ឲ្យគ្រប់បរិបូណ៌ហើយ ទើបត្រាស់តទៅទៀតថា បពិត្រមហារាជ ជនទាំង ៤ នោះ ប្រាថ្នានឹងពោលមួយគាថាៗ ម្នាក់ ( ម្នាក់ៗ ប្រាថ្នាពោលគាថា ១ ) តែមិនអាចនឹងពោលបាន ម្នាក់ពោលបានត្រឹមតែមួយព្យញ្ជនៈប៉ុណ្ណោះ ហើយក៏លិចចុះទៅក្នុងខ្ទះទឹកទង់ដែងវិញទៅ ។ បានឮមកថា ចាប់ផ្តើមអំពីកាលដែលព្រះបាទបសេនទិ-កោសល ទ្រង់ព្រះសណ្តាប់សំឡេងនោះហើយ ជនទាំងនោះលិចចុះទៅខាងក្រោមដូចដើម រហូតដល់សព្វថ្ងៃនេះ ( ក៏នៅមិនទាន់ដល់ ៣ ម៉ឺនឆ្នាំ ) ព្រះបាទបសេនទិកោសលទ្រង់តក់ស្លុត ឬមានសេចក្តីសង្វេគ

ព្រះទ័យ ព្រោះទ្រង់បានស្តាប់ព្រះធម៌ទេសនានោះ ទើបទ្រង់ត្រិះរិះថា បរទារកម្ម គឺអំពើដែលបុរសប្រព្រឹត្តខុស ចំពោះកិរិយារបស់អ្នកដទៃ គឺលួចប្រពន្ធគេ ។ ឮថា ជនទាំង ៤ នាក់នោះ ឆេះនៅក្នុងអវិចីនរក អស់មួយពុទ្ធន្តរហើយ ស្លាប់ពីអវិចីនរកហើយ ទៅកើតនៅក្នុងលោហ-គុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ និងត្រូវឆេះ ៦ ម៉ឺនឆ្នាំទៀត ។ កាលដែលនឹងផុតចាកទុក្ខរបស់ជនទាំងនោះ ក៏នៅមិនទាន់ប្រាកដទេ សូម្បីយើងស្រឡាញ់កិរិយារបស់អ្នកដទៃ ក៏មិនបានដេកលក់ពេញមួយយប់ ចាប់ផ្តើមអំពីនេះទៅ យើងនឹងមិនត្រូវចង់ចិត្តស្រឡាញ់ចំពោះកិរិយារបស់អ្នកដទៃទៀតឡើយ ទើបក្រាបទូលព្រះសយម្ភូថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទើបតែជ្រាបក្នុងថ្ងៃនេះឯងថា រាត្រីវែង ចំពោះអ្នកដេកមិនលក់ ព្រះអង្គ ។ ព្រះសម្ពុទ្ធ ទ្រង់ប្រៀបធៀបពាក្យរបស់អ្នកទាំងពីរនោះហើយ ទ្រង់ត្រាស់ថា

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ ) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹង

ច្បាស់នូវព្រះសទ្ធម្ម ។

ក្នុងពេលដែលព្រះមុនី ទ្រង់ត្រាស់សម្ដែងព្រះធម៌ទេសនាចប់ហើយ បុគ្គលទាំងនោះ ក៏បានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើនទៀត ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទាំងនេះរាប់បានថា ព្រះធម៌ទេសនានោះកើតមានប្រយោជន៍ដល់មហាជនជាច្រើន ។ ព្រះបាទបសេនទិកោសល ទ្រង់ក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធហើយ ស្ដេចត្រឡប់ទៅដល់និវេសន៍ ហើយបញ្ជាឲ្យដោះលែងមនុស្ស និងសត្វទាំងឡាយនោះពីចំណងវិញទាំងអស់ ។ បណ្ដាមនុស្ស និងសត្វទាំងអស់នោះ បុរស និងស្ត្រីទាំងឡាយ ដែលរួចពីចំណង បាននាំគ្នាងូតទឹកជម្រះខ្លួនហើយ ក៏នាំគ្នាត្រឡប់ទៅកាន់ផ្ទះរៀងៗ ខ្លួន ម្នាក់ៗ បានពោលសរសើរគុណរបស់ព្រះនាងមល្លិកាទេវីថា យើងទាំងឡាយមានជីវិតរស់នេះ ក៏ព្រោះអាស្រ័យព្រះនាងមល្លិកាទេវី ហេតុដូច្នេះ សូមឲ្យព្រះនាងម្ចាស់របស់យើង ទ្រង់មានព្រះជន្មយឺនយូរអស់កាលជាអង្វែងទៅ ។ លុះដល់ពេលល្ងាច ភិក្ខុទាំងឡាយបានអង្គុយ

សន្ទនាគ្នា នៅក្នុងសាលាធម្មសភា បានពោលថា គួរឲ្យសរសើរព្រះនាងមល្លិកាទេវីណាស់ ថាជាបណ្ឌិតពិតមែន ព្រោះទ្រង់បានប្រើបញ្ញារបស់ព្រះនាង បានឲ្យជីវិតជាទានដល់មហាជនជាច្រើននោះ ។ គ្រានោះព្រះអង្គស្តេចយាងមកដល់ហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយអម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាពីរឿងអ្វី ? ភិក្ខុទាំងឡាយនោះក្រាបទូលនូវរឿងដែលខ្លួនសន្ទនាគ្នាឲ្យទ្រង់ជ្រាបហើយ ព្រះអង្គក៏បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកាទេវីបានឲ្យជីវិតជាទាន ដោយទ្រង់បានអាស្រ័យបញ្ញារបស់ព្រះនាង មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ព្រះនាងក៏ធ្លាប់បានឲ្យជីវិតជាទាន រួចមកហើយដូចគ្នាដែរ កាលនឹងទ្រង់ប្រកាសសេចក្តីនោះទើបទ្រង់នាំយកអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល មានព្រះរាជឱរសរបស់ព្រះបាទពារាណសីស្តេចយាងទៅកាន់កន្លែងដើមជ្រៃមួយដើម ទ្រង់បានបន់ស្រន់ទេវតាដែលអាស្រ័យនៅដើមជ្រៃនោះថា បពិត្រទេវរាជ ក្នុងជម្ពូទ្វីបនេះ

មានព្រះរាជា ១០១ ព្រះអង្គ មានព្រះអគ្គមហេសី ១០១ ព្រះអង្គដែរ ប្រសិនបើខ្ញុំព្រះអង្គនឹងបានជាព្រះរាជា សោយរាជសម្បត្តិនៅក្នុងពេលដែលព្រះរាជបិតា ទ្រង់សោយទិវង្គតហើយ ខ្ញុំព្រះអង្គនឹងធ្វើពលិកម្មដោយយកឈាមអំពីបំពង់-ករបស់ព្រះរាជា និងអគ្គមហេសីទាំងនោះមកធ្វើពលិកម្ម ។ អំណើះអំពីនោះមក កាលព្រះរាជបិតាសោយទិវង្គតទៅព្រះរាជកុមារនោះ ទ្រង់ក៏បានទទួលសោយរាជសម្បត្តិសមតាមប្រាថ្នាមែនទើបទ្រង់ត្រិះរិះថា យើងបានសោយរាជសម្បត្តិនេះ ដោយអានុភាពរបស់ទេវតានោះ ដូច្នេះ យើងនឹងធ្វើពលិកម្មដល់ទេវតានោះ កាលទ្រង់គិតឃើញដូច្នេះហើយ ទើបស្ដេចយាងចេញទៅដោយសេនាពួកធំធ្វើព្រះរាជាមួយព្រះអង្គឲ្យនៅក្នុងអំណាចរបស់ខ្លួនហើយ រួមជាមួយព្រះរាជាអង្គនោះ បានធ្វើព្រះរាជាអង្គដទៃៗ ឲ្យនៅក្នុងអំណាចរបស់ខ្លួនជាលំដាប់ទៅ រហូតដល់ធ្វើព្រះរាជាទាំងអស់ ( ១០១ ព្រះអង្គ ) ឲ្យនៅក្នុងអំណាចរបស់ខ្លួន ហើយទ្រង់នាំយកព្រះរាជាទាំងអស់នោះព្រមទាំងអគ្គមហេសីទាំងអស់ តែទ្រង់លើកលែងព្រះនាងធម្មទិន្នាទេវី

ទុកមួយព្រះអង្គ ព្រោះហេតុថា ព្រះនាងទ្រង់ព្រះគភ៌ ដោយទ្រង់ជាអគ្គមហេសីរបស់ព្រះរាជាព្រះនាមឧគ្គសេន ដែលទ្រង់ជាព្រះរាជាតូចជាងព្រះរាជាទាំងពួង ហើយស្តេចបញ្ជាឲ្យមនុស្សទាំងឡាយ សម្អាតបរិវេណកន្ទែងដើមជ្រៃនោះឲ្យស្អាត ដោយទ្រង់ត្រិះរិះឲ្យឥស្សរិយជនទាំងនោះផឹកថ្នាំពិសឲ្យស្លាប់ ។ ចំណែកឯទេវតាដែលអាស្រ័យនៅត្រង់ដើមជ្រៃនោះគិតថា ព្រះរាជាអង្គនេះ បានចាប់ព្រះរាជាមកច្រើនដល់ម៉្លេះ ព្រោះអាស្រ័យទ្រង់បំណងនឹងធ្វើពលិកម្មដល់យើង ដោយយកព្រះលោហិត ដែលហូរចេញអំពីបំពង់-ករបស់ព្រះរាជាទាំងនោះ ។ ប្រសិនបើព្រះរាជាព្រះអង្គនេះ ទ្រង់នឹងសម្លាប់ព្រះរាជាទាំងពួងចោលអស់ហើយ ព្រះរាជាក្នុងជម្ពូទ្វីបនឹងដាច់សូន្យ ទាំងគល់ដើមជ្រៃរបស់យើងក៏នឹងមិនស្អាត យើងគួរនឹងហាមព្រះរាជាអង្គនេះ បានយ៉ាងណាហ្ន៎ កាលបើទេវតានោះគិតពិចារណាមើលក៏បានដឹងថា យើងមិនអាចហាមបានទេ ទើបចូលទៅរកទេវតាអង្គដទៃទៀត បានប្រាប់រឿងនោះឲ្យជ្រាបហើយសួរថា លោកអាចជួយហាមព្រះរាជានោះបានឬទេ កាលបើទេវតា

នោះតបបដិសេធហើយ ក៏បានចូលទៅរកទេវតាអង្គដទៃៗ តទៅរហូតដល់ទេវតាក្នុងចក្រវាឡទាំងអស់ ក៏ត្រូវទេវតាទាំងនោះពោលបដិសេធដដែល រួចទើបចូលទៅគាល់មហារាជទាំង ៤ ក្នុងពេលស្ដេចមហារាជទាំង ៤ បដិសេធថា ពួកយើងមិនអាចជួយបានទេក្នុងរឿងនេះ មានតែសក្កទេវរាជរបស់ពួកយើង ដែលទ្រង់ជាអ្នកវិសេសជាងពួកយើងដោយបុណ្យ និងបញ្ញា លោកចូរទៅសួរព្រះអង្គចុះទេវតានោះ ទើបចូលទៅគាល់សក្កទេវរាជ បានក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ហើយក្រាបទូលថា សូមតេជះតម្កល់លើត្បូង កាលនេះ បើព្រះអង្គមិនអើពើវង្សត្រកូលនឹងសាបសូន្យ ហេតុដូច្នេះ សូមព្រះអង្គជាទីពឹងរបស់វង្សត្រកូលទាំងអស់នោះផងចុះ ព្រះអង្គ ។ សក្កទេវរាជតបថា សូម្បីយើងក៏មិនអាចហាមព្រះរាជានោះបានដែរ តែយើងអាចប្រាប់ឧបាយបាន ចូរលោកទៅកាលព្រះរាជាឃើញលោកៗ ចូរស្លៀកសំពត់ក្រហម សម្ដែងអាការដូចចេញពីដើមឈើរបស់ខ្លួន គ្រានោះ ព្រះរាជានឹងពោលអង្វរលោកដោយពាក្យផ្សេងៗ ដោយព្រះអង្គទ្រង់គិតថា ទេវតារបស់យើងនឹងទៅ

យើងនឹងឃាត់ព្រះអង្គ ។ កាលបើដូច្នេះ លោកទើបពោលនឹងព្រះរាជា នោះថា លោកបានបន់ស្រន់ចំពោះយើងថា នឹងនាំយកព្រះរាជា ១០១ ព្រះអង្គ ព្រមទាំងអគ្គមហេសីទាំងអស់ មកធ្វើពលិកម្មដោយព្រះលោហិត ដែលហូរចេញអំពីបំពង់-ករបស់ព្រះរាជា និងព្រះរាជិនីទាំងនោះ តែព្រះអង្គ ទ្រង់នាំយកមក ដោយវៀរលែងព្រះរាជទេវី របស់ព្រះរាជាឧគ្គសេន មួយព្រះអង្គ យើងនឹងមិនព្រមទទួលពលិកម្មរបស់ព្រះអង្គ ដោយ ទ្រង់ជាអ្នកពោលកុហក ។ លុះលោក (ទេវតា) ពោលយ៉ាងនេះ ហើយ ព្រះរាជានឹងទៅឲ្យនាំយកព្រះនាងធម្មទិន្នាទេវី ហើយព្រះនាង ធម្មទិន្នាទេវី នឹងបានសម្តែងធម៌ឲ្យដល់ព្រះរាជាបានស្តាប់ នាងក៏បាន ឲ្យជីវិតជាទានដល់ព្រះរាជា និងអគ្គមហេសីទាំងនោះផងដែរ ។

កាលបើសក្កទេវរាជ បានត្រាស់ប្រាប់ឧបាយដល់ទេវតាដូចនេះ តាមដែលពោលរួចមកហើយ ទេវតានោះក៏បានធ្វើតាមឧបាយយ៉ាងហ្នឹង សូម្បីព្រះរាជាក៏ត្រាស់ឲ្យនាំព្រះនាងធម្មទិន្នាទេវីនោះមក ។ លុះព្រះនាង ធម្មទិន្នាទេវីយាងមកដល់ហើយ បានថ្វាយបង្គំចំពោះព្រះរាជាឧគ្គសេន

ដែលជាព្រះរាជស្វាមីរបស់ព្រះនាងប៉ុណ្ណោះ ទើបទៅគង់ប្រថាប់នៅទីបំផុតនៃព្រះរាជាទាំងនោះ ។ ព្រះរាជាពារាណសី ទ្រង់ពិរោធចំពោះព្រះនាងធម្មទិន្នាទេវីថា យើងស្ថិតនៅក្នុងតំណែង ជាធំជាងព្រះរាជាទាំងពួងនៅក្នុងទីនេះ ព្រះនាងបានទៅថ្វាយបង្គំចំពោះតែព្រះរាជស្វាមីរបស់ព្រះនាង ដែលទ្រង់ជាព្រះរាជាតូចជាងព្រះរាជាទាំងពួង ។ គ្រានោះព្រះនាងធម្មទិន្នាទេវីទើបក្រាបទូលថា រឿងអ្វីទៅដែលខ្ញុំម្ចាស់ត្រូវទៅថ្វាយបង្គំព្រះអង្គ ព្រោះព្រះរាជាអង្គនេះ ជាព្រះរាជស្វាមីរបស់ខ្ញុំព្រះអង្គទ្រង់ជាអ្នកឲ្យភាពជាធំដល់ខ្ញុំម្ចាស់ៗ មិនបានថ្វាយបង្គំព្រះរាជស្វាមីនេះហើយ ទៅថ្វាយបង្គំព្រះអង្គ បានប្រយោជន៍អ្វី ។ រុក្ខទេវតាពោលឡើងថា ពិតយ៉ាងនោះ ព្រះទេវីដ៏ចម្រើន ហើយបូជាព្រះនាងធម្មទិន្នាទេវីដោយផ្កាឈើមួយក្តាប់ នៅចំពោះមុខមហាជន ។ ព្រះរាជាពារាណសីត្រាស់ទៀតថា បើព្រះនាងមិនថ្វាយបង្គំយើង ព្រោះហេតុអ្វីទើបព្រះនាងមិនថ្វាយបង្គំទេវតារបស់យើង ដែលជាអ្នកមានអានុភាពច្រើនយ៉ាងនេះថែមទាំងជាអ្នកឲ្យរាជសម្បត្តិដល់យើងទៀតផង ។ ពេលនោះ ព្រះនាង

ធម្មទិន្នាទេវី ទ្រង់ក្រាបទូលតបថា បពិត្រមហារាជ ព្រះអង្គទ្រង់តាំង នៅក្នុងបុណ្យរបស់ព្រះអង្គ ទើបទ្រង់ចាប់ព្រះរាជាទាំងឡាយមកបាន មិនមែនទេវតាចាប់មកថ្វាយព្រះអង្គទេ ។ រុក្ខទេវតាពោលទៀតថា មែនយ៉ាងនោះ ព្រះទេវីដ៏ចម្រើន ហើយបូជាព្រះនាងធម្មទិន្នាទេវី ដោយផ្កាមួយក្តាប់ទៀត នៅចំពោះមុខមហាជន ។ ព្រះនាងធម្មទិន្នាទេវី ក្រាបទូលចំពោះព្រះរាជាទៀតថា ព្រះអង្គបានត្រាស់ថា ទេវតារបស់ យើងបានចាប់ព្រះរាជាជាច្រើនមកឲ្យដល់យើង ក៏កាលអម្បាញ់មិញនេះ ដើមឈើត្រូវភ្លើងឆេះនៅត្រង់ខាងឆ្វេង នៅខាងលើនៃទេវតារបស់ព្រះអង្គ ប្រសិនបើទេវតារបស់ព្រះអង្គមានអានុភាពច្រើនពិតមែន ព្រោះហេតុអ្វី ទេវតារបស់ព្រះអង្គទើបមិនអាចរំលត់ភ្លើងនោះបានព្រះអង្គ ។ រុក្ខទេវតា ពោលសរសើរព្រះទេវីទៀតថា មែនយ៉ាងនោះ ព្រះទេវីដ៏ចម្រើន ហើយបានបូជាដោយផ្កាដូចមុនទៀត ។ ព្រះនាងធម្មទិន្នាទេវីប្រថាប់ឈរ ត្រាស់យ៉ាងនោះ ទាំងទ្រង់ព្រះកន្សែង និងទ្រង់សើច ។ ព្រះរាជាទើប ត្រាស់នឹងព្រះនាងធម្មទិន្នាទេវីថា ព្រះនាងឆ្កួតឬ ? ព្រះនាងធម្មទិន្នា

ទ្រង់ក្រាបទូលថា សូមតេជះតម្កល់លើត្បូង ព្រោះហេតុអ្វី ព្រះអង្គទើបត្រាស់យ៉ាងនេះ ស្ត្រីដូចខ្ញុំម្ចាស់ មិនមែនធ្លូតទេ ព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា បើដូច្នោះ ម្តេចព្រះនាងយំ ហើយសើចធ្វើអ្វី ? ព្រះនាងធម្មទិន្នាក្រាបទូលថា សូមមហារាជទ្រង់សណ្តាប់ចុះ ក៏ក្នុងអតីតកាលខ្ញុំម្ចាស់ជាធីតានៃត្រកូលមួយ កាលរស់នៅក្នុងត្រកូលរបស់ស្វាមីបានឃើញភ្ញៀវអ្នកជាសម្លាញ់របស់ស្វាមីមក ត្រូវការរកភោជនីយាហារដើម្បីទទួលភ្ញៀវ ទើបឲ្យប្រាក់ដល់នាងទាសី បានប្រាប់ឲ្យទៅទិញសាច់មក ចំណែកនាងទាសីទៅរកទិញសាច់មិនបាន ហើយត្រឡប់មកប្រាប់ថា មិនមានសាច់ទេ ក៏បានកាត់-កមេពពែមួយ ដែលដេកនៅខាងក្រោយផ្ទះមកធ្វើម្ហូប ខ្ញុំម្ចាស់កាត់-កពពែតែមួយក្បាល ត្រូវទៅឆេះនៅក្នុងនរក និងដោយផលកម្មដែលនៅសល់ ត្រូវកាត់-កស្មើគ្នានឹងចំនួនរោមរបស់មេពពែនោះ ។ ព្រះអង្គសម្រេចទោស ( សម្លាប់ ) មនុស្ស មានប្រមាណច្រើនយ៉ាងនេះ ពេលណាទើបនឹងរួចផុតចាកទុក្ខ ខ្ញុំម្ចាស់រឭកដល់ទោសដ៏ធំរបស់ព្រះអង្គយ៉ាងនេះ ទើបបានជាយំ ព្រះនាងបានក្រាបទូលដូច្នេះ

ហើយ ទើបត្រាស់ព្រះគាថាថា

ខ្ញុំកាត់-កមេពពែតែមួយ ត្រូវទៅឆេះនៅក្នុងនរក ត្រូវគេកាត់-ករាប់តាមរោមពពែ បពិត្រខត្តិយរាជ ព្រះអង្គកាត់-ករបស់មនុស្សជាច្រើននឹងទៅជាយ៉ាងណាទៅវិញ ។

ព្រះរាជាត្រាស់សួរនូវហេតុដែលព្រះនាងសើចថា នាងសើចព្រោះហេតុអ្វីដែរ ? ព្រះនាងធម្មទិន្នាទេវីក្រាបទូលថា បពិត្រមហារាជខ្ញុំម្ចាស់សើចព្រោះសប្បាយចិត្តថា ខ្ញុំម្ចាស់ផុតចាកទុក្ខនោះហើយព្រះពរម្ចាស់ ។ ចំណែករុក្ខទេវតា ក៏បានពោលសម្តែងនូវការសរសើរចំពោះព្រះនាងទេវីទៀតថា យ៉ាងនោះព្រះនាងដ៏ចម្រើន ហើយបូជាផ្កាមួយក្តាប់ទៀត ។ ព្រះរាជាទ្រង់ត្រិះរិះថា ឱហ្ន៎ គួរឲ្យតក់ស្លុតចំពោះកម្មរបស់យើងណាស់ បានឮថា ព្រះនាងទេវីនេះ បានសម្លាប់មេពពែតែមួយត្រូវទៅឆេះនៅក្នុងនរក និងដោយផលរបស់បាបកម្មដែលនៅសល់ត្រូវគេកាត់-កស្មើគ្នានឹងចំនួនរោមរបស់មេពពែនោះ យើងបានសម្លាប់មនុស្សមានចំនួនច្រើនដល់ម្ល៉េះ ពេលណាទៅនឹងដល់នូវភាពសួស្តី

( ការផុតទុក្ខ ) ។ ទើបត្រាស់ឲ្យដោះលែងព្រះរាជាទាំងអស់ ទ្រង់បាន ថ្វាយបង្គំព្រះរាជា ដែលទ្រង់ចាស់ជាងព្រះអង្គ ទ្រង់លើកព្រះហស្ត ប្រណម្យចំពោះរាជា ដែលទ្រង់នៅក្មេងជាងព្រះអង្គ ថែមទាំងព្រះអង្គ ក៏សូមខមាទោសចំពោះព្រះរាជាទាំងអស់ ហើយទ្រង់បញ្ជូនទៅកាន់ ប្រទេសរៀងៗ ព្រះអង្គ ដូចដើមវិញ ។ លុះព្រះលោកនាយក ទ្រង់នាំ អតីតនិទាននេះមកសម្ដែងចប់ហើយ ទ្រង់បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកាទេវី ទ្រង់អាស្រ័យបញ្ញារបស់ព្រះ នាងហើយ បានប្រទានជីវិតឲ្យជាទានដល់មហាជន មិនមែនតែក្នុងពេល ឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ព្រះនាងក៏ធ្លាប់បានប្រទាន ជីវិតឲ្យជាទានដូចគ្នាមកហើយៗ ព្រះមានជោគ ទ្រង់ប្រជុំនិទានជាតក លើករឿងអតីតជាតិមកថា ព្រះបាទពារាណសីក្នុងកាលនោះ បានមក ជាព្រះបាទបសេនទិកោសល ព្រះនាងធម្មទិន្នាទេវីក្នុងកាលនោះ បានមក ជាព្រះនាងមល្លិកាទេវី រីឯរុក្ខទេវតាក្នុងកាលនោះ បានមកជាតថាគត ក្នុងកាលឥឡូវនេះឯង ។ លុះព្រះពុទ្ធអង្គទ្រង់លើករឿងក្នុងអតីតជាតិ

យ៉ាងនេះមកហើយ កាលនឹងទ្រង់សម្តែងព្រះធម៌ជាបន្តទៀត ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បាណាតិបាត ( ការញុំាងជីវិតឲ្យធ្លាក់ចុះគន្លងទៅ គឺការផ្តាច់ជីវិតសត្វ ) ជាទោសដែលបុគ្គលមិនសមគួរនឹងធ្វើ ព្រោះថា បុគ្គលអ្នកផ្តាច់ជីវិតជាប្រក្រតី រមែងសោយសោកអស់កាលដ៏យូរ ទើបត្រាស់ព្រះគាថានេះថា

**បុគ្គលគប្បីដឹងយ៉ាងនេះថា ការកើតឡើងជាទុក្ខ អ្នកមានជីវិតមិនគួរសម្លាប់អ្នកមានជីវិត ព្រោះអ្នកសម្លាប់អ្នកមានជីវិតជា ប្រក្រតីរមែងសោយសោក ។**

ព្រះនាងមល្លិកាទេវី ទ្រង់ជាអ្នកមានបញ្ញាស្រួចស្រាល់ ទ្រង់ជាអ្នកមានសមត្ថភាពក្នុងការចាត់ចែងការថ្វាយ **អសទិសទាន** សំដៅដល់ទានដែលឥតមានទានដទៃណាមួយប្រដូចបាន ជាការថ្វាយទានដ៏ធំបំផុតនៅក្នុងព្រះពុទ្ធសាសនាមួយព្រះអង្គៗ មានតែម្តងប៉ុណ្ណោះ ឥតមានពីរដងឡើយ តាមដែលមានរឿងសម្តែងទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃលោកវគ្គ ក្នុងរឿងអសទិសទាន និងក្នុង **អដ្ឋកថាសុមង្គលវិលាសិនី**

ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី **មហាគោវិន្ទសូត្រ** នៅក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ស្តេចចារិកទៅកាន់ទឹកដែនផ្សេងៗ ហើយមានភិក្ខុសង្ឃប្រមាណ ៥០០ រូបជាបរិវារ ស្តេចចូលទៅកាន់វត្តជេតពន ។ គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចយាងទៅកាន់វិហារ ទ្រង់ក្រាបទូលនិមន្តព្រះសម្ពុទ្ធ លុះដល់ពេលព្រឹកឡើង ទ្រង់ចាត់ចែងត្រៀមអាគន្តុកទានហើយ ទ្រង់បានប្រកាសឲ្យមនុស្សក្នុងនគរមកមើលថា សូមអ្នកទាំងឡាយចូរមកមើលទានរបស់យើង ។ អ្នកនគរទាំងអស់នាំគ្នាមកមើលទាន របស់ព្រះបាទបសេនទិកោសល ហើយ លុះដល់ពេលព្រឹកឡើង ក្រាបទូលនិមន្តព្រះភគវា ចាត់ចែងទានហើយ ប្រុងប្រៀបមហាទានហើយ បានបញ្ជូនដំណឹងទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់ស្តេចយាងមកទតមើលទានរបស់ខ្ញុំព្រះករុណាទាំងឡាយចុះ ។ ព្រះបាទបសេនទិកោសល ស្តេចយាងទៅទតមើលទានរបស់អ្នកនគរហើយ ទ្រង់ត្រិះរិះថា ទានដ៏ក្រៃលែង

ជាងទានរបស់យើង ដែលអ្នកនគរទាំងនោះធ្វើហើយ យើងនឹងធ្វើទានទៀត ទើបត្រាស់ឲ្យចាត់ចែងទានម្តងទៀត ។ ថ្ងៃស្អែកឡើង អ្នកនគរបានឃើញទានរបស់ព្រះរាជាហើយ និងថ្ងៃតទៅ អ្នកនគរទើបចាត់ចែងធ្វើទាន ឲ្យក្រៃលែងជាងទានរបស់ព្រះរាជាវិញ ។ សរុបសេចក្តីមកថា ព្រះបាទបសេនទិកោសល ទ្រង់មិនអាចធ្វើឲ្យអ្នកនគរចាញ់បាន ទាំងអ្នកនគរក៏មិនអាចធ្វើឲ្យព្រះរាជាចាញ់បាន ដូចគ្នាដោយវិធីយ៉ាងនេះ ។ តមក ក្នុងវារៈទី ៦ អ្នកនគរបានចាត់ចែងការបន្ថែមទានឡើងជារយជងជាពាន់ជង ត្រៀមមហាទានគ្រប់ប្រការ ដែលនរណាៗ មិនអាចនឹងនិយាយបានថា វត្ថុទានឈ្មោះនេះ មិនមានក្នុងទានរបស់អ្នកនគរទាំងនោះ ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញទាននោះហើយ ទ្រង់ត្រិះរិះថា ប្រសិនបើយើងមិនអាចដើម្បីធ្វើទានឲ្យក្រៃលែងជាងអ្នកនគរទាំងនោះបាន យើងត្រូវការអ្វីជាមួយនឹងជីវិត ហើយទ្រង់ផ្ទំត្រិះរិះរកឧបាយ ។ គ្រានោះ ព្រះនាងមល្លិកាទេវី ស្តេចយាងចូលទៅគាល់ក្រាបទូលសួរថា បពិត្រមហារាជ ព្រោះហេតុអ្វី បានជាព្រះអង្គ ទ្រង់ផ្ទំ

យ៉ាងនេះ ព្រោះហេតុអ្វី ឥន្ទ្រិយរបស់ព្រះអង្គ មើលទៅហាក់បីដូចជាហត់នឿយសម្បើមហើយ ព្រះអង្គ ? ពេលនោះ ព្រះបាទបសេនទិ-កោសលត្រាស់ថា ព្រះទេវី ព្រះនាងនៅមិនទាន់ជ្រាបឬ ? ព្រះនាងមល្លិកាទេវីក្រាបទូលតបថា ខ្ញុំម្ចាស់នៅមិនទាន់ជ្រាបទេ ព្រះអង្គ ព្រះរាជាទើបទ្រង់ត្រាស់រឿងនោះដោយសព្វគ្រប់ ឲ្យព្រះទេវីទ្រង់បានជ្រាប ។ លុះព្រះនាងមល្លិកាទេវីទ្រង់ជ្រាបហើយ ក៏ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំគិតអ្វីឡើយ ព្រោះព្រះអង្គជាព្រះរាជាធំលើផែនដី ទ្រង់ត្រូវតែធ្វើឲ្យអ្នកនគរបាញ់ ព្រះអង្គទ្រង់ធ្លាប់ទតឃើញ ឬធ្លាប់បានស្តាប់ហើយនៅទីណា ខ្ញុំម្ចាស់នឹងចាត់ចែងទេយ្យធម៌ជំនួសព្រះអង្គ ។ ព្រះនាងមល្លិកាទេវីក្រាបបង្គំទូលព្រះបាទបសេនទិ-កោសលយ៉ាងនេះ ព្រោះព្រះនាងទ្រង់បំណងនឹងចាត់ចែងអសទិសទានហើយព្រះនាងទ្រង់ក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គត្រាស់ឲ្យជាងធ្វើបារាំសម្រាប់អង្គុយជារង្វង់មូល ដោយប្រើបន្ទះក្តារឈើសាលៈ (រាំងភ្នំ) ដើម្បីភិក្ខុសង្ឃ ៥០០ រូប ចំណែកឯភិក្ខុទាំងឡាយដ៏សេស

នឹងអង្គុយនៅខាងក្រៅបាពាំរវង្វង់មូល សូមត្រាស់ឲ្យជាងធ្វើឡង់ ៥០០ ដំរី ៥០០ ឲ្យកាន់ឡង់ទាំងនោះ ឈរកាន់ឡង់នៅពីក្រោយភិក្ខុសង្ឃ ៥០០ រូប ឲ្យជាងធ្វើទូកដោយ មាសសុទ្ធ ៨ ឬ ១០ ទូក ។ ទូកមាសទាំងនោះ នឹងតម្កល់ទុកក្នុងទីបារាំ ខត្តិយកញ្ញាមួយអង្គៗ អង្គុយបុករបស់ក្រអូបក្នុងចន្លោះភិក្ខុ ២ រូបៗ ខត្តិយកញ្ញាមួយអង្គៗ ឈរកាន់ផ្លិតបក់ថ្វាយភិក្ខុ ២ រូបៗ ចំណែកឯខត្តិយកញ្ញាមួយអង្គៗ ដ៏សេស ក៏យករបស់ក្រអូបដែលបុកហើយ មកដាក់ក្នុងទូកមាសទាំងឡាយ បណ្ដាខត្តិយកញ្ញាទាំងនោះ ខត្តិយកញ្ញាពួកខ្លះ បានកាន់បាច់ផ្កាឈូកខៀវនិងរបស់ក្រអូប ទៅដាក់ក្នុងទូកមាស ដើម្បីឲ្យភិក្ខុសង្ឃទទួលយកក្លិនអប់ ព្រោះអ្នកព្រះនគរមិនមានខត្តិយកញ្ញា មិនមានឡង់ មិនមានដំរីអ្នកព្រះនគរត្រូវចាញ់ ដោយហេតុទាំងនេះឯង បពិត្រមហារាជ សូមព្រះអង្គត្រាស់ឲ្យធ្វើយ៉ាងនេះចុះ ។

គ្រានោះ ព្រះបាទបសេនទិកោសលត្រាស់ថា ល្អហើយព្រះទេវីនាងបានប្រាប់ឧបាយយ៉ាងល្អឲ្យដល់យើង ហើយព្រះរាជាទើបទ្រង់ត្រាស់

ឲ្យធ្វើកិច្ចទាំងអស់តាមដែលព្រះនាងមល្លិកាទេវី ទ្រង់ក្រាបទូលហើយទាំងប៉ុន្មាន ។ ក្នុងការចាត់ចែងកិច្ចការងារនោះ ខ្វះដំរីមួយសម្រាប់កាន់ឆ្ញង់បាំងឲ្យភិក្ខុមួយរូប ព្រះបាទបសេនទិកោសលទើបត្រាស់នឹងព្រះនាងមល្លិកាទេវីថា ព្រះទេវីខ្វះដំរីមួយ តើយើងគិតធ្វើយ៉ាងណា ។ ព្រះនាងមល្លិកាទេវីត្រាស់សួរថា ដំរីមិនមានឬ ព្រះអង្គ ? ព្រះបាទបសេនទិកោសលត្រាស់តបថា ដំរីមាន ព្រះទេវី តែដំរីដ៏សេសក្រៅអំពីនោះ ជាដំរីកាចសាហាវ លុះឃើញភិក្ខុសង្ឃទាំងឡាយហើយ តែងតែសម្តែងអាការឃោរឃៅ ដូចខ្យល់កំបុតត្បូង ។ ពេលនោះព្រះនាងមល្លិកាទ្រង់ក្រាបទូលថា បពិត្រសម្មតិទេព ខ្ញុំម្ចាស់ជ្រាបដល់កន្លែងដែលដាក់ដំរីកាចសាហាវនោះហើយ ព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា យើងនឹងឲ្យដំរីនោះទៅឈរនៅទីកន្លែងណា ? ព្រះនាងមល្លិកាក្រាបទូលថា នឹងឲ្យដំរីនោះទៅឈរនៅជិតព្រះអង្គុលិមាល៍ព្រះអង្គ ។ ព្រះរាជាត្រាស់ឲ្យរាជបុរស ធ្វើតាមព្រះរាជសវនីយ៍របស់ព្រះនាងដែលបានប្រាប់ ។ ដំរីនោះ កាលទៅឈរជិតព្រះអង្គុលិមាល៍

ក៏មានការភិតភ័យ ទាំងញាត់កន្ទុយទៅក្នុងចន្លោះជើង បានសម្របស្ទឹក ត្រចៀកទាំងពីរ និងឈរបិទភ្នែក ។ គ្រានោះ មហាជនបាននាំគ្នាមើលដំរី ដែលយកប្រមោយកាន់ឡង់ បាំងថ្វាយដល់ព្រះអង្គុលិមាលប៉ុណ្ណោះ ដោយគិតថា នេះជាអាការដំរីកាចឃោរឃៅ ព្រះអង្គុលិមាលអាចធ្វើ ឲ្យដំរីអស់កាពកាចឃោរឃៅបាន ។ ព្រះបាទបសេនទិកោសល ទ្រង់ អង្គាសចង្ហាន់ថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយចង្ហាន់ យ៉ាងប្រណីតហើយ ទ្រង់ថ្វាយបង្គំព្រះមានជោគក្រាបទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន វត្ថុណាជាកប្បិយ: ឬជាអកប្បិយ:នៅក្នុងរោងទាននេះ វត្ថុទាំងអស់នោះ ខ្ញុំព្រះអង្គសូមថ្វាយព្រះសុគតទាំងអស់ ។ នៅក្នុង រោងទាននោះ មានទ្រព្យ ១៤ កោដិ ព្រះរាជាទ្រង់បានបរិច្ចាគត្រឹមតែ មួយថ្ងៃប៉ុណ្ណោះ ។ ចំណែកវត្ថុ ៤ យ៉ាងគឺ ១- ឡង់ ២- បល្ល័ង្កទីប្រថាប់ ៣- ជើងបាត្រ ៤-តាំងទ្រព្រះបាទសម្រាប់ព្រះសម្មាសម្ពុទ្ធ ជារបស់ ប្រមាណតម្លៃមិនបាន និងមាននរណាមួយអាចនឹងថ្វាយទាន ដែលមាន តម្លៃយ៉ាងនេះចំពោះព្រះពុទ្ធទាំងឡាយ ធ្វើឲ្យបានដូចនេះទៀតឡើយ

ព្រោះហេតុដូច្នោះ ទាននេះទើបឈ្មោះថា **អសទិសទាន** ។ បានឮថា អសទិសទាននោះ មានចំពោះព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ត្រឹមតែម្តងគត់ប៉ុណ្ណោះ ។ ស្ត្រីតែប៉ុណ្ណោះចាត់ចែងទានដើម្បីព្រះពុទ្ធ និងភិក្ខុសង្ឃទាំងពួង ។

ស្វាមី និងភរិយារស់នៅជិតគ្នាប្រៀបដូចអណ្តាត និងធ្មេញ រមែងមានការប៉ះទង្គិចគ្នាខ្លះ មិនច្រើនក៏តិចដែរ ដូចគ្នានឹងព្រះនាងមល្លិកា និងព្រះបាទបសេនទិកោសល ក៏កើតការទាស់ព្រះទ័យគ្នាដែរ តាមដែលមានពោលទុកនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **សុជាតាជាតក** និងនៅក្នុង **ភល្លាតិកជាតក** ក្នុង **គម្ពីរខុទ្ទកនិកាយជាតក** ដូចមានសេចក្តីថា ៖

គ្រានោះ ព្រះមានជោគ ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់បានប្រោសប្រទានព្រះធម៌ទេសនា ដោយទ្រង់ប្រារព្ធចំពោះព្រះនាងមល្លិកាឲ្យជាដើមហេតុថា ថ្ងៃមួយ ព្រះនាងមល្លិកាទ្រង់កើតការទាស់ព្រះទ័យជាមួយនឹងព្រះបាទបសេនទិកោសល ដោយរឿងសិរី ។ ព្រះបាទ

បសេនទិកោសលទ្រង់ពិរោធ ថែមទាំងទ្រង់មិនទតមើលព្រះនាងមល្លិកា ទៀត ។ ព្រះនាងមល្លិកាទ្រង់ត្រិះរិះថា ការដែលព្រះរាជាទ្រង់ពិរោធ នឹងយើង ជួនកាលព្រះលោកនាថទ្រង់មិនជ្រាបឡើយ ។ ក្នុងខណៈ ដែលព្រះនាងមល្លិកាទ្រង់ត្រិះរិះនោះ ព្រះមហាវីរៈក៏ទ្រង់ជ្រាបដោយ ព្រះសព្វញ្ញុតញ្ញាណ ។ លុះដល់ព្រឹកឡើង ស្ដេចយាងចូលទៅបិណ្ឌបាត នៅក្នុងក្រុងសាវត្ថី ព្រមដោយភិក្ខុសង្ឃជាបរិវារ ស្ដេចបានយាងទៅ ដោយលំដាប់ រហូតទៅដល់ព្រះរាជវាំង ។ ព្រះបាទបសេនទិកោសល ទ្រង់យាងមកទទួល ដោយទ្រង់ទទួលយកបាត្រ ហើយទ្រង់ក្រាបទូល អារាធនាព្រះមហាមុនីឡើងទៅទទួលភត្ត នៅលើប្រាសាទជាន់ខាងលើ ព្រមដោយភិក្ខុសង្ឃ ។ កាលព្រះមហាវីរៈសោយភត្តាហាររួចហើយ ទើបត្រាស់សួរដល់ព្រះនាងមល្លិកាថា បពិត្រមហារាជ ព្រោះហេតុអ្វី បានជាមិនឃើញព្រះនាងមល្លិកាទេវី តើព្រះនាងបាត់ទៅណា ? ព្រះបាទ បសេនទិកោសលទ្រង់ក្រាបទូលថា ព្រះនាងរវល់សប្បាយរីករាយ ដោយយសសក្ដិរបស់ខ្លួន ទើបព្រះទេវីមិនចេញមកក្រាបថ្វាយបង្គំ

ដូចដែលធ្លាប់ធ្វើមកហើយ ។ ព្រះមានបុណ្យ ទើបត្រាស់ថា បពិត្រមហារាជ ហេតុអ្វីមហាបពិត្រ ទើបទ្រង់ទាស់ព្រះទ័យ រហូតដល់មិនអនុគ្រោះឲ្យព្រះនាងយាងមកជួបព្រះភក្ត្រ ដូចធ្លាប់ធ្វើមកដូចនេះ កាលជាតិមុន មហាបពិត្របានបែកពីព្រះនាង សូម្បីត្រឹមតែមួយរាត្រី ក៏ទ្រង់តូចព្រះទ័យ ទ្រង់យំដល់ទៅ ៦៩៧ ឆ្នាំមែនឬ ? ព្រះបាទបសេនទិកោសលទើបទ្រង់ក្រាបទូលអារាធនា ឲ្យព្រះលោកនាយកត្រាស់សម្តែងរឿងទាំងអស់នោះ ។

គ្រានោះ ព្រះជិនស្រី ទើបទ្រង់ប្រោសប្រទានត្រាស់សម្តែងរឿងក្នុងអតីតជាតិមកថា នៅក្នុងកាលនោះ មានព្រះរាជាព្រះនាមកល្លាតិយៈ បានលះបង់នូវដែន ហើយត្រាច់ចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាងទៅដល់ភ្នំដ៏ប្រសើរឈ្មោះគន្ធមាទន៍ មានផ្ការីកស្គុសស្គាយដ៏ដេរដាសដោយពួកកិន្នរ ។ ព្រះអង្គប្រាថ្នាដើម្បីនឹងពោលពាក្យជាមួយពួកកិន្នរ ទើបហាមឃាត់ហ្វូងឆ្កែ ហើយដាក់ចុះនូវធ្នូ និងបំពង់ព្រួញរួចចូលទៅត្រង់កន្លែងដែលពួកកិន្នរស្ថិតនៅ ។ ព្រះរាជាសួរថា កាល

កន្ទង់ហោមន្តរជូវទៅហើយ ម្ដេចឡើយអ្នកទាំងឡាយ ស្ថិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្របន្ទោរស្មឹងហោមវតី យើងសូមសួរពួកអ្នកដែល មានរាងកាយ និងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបាន ក្នុងមនុស្សលោក ដោយប្រការដូចម្ដេច ? កិន្នរីឆ្លើយថា នែព្រាហ្មណ៍ ពួកយើងតែងត្រាច់ទៅកាន់ភ្នំឈ្មោះ **មាលាគិរិ** ភ្នំឈ្មោះ **បណ្ឌរកៈ** ភ្នំត្រៃកូដ និងស្ទឹងមានទឹកត្រជាក់ ពួកយើងជាម្រឹគ មានភេទប្រាកដ ដូចពួកមនុស្ស គេស្គាល់ពួកយើងថា ជាកិន្នរ ។ ព្រះរាជាសួរថា អ្នកទាំងពីរមានសភាពដូចជាទុក្ខក្រៃលែងទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរឹតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយ និងសម្បុរដូចមនុស្ស អ្នកទាំងឡាយអាក់អន់ចិត្ត ដូចម្ដេច ទើបទួញយំក្នុងព្រៃនេះ អ្នកទាំងពីរ មានសភាពដូចជាទុក្ខ ក្រៃលែងទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ ឱបរឹតហើយ យើងសូមសួរនូវពួកអ្នកដែលមានរាងកាយ និងសម្បុរ ដូចមនុស្ស អ្នកអាក់អន់ចិត្តដូចម្ដេច ទើបសោកស្ដាយក្នុងព្រៃនេះ ?

កិន្នរីឆ្លើយថា នែព្រាហ្មណ៍ យើងទាំងឡាយជាអ្នកព្រាត់ប្រាសគ្នាអស់មួយរាត្រីរឭកគ្នាទៅវិញទៅមក មិនដាច់អាល័យក្តៅក្រហាយនឹងរាត្រីមួយនោះ ទើបយំសោក រាត្រីនោះនឹងមិនមានទៀត ។

ព្រះរាជាត្រាស់សួរថា អ្នកទាំងឡាយក្តៅក្រហាយនឹងរាត្រីណាមួយ ដូចបុគ្គលក្តៅក្រហាយនឹងទ្រព្យដែលបាត់ មាតាបិតាដែលទៅកាន់បរលោក យើងសូមសួរនូវពួកអ្នកដែលមានរាងកាយ និងសម្បុរដូចមនុស្ស ចំពោះរាត្រីនោះ តើអ្នកទាំងឡាយសម្រេចនូវទីនៅផ្សេងគ្នាដូចម្តេច ? កិន្នរីឆ្លើយថា អ្នកឃើញនូវស្ទឹងណាដែលមានខ្សែទឹកដ៏រហ័ស ជាស្ទឹងដែលបិទបាំងដោយដើមឈើផ្សេងៗ មានមាត់ច្រាំងដ៏ល្អ កិន្នរ ( ជាប្តី ) ជាទីស្រឡាញ់របស់ខ្ញុំ បានហែលឆ្លងស្ទឹងនោះ ក្នុងកាលរដូវភ្លៀង ដោយគិតថា កិន្នរីមកតាមក្រោយអាត្មាអញដែរ ។ ចំណែកខាងខ្ញុំកំពុងតែបេះផ្កាព្រូស ផ្កាទន្លា ផ្កាម្ទេះរួត និងផ្កាយុថ្កា ដោយបំណងថា កិន្នរជាប្តីជាទីស្រឡាញ់របស់អាត្មាអញនឹងប្រដាប់កម្រងផ្កាទាំងអាត្មាអញជាអ្នកប្រដាប់កម្រងផ្កា និងបានចូលទៅរកកិន្នរជាប្តីនោះ

ក្នុងជំណោក ៗ មួយទៀត ខ្ញុំបេះផ្កាកុរវកៈ ទាំងផ្ការាជព្រឹក្ស និងផ្កាប្រទៀង ក៏ខ្ញុំបេះ ដោយបំណងថា កិន្នរជាប្ដីជាទីស្រឡាញ់របស់អាត្មាអញ នឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញក៏ជាអ្នកប្រដាប់កម្រងផ្កា បានចូលទៅរកកិន្នរជាប្ដីនោះក្នុងជំណោក ៗ មួយទៀត ខ្ញុំបានបេះនូវផ្កាសាលព្រឹក្ស ដែលរីកស្គុសស្គាយ ធ្វើជាគ្រឿងប្រដាប់ ដោយបំណងថា ថ្ងៃនេះយើងនឹងនៅក្នុងទីណាអស់រាត្រីមួយ គ្រឿងប្រដាប់នេះ នឹងបានជាកម្រាលផ្ការបស់ពួកយើងក្នុងទីនោះ ៗ មួយទៀត ខ្ញុំមានសភាពជាអ្នកធ្វេសប្រហែស ក្លិនខ្លឹមក្រស្នា និងខ្លឹមចន្ទន៍លើថ្ម ដោយបំណងថា កិន្នរ ជាប្ដីជាទីស្រឡាញ់របស់អាត្មាអញ នឹងបានលាបខ្លួនប្រាណ ទាំងខ្លួនអញក៏បានលាបស្រឡាប ហើយបានចូលទៅរកកិន្នរជាប្ដីនោះក្នុងជំណោក ៗ លំដាប់នោះ ទឹកស្ទឹងមានខ្សែដ៏រហ័ស ហូរគួចយកផ្កាសាលព្រឹក្ស ផ្កាស្រស់ និងផ្កាកណ្ណិការដែលខ្ញុំបេះទុកក្នុងទីទៀបមាត់ប្រាំង មានទឹកដ៏ពេញដោយមួយរំពេច ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងបានដោយកម្រក្រៃលែង ៗ គ្រានោះ យើងទាំងពីរ ក៏ឈរប្រេបឆ្នេរស្ទឹង

ម្ខាងម្នាក់ មើលឃើញគ្នាទៅវិញទៅមក ម្ដងយំ ម្ដងសើច រាត្រីនោះរបស់យើងក៏កន្លងទៅដោយក្រ ។ នៃព្រាន កាលបើព្រះអាទិត្យរះឡើងក្នុងវេលាព្រឹក យើងទាំងពីរក៏ចូងស្ទឹងទទេ ស្ទឹងមិនមានទឹក ហើយឱបរឹតគ្នាទៅវិញទៅមក ម្ដងយំ ម្ដងសើច ។ នៃព្រាន កាលមុនយើងបានព្រាត់ប្រាសគ្នាអស់មួយរាត្រី កន្លងមកចំនួន ៧០០ ខ្វះ ៣ ឆ្នាំ ( ៦៩៧ ឆ្នាំ ) ។ នៃភូមិបាល ជីវិតរបស់អ្នកនេះ ត្រឹមតែមួយរយឆ្នាំ អ្នកណាហ្ន៎ ក្នុងលោកនេះ នៅផ្សេងគ្នាអំពីកិរិយាជាទីត្រេកអរបាន ។ ព្រះរាជាសួរថា នៃសម្លាញ់ ចុះអាយុរបស់អ្នកទាំងឡាយចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុដល់យើង ទោះបីអ្នកបានឮអំពីអ្នកណាមួយក្ដី ចាំតមកអំពីពួកជនចាស់ទុំក្ដី សូមអ្នកកុំញញើតប្រាប់សេចក្ដីនោះដល់យើង ? កិន្នរីឆ្លើយថា នៃព្រាន អាយុរបស់យើង ១០០០ ឆ្នាំ បើមិនមានរោគដ៏អាក្រក់ក្នុងចន្លោះអាយុទេ ឯសេចក្ដីទុក្ខមានប្រមាណតិច សេចក្ដីសុខហ្នឹងឯង មានច្រើនក្រៃលែង ពួកយើងមិនប្រាសចាកសេចក្ដីត្រេកអរ និងសេចក្ដីស្រឡាញ់គ្នាទាល់តែលះជីវិតទៅ ។ ពេលនោះ

ព្រះរាជា និងព្រះនាមកល្យាតិយៈ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់ពួកកិន្នរនោះ ហើយក៏វិលត្រឡប់មកព្រះរាជនិវេសន៍ ដោយរំពឹងឃើញថា ជីវិតនេះមានប្រមាណតិចណាស់ រួចឈប់ត្រាច់ទៅកាន់ទីជាទីសម្លាប់ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់នូវភោគសម្បត្តិតាមធម្មតា ។ គ្រានោះ ព្រះសាស្តាទ្រង់ឲ្យឱវាទថា សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនោះហើយ ចូររួសរាយ កុំធ្វើនូវជម្លោះឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ។ សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនោះហើយ ចូររួសរាយ កុំធ្វើនូវការវិវាទឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកម្តៅនូវព្រះអង្គដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកម្តៅនូវកិន្នរទាំងនោះ ។ ព្រះនាងមល្លិកាទេវីទូលថា ខ្ញុំម្ចាស់មានចិត្តត្រេកអរ ស្តាប់ធម្មទេសនាមានហេតុផ្សេងៗ គន្លងនៃព្រះបន្ទូលរបស់ព្រះអង្គ ប្រកបដោយប្រយោជន៍ ព្រះអង្គបញ្ចេញវាចាបន្ទោបង់នូវសេចក្តីក្រវល់ក្រវាយរបស់ខ្ញុំម្ចាស់ បពិត្រ

ព្រះសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ ។ លុះព្រះសាស្តាប្រោសប្រទានព្រះធម៌ទេសនានេះចប់ហើយ ទ្រង់ប្រជុំជាតកថា កិន្នរក្នុងកាលនោះ បានមកជាព្រះបាទបសេនទិកោសល កិន្នរីក្នុងកាលនោះ បានមកជាព្រះនាងមល្លិកាទេវី ចំណែកព្រះបាទភល្លាតិយៈ គឺតថាគត ។

ជីវប្រវត្តិទាក់ទងនឹងការប្រសូតិព្រះរាជធីតា របស់ព្រះនាងមល្លិកាទេវី មានសម្តែងទុកនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **កោសលសំយុត្ត ក្នុងជដិលវគ្គទី ២ ធីតុសូត្រទី ៦** ដែលពោលថា ស្ត្រីក៏ជាអ្នកប្រសើរបានដែរ ដូចមានសេចក្តីថា ៖

សាវត្ថីនិទាន ។ គ្រានោះឯង ព្រះបាទបសេនទិកោសលស្តេចចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅដល់ថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់គង់នៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ បុរសម្នាក់ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ ខ្សឹបទូលព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព ព្រះនាងមល្លិកាទេវីប្រសូត

ព្រះរាជធីតាហើយ ។ កាលបើបុរសនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទបសេនទិកោសល ក៏មានព្រះទ័យអាក់អន់ ។ លុះព្រះសម្ពុទ្ធ ទ្រង់ជ្រាបថា ព្រះបាទបសេនទិកោសល មានព្រះទ័យអាក់អន់ហើយ ទើបត្រាស់នូវគាថាទាំងឡាយក្នុងពេលនោះថា

បពិត្រព្រះអង្គជាធំជាងជន សូមព្រះអង្គចិញ្ចឹមតែស្ត្រីមួយពួក ដែលមានបញ្ញា មានសីល មានម្តាយក្មេក និងឪពុកក្មេក ដូចជាទេវតា ជាអ្នកធ្វើវត្តដល់ប្តី ជាស្រីប្រសើរ បពិត្រព្រះអង្គជាធំក្នុងទិស បុរសណា កើតពីស្ត្រីនោះ បុរសនោះ ជាអ្នកក្លៀវក្លា ឯបុត្រនៃភរិយាល្អប្រាកដ ដូច្នោះ តែងប្រៀនប្រដៅនូវជន ដែលនៅក្នុងដែនបាន ។

ព្រះអដ្ឋកថាចារ្យ បានអធិប្បាយសេចក្តីបាលីនៅក្នុងព្រះគាថា ដែលព្រះមហាវីរៈត្រាស់ហើយនោះ ដើម្បីឲ្យយល់ដល់គោលបំណង របស់ព្រះពុទ្ធតម្រាស់នោះ តាមដែលមានសម្តែងប្រាកដនៅក្នុង គម្ពីរ អដ្ឋកថាសារត្ថប្បកាសិនី ដូចមានសេចក្តីថា ៖

ព្រះបាទបសេនទកោសល ឲ្យចាត់ចែងទីកន្លែងប្រសូតបុត្រ ។

ក្នុងពេលដែលព្រះនាងមល្លិកាប្រសូតបុត្រ ព្រះរាជាបានព្រះរាជទាន ការថែរក្សាហើយ ស្តេចយាងចូលទៅគាល់ព្រះមហាមុនី ។ ចំណែក ព្រះបាទបសេនទិកោសលទ្រង់អាក់អន់ព្រះទ័យនោះ ហេតុព្រោះព្រះ អង្គទ្រង់ត្រិះរិះថា យើងបានឲ្យឥស្សរិយយសធំដល់ធីតា នៃត្រកូល ដែលខ្វះខាតហើយ ប្រសិនបើនាងបានបុត្រា នាងក៏បានសក្ការៈធំជា ពិតប្រាកដ ប៉ុន្តែឥឡូវនេះ នាងវិនាសចាកសក្ការៈធំនោះអស់ហើយ ។ ពាក្យថា **មានម្តាយក្មេក និងឪពុកក្មេកដូចជាទេវតានោះ** សំដៅដល់ ការគោរពម្តាយក្មេក និងឪពុកក្មេកដូចជាទេវតា ។

ព្រះនាងមល្លិកាទេវី សូម្បីនាងជាអ្នកមានបញ្ញាច្រើនក៏ដោយ តែព្រះនាងនៅជាបុថុជ្ជន ទ្រង់ធ្វើខុស ឃ្លាតអាចនឹងកើតឡើងបាន កាលបើចិត្តខ្វះស្មារតី បុរាណពោលថា ដំរីជើង ៤ គង់តែមានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់ គង់តែមានភ្លេច ។ កាលបើទ្រង់ធ្វើខុសហើយ ទ្រង់មិនព្រមទទួលកំហុស ទ្រង់ត្រឡប់គិតត្រាស់មុសាវាទ ព្រោះការ ស្រឡាញ់ខ្លួន និងទ្រង់ក្រែងព្រះអាជ្ញា ផលបាបទើបនាំឲ្យធ្លាក់ទៅនរក

ចំណែកផលដែលធ្វើសេចក្ដីល្អផ្សេងៗ ជាតួយ៉ាងច្រើន កាលផុតចាក នរកហើយ ទើបបានទៅកើតក្នុងស្ថានតុសិត តាមដែលមានរឿងតំណាល ទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ជរាវគ្គ** ក្នុងរឿងព្រះនាងមល្លិកាទេវី ដូចមានសេចក្ដីថា ៖

គ្រានោះ ព្រះភគវា ទ្រង់ប្រថាប់នៅវត្តជេតពន ជិតក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវីឲ្យជាដើមហេតុ ទើបត្រាស់ព្រះធម៌ទេសនានោះថា រាជរថទាំងឡាយដ៏វិចិត្រល្អ រមែងគ្រាំគ្រាជាដើម ។បានឮមកថា ថ្ងៃមួយ ព្រះនាងមល្លិកាទេវី ស្ដេចចូលទៅក្នុងបន្ទប់សម្រាប់ស្រង់ទឹក ទ្រង់ខ្ពុរព្រះឱស្ឋ ទ្រង់បង្អោនព្រះសរីរៈចុះទៅដើម្បីទ្រង់លាងស្មងជើង ។ ពេលនោះ មានសុនខមួយដែលបានដើរចូលទៅព្រមជាមួយព្រះនាង លុះវាបានឃើញព្រះនាងឱនព្រះ ព្រះសរីរៈចុះដូច្នោះ ទើបផ្ដើមនឹងធ្វើអសទ្ធម្មសន្ថវៈ ។កាពស្និទ្ធស្នាល ដោយអំណាចនៃកម្ម ដែលមិនមែនជាធម៌របស់សប្បុរស សំដៅដល់ ការសេពកាមជាមួយនឹងព្រះនាង ។ ចំណែកព្រះនាងមល្លិកាទេវី ក៏ទ្រង់ត្រេកអរចំពោះសម្ផស្សរបស់សុនខ

នោះ ទើបប្រថាប់ឈរ ។ ពេលនោះ ព្រះបាទបសេនទិកោសលទ្រង់ទត ឃើញតាមចន្លោះបង្អួចពីប្រាសាទជាន់ខាងលើ ទ្រង់បានឃើញអំពើនោះ ក្នុងពេលដែលព្រះនាងស្តេចត្រឡប់មកពីបន្ទប់ទឹកមកវិញ ទើបត្រាស់ថា ស្រីថោកទាប ចូរវិនាសទៅ ព្រោះហេតុអ្វី នាងទើបធ្វើកម្មអាក្រក់ យ៉ាងនោះ ។ ព្រះនាងមល្លិកាទេវីបានក្រាបទូលសួរថា ខ្ញុំម្ចាស់ធ្វើកម្ម អាក្រក់អ្វី ព្រះអង្គ ។ព្រះបាទបសេនទិកោសលត្រាស់ឆ្លើយថា នាងធ្វើ ការស្និទ្ធស្នាលជាមួយនឹងសុនខនោះ ។ ព្រះទេវីទ្រង់ក្រាបទូលតបថា ខ្ញុំម្ចាស់មិនបានធ្វើដូច្នោះទេ ព្រះអង្គ ។ ព្រះរាជាបានត្រាស់បញ្ជាក់ថា យើងបានឃើញផ្ទាល់នឹងភ្នែក យើងមិនជឿនាងឯងទេ នែស្រីថោកទាប ចូរវិនាសទៅ ។ ព្រះទេវីទ្រង់ក្រាបបង្គំទូលថា សូមតេជះតម្កល់លើត្បូង មិនថាអ្នកណាចូលទៅក្នុងបន្ទប់ទឹកត្រឹមតែម្នាក់ ក៏ប្រាកដឃើញដូចជា ពីរនាក់ ដល់អ្នកដែលមើលតាមបង្អួចនោះ ព្រះអង្គ ។ព្រះរាជាត្រាស់ ជំទាស់ថា នាងនិយាយពាក្យមិនពិត នែស្រីអាក្រក់ ។ ព្រះទេវីក្រាបបង្គំ ទូលថា បើព្រះអង្គទ្រង់មិនជឿខ្ញុំម្ចាស់ សូមព្រះអង្គស្តេចយាងចូលទៅ

បន្ទប់ទឹកនោះ ខ្ញុំម្ចាស់នឹងមើលតាមបង្អួចនេះ ព្រះអង្គ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ជាមនុស្សឆោតល្ងង់ខ្លៅ ទើបទ្រង់វង្វេងជឿបន្ទូលរបស់ព្រះនាងមល្លិកា ហើយស្តេចបានចូលទៅកាន់បន្ទប់ទឹកនោះ ។ ចំណែកព្រះនាងមល្លិកាប្រថាប់ឈរនៅត្រង់បង្អួច ព្រះនាងមានព្រះបន្ទូលថា មហារាជជាអ្នកល្ងង់ខ្លៅ ហេតុអ្វីព្រះអង្គទ្រង់ធ្វើការស្និទ្ធស្នាលនឹងមេពពែ ។ ព្រះរាជាត្រាស់ជំទាស់ថា នាងដ៏ចម្រើន យើងមិនបានធ្វើដូចនាងពោលនោះទេ ។ ព្រះទេវីទ្រង់ក្រាបទូលថា ខ្ញុំម្ចាស់ឃើញផ្ទាល់នឹងភ្នែកខ្លួនឯង ខ្ញុំមិនជឿព្រះអង្គទេ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ព្រះវាចានោះហើយ ទ្រង់ជឿថាអ្នកចូលទៅក្នុងបន្ទប់ទឹកនោះតែម្នាក់ឯងពិត ក៏មើលឃើញប្រាកដដូចជាពីរនាក់ ។ ព្រះនាងមល្លិកាទ្រង់ត្រិះរិះថា យើងបានបោកបញ្ឆោតព្រះរាជាបានហើយ ព្រោះព្រះអង្គជាអ្នកល្ងង់ខ្លៅខ្វះបញ្ញា យើងបានធ្វើកម្មអាក្រក់ហើយ ទាំងយើងបានពោលបង្កាច់ព្រះរាជា ដោយពាក្យមិនពិត សូម្បីព្រះលោកនាយក ក៏ទ្រង់ជ្រាបការធ្វើអំពើរបស់យើងនេះ ព្រះអគ្គសាវក

ទាំងពីរ និងអសីតិមហាសាវកទាំងអស់ ក៏នឹងបានជ្រាបដល់កម្មនេះ តាមសេចក្តីពិត យើងបានធ្វើកម្មដ៏ធ្ងន់ទុកហើយ ។ ឮមកថា ព្រះនាងមល្លិកា ទ្រង់បានជាជួយព្រះបាទបសេនទិកោសល ក្នុងគ្រាថ្វាយ **អសទិសទាន** គឺទានដែលឥតមានទានដទៃណាមួយប្រដូចបាន ។ ក្នុងអសទិសទាននោះ ព្រះរាជាទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ក្នុងមួយថ្ងៃនោះ អស់ប្រាក់ដល់ទៅ ១៤ កោដិ ។ ចំនួនវត្ថុ ៤ យ៉ាង បានដល់ ១- ឡង់ ២- បល្ល័ង្ក ៣- ជើងបាត្រ ៤- តាំងទ្រទ្រនាប់ព្រះបាទរបស់ព្រះពុទ្ធ មិនអាចវាយតម្លៃបាន ។ ប៉ុន្តែព្រះនាងមល្លិកានោះ ក្នុងពេលដែលអស់ព្រះជន្មទៅ ព្រះនាងមិនបាននឹកដល់ការបរិច្ចាគដ៏ធំក្រៃលែងនោះឡើយ ទ្រង់ត្រឡប់ទៅរឭកឃើញដល់កម្មអាក្រក់លាមក ដែលខ្លួនធ្វើរួចមកហើយ លុះដល់អស់ព្រះជន្មទៅហើយ ក៏បានទៅកើតក្នុងអវិចីនរក ។ ព្រះនាងមល្លិកា បានជាអ្នកប្រោសប្រាណយ៉ាងក្រៃលែងរបស់ព្រះបាទបសេនទិកោសល ។ ចំណែកព្រះបាទបសេនទិកោសលទ្រង់អាល័យចំពោះព្រះនាងមល្លិកាទេវីយ៉ាងក្រៃលែង ត្រាស់ឲ្យថ្វាយ

ព្រះភ្លើងព្រះសពរបស់ព្រះនាងហើយ ទ្រង់ត្រិះរិះថា យើងនឹងទៅទូលសួរព្រះវិជិតមារនូវទីកន្លែងកើតរបស់ព្រះនាង ទើបស្តេចយាងទៅកាន់សម្នាក់ព្រះសក្យមុនី ។

គ្រានោះ ព្រះសាស្តា ទ្រង់បានធ្វើឲ្យព្រះបាទបសេនទិកោសលមិនអាចរឭកដល់ហេតុដែលស្តេចយាងមកក្នុងការសាកសួរបាន កាលព្រះរាជាទ្រង់ព្រះសណ្តាប់ព្រះធម្មីកថាហើយ ក៏ទ្រង់ភ្លេច តែក្នុងពេលដែលស្តេចយាងត្រឡប់មកដល់ព្រះរាជនិវេសន៍វិញ ទើបទ្រង់រឭកឃើញបាន ទើបត្រាស់ថា នែស្នំ ខ្ញុំតាំងចិត្តនឹងទូលសួរព្រះសាស្តានូវទីកន្លែងដែលព្រះនាងមល្លិកាទៅកើត កាលដែលទៅដល់សម្នាក់នៃព្រះមុនីក៏ភ្លេចឈឹងទៅ ថ្ងៃស្អែកនេះ ខ្ញុំនឹងទៅទូលសួរព្រះអង្គទៀត ចំណែកព្រះភគវា ក៏ទ្រង់បានធ្វើដោយប្រការមិនឲ្យស្តេចអាចរឭកបានរហូតទៅដល់ ៧ ថ្ងៃដោយលំដាប់ ។ ចំណែកព្រះនាងមល្លិកាបានធ្លាក់ទៅឆេះក្នុងនរកអស់ ៧ ថ្ងៃប៉ុណ្ណោះ កាលបើដល់ថ្ងៃទី ៨ ព្រះនាងចុតិចាកនរក បានទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ។ មានសំណួរថា

ព្រោះហេតុអ្វី ព្រះលោកនាថ ទើបទ្រង់ធ្វើមិនឲ្យព្រះរាជាវឮកបាន ? មានចម្លើយថា ជាប់ទាក់ទងដោយព្រះនាងមល្លិកា ព្រោះព្រះនាងជាទីសព្វព្រះទ័យយ៉ាងក្រៃលែងនៃព្រះបាទបសេនទិកោសល ព្រោះដូច្នោះ បើព្រះរាជាទ្រង់ជ្រាបថា ព្រះនាងទៅកើតក្នុងនរកហើយ ទ្រង់នឹងកាន់មិច្ឆាទិដ្ឋិ ដោយទ្រង់ត្រិះរិះថា សូម្បីស្ត្រីអ្នកបរិបូណ៌ ដោយសទ្ធាដូចព្រះនាងមល្លិកា នៅតែទៅកើតក្នុងនរកទៅហើយ យើងនឹងថ្វាយទានធ្វើអ្វី ហើយនឹងត្រាស់ឲ្យបញ្ឈប់និច្ចភត្ត ភត្តដែលមានបម្រុងជានិច្ចទុករាល់ពេលនៅក្នុងព្រះរាជនិវេសន៍ ដើម្បីភិក្ខុសង្ឃ ៥០០ រូប ហើយទ្រង់ប្រាកដជាទៅកើតក្នុងនរកដែរ ព្រោះដូច្នោះ បានជាព្រះមានជោគទើបទ្រង់ធ្វើឲ្យព្រះរាជាមិនអាចវឮកបានរហូតទៅដល់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ព្រះអង្គបានស្តេចយាងទៅបិណ្ឌបាត និងបានទៅកាន់ព្រះរាជវាំងដោយមួយព្រះអង្គឯង ។ ពេលនោះ ព្រះបាទបសេនទិកោសលទ្រង់ជ្រាបថា ព្រះសម្មាសម្ពុទ្ធស្តេចយាងមកហើយ ទើបស្តេចចេញទៅទទួលបាត្រ ហើយអារាធនានិមន្តព្រះសាស្តាឲ្យឡើងទៅកាន់ប្រាសាទ

តែព្រះភគវា ទ្រង់សម្តែងព្រះអាការ ដើម្បីនឹងគង់នៅត្រង់រោងរថ ។ ព្រះបាទបសេនទិកោសល ទើបទ្រង់ក្រាបទូលអារាធនាឲ្យព្រះសាស្តា គង់នៅត្រង់រោងរថនោះ ថែមទាំងអង្គាសនូវភត្តាហារថ្វាយព្រះសម្ពុទ្ធ ហើយទ្រង់ថ្វាយបង្គំ រួចព្រះពុទ្ធអង្គគង់នៅក្នុងទីដ៏សមគួរ ហើយទ្រង់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចូលទៅគាល់ដោយបំណងថា នឹងក្រាបទូលសួរនូវទីកន្លែងកើតរបស់ព្រះនាងមល្លិកាទេវី ក៏ភ្លេចសូន្យឈឹង តើព្រះនាងទៅកើតទីកន្លែងណា ព្រះអង្គ ? គ្រានោះព្រះមានព្រះភាគទ្រង់ត្រាស់តបថា បពិត្រមហារាជ ព្រះនាងទៅកើតក្នុងស្ថានតុសិត ។ ព្រះបាទបសេនទិកោសលទើបទ្រង់ក្រាបទូលថា កាលបើព្រះនាងមល្លិកាមិនបានទៅកើតក្នុងស្ថានតុសិតទេនោះ មានបុគ្គលដទៃណានឹងទៅកើតបាន ព្រះអង្គ ព្រោះថា ស្រីណាដូចគ្នានឹងព្រះនាងមល្លិកានោះមិនមាន គ្រប់ពេលវេលាដែលនាងប្រថាប់គង់ ឬឈរជាដើម ព្រះនាងមិនមានកិច្ចយ៉ាងដទៃក្រៅពីការចាត់ចែងថ្វាយទានដោយនាងគិតថា ថ្ងៃស្អែកនេះយើងនឹងថ្វាយវត្ថុនេះ នឹងធ្វើវត្ថុនេះ

ដើម្បីព្រះសម្មាសម្ពុទ្ធ ។ បពិត្រព្រះអង្គដ៏ចម្រើន ចាប់តាំងពីពេលដែលព្រះនាងស្តេចទៅកាន់បរលោកហើយ រាងកាយរបស់ខ្ញុំព្រះអង្គមិនស្វាហាប់ ឬមិនរហ័សរហួនទាល់តែសោះ ព្រះអង្គ ។ លំដាប់តពីនោះព្រះភគវា ព្រះអង្គទើបត្រាស់ថា កុំគិតធ្វើអ្វីឡើយមហារាជ នេះជាធម៌ពិតប្រាកដរបស់សត្វគ្រប់ជំពូក ហើយត្រាស់សួរថា បពិត្រមហារាជរថនេះរបស់នរណា ? ព្រះបាទបសេនទិកោសល ទ្រង់ប្រណម្យព្រះហស្តឡើងលើព្រះសិរសាហើយ ទ្រង់ក្រាបទូលថា រថនេះជារបស់ជីតារបស់ខ្ញុំព្រះអង្គ ។ ព្រះលោកនាយកត្រាស់សួរតទៅទៀតថា រថនេះជារបស់នរណាដែរ ? ព្រះរាជាទ្រង់ក្រាបទូលថា រថនេះជារបស់ព្រះបិតារបស់ខ្ញុំព្រះអង្គ ។ ព្រះលោកនាថ ទ្រង់ត្រាស់សួរតទៅទៀតថា មហារាជ រថនេះជារបស់នរណា ? ព្រះរាជាក្រាបទូលតបថា រថនេះជារបស់ខ្ញុំព្រះអង្គ ។

កាលបើព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលយ៉ាងនេះហើយ ព្រះមហាមុនី ទើបត្រាស់ថា មហារាជ ព្រោះហេតុអ្វី រថជីតារបស់មហារាជទើបមិនវិចិត្រល្អ ដូចរថព្រះបិតារបស់មហារាជ រថព្រះបិតារបស់មហារាជ ព្រោះហេតុអ្វី ទើបមិនវិចិត្រល្អដូចរថរបស់មហារាជ

សូម្បីកំណាត់ឈើដែលមិនមានចិត្តវិញ្ញាណដូច្នេះ ក៏រមែងដល់នូវភាពគ្រាំគ្រា មិនចាំបាច់ពោលថ្វីដល់អត្តភាព គឺរាងកាយនេះដែលមិនដល់នូវភាពគ្រាំគ្រានោះមិនមាន រីឯធម៌របស់សប្បុរសទាំងឡាយប៉ុណ្ណោះទើបមិនដល់នូវការចាស់ជរា ចំណែកសត្វទាំងឡាយ ដែលមិនចាស់ជរាមិនមាន ហើយព្រះពុទ្ធអង្គ ទើបត្រាស់ព្រះគាថានេះថា

រាជរថទាំងឡាយដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈ ក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា រីឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រាដូច្នោះទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

ក្នុងពេលដែលព្រះមហាវីរៈ ទ្រង់ត្រាស់ព្រះធម៌ទេសនានេះចប់ហើយ មានមហាជនជាច្រើន បានសម្រេចអរិយផល គឺជាផលដ៏ប្រសើរទាំងឡាយ មានព្រះសោតាបត្តិផលជាដើម ទៅតាមឧបនិស្ស័យរបស់ខ្លួនរៀងៗ ខ្លួន ។l៚

( ជីវប្រវត្តិរបស់ព្រះនាងមល្លិកាទេវី ចប់ )

88888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះនាងចុន្ទីរាជកុមារី ✍

## " ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ "

ព្រះនាងចុន្ទីរាជកុមារី ទ្រង់ជាឧបាសិកាមកអំពីរាជត្រកូល ព្រះនាងជាអ្នកគោរពរាប់អាននៅក្នុងព្រះពុទ្ធសាសនា ហើយព្រះពុទ្ធសាសនាសម្តែងឲ្យឃើញបានថា ទោះបីជាភិក្ខុសង្ឃ ឬឃរាវាសជាបុរស ឬស្រ្តីមិនថាវណ្ណៈណាទេ កាលបើអប់រំប្រព្រឹត្តតាមសីល សមាធិ បញ្ញាហើយក៏រមែងបានផលល្អ ដែលជាគ្រឿងតបស្នងសងទៅវិញដល់បុគ្គលនោះផងដែរ ។

ជីវប្រវត្តិរបស់ព្រះនាងចុន្ទីរាជកុមារី មានសម្តែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

ព្រះនាងចុន្ទីរាជកុមារី ព្រះនាងជាព្រះរាជធីតារបស់ព្រះបាទពិម្ពិសារ នៅក្នុងដែនមគធៈ ព្រះនាងទ្រង់មានរាជរថ ៥០០ និងកុមារី ៥០០ ពេលដែលព្រះនាងស្តេចយាងទៅកាន់ទីណា ក៏មានរាជបរិវារ

អង្គុយលើព្រះរាជរថ ហែហមទៅជាមួយផងដែរ ហើយព្រះនាងជាអ្នកជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនានេះ តាមព្រះរាជបិតាខ្លួនទៀត ។

មានរឿងតំណាលដល់ការ ដែលព្រះនាងចុន្ទីរាជកុមារី បានចូលទៅគាល់ព្រះសាស្តា ដើម្បីក្រាបទូលសួរបញ្ហា ដែលមានសម្តែងទុកនៅក្នុងព្រះបាលី **ចុន្ទីសូត្រ** នៃ **សុមនវគ្គទី ៤** ក្នុង **គម្ពីរអង្គុត្តរនិកាយបញ្ចកនិបាត** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះនាងចុន្ទីរាជកុមារី មានរាជរថ ៥០០ និងកុមារី ៥០០ ហែហមចូលទៅគាល់ព្រះសាស្តា លុះចូលទៅដល់ ថ្វាយបង្គំព្រះលោកនាថហើយ គង់ប្រថាប់ក្នុងទីដ៏សមគួរ ។ លុះព្រះនាងចុន្ទីរាជកុមារី គង់ប្រថាប់ក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះសាស្តាដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រាជកុមារ ឈ្មោះចុន្ទៈជាបងប្រុសរបស់ខ្ញុំព្រះអង្គនោះ និយាយយ៉ាងនេះថា តាមតែបុគ្គលណាក៏ដោយ ទោះជាស្ត្រីក្តី បុរសក្តីដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងហើយ វៀរចាក

បាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាក មុសាវាទ វៀរចាកសុរាមេរ័យ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិឡើយ ។ម្នាល នាងចុន្ទី រាប់តាំងពីពួកសត្វឥតជើងក្តី សត្វមានជើងពីរក្តី សត្វមានជើង បួនក្តី សត្វមានជើងច្រើនក្តី សត្វមានរូបក្តី សត្វឥតរូបក្តី សត្វមាន សញ្ញាក្តី សត្វឥតសញ្ញាក្តី សត្វមានសញ្ញាក៏មិនមែន មិនមានសញ្ញា ក៏មិនមែនក្តីជាដើម ព្រះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដជា ប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលនាងចុន្ទី បុគ្គលពួកណាជ្រះថ្លា ក្នុងព្រះពុទ្ធ បុគ្គលពួកនោះឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ហើយ ផលដ៏ប្រសើរនោះ រមែងមានដល់បុគ្គលដែលជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ នោះឯង ។ ម្នាលនាងចុន្ទី ពួកសង្ខតធម៌ក្តី អសង្ខតធម៌ក្តី ទាំងប៉ុន្មាន វិរាគធម៌ គឺធម៌ញុំាងសេចក្តីស្រវឹងឲ្យទ្រុឌទ្រោម នាំបង់នូវសេចក្តី ស្រេកឃ្លាន គាស់រំលើងនូវការអាល័យ ផ្តាច់បង់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់ទុក្ខ មិនមានគ្រឿងចាក់ដោត ប្រាកដជាប្រសើរ

ជាងពួកធម៌ទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងវិរាគធម៌ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ហើយផលដ៏ប្រសើរនោះ រមែងមានដល់បុគ្គលដែលជ្រះថ្លាក្នុងធម៌ប្រសើរនោះឯង ។ ម្នាលនាងចុន្ទី សង្ឃក្តី គណៈក្តីទាំងប៉ុន្មាន សង្ឃសាវករបស់តថាគត បើរាប់ជាគូនៃបុរសមាន ៤ គូ ហើយរាប់រៀងជាបុរសបុគ្គលមាន ៨ ព្រះសង្ឃសាវកទាំងនោះ ជាព្រះសង្ឃសាវកនៃព្រះមានព្រះភាគ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយ នាំមកបូជា ជាអ្នកគួរទទួលអាគន្តុកទាន គួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា ជាអ្នកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ ។

ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងព្រះសង្ឃ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ហើយផលដ៏ប្រសើររមែងមានដល់បុគ្គល ដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរនោះឯង ។

ម្នាលនាងចុន្ទី សីលដែលព្រះអរិយៈសរសើរទាំងអម្បាលម៉ាន ជាសីល មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលដែលវិញ្ញូជនសរសើរ ហើយ មិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ប្រព្រឹត្តទៅដើម្បីសមាធិនេះ ប្រាកដជាប្រសើរជាងសីលទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណា ជាអ្នកបំពេញក្នុងពួកសីល ដែលព្រះអរិយៈសរសើរ ហើយពួកបុគ្គល ទាំងនោះ ឈ្មោះថា បានបំពេញក្នុងសីលដ៏ប្រសើរ ហើយផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គល ដែលបំពេញក្នុងសីលដ៏ប្រសើរនោះឯង ។

បុណ្យ គឺអាយុដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះ ដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែង ចម្រើនដល់បុគ្គល ដែលជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ ប្រសើរ ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គល រកបុគ្គលណាមួយប្រសើរជាងគ្មាន ជាអ្នកជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាករាគៈ ជាធម៌ស្ងប់រំងាប់នាំមកនូវសុខ ជាអ្នកជ្រះថ្លា ក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្តរកបុគ្គលដទៃក្រៃលែងជាងគ្មាន

ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ ជាអ្នកមានប្រាជ្ញា មានចិត្តតម្កល់ទុកក្នុងធម៌ដ៏ប្រសើរហើយ ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ តែងបានទៅកើតជាទេវតា ឬមនុស្ស ដែលជាអ្នកប្រសើរ ហើយរីករាយសប្បាយ ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ បុរាណាចារ្យបានអធិប្បាយពាក្យថា **អរិយកន្តសីល** ប្រែថា សីលជាទីស្រឡាញ់របស់ព្រះអរិយៈ បានដល់សីលមិនដាច់ មិនធ្លុះ មិនដាង មិនពពាល ជាសីលដែលបណ្ឌិតបានពោលសរសើរហើយ ជាសីលដែលតណ្ហាមិនអាចពាល់ ត្រូវជាសីលដែលធ្វើឲ្យកើតសមាធិ ។ ពាក្យថា **សីលមិនដាច់** បានដល់ សីល ៥ ដែលមិនដាច់ គឺមិនប្រព្រឹត្តកន្លង កាលបើបុគ្គលធ្វើខុស ប្រព្រឹត្តកន្លងនូវសីល ឬអង្គ ទើបរាប់ថា សីលនោះដាច់ ពាក្យថា **សីលមិនធ្លុះ** បានដល់ សីល ៥.ណាមិនខូចអង្គនៅត្រង់ចំណុចណានីមួយ សីល ៥.នោះរាប់ថា សីលមិនធ្លុះ ប្រៀបដូចជាក្រណាត់សំពត់មិនធ្លុះ នៅត្រង់កណ្តាលសំពត់ ។ ពាក្យថា **សីលមិនពពាល** បានដល់ សីលមិនបានខូចអង្គ

សីលណាទីមួយទេ មិនដូចជាក្រណាត់សំពត់ពពាល គឺក្រណាត់សំពត់ដែលមានពណ៌ប្រឡាក់ នៅត្រង់កន្លែងផ្សេងៗ នៅលើផ្ទាំងក្រណាត់សំពត់នោះ ។ ពាក្យថា **សីលមិនពព្រុស** បានដល់ សីលមិនបានដូចជាធ្នូតពព្រុសដូចជាខ្វាដំបង ឬខ្វារវិន គឺអង្គសីលនោះៗ មិនខូចអង្គសូម្បីតែបន្តិចបន្តួច ។ ពាក្យថា **ជាធំ** គឺមិនជាទាសៈនៃតណ្ហា មានសេចក្តីថា មិនធ្លាក់ទៅក្នុងអំណាចនៃតណ្ហា បានដល់ សីលដែលមិនវិនាសខូចដោយតណ្ហាជាហេតុនាំទៅ ។ ពាក្យថា **ជាសីលដែលបណ្ឌិតបានពោលសរសើរហើយ** បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមបានពោលសរសើរថា ជាសីលដ៏ល្អ ។ ពាក្យថា **ជាសីលដែលតណ្ហាមិនពាល់ត្រូវ** បានដល់ អ្នករក្សាសីល មិនរក្សាដោយសេចក្តីប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិស្ថានសួគ៌ តែរក្សាដោយប្រាថ្នានូវនិព្វានសម្បត្តិ គឺប្រាថ្នាដើម្បីឲ្យបានអស់កិលេសតណ្ហាប៉ុណ្ណោះ ។ ពាក្យថា **ជាសីលដែលធ្វើឲ្យកើតសមាធិ** គឺសីលនោះជាហេតុ ជាបច្ច័យ ឲ្យកើតសមាធិដល់អ្នករក្សា ។ ពាក្យថា **ព្រះអរិយៈទាំងឡាយ ទោះទៅកើតក្នុងភពដទៃ**

កំមិនលះបង់នូវសីលនោះ គឺកាលព្រះអរិយៈធ្វើមរណកាលពីជាតិនេះ ទៅហើយ ទោះ បីទៅកើតក្នុងជាតិដទៃ លោកក៏មិនលះបង់សីល ៥ នៅមានសីល ៥ កើតជាប្រចាំក្នុងចិត្ត ។

ព្រោះដូច្នោះ ពួកបុគ្គលណាជ្រះថ្លាក្នុងព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានធ្វើឲ្យបរិបូណ៌ក្នុងអរិយកន្តសីល អ្នកនោះ លុះស្លាប់ទៅហើយ នឹងមិនទៅកើតក្នុងទុគ្គតិ តែងតែទៅកើតក្នុងសុគតិ គឺកើតជាមនុស្សនិងទេវតាប៉ុណ្ណោះកាលទៅកើតជាមនុស្ស ឬទេវតា ក៏បានទទួលផលដ៏ប្រសើរច្រើនប្រការ ដូចជាមានអាយុវែង មានពណ៌ សម្បុរស្អាត មានសេចក្តីសុខ មានកម្លាំងខ្លាំងក្លា មានសតិបញ្ញាល្អ មានទ្រព្យសម្បត្តិច្រើន មានកេរ្តិ៍ឈ្មោះល្អ រួមសេចក្តីមកថា មិនថាទៅ កើតជាមនុស្ស ឬទេវតាទេ ក៏ជាអ្នកប្រសើរដោយវត្ថុ ដែលប្រាថ្នា ហើយនោះឯង ( អ្នកប្រាថ្នាផលដ៏ប្រសើរ ត្រូវធ្វើសេចក្តីល្អផ្សេងៗ ទុកជានិច្ច ) ។៚

( ជីវប្រវត្តិរបស់ព្រះនាងចុន្ទីកុមារី ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាងរោហិណី ✍

### “ ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ព្រះនាងរោហិណី រាប់ថាជាឧបាសិកាម្នាក់ ជាអ្នកទ្រទ្រង់នូវកេរ្តិ៍ឈ្មោះដ៏ខ្ពង់ខ្ពស់ និងជាស្ត្រីដ៏ល្អនៅក្នុងវង្សសក្យរាជ តែព្រះនាងក៏ជាអ្នកមានសទ្ធាយ៉ាងមាំទាំ នៅក្នុងព្រះពុទ្ធសាសនានេះ ថែមទាំងធ្វើជាគំរូដ៏ល្អសម្រាប់ស្ត្រីទាំងឡាយ ដែលចូលមកគោរពរាប់អាននៅក្នុងព្រះពុទ្ធសាសនានេះទៀតផង ។

ជីវប្រវត្តិរបស់ព្រះនាងរោហិណី មានសម្ដែងប្រាកដក្នុង **គម្ពីរអដ្ឋកថាធម្មបទ** នៃ **កោធវគ្គ** ក្នុងរឿងរបស់ព្រះនាងរោហិណី មានទាំងចំណែកបច្ចុប្បន្នជាតិ និងអតីតជាតិ ដូចមានសេចក្ដីថា ៖

កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ទ្រង់បានត្រាស់ព្រះធម៌ទេសនា ដោយប្រារព្ធនូវព្រះនាងរោហិណី ។ ព្រះនាងរោហិណី ទ្រង់ជាធីតារបស់ព្រះបាទអមិតោទនៈ

ដែលជាព្រះអនុជរបស់ព្រះបាទសុទ្ធោទនៈ ដោយរាប់តាមលំដាប់ព្រះញាតិវង្ស ព្រះបាទអមិតោទនៈ ជាព្រះបិតុលារបស់ព្រះសម្ពុទ្ធ ព្រះនាងជាព្រះភគិនី គឺប្អូនស្រីរបស់ព្រះមហានាមសក្យៈ និងព្រះអនុរុទ្ធ ។ហេតុដែលព្រះនាងរោហិណីទ្រង់មានសទ្ធាជ្រះថ្លា ថែមទាំងថ្វាយខ្លួនជាឧបាសិកា និងកាពជាអ្នកចូលដល់អចលសទ្ធានោះ ។ក្នុងសម័យមួយ ព្រះអនុរុទ្ធបានទទួលការលើកតម្កើងពីព្រះពុទ្ធជាម្ចាស់ថា ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងទិព្វចក្ខុហើយនោះ លោកបាននាំភិក្ខុសង្ឃ ៥០០ រូបទៅកាន់ក្រុងកបិលពស្តុ ។ គ្រានោះ ពួកព្រះញាតិរបស់លោកបានឮដំណឹងថា ព្រះអនុរុទ្ធនិមន្តមកហើយ ទើបបាននាំគ្នាទៅកាន់សម្នាក់របស់ព្រះថេរៈ វៀរលែងតែព្រះនាងរោហិណី ដែលជាប្អូនស្រីរបស់ព្រះថេរៈ ។ពេលនោះ ព្រះអនុរុទ្ធទើបសួរព្រះញាតិថា ព្រះនាងរោហិណីប្រថាប់នៅទីណា បានជាមិនឃើញមក ? ដោយព្រះអនុរុទ្ធត្រូវការដឹងដល់ហេតុ ដែលព្រះនាងរោហិណី មិនបានយាងមក ទើបសួរតទៅទៀតថា ព្រោះហេតុអ្វីទើបព្រះនាងរោហិណីមិនបានយាងមក ? ពពួក

ព្រះញាតិតបថា ហេតុដែលព្រះនាងមិនបានយាងមក ព្រោះទ្រង់ខ្មាសថា ខ្លួនកើតរោគរមាស់ពេញសរីរៈ ព្រោះដូច្នោះ ទើបមិនបានមក ។ គ្រានោះ ព្រះអនុរុទ្ធទើបពោលថា អ្នកទាំងឡាយចូរទៅហៅនាងមក ។ ពេលនោះ ពពួកព្រះញាតិទៅហៅនាងមក ដោយព្រះនាងបានតាក់តែងខ្លួនយ៉ាងស្អាត យាងមករកព្រះថេរៈមែន ។ ព្រះអនុរុទ្ធទើបសួរថា ម្នាលនាងរោហិណី ហេតុអ្វីទៅ នាងទើបមិនយាងមកទីនេះ ? ព្រះនាងរោហិណីឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដែលខ្ញុំមិនយាងមកទីនេះ ព្រោះខ្ញុំម្ចាស់ កើតរោគរមាស់ពេញសរីរៈ ទើបខ្ញុំម្ចាស់មិនបានមក ព្រោះខ្ញុំម្ចាស់មាន ការខ្មាសចំពោះលោកម្ចាស់ផងដែរ ។ ព្រះអនុរុទ្ធសួរថា នាងមិនចង់ធ្វើ បុណ្យទេឬ ? ព្រះនាងរោហិណីឆ្លើយថា តើធ្វើបុណ្យយ៉ាងណាទៅល្អ ? ព្រះអនុរុទ្ធតបថា នាងចូរឲ្យគេកសាងសាលាឆាន់ ។ ព្រះនាងរោហិណី សួរថា ខ្ញុំព្រះករុណានឹងយកអ្វីធ្វើ ? ព្រះអនុរុទ្ធតបថា គ្រឿងអលង្ការ របស់នាងមិនមានទេឬ ? ព្រះនាងរោហិណីឆ្លើយថា គ្រឿងអលង្ការ របស់ខ្ញុំមាន ។ ព្រះអនុរុទ្ធសួរថា គ្រឿងអលង្ការរបស់ព្រះនាងមានតម្លៃ

ប៉ុន្មាន ? ព្រះនាងរោហិណីឆ្លើយថា គ្រឿងអលង្ការរបស់ខ្ញុំមានតម្លៃ ១ ម៉ឺនកហាបណៈ លោកម្ចាស់ ។ ព្រះថេរៈបានពោលទៀតថា បើដូច្នោះ នាងចូរយកគ្រឿងអលង្ការនោះទៅលក់ ហើយយកមកកសាងសាលាឆាន់ចុះ ។ ព្រះនាងសួរទៀតថា នរណាទៅនឹងជាអ្នកជួយធ្វើដល់ខ្ញុំ ? ព្រះថេរៈបានក្រឡេកមើលព្រះញាតិទាំងឡាយ ដែលនៅក្នុងទីជិតនោះហើយ ពោលថា សូមអ្នកទាំងឡាយជួយក្នុងរឿងនេះផងចុះ ។គ្រានោះ ពពួកព្រះញាតិសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ចង់ធ្វើអ្វីឬ ? ព្រះអនុរុទ្ធពោលថា អាត្មាចង់ឲ្យជួយធ្វើសាលាឆាន់ អាត្មាក៏នៅទីនេះដែរ បើដូច្នោះ ពួកលោកចូរជួយគ្នាចាត់ចែងគ្រឿងទព្វសម្ភារៈដើម្បីកសាងសាលាឆាន់ផង ។ លំដាប់នោះ ពពួកព្រះញាតិទទួលថា ល្អហើយលោកម្ចាស់ ហើយក៏នាំគ្នាជួយធ្វើសាលាឆាន់នោះទៅ ។

គ្រានោះ ព្រះអនុរុទ្ធ ពេលដែលចាត់ចែងកសាងសាលាឆាន់បានពោលជាមួយនឹងរោហិណីថា ម្នាលនាងដ៏ចម្រើន នាងចូរឲ្យកសាងសាលាឆាន់ពីរជាន់ ហើយនាងចូរជួយសម្អាតបណ្តើរៗ មកផងចុះ ។

ព្រះនាងរោហិណីទទួលពាក្យថា ល្អហើយលោកម្ចាស់ ហើយព្រះនាងរោហិណី បានយកគ្រឿងអលង្ការទាំងនោះទៅលក់ ដើម្បីបានប្រាក់យកមកកសាងសាលាឆាន់ពីរជាន់ទៅ ។ ចាប់តាំងពីពេលដែលកសាងជាន់ខាងលើរួច នាងក៏តែងតែទៅបោសសម្អាតផ្ទៃខាងលើជាប្រចាំ ។ មានសេចក្តីអស្ចារ្យបានកើតឡើងដល់ព្រះនាងរោហិណី ដោយមិនមាននរណាៗ នឹកស្មានដល់ថា ពេលដែលព្រះនាងរោហិណី ដែលជាអ្នកមានប្រក្រតីតែងតែទៅបោសសម្អាតសាលាឆាន់នោះជាប្រចាំ រោគរមាស់ក៏ជាបណ្តើរៗ ទៅ ។ គ្រាកាលសាលាឆាន់នោះកសាងរួចជាស្រេច ព្រះនាងរោហិណីបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកពេញសាលាឆាន់ហើយ បានថ្វាយខាទនីយៈ និងភោជនីយាហារដ៏ប្រណីតដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះលោកនាថទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយត្រាស់ថា នេះជាទានរបស់នរណា ? ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នេះជាទានរបស់ព្រះនាងរោហិណីដែលជាប្អូនស្រីរបស់ខ្ញុំព្រះអង្គ ។ ព្រះភគវាត្រាស់សួររកថា ព្រះនាង

រោហិណីទៅទីណាហើយ ? ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងប្រថាប់នៅក្នុងព្រះដំណាក់ ព្រះអង្គ ។ ព្រះលោកនាថត្រាស់បញ្ជាថា ពួកអ្នកចូរទៅហៅព្រះនាងមក ។ ព្រះនាងរោហិណីទ្រង់មិនមានបំណងនឹងស្ដេចយាងមក ដោយទ្រង់ខ្មាស ព្រោះខ្លួនមានរោគរមាស់ ។ ព្រះលោកនាយកត្រាស់បញ្ជាឲ្យទៅហៅព្រះនាងរោហិណីម្ដងទៀត សូម្បីព្រះនាងទ្រង់មិនចង់យាងមក ព្រះអង្គក៏បានត្រាស់បញ្ជាឲ្យហៅនាងមកទាល់តែបាន ។ ព្រះនាងរោហិណី ក៏បានយាងមកតាមព្រះតម្រាស់ ហើយបានចូលទៅថ្វាយបង្គំព្រះមានជោគរួចក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ ពេលនោះ ព្រះមហាវីរៈទ្រង់ត្រាស់សួរថា ម្នាលនាងរោហិណី ហេតុអ្វីនាងទើបមិនយាងមកទីនេះ ? ព្រះនាងរោហិណីក្រាបទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំម្ចាស់មានរោគរមាស់ប្រចាំកាយ ដោយខ្មាសចំពោះព្រះអង្គ បានជាមិនហ៊ានយាងមកទីនេះ ព្រះអង្គ ។ ព្រះសម្ពុទ្ធ ទើបត្រាស់សួរថា ម្នាលនាងរោហិណី នាងដឹងទេថា រោគរមាស់កើតឡើងដល់នាងដូច្នេះ ព្រោះ

កម្មអ្វីដែលនាងធ្លាប់ធ្វើទុកមកហើយឬ ? ព្រះនាងរោហិណីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងទេ ។ ព្រះជិនស្រីទ្រង់ត្រាស់ប្រាប់ថា រោគនេះអាស្រ័យសេចក្តីក្រោធរបស់នាង ទើបរោគរមាស់នេះកើតឡើងដល់នាងយ៉ាងនេះ ។ ព្រះនាងរោហិណី មានសេចក្តីប្រាថ្នាចង់ដឹងសេចក្តីនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គបានធ្វើកម្មអ្វីទុក បានជាខ្ញុំកើតរោគរមាស់ដូច្នេះ ព្រះអង្គ ? ព្រះសក្យមុនី ទ្រង់ត្រាស់ថា ម្នាលនាងរោហិណី បើដូច្នោះ នាងចូរតាំងចិត្តស្តាប់ឲ្យល្អចុះ តថាគតនឹងសម្តែងប្រាប់ដល់នាង ហើយព្រះលោកនាថ ទ្រង់បាននាំអតីតនិទាន មកសម្តែងដូច្នេះថា

ក្នុងអតីតកាល មានអគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តម្នាក់ចងអាឃាតចំពោះស្ត្រីរបាំម្នាក់របស់ព្រះរាជា ទើបទ្រង់ត្រិះរិះថា យើងនឹងធ្វើឲ្យស្ត្រីនេះដល់នូវសេចក្តីទុក្ខ បានបញ្ជាឲ្យមនុស្សទៅកាច់យកខ្ទែរមកយ៉ាងច្រើន ហើយបានឲ្យទៅហៅស្រីរបាំនោះមក ក្នុងដំណាក់របស់ខ្លួន ដោយឲ្យគេយកម្ទេចខ្ទែរដាក់លើគ្រែដេកផង ត្រង់សំពត់

ដណ្តប់ផង និងត្រង់គ្រឿងប្រើប្រាស់ មានសំពត់កម្រាលដេកជាដើម របស់ស្រីរបាំនោះផង ដោយនាងមិនបានដឹងខ្លួន ទាំងឲ្យរោយដាក់លើខ្លួនរបស់នាង ហាក់បីដូចជាធ្វើការសើចចំអកលេងសប្បាយទៅ ។ ក្នុងមួយរំពេចនោះ រាងកាយរបស់ស្រីរបាំនោះ ប៉ោងឡើងជាពងតូចធំ នាងក៏បានទៅដេកអេះនៅលើគ្រែ ។ ពេលនាងត្រូវកម្ទេចខ្ទេរជាច្រើន ដែលរោយនៅលើគ្រែដេកប៉ះទៀត ទុក្ខវេទនាយ៉ាងខ្លាំងក្លា បានកើតដល់នាងទៀត ។ ព្រះអគ្គមហេសីក្នុងអតីតជាតិកាលនោះ បានមកកើតជាព្រះនាងរោហិណីក្នុងកាលឥឡូវនេះ ។ ព្រះទសពល គ្រាកាលទ្រង់នាំអតីតនិទានមកត្រាស់ហើយ បានមានព្រះពុទ្ធតម្រាស់ថា ម្នាលនាងរោហិណី បាបកម្មនោះ ដែលនាងបានធ្វើហើយក្នុងកាលនោះ ទើបធ្វើឲ្យនាងមានរោគរមាស់ សេចក្តីក្រោធក្តី សេចក្តីប្រណែនក្តី សូម្បីមានប្រមាណតិចតួច មិនគួរធ្វើឡើយ ហើយព្រះសម្ពុទ្ធ ទ្រង់ត្រាស់ព្រះគាថានេះថា

បុគ្គលគួរលះបង់សេចក្តីក្រោធចេញ គួរលះបង់មានះចេញ

គួរកន្ទង់សំយោជនធម៌ទាំងអស់ចោលចេញ ទុក្ខទាំងឡាយតែងមិន
ជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និងរូប មិនមានកិលេស
គ្រឿងកង្វល់នោះឡើយ ។

ត្រង់ព្រះគាថានេះ ព្រះអដ្ឋកថាចារ្យបានអធិប្បាយទុកថា ពាក្យថា
**សេចក្តីក្រោធ** បានដល់ គួរលះបង់សេចក្តីក្រោធគ្រប់ៗ ប្រការ គួរ
លះបង់មានះ គឺសេចក្តីប្រកាន់ខ្លួន ឬសេចក្តីសម្គាល់ខ្លួនថា ជាយ៉ាងនេះ
ជាយ៉ាងនោះជាដើម ។ ពាក្យថា **សំយោជនៈ** ប្រែថា កិលេស ដែលជា
គ្រឿងចងចិត្តសត្វទុកក្នុងវដ្តៈ បានដល់ កាមរាគសំយោជនៈជាដើម ។
ពាក្យថា **អ្នកមិនជាប់** អធិប្បាយថា អ្នកណាមិនប្រកាន់ចំពោះនាមរូបថា
រូបរបស់យើង វេទនារបស់យើងជាដើម កាលនាមរូបនោះ បែកធ្លាយ
ទៅហើយ សេចក្តីសោកសៅ ការក្តៅក្រហាយចិត្តបានកើតឡើងដល់
បុគ្គលនោះៗ ឈ្មោះថា ជាអ្នកជាប់នៅក្នុងនាមរូប ចំណែកអ្នកមិនជាប់
ប្រកាន់យ៉ាងនោះ ឈ្មោះថា មិនជាប់ ។ ពាក្យថា **ទុក្ខទាំងឡាយ
តែងមិនជាប់តាមបុគ្គល ដែលមិនជំពាក់ក្នុងនាម និងរូប** បានដល់

អ្នកមិនមានកង្វល់ ព្រោះមិនមានកិលេស មានរាគៈជាដើម ។ ក្នុងពេលដែលព្រះភគវា ទ្រង់ត្រាស់សម្ដែងព្រះធម៌ទេសនានេះចប់ មានមហាជនជាច្រើនបាន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។សូម្បីព្រះនាងរោហិណី ក៏បានសម្រេចសោតាបត្តិផលផងដែរក្នុងខណៈនោះ ក្រោយពីព្រះនាងបានសម្រេចសោតាបត្តិផលហើយព្រះសរីរៈរបស់ព្រះនាងមានពណ៌សម្បុរដូចជាមាសទៅ ។

ព្រះនាងរោហិណី កាលអស់ព្រះជន្មពីអត្តភាពនេះទៅហើយបានទៅកើតក្នុងវាងចន្លោះខេត្តដែនរបស់ទេវបុត្រទាំង ៤ អង្គ ក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស បានជាទេពធីតា គួរឲ្យជាទីពិចពិលរមិលមើល ព្រោះជាអ្នកមានរូបស្អាតលើសលប់ ។ ទេវបុត្រទាំង ៤ អង្គនោះ កាលបានឃើញនាងហើយ ក៏បានកើតសេចក្ដីស្នេហាចំពោះនាងទាំងអស់គ្នារហូតដល់កើតការវិវាទប្រកែកគ្នាថា នាងកើតនៅក្នុងខេត្តរបស់យើង ។ជាទីបំផុតទេវបុត្រទាំង ៤ អង្គនោះ មិនអាចបែងចែកគ្នាបាន ព្រោះគ្រប់អង្គចង់បាននាងរោហិណីទេពធីតាដូចគ្នា ទើបបាននាំគ្នាទៅគាល់

សក្កទេវរាជ ហើយក្រាបទូលថា បពិត្រទេវរាជ ខ្ញុំព្រះអង្គទាំង ៤ អង្គ បានកើតរឿងក្តីឡើង ព្រោះអាស្រ័យទេពធីតានេះ ហេតុដូច្នេះ សូមព្រះអង្គជួយវិនិច្ឆ័យក្តីនេះ ឲ្យពួកខ្ញុំព្រះអង្គផងចុះ ។ ចំណែកសក្កទេវរាជ លុះទ្រង់ទតព្រះនេត្រឃើញនាងរោហិណីហើយដែរ ក៏កើតសេចក្តីស្នេហា ទើបត្រាស់សួរថា ចាប់តាំងពីពេលដែលអ្នកទាំងអស់គ្នាបានឃើញទេពធីតានេះហើយ ចិត្តរបស់អ្នកទាំងអស់គ្នា មានអាការដូចម្តេច ? ទេវបុត្រអង្គទី ១ ក្រាបទូលថា ចិត្តរបស់ខ្ញុំព្រះអង្គមិនអាចស្ងប់ទៅបាន ដូចជាស្គរនៅក្នុងសង្គ្រាមដូច្នោះដែរព្រះអង្គ ។ ទេវបុត្រអង្គទី ២ ក្រាបទូលថា ចិត្តរបស់ខ្ញុំព្រះអង្គដូចជាក្រសែទឹក ដែលធ្លាក់មកអំពីលើភ្នំដូច្នោះដែរ ព្រះអង្គ ។ ទេវបុត្រអង្គទី ៣ ក្រាបទូលថា ចាប់តាំងពីពេលដែលខ្ញុំព្រះអង្គ បានឃើញនាងទេពធីតានេះហើយ ភ្នែកទាំងសងខាងរបស់ខ្ញុំ បានសម្លឹងមើលនាងលៀនមកខាងក្រៅដូចជាភ្នែកក្តាមទៅហើយ ព្រះអង្គ ។ ទេវបុត្រទី ៤ ក្រាបទូលថា ចិត្តរបស់ខ្ញុំព្រះអង្គមិនអាចនៅស្ងៀមបាន ដូចជាទង់ដែលគេចងនៅលើ

ព្រះចេតិយដូច្នោះដែរ ព្រះអង្គ ។ គ្រានោះ សក្កទេវរាជ បានត្រាស់ប្រាប់សេចក្តីក្នុងព្រះហឫទ័យរបស់ខ្លួនថា ចិត្តរបស់ពួកលោកអាចគ្រប់សង្កត់បាន ចំណែកយើងវិញ ពេលដែលបានឃើញទេពធីតានេះហើយ បើយើងមិនបាននាងទេ យើងនឹងត្រូវស្លាប់ ។ គ្រានោះ ទេវបុត្រទាំង ៤ អង្គនោះ បានស្តាប់ព្រះវាចារបស់សក្កទេវរាជដូច្នេះហើយ ទើបនាំគ្នាក្រាបទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយ មិនត្រូវការឲ្យព្រះអង្គសោយទិវង្គតឡើយ ទើបបាននាំគ្នាលះបង់នាងរោហិណីទេពធីតា ថ្វាយដល់សក្កទេវរាជ ហើយក្រាបទូលលាទៅកាន់ទីកន្លែងដើមវិញ ។ នាងរោហិណីទេពធីតា បានជាទីស្រឡាញ់ពេញចិត្តសព្វព្រះហឫទ័យរបស់សក្កទេវរាជយ៉ាងខ្លាំង ពេលដែលនាងរោហិណីទេពធីតាក្រាបទូលថា ទូលបង្គំនឹងទៅទីកន្លែងឯណោះ ព្រះអង្គ ។ សក្កទេវរាជ ទ្រង់មិនដែលឆ្លើយបដិសេធចំពោះពាក្យរបស់នាងឡើយ តែងតែនាំនាងទៅជារឿយៗ ផង ។៚

( ជីវប្រវត្តិរបស់ព្រះនាងរោហិណី ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាងសុមនារាជកុមារី ✍

## “ ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ ”

ព្រះនាងសុមនារាជកុមារី ទ្រង់ជាឧបាសិកាម្នាក់ ដែលមានអរិយធម៌ ជាគ្រឿងទ្រទ្រង់នូវគុណ ព្រោះតែបានសម្រេចនូវចំណេះចេះដឹង ក្នុងផ្នែកខាងព្រះពុទ្ធសាសនា ប្រៀបដូចជាបរិញ្ញាបត្ររបស់សត្វលោក ជាគ្រឿងសម្តែងបញ្ជាក់អំពីការសិក្សាថា មានលំដាប់យ៉ាងនេះ យ៉ាងនោះជាដើម ។

ជីវប្រវត្តិរបស់ព្រះនាងសុមនារាជកុមារី មានសម្តែងទុកទាំងបច្ចុប្បន្នជាតិ និងអតីតជាតិផងដែរ ចំណែកជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិនេះ មានសម្តែងទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដូចមានសេចក្តីថា ៖

ព្រះនាងសុមនារាជកុមារី ទ្រង់បានមកចាប់បដិសន្ធិនៅក្នុងព្រះគភ៌នៃព្រះអគ្គមហេសីរបស់ព្រះបាទបសេនទិកោសល ។ ក្នុងថ្ងៃដែលព្រះនាងសុមនារាជកុមារី ទ្រង់មកចាប់បដិសន្ធិនោះ ក៏បានមានកុមារី ៥០០ នាក់ មកចុះចាប់បដិសន្ធិនៅក្នុងត្រកូលផ្សេងៗ ផងដែរ ហើយបានប្រសូត

ចាកព្រះគភ៌មាតា ព្រមគ្នានៅក្នុងថ្ងៃតែមួយ ជាមួយនឹងការប្រសូតិចាក ព្រះគភ៌ព្រះមាតារបស់ព្រះនាងសុមនារាជកុមារី ។ ពេលដែលព្រះនាង ប្រសូតិនោះ ក៏មានភ្លៀងផ្កាម្លិះធ្លាក់ចុះមក រហូតដល់ត្រឹមជង្គង់ ។ ព្រះបាទ បសេនទិកោសលទ្រង់ឃើញនិមិត្តយ៉ាងនោះហើយ ទ្រង់ក៏រិះរកក្នុង ព្រះហឫទ័យថា ព្រះរាជធីតារបស់យើង ជាអ្នកមានបុណ្យច្រើនណាស់ ទើបទ្រង់ត្រាស់ថា ព្រះរាជធីតារបស់យើងបានកាន់យកឈ្មោះមកព្រម ជាមួយការប្រសូតិហើយ ទើបបានព្រះរាជទានព្រះនាមថា **សុមនា** (ដោយ ព្រះអង្គទ្រង់កាន់យកនូវផ្កាម្លិះជានិមិត្តធ្លាក់ចុះមក ពាក្យថា **សុមនា** ប្រែថា ផ្កាម្លិះ) ក្រោយពីព្រះបាទបសេនទិកោសលព្រះរាជទានព្រះនាមដល់ព្រះ រាជធីតាហើយ បានមានព្រះរាជឱង្ការថា ព្រះរាជធីតារបស់យើងគង់ នឹងមិនមកកើតតែម្នាក់ឯងទេ ហេតុដូច្នេះ ពួកលោកទាំងឡាយចូរទៅ ស៊ើបមើលក្នុងក្រុងនេះថា តើមានធីតារបស់អ្នកណាខ្លះ ដែលកើតក្នុងថ្ងៃ ជាមួយនឹងព្រះរាជធីតារបស់យើង ។ បុគ្គលទាំងនោះក៏ទទួលព្រះរាជឱង្ការ ហើយ បាននាំគ្នាទៅស៊ើបរកមើល ក៏បានជួបនឹងទារិកា ៥០០ នាក់

ដែលកើតក្នុងថ្ងៃជាមួយគ្នានឹងព្រះរាជធីតា ទើបប្រញាប់ទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប កាលបើព្រះរាជាទ្រង់ជ្រាបហើយ ព្រះរាជាក៏បានត្រាស់បញ្ជាឲ្យអ្នកជាមាតាបិតាចិញ្ចឹមទារិកា ទាំងនោះទុកឲ្យបានល្អដោយបានគ្រប់មួយខែៗ ចូរនាំទារិកាទាំងនោះ មករកព្រះរាជធីតារបស់យើង ។ ចំណែកព្រះនាងសុមនារាជកុមារី ទ្រង់មានព្រះនាមយ៉ាងនេះព្រោះទ្រង់ធ្វើសក្ការបូជាយ៉ាងធំមកហើយ ថែមទាំងបានតាំងសេចក្តីប្រាថ្នាទុកក្នុងជាតិមុនមកហើយ ទើបបានទទួលផល ក្នុងបច្ចុប្បន្នជាតិយ៉ាងនេះទៅបាន ។

លុះកាលតមក ព្រះនាងសុមនារាជកុមារី មានព្រះជន្មាយុបាន ៧ ខួប អនាថបិណ្ឌិកសេដ្ឋីបានចាត់ចែងកសាងវត្តជេតពនរួចជាស្រេចហើយ បានប្រើឲ្យមនុស្សទៅក្រាបទូលអារាធនាព្រះសម្ពុទ្ធ សូមស្តេចយាងមកកាន់ក្រុងសាវត្ថី ។ ព្រះសាស្តា ព្រមដោយភិក្ខុសង្ឃជាបរិវារយ៉ាងច្រើន បានស្តេចយាងមកកាន់ក្រុងសាវត្ថី ។ រីឯអនាថបិណ្ឌិកសេដ្ឋីបានចូលទៅគាល់ព្រះបាទបសេនទិកោសល ហើយក្រាបទូលថា បពិត្រ

តេជះជីវិតតម្កល់លើត្បូង កាលដែលព្រះពុទ្ធជាម្ចាស់ស្តេចយាងមកកាន់ក្រុងនេះ រាប់ថាជាមង្គលរបស់ខ្ញុំព្រះអង្គ និងជាមង្គលរបស់ព្រះអង្គផងដែរ ព្រោះហេតុដូច្នោះ សូមព្រះអង្គមេត្តាឲ្យព្រះនាងសុមនារាជកុមារី ព្រមទាំងទារិកា ៥០០ នាក់ កាន់ឃ្លោកទឹក គ្រឿងក្រអូប និងផ្កាកម្រងជាដើម ទៅចាំទទួលព្រះលោកនាយកផងចុះ ។ ព្រះបាទបសេនទិកោសល ទ្រង់បានស្តាប់ពាក្យក្រាបទូលសូមដូច្នេះហើយ ទ្រង់បានត្រាស់ថា ល្អហើយលោកសេដ្ឋី ហើយព្រះអង្គទ្រង់ក៏បានធ្វើតាមពាក្យទូលសូមរបស់អនាថបិណ្ឌិកសេដ្ឋី ។ ចំណែកព្រះនាងសុមនារាជកុមារី ស្តេចបានយាងទៅតាមព្រះរាជបញ្ជា ព្រមដោយទារិកាជាបរិវារ ៥០០ នាក់ទៀត ពេលដែលព្រះនាងសុមនារាជកុមារី ព្រមដោយបរិវាររបស់ខ្លួន ទៅជួបព្រះលោកនាថហើយ បានថ្វាយបង្គំព្រះពុទ្ធអង្គ ថែមទាំងបានធ្វើការបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម រួចព្រះនាងព្រមដោយបរិវារបានទៅឈរនៅក្នុងទីកន្លែងដ៏សមគួរ ។ គ្រានោះ ព្រះទសពល ទ្រង់បានសម្តែងព្រះធម៌ប្រោសទៅតាមឧបនិស្ស័យរបស់បុគ្គលទាំងនោះ ។ ចំណែក

ព្រះនាងសុមនារាជកុមារី និងបរិវារ ៥០០ នាក់ កាលបានស្តាប់ព្រះធម៌ទេសនានោះចប់ហើយ ក៏បានសម្រេចសោតាបត្តិផលក្នុងខណៈនោះឯង ។ នៅក្នុងថ្ងៃនោះ មានអ្នកបានសម្រេចអរិយធម៌ ជាព្រះសោតាបន្នដល់ទៅ ២ ពាន់នាក់ ក្នុងវាំងផ្លូវដែលព្រះលោកនាថស្តេចយាងមក ។

ការសព្វព្រះទ័យរបស់ព្រះនាងសុមនារាជកុមារី ទាក់ទងនឹងការប្រព្រឹត្តបដិបត្តិសីលធម៌ថា នឹងមានសេចក្តីផ្សេងគ្នាយ៉ាងណាខ្លះ រវាងបុគ្គលពីរនាក់ ព្រះនាងទើបស្តេចយាងទៅគាល់ព្រះពុទ្ធអង្គ ដើម្បីក្រាបទូលសួរព្រះលោកនាយក តាមដែលមានរឿងសម្តែងទុកក្នុងព្រះបាលី **សុមនសូត្រ ក្នុង គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត នៃ សុមនវគ្គទី ៤** ដូចមានសេចក្តីថា ៖

គ្រានោះ ព្រះនាងសុមនារាជកុមារី មានរថ ៥០០ និងរាជកុមារី ៥០០ នាក់ បានហែហមចូលទៅគាល់ព្រះលោកនាថ លុះចូលទៅដល់បានថ្វាយបង្គំព្រះមហាមុនី ហើយគង់ប្រថាប់នៅក្នុងទីដ៏សមគួរ ។ កាលព្រះនាងសុមនារាជកុមារី ប្រថាប់នៅក្នុងទីដ៏សមគួរ ហើយបានក្រាបទូល

សួរព្រះមហាវីរបុរសដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សាវកពីររូបរបស់ព្រះមានបុណ្យនៅក្នុងព្រះសាសនានេះ មានសទ្ធាស្មើគ្នា មានបញ្ញាស្មើគ្នា ប៉ុន្តែមួយអង្គជាទាយក មួយអង្គមិនមែនជាទាយក សាវកទាំងនោះពេលដែលបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក បពិត្រព្រះអង្គដ៏ចម្រើន សាវកទាំងពីរដែលកើតជាទេវតានោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ព្រះអង្គ ? ព្រះមុនីត្រាស់ថា ម្នាលនាងសុមនាមានដែរ ។ ម្នាលនាងសុមនា សាវកណាជាទាយក សាវកនោះដល់ពេលបានទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះដែលមិនមែនជាទាយក ដោយហេតុ ៥ ប្រការ គឺអាយុជាទិព្វ ១ សម្បុរជាទិព្វ ១ សុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ ។ ម្នាលនាងសុមនា សាវកណាជាទាយក សាវកនោះដល់ពេលទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ ប្រការនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើទេវតាទាំងពីរនោះច្យុតអំពីទេវលោកនោះមកកើតជាមនុស្សនេះវិញ បពិត្រព្រះអង្គដ៏ចម្រើន

បុគ្គលទាំងពីរនោះ ដែលកើតជាមនុស្សហើយ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាយ៉ាងណាដែរឬទេ ព្រះអង្គ ? ព្រះវិជិតមារត្រាស់ថា ម្នាលនាងសុមនាមានដែរ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះ ដល់ពេលបានមកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ ប្រការ គឺអាយុជារបស់មនុស្ស ១ សម្បុរជារបស់មនុស្ស ១ សុខជារបស់មនុស្ស ១ យសជារបស់មនុស្ស ១ អធិបតីជារបស់មនុស្ស ១ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់ពេលបានមកកើតជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ ប្រការនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើអ្នកទាំងពីរនោះចេញចាកផ្ទះមកកាន់ផ្នួស បពិត្រព្រះអង្គដ៏ចម្រើន បព្វជិតទាំងនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ព្រះអង្គ ? ព្រះសក្យមុនិត្រាស់ថា ម្នាលនាងសុមនាមានដែរ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះ លុះដល់បានបួសហើយ រមែងគ្របសង្កត់បព្វជិតឯណោះ ដែលមិនមែនជាទាយក

ដោយហេតុ ៥ ប្រការ មានអ្នកដទៃអង្វរឲ្យទទួលនូវចីវរច្រើនៗ មិនមានអ្នកដទៃឲ្យ សូមទទួលនូវចីវរតិចៗ ឡើយ ១ មានអ្នកដទៃអង្វរឲ្យទទួលនូវចង្ហាន់បិណ្ឌបាតច្រើនៗ មិនមានអ្នកដទៃឲ្យសូមទទួលនូវចង្ហាន់បិណ្ឌបាតតិចៗ ឡើយ ១ មានអ្នកដទៃអង្វរឲ្យទទួលនូវសេនាសនៈច្រើនៗ មិនមានអ្នកដទៃឲ្យសូមទទួលនូវសេនាសនៈតិចៗ ឡើយ ១ មានអ្នកដទៃអង្វរឲ្យទទួលនូវភេសជ្ជៈច្រើនៗ មិនមានអ្នកដទៃឲ្យសូមទទួលនូវភេសជ្ជៈតិចៗ ឡើយ ១ ប្រសិនបើនៅរួមជាមួយសព្រហ្មចារីពួកណា សព្រហ្មចារីពួកនោះ រមែងរាប់អានភិក្ខុនោះ ដោយកាយកម្ម វចីកម្ម មនោកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តមានតិច រមែងនាំវត្ថុដែលជាទីគាប់ចិត្តមកឲ្យជាច្រើន រមែងនាំវត្ថុដែលមិនជាទីគាប់ចិត្តមកឲ្យមានតិចតួច ១ ។ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់បានបួសហើយ រមែងគ្របសង្កត់នូវបព្វជិតឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ ប្រការនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបើបព្វជិតទាំងពីររូបនោះបានសម្រេចជាព្រះអរហន្តវិញ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបព្វជិត

ទាំង ២ រូប ដែលបានសម្រេចជាព្រះអរហន្តហើយនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ព្រះអង្គ ? ម្នាលនាងសុមនា ត្រង់រឿងនោះតថាគតមិនសម្តែងហេតុផ្សេងគ្នា ត្រង់ចិត្តដែលរួចស្រឡះដោយវិមុត្តិនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលគួរឲ្យទានទាំងឡាយមែន បុគ្គលគួរធ្វើបុណ្យទាំងឡាយមែន ព្រោះថា បុណ្យទាំងឡាយជាឧបការៈដល់អ្នកដែលទៅកើតជាទេវតាផង ដែលទៅកើតជាមនុស្សផង ឬដល់អ្នកបួសផងដែរ ។ ម្នាលនាងសុមនា ហេតុនោះយ៉ាងនេះឯង ម្នាលនាងសុមនា ហេតុនោះយ៉ាងនេះឯង ម្នាលនាងសុមនា បុគ្គលគួរឲ្យទានទាំងឡាយ គួរធ្វើបុណ្យទាំងឡាយ ព្រោះថា បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលទៅកើតជាទេវតាផង ជាមនុស្សផង ដល់អ្នកបួសផងដែរ ។ ព្រះភគវាបានត្រាស់ពាក្យនេះ លុះព្រះសុគតបានត្រាស់ពាក្យនេះចប់ហើយ ព្រះសាស្តា បានត្រាស់ពាក្យជាគាថាទាំងនេះតទៅទៀតថា

ព្រះច័ន្ទប្រាសចាកមន្ទិល កាលចរទៅតាមអាកាស រមែងរុងរឿងលើសជាងពួកផ្កាយទាំងអស់លើអាកាស ដោយពន្លឺរបស់ខ្លួនយ៉ាងណាមិញ បុរសបុគ្គលមានសទ្ធា បរិបូណ៌ដោយសីល រមែងរុងរឿងជាងពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោក ដោយចាគៈក៏យ៉ាងនោះដែរ ។ កាលភ្លៀងប្រកបដោយផ្គរបន្ទោរដ៏ច្បាស់ បរិបូណ៌ដោយភ្នំទឹកដ៏ច្រើនបង្អុរចុះមក ពេញលើផែនដី កន្លែងដែលខ្ពស់ទាបឲ្យពោរពេញ យ៉ាងណាមិញ សាវករបស់ព្រះសម្មាសម្ពុទ្ធ ដែលបរិបូណ៌ដោយទស្សនៈជាបណ្ឌិត រមែងគ្របសង្កត់នូវបុគ្គល ដែលជាអ្នកមានសេចក្តីកំណាញ់ដោយហេតុ ៥ ប្រការ ដោយអាយុ វណ្ណៈ សុខ យស និងអធិបតី បណ្ឌិតនោះឯង បរិបូណ៌ដោយភោគៈ ដល់ទៅលោកខាងមុខ រមែងរីករាយក្នុងស្ថានសួគ៌ ក៏ដូច្នោះដែរ ។

ដោយហេតុដែលព្រះនាងសុមនារាជកុមារី ទ្រង់មានបំណងនឹងក្រាបទូលសួរបញ្ហាចំពោះព្រះសាស្តានេះ មានរឿងពោលទុកនៅក្នុងអដ្ឋកថាមនោរថបូរណី ដូចមានសេចក្តីថា ៖

មានពាក្យសួរថា ព្រោះហេតុអ្វី ក្នុងព្រះបាលីទើបពោលទុកថា គ្រានោះ ព្រះនាងសុមនារាជកុមារី បានចូលទៅគាល់ព្រះមានជោគ ដោយក្បួនរាជរថដល់ទៅ ៥០០ ដែលមានរាជកុមារី ៥០០ នាក់ ប្រថាប់លើរាជរថចោមរោមហែហមព្រះនាងទៅ ។ មានពាក្យឆ្លើយថា ព្រោះព្រះនាងសុមនារាជកុមារី ទ្រង់មានព្រះបំណងក្រាបទូលសួរបញ្ហា តាមដែលព្រះនាងធ្លាប់ស្តាប់មក ។ បានឮមកថា ក្នុងពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ មានភិក្ខុពីររូបជាសម្លាញ់នឹងគ្នា ។ បណ្តាភិក្ខុពីររូបនោះ មួយរូបបំពេញសារាណីយធម៌ ( ធម៌ដែលប្រព្រឹត្តទៅ ដើម្បីការរឭកដល់គ្នានិងគ្នា គឺធ្វើឲ្យមានការគោរពគ្នា អនុគ្រោះគ្នា និងការព្រមព្រៀងសាមគ្គីគ្នា មាន ៦ ប្រការ ) ចំណែកភិក្ខុមួយរូបទៀត ជាអ្នកបំពេញនូវភត្តគ្គវត្ត ( ខ.គួរបដិបត្តិក្នុងរោងឆាន់ ឬទំនៀមក្នុងរោងអាហារដែលលោកចាត់ចូលក្នុងកិច្ចវត្តម្យ៉ាង ដូចជាស្លៀកដណ្តប់ឲ្យសមរម្យ ឬដឹងអាសនៈឲ្យសមគួរដល់ខ្លួនជាដើម ) ។ ភិក្ខុមួយរូបដែលបំពេញនូវសារាណីយធម៌ បាននិយាយជាមួយនឹងភិក្ខុដែលជាសម្លាញ់ជាអ្នក

បំពេញនូវកត្តគ្គវត្តថា លោកដ៏មានអាយុ ទានដែលឲ្យមិនមានផល រមែងមិនមាន យើងគួរឲ្យរបស់ដែលយើងបាន មកដល់អ្នកដទៃជាមុន ហើយ ទើបបរិភោគក្នុងកាលជាខាងក្រោយ ទើបជាការល្អ ។ចំណែក ភិក្ខុដែលជាអ្នកបំពេញនូវកត្តគ្គវត្ត បានពោលថា លោកដ៏មានអាយុ លោកមិនដឹងឬ ការដែលយើងនឹងធ្វើឲ្យខូចទេយ្យធម៌របស់អ្នកស្រុក រមែងមិនគួរ យើងគួរទទួលល្មមចិញ្ចឹម ជីវិតរបស់យើងឲ្យប្រព្រឹត្តទៅ បានហើយៗ ធ្វើវត្តក្នុងរោងឆាន់ ទើបជាការល្អ ។ ក្នុងបណ្ដាភិក្ខុទាំង ពីររូបនោះ មួយរូបៗ ក៏មិនអាចធ្វើឲ្យភិក្ខុមួយរូបទៀត តាំងនៅក្នុង ឱវាទរបស់ខ្លួនបាន ដោយប្រកាន់ថា ខ្លួនល្អហើយ ។ កាលតមក ភិក្ខុទាំងពីររូបនោះ បានធ្វើមរណភាពពីជាតិនោះទៅ ក៏បានទៅកើត ក្នុងទេវលោក ។ ក្នុងបណ្ដាភិក្ខុទាំងពីររូបនោះ ភិក្ខុដែលជាអ្នកបំពេញ នូវសារាណីយធម៌ ជាអ្នកប្រសើរជាងភិក្ខុដែលជាអ្នកបំពេញនូវកត្តគ្គវត្ត ដោយឋានៈ ៥ ប្រការ ដូចដែលបានពោលពីខាងលើរួចមកហើយ ។ ភិក្ខុទាំងពីររូបនោះស្លាប់កើតៗ ស្លាប់ជាមនុស្ស និងទេវតារហូតមួយ

ពុទ្ធន្តរ ។ លុះមកដល់ពុទ្ធកាលព្រះបរមគ្រូនៃយើងនេះ ទើបបានមក កើតនៅក្នុងក្រុងសាវត្ថី ។ ភិក្ខុដែលជាអ្នកបំពេញនូវសាវកណីយធម៌ ក៏បានមកចាប់បដិសន្ធិនៅក្នុងព្រះគភ៌ នៃព្រះអគ្គមហេសីរបស់ព្រះបាទ បសេនទិកោសល ។ ចំណែកភិក្ខុមួយរូបទៀត ដែលជាអ្នកបំពេញ នូវភត្តគ្គវត្ត បានមកចាប់បដិសន្ធិនៅក្នុងគភ៌ នៃស្ត្រីអ្នកបម្រើរបស់ ព្រះអគ្គមហេសី នៃព្រះបាទបសេនទិកោសល ។ បុគ្គលទាំងពីរនោះ បានមកកើតក្នុងថ្ងៃជាមួយគ្នា ។ ក្នុងថ្ងៃដែលថ្វាយព្រះនាមឲ្យព្រះរាជកុមារ និងដាក់ឈ្មោះឲ្យកុមារនោះ មនុស្សទាំងឡាយ បាននាំគ្នាងូតទឹកជម្រះ កាយឲ្យព្រះរាជកុមារ និងកុមារនោះឲ្យស្អាត ។ រីឯព្រះមាតា និងមាតា បានចាត់ចែងនូវរង្វាន់ សម្រាប់ចែកដល់មនុស្សទាំងឡាយដែលនៅ ខាងក្រៅ ។ ព្រះរាជកុមារ ដែលនៅក្នុងអតីតជាតិ ជាភិក្ខុអ្នកបំពេញ នូវសាវកណីយធម៌ លុះបើកភ្នែកបានឃើញស្វេតច្ឆត្រធំនៅក្នុងកន្ទេនផ្ទុំ ប្រកបដោយសិរីដែលគេបានរៀបចំទុកយ៉ាងល្អនិងនិវេសន៍ដែលប្រដាប់ ដោយគ្រឿងអលង្ការ ក៏បានដឹងថា យើងបានកើតក្នុងរាជត្រកូលហើយ

ទើបនឹកតទៅទៀតថា យើងធ្វើកម្មអ្វីទុក ទើបបានមកកើតក្នុងទីនេះ ហើយក៏ដឹងថា យើងបានបំពេញនូវសារាណីយធម៌ទុក រួចក៏បានបែរមកនឹកដល់សម្លាញ់ថា សម្លាញ់របស់យើងទៅកើតក្នុងទីណាហ្ន៎ ក៏បានឃើញគេដេកនៅទីទាបជាងខ្លួន ទើបគិតថា សម្លាញ់របស់យើងរវល់តែបំពេញកត្តគ្គវត្ត គឺធ្វើវត្តក្នុងរោងឆាន់ មិនព្រមស្តាប់ពាក្យរបស់យើងឥឡូវនេះ យើងនឹងពោលសង្កត់សង្កិនគេនៅក្នុងទីនេះ ហើយព្រះរាជកុមារបានពោលឡើងថា សម្លាញ់ៗ មិនព្រមធ្វើតាមពាក្យរបស់យើង កុមារនោះតបថា បើដូច្នេះ នឹងកើតមានអ្វី ព្រះរាជកុមារពោលថា សម្លាញ់ចូរមើលសម្បត្តិរបស់យើង ដែលយើងបានផ្ទំលើព្រះបន្ទំដ៏មានសិរីនៅក្រោមស្វេតច្ឆត្រ ចំណែកសម្លាញ់វិញ បានមកដេកនៅលើគ្រែទាបដែលក្រាលដោយរបស់រឹង កុមារនោះពោលជំទាស់ថា ហេតុអ្វីបានជាលោកមានមានះ ព្រោះអាស្រ័យរបស់ទាំងអស់នោះ សុទ្ធតែជារបស់ដែលគេធ្វើដោយចម្រៀកឫស្សី រុំព័ទ្ធដោយក្រណាត់ ប្រឡាក់អាចម៍ខ្ទប់ទុក គ្រាន់តែជាបឋវីធាតុពិតមែនឬ ចំណែកព្រះនាងសុមនារាជធីតា

ទ្រង់បានស្តាប់ពាក្យរបស់ព្រះរាជកុមារ ដែលបានសន្ទនាគ្នាហើយ យ៉ាងនេះ ទើបទ្រង់មានព្រះតម្រិះថា អ្នកដទៃ មិនមាននៅទីជិតទារក ទាំងពីរនោះទេ ទើបព្រះនាងស្តេចយាងចូលទៅក្បែរទារកទាំងពីរនោះ ហើយទ្រង់ឈរផ្អែកទ្វារអែបចាំ ទ្រង់បានស្តាប់ឮពាក្យថា ធាតុ ហើយ ទ្រង់ព្រះតម្រិះថា ពាក្យថា ធាតុ នេះមិនមែន មានឮនៅខាងក្រៅទេ ទារកទាំងពីរនេះ គង់ជាសមណទេវបុត្រហើយមើលទៅ ហើយទ្រង់ ព្រះតម្រិះតទៅទៀតថា ប្រសិនបើយើងនឹងក្រាបទូលសេចក្តីនេះដល់ ព្រះរាជមាតា និងព្រះរាជបិតា អំពីការសន្ទនាគ្នា រវាងទារកទាំងពីរ នាក់នេះ ព្រះរាជមាតា និងបិតា ប្រាកដជាត្រាស់បញ្ជាឲ្យយកទារក ទាំងពីរនេះទៅចោលមិនខាន ដោយទ្រង់យល់ក្នុងព្រះទ័យថា ទារកទាំង ពីរនេះជាអមនុស្ស ហេតុដូច្នេះ យើងនឹងមិនប្រាប់រឿងហេតុទាំងអស់ នេះដល់អ្នកដទៃឡើយ យើងនឹងទៅគាល់ក្រាបទូលព្រះមានព្រះភាគ ទ្រង់ជាព្រះពុទ្ធគោត្រជាម្ចាស់ ដែលជាព្រះពុទ្ធបិតារបស់យើង ទ្រង់ជា អ្នកកាត់សេចក្តីសង្ស័យរបស់ទេវតា និងមនុស្សទាំងអស់បាន លុះព្រះ

នាងទ្រង់បានព្រះតម្រិះឃើញដូច្នេះហើយ ក្រោយពីបានសោយព្រះក្រយាហារពេលព្រឹករួចស្រេច ទើបស្តេចយាងចូលទៅគាល់ព្រះរាជបិតា ដើម្បីក្រាបទូលសូមអនុញ្ញាត ចូលទៅគាល់ព្រះសាស្តា ។ ព្រះបាទបសេនទិកោសល ទើបទ្រង់ត្រាស់បញ្ជាឲ្យរៀបចំទឹមរាជរថ ៥០០ ។ សេចក្តីពិតក្នុងពេលនោះ នៅក្នុងជម្ពូទ្វីប មានកុមារីត្រឹមតែ ៣ នាក់ប៉ុណ្ណោះ ដែលមានរថ ៥០០ ក្នុងសម្នាក់របស់បិតាទាំងឡាយ បានដល់ព្រះនាងចុន្ទីរាជធីតារបស់ព្រះបាទពិម្ពិសារ ១ នាងវិសាខាដែលជាធីតារបស់ធនញ្ជយសេដ្ឋី ១ ព្រះនាងសុមនារាជធីតារបស់ព្រះបាទបសេនទិ-កោសល ១ ។ ព្រះនាងសុមនារាជធីតា ទ្រង់បានកាន់យកគ្រឿងក្រអូបនិងផ្កាកម្រងហើយ ប្រថាប់ឈរនៅលើរាជរថ ដែលមានរថ ៥០០ ជាបរិវារ ព្រះនាងបានយាងទៅគាល់ព្រះលោកនាថ ដោយទ្រង់ព្រះតម្រិះថា យើងនឹងក្រាបទូលសួរបញ្ហានេះ លុះព្រះនាងស្តេចយាងទៅដល់ហើយ ទ្រង់ទើបបានក្រាបទូលសួរបញ្ហានោះ ដូចពោលរួចមកហើយ នៅខាងដើម ។

ជីវប្រវត្តិនៅក្នុងអតីតជាតិ របស់ព្រះនាងសុមនារាជកុមារី ដែលបានពោលដល់ចរិយាវត្ត ដែលព្រះនាងធ្លាប់បានធ្វើទុកមកពីមុន តាមដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាមនោរថបូរណី** ថា ៖

ព្រះនាងសុមនារាជកុមារី ដែលទ្រង់មានព្រះនាមយ៉ាងនេះ ព្រោះព្រះនាងធ្លាប់បានធ្វើសក្ការៈទុកមកជាច្រើន ហើយទ្រង់បានតាំងសេចក្តីប្រាថ្នាទុកដើម្បីឲ្យបានព្រះនាមដូច្នេះ មានសេចក្តីពិស្តារក្នុងរឿងនេះថា ក្នុងសម័យពុទ្ធកាលនៃព្រះវិបស្សីសម្ពុទ្ធ ពេលនោះ ពួកមហាជនបានប្រឹក្សាគ្នាថា ពួកយើងនឹងព្រមព្រៀងគ្នាទប់ទល់ព្រះរាជា ដើម្បីដណ្តើមយកការថ្វាយទាន ដល់ព្រះពុទ្ធអង្គឲ្យទាល់តែបាន ជាទីបំផុតក៏បានដូចបំណងមែន ហើយបាននាំគ្នានិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដោយអាស្រ័យសេនាបតីម្នាក់ ទើបនាំគ្នាប្រារព្ធធ្វើនូវបុណ្យនោះឡើង ។ ក្នុងថ្ងៃដំបូងបង្អស់នៃការធ្វើបុណ្យ ជាភារៈរបស់លោកសេនាបតី ( ជាអ្នករួមដៃគ្នា ក្នុងការក្រាបទូលសូមព្រះរាជានុញ្ញាត ដើម្បីសូមព្រះពុទ្ធមកថ្វាយទាន ) ។ ក្នុងថ្ងៃដំបូងនោះ

លោកសេនាបតីបានចាត់ចែងទានរួចហើយ បានបញ្ជាឲ្យបុរសរក្សា សន្តិសុខថា ថ្ងៃនេះ ពួកលោកចូរមើលកិច្ចការងារក្នុងការធ្វើនេះឲ្យបានល្អ ដោយមិនឲ្យអ្នកណាម្នាក់ បានថ្វាយទានមុនយើងឡើយ ។ ក្នុងថ្ងៃនោះ មានកិរិយារបស់លោកសេដ្ឋីម្នាក់បានយំសោក ព្រោះតែចង់បរិច្ចាគទាន ដល់ព្រះបរមគ្រូ លុះបានឃើញធីតា ដែលបានទៅដើរលេងជាមួយ នឹងស្ត្រី ៥០០ នាក់ បានត្រឡប់មកដល់ផ្ទះវិញ ទើបបានជានិយាយ ប្រាប់កូនថា កូនសម្លាញ់ ថ្ងៃនេះម៉ែបំណងថ្វាយទានដល់ព្រះពុទ្ធមុន អ្នកដទៃ ប៉ុន្តែមិនដឹងធ្វើយ៉ាងណាបានថ្វាយទានមុនគេទេ ។ គ្រានោះ កូនស្រីបាននិយាយនឹងមាតាថា បពិត្រអ្នកម៉ែ សូមអ្នកម៉ែកុំព្រួយឡើយ កូននឹងរកវិធីឲ្យភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ឆាន់អាហាររបស់ យើងមុនគេឲ្យទាល់តែបាន ។តពីនោះមក នាងទើបដួសបាយបាយាស ដាក់ទៅក្នុងថាសមាស ដែលមានតម្លៃមួយសែនកហាបណៈ ដោយ លាយជាមួយនឹងទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅជាដើមពេញក្នុងថាស មាសហើយ បាននាំយកថាសមាសមួយទៀតមកគ្របពីលើ រួចយក

កម្រងផ្កាម្លិះមករុំព័ទ្ធកាជនៈនោះឡើង ធ្វើឲ្យស្រដៀងដូចគ្នានឹងកម្រងផ្កាម្លិះរួចហើយ ។ លុះដល់ពេលដែលព្រះវិបស្សីសម្ពុទ្ធ កំពុងស្តេចយាងចូលទៅក្នុងស្រុក នាងលើកកាជនៈនោះឡើងដាក់ទូលនៅលើក្បាលព្រមដោយពួកទាសីដើរចេញពីផ្ទះទៅ ។ ពេលដែលនាងដើរទៅដល់វាំងផ្លូវ ពួកបុរសទទួលបម្រើរបស់លោកសេនាបតីបាននិយាយថា នែនាង កុំដើរមកផ្លូវនេះ ។ ធម្មតាអ្នកមានបុណ្យច្រើន រមែងមានវាចាពីរោះ ពេលបុរសអ្នកទទួលបម្រើរបស់លោកសេនាបតីនិយាយហាមហើយ ហាមទៀត ក៏មិនមាននរណាបដិសេធពាក្យរបស់ស្ត្រីអ្នកមានបុណ្យបាន ព្រោះហេតុនោះ ធីតារបស់លោកសេដ្ឋីបានសួរឡើងថា បពិត្រលោកពូ លោកអ៊ំ តើមានហេតុអ្វី ទើបអ្នកមិនឲ្យនរណាៗ ចូលទៅក្នុងផ្លូវនេះបាន ពួកបុរសអ្នកទទួលបម្រើទាំងនោះបានឆ្លើយថា នែនាង ពួកយើងជាអ្នកដែលលោកសេនាបតីបញ្ជាថា មិនឲ្យនរណាៗ បានថ្វាយអាហារបិណ្ឌបាតដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធានមុនដាច់ខាត ។ គ្រានោះ សេដ្ឋីធីតាទើបពោលឡើងថា

តើពួកលោកបានឃើញនូវអាហារបិណ្ឌបាតក្នុងដៃរបស់ខ្ញុំឬទេ ? ពួកបុរសទាំងនោះឆ្លើយថា មិនបានឃើញអាហារបិណ្ឌបាតទេ បានឃើញតែកម្រងផ្កាម្លិះតែប៉ុណ្ណោះ ។ សេដ្ឋីធីតាសួរថា លោកសេនាបតីរបស់ពួកលោកបានហាមដល់ការបូជាផ្កាឬទេ ? ពួកបុរសអ្នកបម្រើឆ្លើយថា មិនហាមទេ ហេតុដូច្នេះ នាងចូរបូជាទៅចុះ ។ សេដ្ឋីធីតាទើបពោលថា បើដូច្នោះ អ្នកទាំងឡាយចូរចៀសចេញ ហើយនាងបានចូលទៅគាល់ព្រះភគវា បានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសុគតទ្រង់ទទួលនូវកម្រងផ្កាម្លិះនេះផងចុះ ព្រះអង្គ ។ ព្រះវិបស្សីសម្ពុទ្ធ ទ្រង់បានទតមើលបុរសអ្នកទទួលបម្រើរបស់លោកសេនាបតីម្នាក់ ហើយឲ្យទទួលកម្រងផ្កាម្លិះនេះទុក ។ សេដ្ឋីធីតាបានថ្វាយបង្គំព្រះវិបស្សីសម្ពុទ្ធ ហើយ បានតាំងសេចក្តីប្រាថ្នាថា ពេលខ្ញុំព្រះអង្គអន្ទោលទៅក្នុងភពតូចនិងភពធំ សូមកុំឲ្យមានជីវិតរស់នៅដោយសេចក្តីលំបាកឡើយ សូមឲ្យខ្ញុំព្រះអង្គ ជាទីស្រឡាញ់ពេញចិត្ត រប់អានរបស់មនុស្សទាំងឡាយដូចជាកម្រងផ្កាម្លិះនេះ សូមឲ្យមានឈ្មោះថា **សុមនា** ព្រះអង្គ ។

គ្រានោះ ព្រះវិបស្សីសម្ពុទ្ធត្រាស់ថា នាងចូរមានសេចក្ដីសុខចុះ ។ សេដ្ឋីធីតាបានថ្វាយបង្គំហើយ ធ្វើប្រទក្សិណព្រះវិបស្សីសម្ពុទ្ធ រួចក្រាបថ្វាយបង្គំលាត្រឡប់ទៅវិញ ។ ពេលនោះ ព្រះវិបស្សីសម្ពុទ្ធក៏បានស្ដេចយាងទៅកាន់ផ្ទះរបស់លោកសេនាបតី គង់ប្រថាប់លើអាសនៈដែលគេរៀបចំទុកថ្វាយ ។ ចំណែកលោកសេនាបតី បានលើកយកបបរបង្អែមមកថ្វាយដល់ព្រះវិបស្សីសម្ពុទ្ធ ។ លំដាប់នោះ ព្រះវិបស្សីសម្ពុទ្ធទ្រង់យកព្រះហស្ដបិទបាត្រ លោកសេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃគង់រៀបរយហើយ ព្រះអង្គ ។ ព្រះវិបស្សីសម្ពុទ្ធទើបទ្រង់ត្រាស់ថា ម្នាលសេនាបតី តថាគតបានទទួលចង្ហាន់បិណ្ឌបាត ក្នុងរវាងផ្លូវហើយ ។ លោកសេនាបតី ទើបលើកកម្រងផ្កាម្លិះនោះ ចេញពីភាជនៈនោះ ក៏បានឃើញចង្ហាន់បិណ្ឌបាតនៅក្នុងភាជនៈនោះមែន ។ ពេលនោះ អ្នកទទួលបម្រើជិតស្និទ្ធប្រាប់ថា បពិត្រលោក នាយមានស្ត្រីម្នាក់បញ្ឆោតខ្ញុំថា ជាកម្រងផ្កាម្លិះ ទើបខ្ញុំឲ្យឱកាស ដល់នាងថ្វាយបាយបាយាស ( ដែលសេដ្ឋីធីតាថ្វាយ ) នោះ

ល្មមគ្រប់គ្រាន់ដល់ភិក្ខុសង្ឃទាំងឡាយ ដែលមានព្រះពុទ្ធជាប្រធាន នៅក្នុងទីនោះឯង ។ចំណែកលោកសេនាបតី បានថ្វាយទេយ្យធម៌របស់ខ្លួន ក្នុងកាលជាខាងក្រោយទៅ ។ ព្រះវិបស្សីសម្ពុទ្ធ កាលឆាន់រួចជាស្រេច ហើយ បានត្រាស់អនុមោទនាមង្គលកថាចប់ ទើបស្តេចយាងត្រឡប់ ទៅវិញ ហើយលោកសេនាបតីទើបសួរថា ស្ត្រីដែលបានថ្វាយចង្ហាន់ បិណ្ឌបាតនោះជានរណា ? អ្នកបម្រើឆ្លើយថា ជាធីតារបស់លោកសេដ្ឋី ។ លោកសេនាបតីគិតថា ស្ត្រីនេះជាអ្នកមានបញ្ញាច្រើន ពេលដែលនាង នៅក្នុងផ្ទះរបស់អ្នកណា ផ្ទះរបស់អ្នកនោះ នឹងបានសម្បត្តិសួគ៌ដោយ មិនលំបាកឡើយ ទើបឲ្យមនុស្សទៅនាំសេដ្ឋីធីតានោះមក បានតាំងនាង ទុកនៅក្នុងតំណែងជាភរិយា ។សេដ្ឋីធីតានោះ បានចំណាយទ្រព្យសម្បត្តិ នៅក្នុងផ្ទះរបស់មាតា និងផ្ទះរបស់លោកសេនាបតី ថ្វាយទានដល់ ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធានជារឿយៗ រហូតដល់នាងអស់ជីវិត លុះកាលនាងអស់ជីវិតទៅហើយ បានទៅកើតក្នុងទេវលោក សូម្បី នាងកើតឡើងនៅក្នុងទីកន្លែងណាក៏ដោយ តែងតែមានភ្លៀងផ្កាម្ទេះធ្លាក់

មកត្រឹមជង្គង់ ដូចនាងទៅកើតនៅក្នុងទេវលោក ក៏មានផ្កាម្ទិះធ្លាក់ចុះមកត្រឹមជង្គង់ដែរ ។ ពួកទេវតាគិតថា ទេពធីតានេះកាន់យកឈ្មោះរបស់ខ្លួនមកជាមួយផងដែរ ទើបដាក់ឈ្មោះឲ្យទេពធីតានោះថា **សុមនា** ។ សុមនាធីតាបានត្រាច់រង្គាត់នៅក្នុងមនុស្ស និងទេវតាអស់ ៩១ កប្ប មិនថានាងកើតក្នុងទីណាទេ តែងតែមានផ្កាម្ទិះធ្លាក់ចុះមកដូចគ្នា នាងទើបមានឈ្មោះថាសុមនាដូចមុន សូម្បីក្នុងគ្រាដែលនាងមកចុះចាប់បដិសន្ធិនៅក្នុងព្រះគភ៌ នៃព្រះអគ្គមហេសីរបស់ព្រះបាទបសេនទិកោសល ក្នុងថ្ងៃនោះ កុមារិកា ៥០០ នាក់ ក៏បានចុះមកចាប់បដិសន្ធិនៅក្នុងត្រកូលផ្សេងៗ ហើយប្រសូតចាកគភ៌មាតាក្នុងថ្ងៃជាមួយគ្នានឹងការប្រសូតិចាកព្រះគភ៌ ព្រះមាតារបស់ព្រះនាងសុមនារាជកុមារី និងក្នុងខណៈនោះផងដែរ ក៏មានភ្លៀងផ្កាម្ទិះធ្លាក់មកត្រឹមជង្គង់ ( អ្នកឲ្យទានរមែងចម្រើនដោយអាយុ វណ្ណៈ សុខ និងភាពជាធំ ) ។l ៙

( ជីវប្រវត្តិរបស់ព្រះនាងសុមនារាជកុមារី ចប់ )

8888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ឧបាសិកាចូឡសុភទ្ទា ✍

## " ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ "

*ឧបាសិកាចូឡសុភទ្ទា ជាអរិយសាវិកា ដែលមានភាពច្លាតឈ្លាស ចំពោះការប្រព្រឹត្តល្អ រហូតធ្វើឲ្យឪពុកក្មេកម្ដាយក្មេក និងបរិវារ នៅក្នុងត្រកូលស្វាមីរបស់នាងដែលជាមិច្ឆាទិដ្ឋិ ឲ្យត្រឡប់មកជាសម្មាទិដ្ឋិវិញបាន ទាំងដែលបានធ្វើឲ្យនៅក្នុងផ្ទះនោះ បើកទ្វារទទួលនិមន្តភិក្ខុសង្ឃ ដែលជាអ្នកបួសនៅក្នុងព្រះពុទ្ធសាសនានេះ ដោយសេចក្ដីពេញចិត្តយ៉ាងក្រៃលែងជាទីបំផុត ។*

*ជីវប្រវត្តិរបស់ឧបាសិកាចូឡសុភទ្ទា មានសម្ដែងប្រាកដនៅក្នុងអដ្ឋកថាធម្មបទ នៃ បកិណ្ណកវគ្គ ក្នុងរឿងរបស់នាងចូឡសុភទ្ទា ថា ៖*

*នាងចូឡសុភទ្ទា ជាធីតារបស់អនាថបិណ្ឌិកសេដ្ឋី ជាមួយនឹងនាងបុញ្ញលក្ខណាទេវី នៅក្នុងក្រុងសាវត្ថី ។ ពេលដែលនាងចម្រើនវ័យធំដឹងក្ដីហើយ បានទទួលនាទីពីអនាថបិណ្ឌិកសេដ្ឋីឲ្យជួយខ្វល់ខ្វាយ ក្នុងការ*

ប្រគេនភត្តដល់ភិក្ខុសង្ឃទាំងឡាយ ដែលនិមន្តមកក្នុងផ្ទះរបស់ខ្លួន ដោយលោកសេដ្ឋីមានការៈ គឺបានទទួលការអញ្ជើញទៅបុណ្យផ្សេងៗ នៅខាងក្រៅផ្ទះ ជាពិសេស គឺជាប់រវល់ការងារច្រើនមិនទំនេរឡើយ ។ នាងចូឡសុភទ្ទាបានចាត់ចែងថ្វាយទាន ស្តាប់ព្រះធម៌នៅជាប្រចាំ រហូតធ្វើឲ្យនាងបានសម្រេចជាព្រះសោតាបន្ន ។ ចំណែកស្វាមីរបស់នាងចូឡសុភទ្ទា ជាកូនប្រុសរបស់ឧគ្គសេដ្ឋី ដែលជាសម្លាញ់របស់អនាថ-បិណ្ឌិកសេដ្ឋី ដែលជាបិតារបស់នាងចូឡសុភទ្ទា ហេតុនោះ ឧគ្គសេដ្ឋី និងអនាថបិណ្ឌិកសេដ្ឋីធ្លាប់បានធ្វើកតិកាគ្នានិងគ្នាទុកមក ។សម័យដែលលោកទាំងពីរនៅពីកំលោះម៉្លេះ ។ ក្នុងសម័យដែលឧគ្គសេដ្ឋីនៅកំលោះនោះ លោកជាកូនប្រុសរបស់សេដ្ឋីឧគ្គនគរ ។ ចំណែកអនាថបិណ្ឌិកសេដ្ឋីពីដើមឈ្មោះថា **សុទត្តៈ** ជាកូនប្រុសរបស់សុមនសេដ្ឋី នៅក្នុងក្រុងសាវត្ថី ។ បុគ្គលទាំងពីរនោះ គឺឧគ្គៈ និងសុទត្តៈ ក្នុងពេលនៅជាកំលោះបានទៅរៀនសិល្បវិជ្ជា ក្នុងត្រកូលនៃអាចារ្យជាមួយគ្នា បានធ្វើនូវកតិកាដល់គ្នានិងគ្នាដូច្នេះថា បើយើងទាំងពីរនាក់ចម្រើនវ័យ រហូតដល់មានបុត្រា

និងបុត្រីហើយ យើងទាំងពីរនាក់នឹងចងជន្ទងជាមួយគ្នា បើអ្នកមានបុត្រា យើងមានបុត្រី យើងនឹងឲ្យកូនស្រីយើងទៅធ្វើជាភរិយារបស់កូនប្រុសលោក បើលោកមានបុត្រី យើងមានបុត្រា លោកត្រូវឲ្យកូនស្រីរបស់លោក មកធ្វើជាភរិយារបស់កូនប្រុសយើង ។ ក្នុងគ្រានោះ អ្នកទាំងពីរនាក់នោះដល់ហើយនូវវ័យ បានតាំងនៅក្នុងតំណែងជាសេដ្ឋីបន្តពីបិតារបស់ខ្លួន ។ ឧគ្គសេដ្ឋី កាលប្រកបនូវការធ្វើជំនួញ បានទៅកាន់ក្រុងសាវត្ថី ទៅដោយរទេះ ៥០០ ហើយបានទៅសម្រាកនៅក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី ។

ចំណែកអនាថបិណ្ឌិកសេដ្ឋី បានហៅនាងចូឡសុភទ្ទាជាកូនស្រីទី ២ បង្គាប់ថា នែកូន ឧគ្គសេដ្ឋីជាសម្លាញ់របស់បិតា ទុកស្មើជាបិតារបស់កូនចុះ កិច្ចដែលគួរធ្វើដល់លោកសេដ្ឋី បិតាប្រគល់ឲ្យជាភាររបស់កូនហើយ ។ នាងចូឡសុភទ្ទាបានទទួលយល់ព្រមថា ចាំះ ដូច្នេះហើយ នាងបានចាត់ចែងអាហារ ដែលមានម្ហូបទឹក ម្ហូបគោកជាដើម ដោយដៃរបស់ខ្លួន តាំងតែពីថ្ងៃដែលឧគ្គសេដ្ឋីមកកាន់ផ្ទះរបស់នាងៗ

បានចាត់ចែងនូវវត្ថុ មានផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបជាដើម ផងដែរដល់លោកសេដ្ឋី ពិតមែន ចាប់ផ្តើមអំពីថ្ងៃដែលឧគ្គសេដ្ឋីនោះ បានទទួលការចាត់ចែង ឬយកចិត្តទុកដាក់ពីនាងចូឡសុភទ្ទា ដូចជាទឹកសម្រាប់ងូត និងអាហារសម្រាប់បរិភោគ ជាពិសេស គឺកិច្ចការផ្សេងៗដទៃយ៉ាងប្រពៃទៀត ។ ឧគ្គសេដ្ឋីបានឃើញនូវចរិយាសម្បត្តិរបស់នាងចូឡសុភទ្ទានោះហើយ នឹកពេញចិត្ត ។ តមកថ្ងៃមួយ ឧគ្គសេដ្ឋីបានអង្គុយនិយាយលេងជាមួយនឹងអនាថបិណ្ឌិកសេដ្ឋី នូវពាក្យដែលជាទីនាំមកនូវភាពសប្បាយរីករាយ ថែមទាំងបាននិយាយជាស់តឿនរឭកថា ក្នុងពេលដែលយើងនៅពីកំលោះ យើងទាំងពីរនាក់បានធ្វើនូវកតិកាទុកដើម្បីកូនរបស់យើងមែនឬ ហើយទើបនិយាយសំដៅ សូមដណ្តឹងនាងចូឡសុភទ្ទា ឲ្យដល់កូនប្រុសរបស់ខ្លួនផងដែរ ។ តែថា ឧគ្គសេដ្ឋីជាមនុស្សមិច្ឆាទិដ្ឋិ ពេលដែលលោកបាននិយាយសូមដណ្តឹងនាងចូឡសុភទ្ទាពីលោកអនាថបិណ្ឌិកសេដ្ឋីៗ មិនទាន់សម្រេចចិត្តនឹងលើកនាងចូឡសុភទ្ទាឲ្យភ្លាមៗ ទេ ដោយបានចូលទៅគាល់ក្រាបទូលសេចក្តី

នោះ ឲ្យព្រះមានព្រះភាគទ្រង់ជ្រាប ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ឃើញឧបនិស្ស័យរបស់ឧគ្គសេដ្ឋីហើយ ទ្រង់ក៏បានអនុញ្ញាតទៅ ។ អនាថបិណ្ឌិកសេដ្ឋី បានមកប្រឹក្សាជាមួយនឹងភរិយា ហើយបានព្រមទទួលពាក្យរបស់ឧគ្គសេដ្ឋី អំពីការស្តីដណ្តឹងកូនស្រីនោះ ដោយបានកំណត់ថ្ងៃធ្វើនូវមង្គល ថែមទាំងបានធ្វើគ្រឿងតាក់តែង និងប្រគល់ទ្រព្យសម្បត្តិ គ្រឿងប្រើប្រាស់ ព្រមទាំងខ្ញុំប្រុស ខ្ញុំស្រី និងបរិវារជាច្រើនទៀត ដូចជាធនញ្ជយសេដ្ឋីឲ្យនូវធីតាឈ្មោះវិសាខា ហើយបញ្ជូនទៅជូនច្នោះដែរ ។ មុននឹងអនាថបិណ្ឌិកសេដ្ឋីបញ្ជូននាងចូឡសុភទ្ទាទៅកាន់ត្រកូលស្វាមី បានហៅនាងចូឡសុភទ្ទាមកហើយ ឲ្យឱវាទ ១០ ចំណុចថា ១- កូនមិនត្រូវនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ ២- កូនមិនត្រូវនាំភ្លើងខាងក្រៅចូលមកខាងក្នុង ៣- កូនគួរឲ្យដល់អ្នកដែលគួរឲ្យ ៤- កូនមិនគួរឲ្យដល់បុគ្គលដែលមិនគួរឲ្យ ៥- កូនគួរឲ្យដល់បុគ្គលដែលគួរ និងមិនគួរឲ្យដល់បុគ្គលដែលមិនគួរឲ្យ ៦- កូនគួរអង្គុយឲ្យសប្បាយ ៧- កូនគួរបរិភោគឲ្យជាសុខ ៨- កូនគួរ

ដេកឲ្យសប្បាយ ៩- កូនគួរបម្រើភ្លើង ១០- កូនគួរនមស្ការទេវតាខាងក្នុង ។ ( សេចក្ដីពិស្ដារចំពោះឱវាទទាំង ១០ ចំណុចនេះ ចូរមើលនៅក្នុងជីវប្រវត្តិរបស់មហាឧបាសិកាវិសាខាចុះ ) ។

លុះពេលអនាថបិណ្ឌិកសេដ្ឋី បានបញ្ជូននាងចូឡសុភទ្ទាទៅកាន់ត្រកូលខាងស្វាមីនោះ ក៏បានបញ្ជូនកុដុម្ពិក ៨ នាក់ទៅជាមួយដើម្បីឲ្យជាអ្នកធានាដោយពាក្យថា បើទោសរបស់កូនស្រីខ្ញុំកើតឡើងក្នុងផ្ទះនោះហើយ ពួកលោកត្រូវជួយកាត់សេចក្ដី ក្នុងរឿងដែលកើតឡើងនោះឲ្យបានល្អ ។ ក្នុងថ្ងៃដែលបានបញ្ជូននាងចូឡសុភទ្ទាទៅនោះ អនាថបិណ្ឌិកសេដ្ឋីបានថ្វាយមហាទានដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ហើយទើបបញ្ជូននាងចូឡសុភទ្ទាទៅកាន់ត្រកូលខាងស្វាមីព្រមដោយគ្រឿងសក្ការៈជាច្រើនទៀត ហាក់បីដូចជាការសម្ដែងនូវកស្ដុតាងរបស់ផលនៃអំពើសុចរិតកម្មទាំងឡាយ ដែលនាងចូឡសុភទ្ទាធ្លាប់បានធ្វើទុកមកហើយ ក្នុងភពមុនៗ ។ក្នុងពេលដែលនាងចូឡសុភទ្ទាបានធ្វើដំណើរទៅដល់ឧគ្គនគរដោយលំដាប់ មហាជននៅក្នុងត្រកូល

របស់ឪពុកក្មេក ម្តាយក្មេក ម្នាក់ៗ បានធ្វើការទទួលរាក់ទាក់យ៉ាងសម្បើម ។ ចំណែកនាងចូឡសុភទ្ទា កាលនឹងសម្តែងខ្លួន ឲ្យប្រាកដដល់ពួកអ្នកនគរទាំងអស់ ដូចជានាងវិសាខា ដើម្បីធ្វើឲ្យសិរីសម្បត្តិរបស់ខ្លួន ប្រាកដដល់មហាជនបានឃើញនោះ នាងបានឈរនៅលើរថដែលបរសំដៅចូលទៅកាន់ក្រុង ពេលដែលនាងបានទទួលនូវគ្រឿងបណ្ណាការ ដែលអ្នកនគរយកមកជូននោះ នាងក៏បានជូននូវវត្ថុដ៏សមគួរតបស្នង ដល់អ្នកទាំងអស់នោះទៅវិញផងដែរ ការធ្វើបែបនេះបានធ្វើឲ្យអ្នកនគរទាំងអស់ កើតមានការស្រឡាញ់ពេញចិត្តចំពោះនាង ។

ពេលឧគ្គសេដ្ឋីជាឪពុកក្មេករបស់នាងចូឡសុភទ្ទា ធ្វើសក្ការៈដល់ពួកអចេលក៏នោះ បានប្រើឲ្យអ្នកបម្រើទៅប្រាប់ដល់នាងចូឡសុភទ្ទាថា ចូឡសុភទ្ទាចូរមកថ្វាយបង្គំ នូវសមណៈទាំងឡាយរបស់ពួកយើង ។ នាងចូឡសុភទ្ទាគិតថា កាលមិនប្រាថ្នាដើម្បីចង់ឃើញនូវសមណៈអាក្រាតទាំងឡាយនោះ ដោយសេចក្តីអៀនខ្មាស ក៏មិនបានចេញទៅ ។ ឧគ្គសេដ្ឋីសូម្បីបានបញ្ជូនអ្នកបម្រើទៅប្រាប់នាងជារឿយៗ នាងក៏ប្រកែក

មិនព្រមទៅដដែល រហូតដល់កើតសេចក្ដីក្រោធឡើងនិយាយថា ពួកលោកចូរបណ្ដេញនាងចូឡសុភទ្ទាចេញពីផ្ទះយើងទៅភ្លាមៗ ។ នាងចូឡសុភទ្ទាគិតថា ឪពុកក្មេករបស់យើងមិនអាចអត់ទោសដល់យើងបានដោយមិនមានហេតុយ៉ាងនេះសោះ ហើយនាងបានឲ្យមនុស្សទៅហៅពួកកុដុម្ពិកទាំងនោះមក ហើយបានប្រាប់រឿងរ៉ាវទាំងអស់នោះ ឲ្យកុដុម្ពិកដែលមកតាមខ្លួនឲ្យបានជ្រាប ។ ចំណែកកុដុម្ពិកទាំងនោះដឹងថា នាងចូឡសុភទ្ទាមិនមានកំហុស ទើបប្រាប់ឲ្យលោកសេដ្ឋីបានជ្រាបថា នាងមិនមានកំហុសទេ ។ ឧគ្គសេដ្ឋីបានប្រាប់ភរិយាថា នាងចូឡសុភទ្ទាកូនប្រសារបស់យើងមិនព្រមទៅថ្វាយបង្គំ នូវសមណៈរបស់ពួកយើងទេ ព្រោះឃើញថា សមណៈរបស់ពួកយើង ជាអ្នកមិនមានសេចក្ដីអៀនខ្មាស ។ ភរិយារបស់លោកសេដ្ឋីគិតថា ពួកសមណៈរបស់នាងចូឡសុភទ្ទាតើមានសភាពយ៉ាងណាហ្ន៎ ដែលនាងតែងតែពោលសរសើរសមណៈទាំងនោះ ទើបប្រើបម្រើឲ្យទៅហៅនាងចូឡសុភទ្ទាមកសួរថា ពួកសមណៈរបស់នាងមានសភាពយ៉ាងណា បានជានាងតែងតែពោល

សរសើរហើយ សរសើរទៀត សមណៈទាំងនោះ មានសីលយ៉ាងណា មានមារយាទ យ៉ាងណា ? ចូរប្រាប់យើងមកមើល ! គ្រានោះ នាងចូឡសុភទ្ទា បានប្រកាសគុណទាំងឡាយរបស់ព្រះពុទ្ធអង្គ និងសាវករបស់ព្រះពុទ្ធដល់ឪពុកក្មេកម្ដាយក្មេកជាច្រើន រហូតធ្វើឲ្យឪពុកក្មេកម្ដាយក្មេកត្រេកអររីករាយដោយពាក្យទាំងនេះជាដើមថា

សមណៈរបស់ខ្ញុំ ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ ដំណើររបស់លោកស្ងប់ ជាអ្នកមានចក្ខុដាក់ចុះ ជាអ្នកពោលនូវសម្ដីជាទីរាប់អានជាប្រក្រតី សមណៈរបស់ខ្ញុំប្រាកដ ដូច្នោះ កាយកម្ម វចីកម្ម មនោកម្មស្អាតល្អប្រពៃណាស់ សមណៈរបស់ខ្ញុំប្រាកដដូច្នោះ លោកមានមន្ទិលប្រាសចាក ជាអ្នកស្មើដោយស័ង្ខខាត់ និងកែវមុក្ដា លោកស្អាតទាំងខាងក្នុង និងខាងក្រៅ ជាអ្នកពេញដោយធម៌ទាំងឡាយដ៏ស្អាត សមណៈរបស់ខ្ញុំប្រាកដដូច្នោះ លោកខ្ពស់ឡើងដោយលាភផង ទាបចុះដោយការមិន មានលាភផង លោកជាអ្នកតាំងនៅដោយការៈតែមួយ ដោយលាភ និងមិនមានលាភ សមណៈរបស់ខ្ញុំប្រាកដដូច្នេះ

លោកខ្ពស់ឡើង ព្រោះមានយសផង ទាបចុះដោយការមិនមានយសផង លោកតាំង នៅដោយការៈតែមួយ ដោយយស និងមិនមានយស សមណៈរបស់ខ្ញុំប្រាកដដូច្នោះ លោកខ្ពស់ឡើង ព្រោះដោយការសរសើរផង ទាំងទាបចុះដោយការនិន្ទាផង ជាអ្នកស្មើក្នុងការនិន្ទា និងការសរសើរផង សមណៈរបស់ខ្ញុំប្រាកដដូច្នោះ លោកខ្ពស់ឡើងដោយសុខផង ទាបចុះដោយទុក្ខផង ជាអ្នកមិនកម្រើកក្នុងសុខ និងទុក្ខផង សមណៈរបស់ខ្ញុំប្រាកដដូច្នោះឯង ។

ម្តាយក្មេករបស់នាងចូឡសុភទ្ទា បានស្តាប់ការពណ៌នាគុណនេះហើយ ទើបសួរនាងថា នាងអាចបង្ហាញសមណៈទាំងឡាយរបស់នាងដល់យើងបានឬទេ ? នាងចូឡសុភទ្ទាតបថា ចាំះ ម៉ែ បាន ។ឪពុកក្មេកទើបនិយាយថា ប្រសិនបើដូច្នោះ នាងចូរធ្វើដោយអាការដែលពួកយើងនឹងបានឃើញសមណៈទាំងឡាយរបស់នាង ។ នាងចូឡសុភទ្ទាពោលទទួលថា ចាំះ ល្អណាស់ ។ ហើយនាងត្រៀមអាហារទានដើម្បីភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ នាងបានឡើងទៅឈរនៅលើប្រាសាទជាន់

ខាងលើបែរមុខឆ្ពោះទៅកាន់វត្តជេតពន លើកដៃឡើងថ្វាយបង្គំដោយសេចក្តីគោរព ។ ក្នុងខណៈនោះ អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ធម្មីកថារបស់ព្រះសាស្តាហើយ បានក្រាបទូលនិមន្តព្រះសម្ពុទ្ធ ដើម្បីទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។ ពេលនោះ ព្រះសាស្តាត្រាស់ថា ម្នាលគហបតីតថាគតបានទទួលនិមន្ត ដើម្បីឆាន់កត្តនៅក្នុងថ្ងៃស្អែកនេះ ហើយអនាថបិណ្ឌិកសេដ្ឋី មានសេចក្តីសង្ស័យនៅក្នុងព្រះពុទ្ធតម្រាស់នោះទើបក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដទៃដែលមកមុនខ្ញុំព្រះអង្គ ដូចមិនឃើញមានទេ តើព្រះអង្គទ្រង់ទទួលនិមន្តរបស់នរណាទុក ព្រះអង្គ ? ព្រះសាស្តាទើបត្រាស់ថា ម្នាលគហបតី នាងចូឡសុភទ្ទាបាននិមន្តតថាគតទុករួចមកហើយ ។ ពេលអនាថបិណ្ឌិកសេដ្ឋីបានស្តាប់ព្រះពុទ្ធតម្រាស់ថា នាងចូឡសុភទ្ទា ដែលជាធីតារបស់ខ្លួនបានក្រាបទូលនិមន្តព្រះអង្គហើយ ក៏រឹងរឹតតែមានសេចក្តីសង្ស័យឡើងថែមទៀត ទើបក្រាបទូលសួរឡើងទៀតថា នាងចូឡសុភទ្ទានៅឆ្ងាយពីទីនេះប្រមាណ ១២០ យោជន៍ មិនមែនឬ ព្រះអង្គ ? ព្រះមានជោគ

ត្រាស់ថា ត្រូវហើយគហបតី សប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ រមែងប្រាកដដូចនៅក្នុងទីចំពោះមុខដែរ ហើយព្រះមហាមុនីទ្រង់ត្រាស់ព្រះគាថាទាំងនេះថា

ពួកសប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ រមែងប្រាកដដូចនៅក្នុងទីចំពោះមុខ ដូចជាភ្នំហិមពាន្តដូច្នោះដែរ ពួកអសប្បុរសទុកជានៅក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ ក្នុងវេលាយប់ ។

គ្រានោះ ម្ដាយក្មេករបស់នាងចូឡសុភទ្ទា បានស្ដាប់ពាក្យពណ៌នាគុណនេះហើយ ទើបសួរនាងថា តើនាងអាចបង្ហាញសមណៈទាំងឡាយ របស់នាងឲ្យយើងឃើញបានដែរឬទេ ? នាងចូឡសុភទ្ទាឆ្លើយថា អាចបានអ្នកម៉ែ ។ ម្ដាយក្មេកទើបនិយាយថា បើដូច្នោះ នាងចូរបង្ហាញនូវសមណៈរបស់នាង ឲ្យយើងបានឃើញដោយអាការយ៉ាងណាចូរបង្ហាញមកចុះ ។ នាងចូឡសុភទ្ទាព្រមទទួលថា សាធុ ដូច្នេះហើយនាងក៏បានចាត់ចែងមហាទាន ដើម្បីព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន

រួចហើយ នាងក៏បានទៅឈរនៅលើប្រាសាទជាន់ខាងលើ មានមុខឆ្ពោះទៅកាន់វិហារជេតពន បានថ្វាយបង្គំដោយសេចក្តីគោរព ថែមទាំងរឭករំពឹងដល់ព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ហើយបានបូជាដោយគ្រឿងក្រអូបទាំងឡាយផ្សេងៗ ហើយបានពោលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាអ្នកទ្រទ្រង់នូវគុណដ៏ប្រសើរបំផុត ខ្ញុំព្រះអង្គសូមនិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ដើម្បីទទួលចង្ហាន់ក្នុងថ្ងៃស្អែកនេះ ដោយសញ្ញារបស់ខ្ញុំព្រះអង្គយ៉ាងនេះ សូមព្រះមុនីទ្រង់ជ្រាបថា ខ្ញុំព្រះអង្គបានក្រាបទូលនិមន្តហើយៗ នាងបានបោះផ្កាម្លិះ ៨ ក្តាប់ ឡើងទៅលើអាកាស ផ្កាម្លិះទាំង ៨ ក្តាប់នោះ បានអណ្តែតទៅធ្វើជាពិតានផ្កាម្លិះបាំងនៅពីលើព្រះភគវា ដែលព្រះអង្គកំពុងតែសម្តែងនូវព្រះធម៌នៅក្នុងកណ្តាលបរិស័ទទាំង ៤ ពួកនោះទៅ ។

ក្នុងព្រះគាថានេះ មានពាក្យអធិប្បាយរបស់ព្រះអដ្ឋកថាចារ្យដើម្បីឲ្យយល់នៅក្នុងព្រះគាថានេះថា ពាក្យថា **សប្បុរសទាំងឡាយ** បានដល់ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម ឈ្មោះថា

សប្បុរស ព្រោះជាអ្នកស្ងប់រំងាប់កិលេស មានរាគៈជាដើម ឲ្យស្ងប់ហើយ ។ ចំណែកក្នុងព្រះគាថានេះ ព្រះមានព្រះភាគទ្រង់សំដៅដល់បុគ្គលទាំងឡាយ អ្នកមានកុសលមូលចម្រើនហើយ ឬអ្នកមានកុសលភាវនាចម្រើនហើយថា **ជាសប្បុរស** ។ ពាក្យថា **ប្រាកដ** គឺសប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយនោះ កាលមកកាន់គន្លងនៃញាណរបស់ព្រះពុទ្ធអង្គហើយ ឈ្មោះថា **រមែងប្រាកដ** ។ ពាក្យថា **ដូចជាភ្នំហិមពាន្ត** គឺភ្នំហិមពាន្តមានទំហំ ៣ ពាន់យោជន៍ មានកម្ពស់ ៥ រយយោជន៍ ដែលប្រដាប់ដោយកំពូលភ្នំ ៨ ម៉ឺន ៤ ពាន់កំពូល រមែងប្រាកដដល់មហាជនទាំងឡាយ ដែលនៅក្នុងទីឆ្ងាយ ហាក់បីដូចជាតាំងនៅក្នុងទីចំពោះមុខយ៉ាងណា សប្បុរសទាំងឡាយ ក៏រមែងប្រាកដដូច្នោះដែរ ។ ពាក្យថា **អសប្បុរសទាំងឡាយ សូម្បីនៅក្នុងទីជិតក៏រមែងមិនប្រាកដ** គឺបុគ្គលពាលជាអ្នកជូន់ក្នុងធម៌ជាបច្ចុប្បន្ន ( ទិដ្ឋធម្ម ) លះបង់លោកខាងមុខចេញ ជាអ្នកមានភ្នែកប្រឡាក់ហើយ ដោយអាមិសសូម្បីតែអ្នកបួសៗ ដើម្បីតែប្រយោជន៍នៃជីវិត ឈ្មោះថា **អសប្បុរស** ។

អសប្បុរសទាំងនោះ ទោះបីអង្គុយនៅក្នុងទីជិតព្រះលោកនាថហើយ រមែងមិនប្រាកដច្បាស់បាន ។ ពាក្យថា ដែលបុគ្គលបាញ់ទៅក្នុងរាត្រី គឺដូចកូនសរដែលបុគ្គលបាញ់ទៅក្នុងពេលដែលងងឹត គឺក្នុងថ្ងៃ ១៤-១៥ រោច ពេលអធ្រាត្រ ព្រៃក្រាស់ ជុំពពកអ័ព្ទ អសប្បុរសទាំងនោះ រមែងមិនប្រាកដ ព្រោះមិនមានបុព្វហេតុ ដែលជាឧបនិស្ស័យដូច្នោះដែរ ។ ក្នុងពេលដែលព្រះមុនីទ្រង់ត្រាស់សម្តែងព្រះគាថានេះចប់ មានបុគ្គលជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានព្រះសោតាបត្តិផលជាដើម ។

ចំណែកសក្កទេវរាជទ្រង់ជ្រាបថា ព្រះជិនស្រីទ្រង់ទទួលការនិមន្តរបស់នាងចូឡសុភទ្ទាហើយ ទើបត្រាស់បង្គាប់នូវវិស្សកម្មទេវបុត្រថា អ្នកចូរទៅនិម្មិតផ្ទះកំពូល ៥០០ ហើយចូរនិមន្តភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធានទៅកាន់ឧគ្គនគរក្នុងថ្ងៃស្អែកនេះ ។ លុះដល់ព្រឹកថ្ងៃស្អែកឡើង វិស្សកម្មទេវបុត្របាននិម្មិតផ្ទះកំពូលប្រមាណ ៥០០ ថែមទាំងទៅឈរនៅត្រង់ទ្វារនៃវត្តជេតពន ។ ព្រះសក្យមុនី ទ្រង់បានជ្រើសរើស

យកតែភិក្ខុ ដែលជាព្រះខីណាស្រពប្រមាណ៥០០រូប ហើយព្រះអង្គ ព្រមទាំងភិក្ខុសង្ឃជាបរិវារទៅគង់ប្រថាប់នៅក្នុងផ្ទះកំពូល ហើយស្តេច យាងទៅកាន់ឧគ្គនគរ ។ ចំណែកឧគ្គសេដ្ឋី ព្រមដោយបរិវារ កាល រមិលមើលផ្លូវជាទីស្តេចយាងមករបស់ព្រះសម្ពុទ្ធមិនឃើញ ព្រមទាំង បានឃើញការយាងមករបស់ព្រះសាស្តា ដែលមានភិក្ខុសង្ឃជាបរិវារ យ៉ាងច្រើនប្រមាណ ៥០០ រូប សុទ្ធសឹងតែជាព្រះខីណាស្រពប្រកប ដោយសិរីសម្បត្តិដ៏ធំដូច្នេះ ក៏មានចិត្តជ្រះថ្លាឡើង បាននាំគ្នាធ្វើសក្ការ គោរពបូជាដោយវត្ថុផ្សេងៗមានផ្កាកម្រងជាដើម ជាការទទួលព្រះមុនី ថ្វាយបង្គំហើយ បានថ្វាយមហាទាន ដោយលោកសេដ្ឋីបានក្រាបទូល និមន្តថ្វាយមហាទានទៀត រហូតដល់ ៧ ថ្ងៃ ។ ព្រះបរមគ្រូទ្រង់បានដឹង ពេលជាទីសប្បាយនៃឧគ្គសេដ្ឋី ហើយទើបទ្រង់សម្តែងព្រះធម៌ប្រោស ដល់លោកសេដ្ឋី មានបុគ្គលប្រមាណ ៨៤០០០ នាក់ មានឧគ្គសេដ្ឋី ជាដើម បានសម្រេចជាព្រះសោតាបន្ន ។ព្រះជិនវរដើម្បីនឹងទ្រង់អនុគ្រោះ ដល់នាងចូឡសុភទ្ទា ទើបត្រាស់ប្រាប់ដល់ព្រះអនុរុទ្ធថា ម្នាលអនុរុទ្ធ

អ្នកចូរស្នាក់នៅក្នុងទីនេះសិនចុះ ហើយព្រះពុទ្ធអង្គ បានស្តេចយាង មកកាន់ក្រុងសាវត្ថីវិញ ។ ចាប់ពីពេលនោះមក ឧគ្គនគរបានជានគរ ដែលមានមហាជន ជាអ្នកមានសទ្ធាជ្រះថ្លា នៅក្នុងព្រះពុទ្ធសាសនា យ៉ាងច្រើន ។ ( ខ្លឹមសារក្នុងព្រះគាថានៃរឿងនេះ សប្បុរសទោះបី នៅទីឆ្ងាយ ក៏ដូចនៅជិតដែរ ចំណែកបុគ្គលជាអសប្បុរស ទោះបីនៅ ទីជិត ក៏ហាក់បីដូចនៅទីឆ្ងាយដែរ ។

ជីវប្រវត្តិរបស់នាងចូឡសុភទ្ទា ដែលមានសេចក្តីទាក់ទងនឹង ការជួយឲ្យព្រះកិត្តិគុណ និងព្រះធម៌របស់ព្រះសាស្តា ប្រថាប់នៅក្នុង **កាឡការាម** នៅក្នុងក្រុងសាកេត ដើម្បីឲ្យបានជាប្រយោជន៍ដល់មហាជន តាមដែលមានរឿងសម្តែងប្រាកដទុកនៅក្នុង **អដ្ឋកថាមនោរថបូរណី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី **កាឡកសូត្រ** ក្នុង **គម្ពីរ អង្គុត្តរនិកាយ ចតុក្កនិបាត** ដូចមានសេចក្តីថា ៖

គ្រាមួយ នាងចូឡសុភទ្ទា ដែលជាធីតារបស់អនាថបិណ្ឌិកសេដ្ឋី ដោយនាងបានគិតឃើញថា យើងនឹងត្រូវទៅកាន់ផ្ទះត្រកូលរបស់បុត្រ

កាឡកសេដ្ឋី ( បាលីថា ឧគ្គសេដ្ឋី ) នៅក្នុងក្រុងសាកេត នាងទើប
ចូលទៅគាល់ព្រះមានព្រះភាគ ដើម្បីក្រាបទូលសូមប្តេជ្ញាថា បពិត្រ
ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងត្រូវទៅកាន់ត្រកូលមិច្ឆាទិដ្ឋិ បើខ្ញុំព្រះអង្គ
ធ្វើសក្ការៈក្នុងត្រកូលនោះ កាលបញ្ជូនអ្នកបម្រើណាម្នាក់មកក្រាបទូល
សូមនិមន្តហើយ សូមព្រះអង្គកុំឃើតយ៉ាវ និមន្តដោយសេចក្តីអនុគ្រោះ
ដល់ខ្ញុំព្រះអង្គផង ហើយនាងក៏ថ្វាយបង្គំលាត្រឡប់ទៅវិញទៅ ។
ឧគ្គសេដ្ឋីបានគិតថា កូនប្រសាស្រីរបស់យើងមកដល់ហើយ កាល
នឹងធ្វើមង្គលការ បានឲ្យមនុស្សទាំងឡាយរៀបចំអាហារជាច្រើន ហើយ
បានទៅអញ្ជើញពួកអចេលក៍ ៥០០ នាក់មកបរិភោគផងដែរ ។ ពេល
ពួកអចេលក៍ទាំងនោះមកអង្គុយនៅក្នុងផ្ទះរៀបរយអស់ហើយ ឧគ្គសេដ្ឋី
បានប្រើអ្នកបម្រើឲ្យទៅហៅនាងចូឡសុភទ្ទាថា នាងចូរមកថ្វាយបង្គំ
ព្រះអរហន្តទាំងឡាយរបស់យើង ។ ធម្មតាព្រះអរិយសាវិកាទាំងឡាយ
អ្នកបានសម្រេចអរិយផលហើយ លុះបានឮពាក្យថា ព្រះអរហន្ត
ក៏មានចិត្តត្រេកអររីករាយ ព្រោះដូច្នោះ នាងចូឡសុភទ្ទាបានគិតថា

ជាលាភរបស់យើងហើយ នាងបានក្រោកឡើងដើរទៅកាន់កន្លែងពួកអចេលក៍ ដែលអង្គុយនោះ លុះនាងបានឃើញពួកអចេលក៍ ជាអ្នកសម្តែងអាការមិនអៀនខ្មាសទាំងនោះ ទើបពោលឡើងថា ពុក ការពិតសមណៈទាំងនេះមិនមានហិរិ និងឱត្តប្បៈ ដោយនាងគិតទៀតថា ពួកអចេលក៍នេះមិនមែនជាសមណៈ ហើយនាងក៏បានស្តោះទឹកមាត់ចើ្ជយរួចក៏បានដើរត្រឡប់ទៅកាន់បន្ទប់របស់នាងវិញ ។ ចំណែកពួកអចេលក៍កាលបានជួបហេតុការណ៍ដូច្នេះ ទើបពោលទៅនឹងឧគ្គសេដ្ឋីថា នែលោកសេដ្ឋី ស្ត្រីកាឡកណ្ណីបែបនេះ លោកបាននាងមកពីណា ស្ត្រីដទៃនៅក្នុងជម្ពូទ្វីបទាំងអស់នេះ មិនមានឬ ? ឧគ្គសេដ្ឋីពោលថា បពិត្រលោកម្ចាស់ រឿងកូនប្រសាស្រីរបស់ខ្ញុំ បានធ្វើយ៉ាងនេះដាក់លោកម្ចាស់ព្រោះនាងមិនដឹងអីទេ សូមលោកម្ចាស់កុំប្រកាន់នឹងនាងអី ហើយលោកសេដ្ឋីបានអញ្ជើញឲ្យពួកអចេលក៍ត្រឡប់ទៅវិញ ចំណែកឧគ្គសេដ្ឋីបានចូលទៅរកនាងចូឡសុភទ្ទា ហើយបានសួរថា នែចូឡសុភទ្ទាហេតុអ្វីទើបបានជានាងធ្វើយ៉ាងនេះ ជាមួយនឹងព្រះអរហន្តរបស់យើង

ហើយធ្វើឲ្យពួកលោកអន់ចិត្តចំពោះយើងទៀតផង ? នាងចូឡសុភទ្ទា ពោលថា បពិត្រលោកឪពុក ជម្ទាតាព្រះអរហន្តទាំងឡាយ រមែងមិនធ្វើ ដូច្នោះទេ ។ លោកសេដ្ឋីទើបសួរថា សមណៈរបស់នាង តើមានសភាព បែបណាទៅវិញ ដែលនាងតែងតែពោលសរសើរនោះ សមណៈ ទាំងឡាយរបស់នាងមានសីលយ៉ាងណា មានការប្រព្រឹត្តយ៉ាងណា ? នាងចូរប្រាប់មកមើល៍ ! នាងចូឡសុភទ្ទាបាននិយាយប្រាប់ថា បពិត្រ លោកឪពុក សមណៈទាំងឡាយរបស់ខ្ញុំជាអ្នកមានឥន្ទ្រិយស្ងប់ មាន ចិត្តស្ងប់ហើយ ដំណើរលោកស្ងប់ហើយ ជាអ្នកមានចក្ខុដាក់ចុះហើយ ជាអ្នកពោលនូវសម្ដីជាទីរាប់អានជាប្រក្រតី ជាអ្នកនៅក្នុងព្រៃដូចជាដំរី ដែលដោះចំណងចងហើយ សមណៈទាំងឡាយរបស់ខ្ញុំនៅតែម្នាក់ឯង មិនមានអ្នកគម្រប់ពីរ ជាអ្នកមានចិត្តមាំទាំ ។ ពេលដែលនាងនិយាយ យ៉ាងនេះហើយ បានឈរប្រកាសគុណព្រះរតនត្រ័យនៅចំពោះមុខ របស់លោកសេដ្ឋីទៀត ។ លោកសេដ្ឋី ក្រោយអំពីបានស្ដាប់ហើយ ទើបពោលថា បើដូច្នោះ យើងនឹងនិមន្តសមណៈទាំងឡាយរបស់នាង

មកធ្វើមង្គល ។ នាងចូឡសុភទ្ទាបានសួរលោកសេដ្ឋីថា បពិត្រលោកឪពុក តើលោកឪពុកធ្វើមង្គលអង្កាល់ណា ? លោកសេដ្ឋីបានគិតជញ្ជីងរកមើលពេលវេលាហើយ ពោលថា នាងចាំ ២-៣ ថ្ងៃទៀត យើងនឹងឲ្យអ្នកបម្រើទៅប្រាប់ដល់នាង ។ កាលកន្លងទៅបាន ២-៣ ថ្ងៃ លោកសេដ្ឋីបានប្រើឲ្យអ្នកបម្រើទៅប្រាប់នាងចូឡសុភទ្ទាថា ថ្ងៃស្អែកនេះ យើងនឹងធ្វើមង្គល ។

ចំណែកនាងចូឡសុភទ្ទា ទើបឡើងទៅលើប្រាសាទជាន់ខាងលើក្នុងវេលាល្ងាច ដោយបានកាន់យកផ្កាម្លិះ ៨ ក្តាប់ទៅជាមួយផងនាងបានរឭកដល់គុណរបស់ព្រះពុទ្ធ ហើយនាងបានបាចផ្កាម្លិះទាំង ៨ ក្តាប់នោះឡើងទៅលើអាកាសហើយ បានប្រណម្យអញ្ជលី ព្រមទាំងពោលថា សូមព្រះមានជោគ ព្រមទាំងភិក្ខុសង្ឃប្រមាណ ៥០០ រូប សូមនិមន្តមកទទួលចង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ចំណែកផ្កាម្លិះទាំងនោះក៏បានអណ្តែតទៅធ្វើជាពិតាន នៅពីលើព្រះសាស្តា ។ កាលព្រះលោកនាថទ្រង់ពិចារណាមើល ក៏ទ្រង់បានជ្រាបនូវហេតុការណ៍

ទាំងនោះ ។ ក្នុងពេលព្រះមហាវីរបុរសទ្រង់សម្ដែងព្រះធម៌ចប់ហើយ អនាថបិណ្ឌិកសេដ្ឋី ទើបចូលទៅក្រាបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃស្អែកនេះ សូមព្រះសាស្ដា ព្រមទាំងភិក្ខុសង្ឃ ៥០០ រូប និមន្តទៅទទួលភត្តក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលគហបតី នាងចូឡសុភទ្ទា បាននិមន្តតថាគតទុករួចហើយ អនាថបិណ្ឌិកសេដ្ឋីទើបក្រាបទូលសួរថា ខ្ញុំព្រះអង្គមិនបានឃើញនរណាម្នាក់មកនិមន្តឡើយ ព្រះអង្គ ។ ពេលនោះ ព្រះលោកនាថត្រាស់ថា ម្នាលគហបតី ឧបាសិកាអ្នកជាសប្បុរស ទោះបីនៅទីឆ្ងាយប្រមាណមួយពាន់យោជន៍ ក៏ប្រាកដដូចជាភ្នំហិមពាន្ត គឺដូចជានៅជិតដូច្នោះដែរ ។ គ្រានោះ ព្រះសាស្ដាត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ពួកសប្បុរសទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយ រមែងប្រាកដដូចនៅក្នុងទីចំពោះមុខ ដូចជាភ្នំហិមពាន្តដូច្នោះដែរ ពួកអសប្បុរសទុកជានៅក្នុងទីជិត ក៏រមែងមិនប្រាកដ ដូចព្រួញដែលបុគ្គលបាញ់ក្នុងវេលាយប់ ។

អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ព្រះពុទ្ធតម្រាស់ដូច្នេះហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាអនុគ្រោះដល់ធីតារបស់ខ្ញុំព្រះអង្គចុះ ។ លុះលោកសេដ្ឋីក្រាបទូលដូច្នេះហើយក៏ក្រាបថ្វាយបង្គំលាត្រឡប់មកគេហដ្ឋានវិញ ។ ព្រះភគវាទ្រង់ត្រាស់ជាមួយនឹងព្រះអានន្ទថា ម្នាលអានន្ទ តថាគតនឹងទៅកាន់ក្រុងសាកេតអ្នកចូរចាត់ចែងសលាកឲ្យដល់ភិក្ខុ ៥០០ រូប កាលអ្នកចែកសលាកអ្នកគួរចែកឲ្យដល់ពួកភិក្ខុ ដែលបានសម្រេចអភិញ្ញា ៦ ប៉ុណ្ណោះ ។ ព្រះអានន្ទក៏បានធ្វើតាមព្រះពុទ្ធតម្រាស់បញ្ជានោះមែន ។ លុះដល់ពេលអធ្រាត្រ នាងចូឡសុភទ្ទាគិតរំពឹងដល់ព្រះសាស្តាថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានកិច្ចច្រើន យើងនឹងធ្វើដូចម្តេចហ្ន៎ទើបល្អ ។ ក្នុងខណៈនោះ ស្តេចវេស្សវ័ណបានប្រាប់ដល់នាងចូឡសុភទ្ទាថា នែនាងនាងកុំភ័យអី ព្រះជិនស្រីទ្រង់បានទទួលនិមន្តរបស់នាងហើយ នាងកុំបារម្ភអ្វីឡើយ ។ នាងចូឡសុភទ្ទាបានស្តាប់ពាក្យរបស់ស្តេចវេស្សវ័ណដូច្នេះហើយ ក៏មានចិត្តសប្បាយរីករាយ បានចាត់ចែងនូវទេយ្យធម៌

សព្វគ្រប់ប្រការ ទុកដើម្បីចាំថ្វាយទានចំពោះព្រះភគវា និងភិក្ខុសង្ឃ ដែលនិមន្តមក ។ ចំណែកសក្កទេវរាជ ក៏បានត្រាស់បញ្ជាឲ្យវិស្សកម្ម-ទេវបុត្រថា ព្រះសម្ពុទ្ធស្តេចយាងទៅកាន់ក្រុងសាកេត ដើម្បីប្រោសនាងចូឡសុភទ្ទា ដូច្នេះ លោកចូរនិម្មិតផ្ទះកំពូល ៥០០ ។ វិស្សកម្មទេវបុត្រក៏បានធ្វើតាមបញ្ជារបស់សក្កទេវរាជ ព្រះមានជោគមួយអន្ទើដោយភិក្ខុសង្ឃប្រមាណ ៥០០ រូប ដែលសុទ្ធសឹងតែជាអ្នកបានសម្រេចអភិញ្ញា ៦ ត្រូវនិមន្តទៅជាមួយនឹងព្រះលោកនាថទៅកាន់ក្រុងសាកេត គឺទៅដោយទិព្វយាន បានដល់ ផ្ទះកំពូល ។ នាងចូឡសុភទ្ទា កាលដែលព្រះលោកនាយក មួយអន្ទើដោយភិក្ខុសង្ឃនិមន្តទៅដល់ហើយ បានចាត់ចែងថ្វាយទានដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធានស្រេចហើយ នាងបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ត្រកូលស្វាមីរបស់ខ្ញុំព្រះអង្គ ជាត្រកូលមិច្ឆាទិដ្ឋិ ហេតុដូច្នេះ សូមព្រះអង្គទ្រង់មានសេចក្តីអនុគ្រោះ សម្តែងធម៌ប្រោសដល់ពួកអ្នកទាំងអស់នេះផងចុះព្រះអង្គ ។ ព្រះមុនី ទ្រង់បានសម្តែងធម៌ប្រោសដល់អ្នកទាំងអស់នោះ

ទៅតាមពាក្យក្រាបទូលអារាធនារបស់នាងចូឡសុភទ្ទា ។

គ្រានោះ ឧគ្គសេដ្ឋីពេលដែលស្តាប់ព្រះធម៌នោះចប់ហើយ ក៏បានសម្រេចអរិយផលជាព្រះសោតាបន្ន ថែមទាំងបានថ្វាយឧទ្យានរបស់ខ្លួន ដល់ព្រះមហាវីរបុរសទៀតផង ។ ចំណែកពួកអចេលក៍បាននាំគ្នាពោលឡើងថា ឧទ្យាននេះ លោកសេដ្ឋីបានឲ្យដល់ពួកយើងមុនហើយ ពួកគេក៏មិនព្រមចេញពីឧទ្យាននោះ ។ ឧគ្គសេដ្ឋី ទើបបញ្ជាឲ្យពួកអចេលក៍ទាំងអស់ចេញទៅ ដោយពោលថា ពួកលោកចូរទៅឲ្យពួកអចេលក៍ទាំងនោះចៀសចេញទៅ ដោយវិធីដែលគប្បីនាំចេញទៅពីឧទ្យានឲ្យបាន ហើយលោកសេដ្ឋីបានឲ្យកសាងវិហារនៅក្នុងឧទ្យាននោះ ក្រោយពីពួកអចេលក៍ចេញទៅអស់ហើយ ។ ពេលកសាងវិហាររួចស្រេចហើយ ឧគ្គសេដ្ឋីទើបប្រូចទឹកធ្វើឲ្យជា ព្រហ្មទេយ្យ ឧទ្ទិសថ្វាយហើយ វិហារនោះទើបមានឈ្មោះថា **កាឡការាម** ជាឈ្មោះរបស់លោកសេដ្ឋី ដែលជាអ្នកបានសាងថ្វាយទុកនៅក្នុងព្រះសាសនានេះ ។ ពេលដែលថ្វាយវិហារនោះរួចហើយ ព្រះសាស្តាទ្រង់បានគន់ប្រថាប់

នៅក្នុងកាឡការាម ទៅតាមកាលដ៏សមគួរ ។

ចំពោះរឿងរបស់ឧបាសិកាចូឡសុភទ្ទា កាលទ្រទ្រង់អាយុជីវិតមកដល់កាលដ៏សមគួរហើយ ក៏អស់ជីវិតទៅ បានទៅកើតនៅក្នុងទេវលោកទៅ ដោយអំណាចនៃសេចក្តីល្អរបស់នាង ដែលបានធ្វើទុករួចមកហើយ ៕៚

( ជីវប្រវត្តិរបស់ឧបាសិកាចូឡសុភទ្ទា ចប់ )

8888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់នាងបតិបូជិកា ✍

## " ជាឧបាសិកាម្នាក់ដ៏ឆ្នើមនៅក្នុងព្រះពុទ្ធសាសនានេះ "

រឿងរបស់នាងបតិបូជិកានេះ ជារឿងដែលកើតឡើង កាលព្រះលោកនាយកប្រថាប់គង់នៅក្នុងក្រុងសាវត្ថី ដោយព្រះអង្គប្រារព្ធនាងបតិបូជិកាឲ្យជាដើមហេតុ ហើយព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនាប្រោសដល់មហាជនទាំងឡាយ ដែលមកប្រជុំគ្នានៅក្នុងគ្រានោះ ដើម្បីឲ្យបានជាប្រយោជន៍ ។

ជីវប្រវត្តិរបស់នាងបតិបូជិកា មានសម្តែងទុកនៅក្នុង **អដ្ឋកថា** នៃ **បុប្ផវគ្គ** ក្នុងរឿងបតិបូជិកា ដូចមានសេចក្តីថា ៖

នាងបតិបូជិកា មុននឹងមកកើតជាមនុស្សលោកនេះ នាងធ្លាប់បានទៅកើតជាទេពធីតា នៅក្នុងស្ថានតាវត្តិង្ស បានជាភរិយារបស់មាលាភារីទេវបុត្រមួយអង្គ ក្នុងបណ្តាភរិយាទាំងអស់របស់មាលាភារីទេវបុត្រ ដែលមានចំនួន ១០០០ អង្គ ។ ថ្ងៃមួយ មាលាភារីទេវបុត្រ

ដែលមានស្រីទេពអប្សរ ១០០០ ហែហមជាបរិវារ ចូលទៅកាន់ឧទ្យាន មានស្រីទេពអប្សរ ៥០០ អង្គឡើងបេះផ្កា ស្រីទេពអប្សរ ៥០០ អង្គទៀត ចាំរើសផ្កាដើម្បីយកមកប្រដាប់ឲ្យដល់មាលាការីទេវបុត្រ ។ ក្នុងបណ្ដាទេពធីតាទាំងនោះ មានទេពធីតាមួយអង្គ ដែលឡើងទៅលើដើមផ្កា មានបតិបូជិកាទេពធីតារួមផងដែរ និងបតិបូជិកាទេពធីតាបានចុតិត្រង់ខាងលើមែកផ្កា ដែលនាងឡើងនុ៎ះនោះឯង ហើយចុះមកកើតក្នុងមនុស្ស ។ ឯសរីរៈរលត់ទៅដូចអណ្ដាតប្រទីប បានទៅបដិសន្ធិនៅក្នុងផ្ទៃស្ត្រីម្នាក់ នៅក្នុងក្រុងសាវត្ថី ។ ពេលដែលនាងកើតមកហើយក៏បានរឭកជាតិបានថា យើងធ្លាប់បានជាភរិយារបស់មាលាការីទេវបុត្រ ។ លុះដល់ពេលដែលនាងចម្រើនវ័យធំដឹងក្ដីហើយ បានខំប្រឹងប្រែងធ្វើកុសល ដោយប្រាថ្នាឲ្យទៅកើតនៅក្នុងសម្នាក់របស់ស្វាមីវិញ ។ សូម្បីនាងទៅកាន់ត្រកូលស្វាមីរបស់នាង ពេលដែលម្ដាយឪពុករៀបចំឲ្យហើយក៏ដោយ នាងតែងតែថ្វាយសលាកភត្ត បក្ខិកភត្ត និងវស្សាវាសិកភត្តជាដើម ហើយបានប្រាថ្នាថា សូមឲ្យបុណ្យនេះចូរជាបច្ច័យឲ្យខ្ញុំបានទៅកើត

នៅក្នុងសម្នាក់ស្វាមីរបស់ខ្ញុំវិញ ។ លំដាប់នោះ ភិក្ខុទាំងឡាយបាន ជ្រាបថា នាងនេះតែងតែប្រាថ្នាឲ្យបានទៅកើតនៅក្នុងសម្នាក់របស់ ស្វាមីនាងវិញ ទើបដាក់ឈ្មោះឲ្យនាងថា **បតិបូជិកា** ។នាងបតិបូជិកានោះ ក៏តែងតែទៅបដិបត្តិនៅក្នុងសាលាឆាន់ មានការតម្កល់ទឹក ក្រាលអាសនៈ ជាដើម អស់កាលជានិច្ច ។ សូម្បីមនុស្សឯទៀតមានបំណងដើម្បីនឹង ថ្វាយសលាកភត្តជាដើម ក៏តែងតែនាំនូវទេយ្យធម៌នោះមកប្រគល់ឲ្យ នាង ដោយពោលថា នាងចូរចាត់ចែងភត្តទាំងនេះ ដល់ភិក្ខុសង្ឃផង ។ សម័យខាងក្រោយមក ពេលដែលនាងបានរស់នៅជាមួយស្វាមី មិនយូរប៉ុន្មាននាងក៏បានតាំងគភ៌ឡើង ពេលដែលគភ៌គ្រប់ ១០ ខែ នាងក៏បានប្រសូតបុត្រប្រុសម្នាក់ ។ ក្នុងកាលដែលបុត្រនោះចេះដើរបាន នាងក៏បានបុត្រមួយទៀត ដោយទំនងនេះ នាងមានបុត្រទាំងអស់ ៤ នាក់ ។ ក្នុងថ្ងៃមួយ នាងបានថ្វាយទាន ធ្វើការបូជា ស្តាប់ព្រះធម៌ រក្សាសិក្ខាបទ ដល់ពេលល្ងាច នាងក៏បានធ្វើកាលកិរិយាដោយរោគម្យ៉ាង ហើយនាងក៏បានទៅកើតនៅក្នុងសម្នាក់ស្វាមីដើមរបស់នាងវិញ ដូច

បំណងដែលនាងប្រាថ្នាមែន ។ ចំណែកស្រីទេពអប្សរក្រៅពីនោះ ដែលកំពុងតែសប្បាយដោយការបេះផ្កាជាដើមមកប្រដាប់កាយ ។ គ្រានោះមាលាការីទេវបុត្រ បានឃើញនាងបតិបូជិកាមកហើយ ពោលថានាងបាត់មុខទៅណាតាំងពីព្រឹក ពេលនេះទើបបានជាឃើញ ? នាងបតិបូជិកាតបថា ខ្ញុំម្ចាស់បានចុតិទៅកើតនៅក្នុងមនុស្ស ។ មាលាការីទេវបុត្រសួរតទៅទៀតថា នាងនិយាយស្អី ? បតិបូជិកាតបថា គឺខ្ញុំម្ចាស់បានចុតិទៅកើតនៅក្នុងមនុស្ស ។ មាលាការីទេវបុត្រសួរទៀតថា នាងទៅកើតក្នុងទីណា ?នាងបតិបូជិកាតបថា ខ្ញុំម្ចាស់ទៅកើតនៅក្នុងត្រកូលម្នាក់នៅក្នុងក្រុងសាវត្ថី ។មាលាការីទេវបុត្រសួរថា តើនាងរស់នៅក្នុងក្រុងនោះអស់ កាលយូរប៉ុនណា ?នាងបតិបូជិកាតបថា ពេលដែលខ្ញុំម្ចាស់ប្រសូតចាកគភ៌របស់មាតា រហូតដល់ខ្ញុំម្ចាស់មានអាយុ ១៦ ឆ្នាំ ខ្ញុំម្ចាស់ក៏បានស្វាមី រួចបានទៅរស់នៅក្នុងត្រកូលស្វាមី រហូតមានបុត្រ ៤ នាក់ ខ្ញុំម្ចាស់បានធ្វើបុណ្យកុសល មានការឲ្យទានជាដើម ហើយតាំងសេចក្តីប្រាថ្នាឲ្យមកកើតក្នុងទីនេះវិញ ។មាលាការីទេវបុត្រសួរថា អាយុរបស់

មនុស្សមានប្រមាណប៉ុន្មាន ? នាងបតិបូជិកាតបថា អាយុរបស់មនុស្ស មានប្រមាណ ១០០ ឆ្នាំប៉ុណ្ណោះ ។ មាលាភារីទេវបុត្រសួរបញ្ជាក់ទៀតថា អាយុរបស់មនុស្សមានប្រមាណប៉ុណ្ណោះឯងឬ បតិបូជិកា ? នាងបតិបូជិកាតបថា ប៉ុណ្ណោះឯង ។ មាលាភារីទេវបុត្រសួរដល់ការរស់នៅ ឬការប្រព្រឹត្តរបស់មនុស្សតទៅទៀតថា បតិបូជិកា ពួកមនុស្សដែលមានអាយុប្រមាណប៉ុណ្ណោះ ពួកគេជាអ្នករស់នៅដោយសេចក្តីប្រមាទ ឬពួកគេចូលចិត្តធ្វើបុណ្យ មានការឲ្យទានជាដើមឬ ? នាងបតិបូជិកាតបថា ជាអ្នករស់នៅដោយសេចក្តីប្រមាទ ហាក់បីដូចជាខ្លួនឯងមានអាយុដល់មួយអសង្ខេយ្យ ឬថាដូចខ្លួនឯង មិនស្លាប់អ៊ីចឹង ។ មាលាភារីទេវបុត្របានស្តាប់ពាក្យនោះដូច្នេះហើយ ក៏បានកើតមានសេចក្តីសង្វេគថា ពួកមនុស្សមានអាយុប្រមាណ ១០០ ឆ្នាំ ប៉ុន្តែពួកគេជាអ្នកប្រមាទទៅវិញ ធ្វើយ៉ាងណាហ្ន៎ ពួកយើងនឹងផុតចាកទុក្ខបាន ។

## ការប្រៀបធៀបអាយុរវាងមនុស្ស និងទេវតានៅក្នុងស្ថានតាវត្តិង្ស

១០០ ឆ្នាំរបស់មនុស្ស = ១ យប់ ១ ថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស

ដោយ ៣០ រាត្រីជា ១ ខែ ១២ ខែជា ១ ឆ្នាំ ។ ១០០០ ឆ្នាំទិព្វ ជាប្រមាណអាយុរបស់ទេវតាជាន់តាវត្តិង្ស ១០០០ ឆ្នាំទិព្វនោះ ប្រសិនបើរាប់ប្រៀបធៀបជាមួយនឹងឆ្នាំមនុស្ស = ៣ កោដិ ៦ លានឆ្នាំ ។ ព្រោះដូច្នោះ ១ ថ្ងៃរបស់ទេវបុត្រនោះ ដោយកន្លងផុតទៅបានមួយស្របក់ប៉ុណ្ណោះ ។ សេចក្តីពិតសត្វដែលមានអាយុតិចយ៉ាងនេះ មិនគួរជាអ្នកមានសេចក្តីប្រមាទសោះ ។ លុះដល់ព្រឹកថ្ងៃស្អែកឡើង ពួកភិក្ខុទាំងឡាយបានចូលទៅកាន់ស្រុក បានឃើញសាលាឆាន់ មិនមានអ្នកណាចាត់ចែងឲ្យរៀបរយ សូម្បីអាសនៈក៏នៅមិនទាន់ក្រាល ទឹកឆាន់ក៏មិនទាន់តម្កល់ទុក ទើបសួរថា នាងបតិបូជិកាទៅណាហើយ ? ពពួកអ្នកស្រុកតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ នឹងឃើញនាងនៅក្នុងទីណាបាន បើពីល្ងាចម្សិលមិញនេះ នាកាលលោកម្ចាស់ឆាន់រួចហើយ និមន្តត្រឡប់ទៅវិញ នាងក៏បានធ្វើកាលកិរិយានៅក្នុងវេលាល្ងាចនោះឯង ។ គ្រានោះ ភិក្ខុដែលនៅជាបុថុជ្ជន ពេលដែលបានឮពាក្យដូច្នោះហើយ ថែមទាំងបានរឭកឃើញនូវឧបការៈរបស់នាងបតិបូជិកា

ក៏មិនអាចទប់ទឹកភ្នែកបាន ។ រីឯភិក្ខុជាព្រះខីណាស្រពបានកើតធម្មសង្វេគឡើង ។ ភិក្ខុទាំងនោះធ្វើភត្តកិច្ចរួចហើយ ត្រឡប់ទៅកាន់វិហារវិញ ដោយបាននាំគ្នាចូលទៅថ្វាយបង្គំព្រះមានជោគ រួចទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន នាងបតិបូជិកាដើរទៅដើរមក ដោយនាងបានមកធ្វើបុណ្យផ្សេងៗ មានការបោត់បែងរៀបចំក្នុងសាលាឆាន់ ដូចជាក្រាលអាសនៈជាដើមហើយនាងប្រាថ្នាដើម្បីឲ្យទៅកើតនៅក្នុងសម្នាក់ស្វាមីរបស់នាងវិញ ឥឡូវនេះ នាងបានស្លាប់ទៅហើយ តើនាងទៅកើតក្នុងទីណា ព្រះអង្គ ? គ្រានោះ ព្រះសម្មាសម្ពុទ្ធត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ នាងបតិបូជិកាបានទៅកើតក្នុងសម្នាក់របស់ស្វាមីនាងវិញហើយ ។ ភិក្ខុទាំងឡាយនោះ នៅមិនទាន់អស់ចិត្តចំពោះព្រះពុទ្ធតម្រាស់នោះ ទើបក្រាបទូលថា ក្នុងសម្នាក់របស់ស្វាមីនាងមិនឃើញព្រះអង្គ ។ ពេលនោះ ព្រះភគវាត្រាស់ចម្លលថា ម្នាលភិក្ខុទាំងឡាយ នាងបតិបូជិកា មិនបានប្រាថ្នាដើម្បីមកកើតក្នុងសម្នាក់ស្វាមីជាមនុស្សនេះទេ គឺប្រាថ្នាឲ្យទៅកើតនៅក្នុងសម្នាក់មាលាភារីទេវបុត្រ ដែលជា

ស្វាមីរបស់នាងនៅក្នុងស្ថានតាវត្តិង្ស គឺដោយនាងបានបេះផ្កាចាកឧទ្យាន ដែលជាទីកន្លែងកំពុងតែបេះផ្កា យកទៅប្រដាប់ឲ្យស្វាមីរបស់នាង ហើយ ឥឡូវនេះ នាងបានត្រឡប់ទៅកើតនៅក្នុងសម្នាក់មាលាភារីទេវបុត្រ ដែលជាស្វាមីរបស់នាងវិញហើយ ។ភិក្ខុទាំងឡាយនោះសួរបញ្ជាក់ថា ជាយ៉ាងនោះឬ ព្រះអង្គ ? ព្រះសាស្ដាត្រាស់ធានាថា ជាការពិតមែន ភិក្ខុ ។ ភិក្ខុទាំងឡាយបានក្រាបទូលថា គួរឲ្យសង្វេគណាស់ ព្រះអង្គ ជីវិតរបស់សត្វទាំងឡាយ មានប្រមាណតិចណាស់ ព្រះអង្គ ។បពិត្រ ព្រះអង្គដ៏ចម្រើន ព្រឹកម្សិលមិញនេះ នាងបានអង្គាសចង្ហាន់ដល់ពួកខ្ញុំ ព្រះអង្គនៅឡើយ លុះដល់ពេលល្ងាច នាងក៏បានស្លាប់ទៅដោយ រោគាពាធដែលកើតឡើង ព្រះអង្គ ។ គ្រានោះ ព្រះសាស្ដាត្រាស់ថា យ៉ាងនោះហើយ ម្នាលភិក្ខុទាំងឡាយ ជីវិតរបស់មនុស្សទាំងឡាយ មានប្រមាណតិចណាស់ ដោយហេតុនោះឯង មច្ចុ គឺសេចក្ដីស្លាប់ បានញ៉ាំងសត្វទាំងនេះមិនឲ្យឆ្អែតឆ្អន់ដោយវត្ថុកាម និងកិលេសកាម ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ រមែងតែងតែធ្វើឲ្យសត្វកន្ទក់

កន្ទេញទៅដូច្នោះឯង ហើយទើបព្រះភគវាទ្រង់ត្រាស់ព្រះគាថានេះថា

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

ក្នុងពេលដែលព្រះលោកនាយក ទ្រង់សម្តែងព្រះធម៌ទេសនានេះចប់ មានមហាជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ហើយព្រះធម៌ទេសនាក្នុងពេលនោះ ក៏បានជាប្រយោជន៍ដល់មហាជន ដែលមកប្រជុំគ្នានៅក្នុងទីនោះឯង ៕

( ជីវប្រវត្តិរបស់នាងបតិបូជិកា ចប់ )

8888888888888888888888888888888888888888

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៦

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានត្រៃចីវរជាដើម ក្នុងកិច្ចការងារជាធម្មទាន

❋ឧបាសក ឈុំ គីម គីមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុធា (ហៅអាហួយ)

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុនឃីម) ឧបាសិកា ណៃ គីមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ ឧបាសិកា ហម ឃិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ធា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដារី កញ្ញា អ៊ឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទថូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម+បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា+បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង+បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ធាន់ កាន់ជួន+បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ុង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

✵ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

✵ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គីមប៉ៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គីមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងងិម និងស្វាមី ព្រមទាំងកូនចៅ

✵ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

✵ឧបាសក ឡាំ ធៀន ឧបាសិកា សឹន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដារណ្ណ ឧបាសិកា ឡាំ ចាន់រ៉ារី

✵ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ួន ព្រមទាំងបុត្រ

ញោម ឥម្មុន្ទីនិងជូ ញោម ហាន ញោម វ៉ន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លីកញ្ញា នា ញោម ឆាង ញោម ធឹង ឡេង ញោម អៀម ញោម ភួង ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ឆាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម សុិន ញោម ភាព សារឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី

លោក ជែង ស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ឹង ហេ្គចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ឹង ស៊ុវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាងនិងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុកនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ផាង + ផាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ែ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នៀង+យាយ ធីង+គួង កាង+សើន គា+សៀង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ផាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ែ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមប៉ែ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ុង+នាង មឿន+អួន ប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+តាំង វេន+យុន+យាយ ធុច + យាយ យន
ញោម ហ៊ិន ស៊ិម ញោម អឿន គី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវ៉ាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី
ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាវ៉ា
ញោម ធាវ៉ា+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សាន្ទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា
# ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

ឧបាសិកា ធីក ស្រ៊ីន ព្រមទាំងកូនប្រុស អ៊ីង រិទ្ធី និងភរិយា

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ីងរិទ្ធារី ព្រមទាំងបុត្រ

ឧបាសក យឹម សំណាង ឧបាសិកា យឹម ឡូរ៉ា ព្រមទាំងបុត្រ

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីនា ព្រមទាំងបុត្រ

ឧបាសក ឈៀង សារឿន ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រ

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួង ព្រមទាំងបុត្រ

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ

ឧបាសិកា ម៉ី ចាន់រ៉ាវី ព្រមទាំងបុត្រ

ឧបាសិកា យ៉ក់ ស៊ីមូរ៉ា ព្រមទាំងបុត្រ

ឧបាសិកា វ៉ាន់ ចាន់ ព្រមទាំងបុត្រ

ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ធាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ
ឧបាសិកា យូ ស៊ាងនទួលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម
ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ
ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ
ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន

ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈឹន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក នាង រ៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ុន្ទរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ងិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ុម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ្គិច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ននៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

ឧបាសិកា ប៉ោ គឹមស៊ុន ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា និងចៅ

លោក ផូ ចាន់ថន លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លឹម ចាន់ឌី លោកស្រី ទេព ចិន្តា+បុត្រ ធីតា និងចៅ

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា លោកស្រី លឹម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន+កូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គឹមហ៊ាន+កូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័គ លោកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី+បុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ ងីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

លោក ស៊ារិត សឿន លោកស្រី ជុន បូណ៌មី ព្រមទាំងបុត្រ

ឧបាសិកា ធា ព្រមទាំងកូនក្មួយ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង+កូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំ ម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ជី ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង+កូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ លោកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ
ឧបាសិកា យន សាក ព្រមទាំងកូនចៅ
ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ
ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនក្មួយ
ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ
ឧបាសិកា ស៊ិន ឡាច ព្រមទាំងក្រុមគ្រួសារ
ឧបាសក ប៊ុន ប៊ួន ឧបាសិកា យុត សួរ ព្រមទាំងកូនចៅ
លោក ផាន សុបិន លោកស្រី សំ សុវណ្ណមល្លិកា+បុត្រ
បងស្រី ណៅ សុភី និង ប្អូនស្រី ណៅ សុផល
ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ
លោក ម៉ាន់ រិទ្ធី លោកស្រី អួន សារ៉េត ព្រមទាំងបុត្រ ធីតា
លោក ឱម ឡូត លោកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ ធីតា
លោក ម៉ាន់ សារឿន លោកស្រី ម៉ម សុជា+បុត្រ ធីតា
លោក ស៊ឹម សារ៉ាន់ លោកស្រី លី សុខរ៉េត ព្រមទាំងបុត្រ
ឧបាសក ទិត្យ លី ឧបាសិកា ហេង វណ្ណា ព្រមទាំងកូនចៅ
ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៊ុក ព្រមទាំងកូនចៅ

ឧ.សិ ប៉េ សារ៉ា ឧ.ស ម៉ី ធារី ឧ.សិ ម៉ៅ ណារី+កូនចៅ

ឧបាសក ប៉ែ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ ព្រមទាំងក្រុមគ្រួសារ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃ្លោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងបុត្រ ធីតា

លោក លឹម លី លោកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ ធីតា

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធធារី ព្រមទាំងកូនចៅ

ឧបាសិកា មាស ជី ព្រមទាំងកូនចៅ

ឧបាសិកា ទេព ធុនណារី ព្រមទាំងកូនចៅ

ឧបាសិកា អៀវ គឹមហេង យាយទ្រព្យ ព្រមទាំងកូនចៅ

លោក ទូច ថៃ លោកស្រី សុខ នី ព្រមទាំងកូនចៅ

លោក ផូ ប៊ុនធឿន លោកស្រី កង ស្រីអូន ព្រមទាំងកូនចៅ

លោក ពៅ វឌ្ឍា លោកស្រី ខិន សុផល ព្រមទាំងកូនចៅ

ឧបាសិកា ឈឹន សន ព្រមទាំងកូនចៅ

ឧបាសិកា ឡេង ស៊ីម ព្រមទាំងកូនចៅ

លោក ស៊ិន ឡោ លោកស្រី កុក សេងលី ព្រមទាំងកូនចៅ

លោក គិត សេដ្ឋ លោកស្រី យឹម សុភណា ព្រមទាំងបុត្រ

ឧបាសិកា ទូច គឹមយី ព្រមទាំងកូនចៅ

ឧបាសិកា កែ យ៉ុម ព្រមទាំងកូនចៅ

លោកស្រី អ៊ុង សុជាវី ព្រមទាំងកូនក្មួយ

លោក សាន់ វ៉ុន លោកស្រី អ៊ុង ស្រីពៅ

លោក ជុំ ឌី លោកស្រី ជឹម ណារី ព្រមទាំងបុត្រ

ឧបាសិកា គាំ នួន ព្រមទាំងកូនចៅ

លោក ជឹម វុធី លោកស្រី គង់ ណាគ្រី ព្រមទាំងបុត្រ

ឧបាសិកា ទូច អ៊ឹមអ៊ីម ព្រមទាំងកូនចៅ

លោក វិសាល និង ភរិយា

ឧបាសក រស់ ហុងអៀង ឧបាសិកា កា គឹមហេង+កូនចៅ

ឧបាសិកា អ៊ិត លៀងពិន ព្រមទាំងកូនចៅ

ឧបាសិកា ឆេង ម៉ែន យុន វដ្ឋារ៉ា ហៅ ដារ៉េត ព្រមទាំងបុត្រ

លោកស្រី ម៉ៅ សុធារី និង ស្វាមី ព្រមទាំងបុត្រ

លោកស្រី ចាន់ មាលី និង ស្វាមី ព្រមទាំងបុត្រ

លោកស្រី ស៊ុន សុធារី និង ស្វាមី ប្រមទាំងបុត្រ

ឧបាសិកា មុត សំអុន ព្រមទាំងកូនចៅ

ឧបាសិកា ទុំ លាន ព្រមទាំងកូនចៅ

ឧបាសិកា ឡាយ មួយ និង ស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ស្រេអែម ផល្លា ព្រមទាំងកូនចៅ

ឧបាសិកា ចាន់ សុភី ព្រមទាំងកូនចៅ

ឧបាសិកា សួន សុខយាង ព្រមទាំងកូនចៅ

ឧបាសក ធីង ផាត់ ឧបាសិកា ណុប សៀងហេង+កូនចៅ

លោកស្រី សួង សុភាព និងស្វាមី ព្រមទាំងបុត្រ

លោកស្រី សួង សុភី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា សាយ សុខលីម ព្រមទាំងកូនចៅ

ឧបាសក ថៃ ប៊ុនលី ឧបាសិកា សាយ សុខហួត+កូនចៅ

លោក ហេង ម៉ានិត និងភរិយា ព្រមទាំងបុត្រ

លោកស្រី យន់ សុភាវី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា តាំង សៀមគាវ ព្រមទាំងកូនចៅ

ឧបាសិកា ខ្នុរ សេរី និងស្វាមី ព្រមទាំងបុត្រ

លោក ឡឹង លោកស្រី ស្រីណា ព្រមទាំងបុត្រ

ឧបាសក ឃី គង់មា ឧបាសិកា សាម មុយពង+កូនចៅ

ឧបាសិកា ជា ប៊ិច ព្រមទាំងកូនចៅ

ឧបាសិកា ឃឹម តុន ហៅយាយ ប្រាក់ ព្រមទាំងកូនចៅ

ឧបាសិកា បេអិច ស៊ាង ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា
## ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ជីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគឹម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុជី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទនៅវត្តវិសុទ្ធិមគ្គមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ព្រះអង្គគ្រូចៅអធិការ វត្តវិសុទ្ធិមគ្គ ធម្មបាលោ សាន សប្បាយ

រួមទាំងញោមប្រុស ញោមស្រី និងបងប្អូនប្រុសស្រីផង

លោកឪពុក ហៀង លីបទៀង ព្រមទាំងកូនចៅ

អ្នកម្ដាយ ហ៊ួ រីម ព្រមទាំងកូនចៅ

អ្នកម្ដាយ ទិត ញ៉ែប ព្រមទាំងកូនចៅ

ឧបាសិកា ទៀង សុធម្មវិទ្ធ ព្រមទាំងកូនចៅ

ឧបាសិកា គី សុភិន ព្រមទាំងកូនចៅ

ឧបាសិកា អ៊ឹង វិជ្ជា ព្រមទាំងកូនចៅ

ឧបាសិកា ជីវ យ៉ា ព្រមទាំងកូនចៅ

រួមទាំងមាតាបិតា បងប្អូនប្រុសស្រី និងកូនចៅទាំងអស់

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការចេញធម្មទាន

| | |
|---|---|
| ១- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ២- ឧបាសិកា ប៉េង តាំងហៃ | ឧបាសិកា ហ៊ួ គីមហៀក |
| ៣- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ទា |
| ៤- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គីមហាប់ |
| ៥- ឧបាសិកា បួ ម៉ាឡា | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា ឡឹក ពេញចិត្ត |
| ៧- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៨- ឧបាសិកា កែវ កល្យាណ | ឧបាសិកា សៀក ឆាយគីម |
| ៩- ឧបាសិកា សឹន ចន្ទា | លោក ឡាំ ដាវណ្ណ |
| ១០-ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា តាំង ប៉ោងជីង |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវន្តី |
| ១២-ឧបាសិកា គី យក់បូយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ីង វិទ្ធារី | ឧបាសក បញ្ញា |
| ១៤-ឧបាសិកា វៀម ជុល | ឧបាសិកា ម៉ៅ នី |
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |

១៦-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ាន ណាម

១៧-ឧបាសិកា ស៊ួន កល្យាណ ឧបាសិកា ភួង កក្តី

១៨-ឧបាសក អ៊ឹង វ៉ែយ៉ា ឧបាសក កុយ សាមន

១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

តម្លៃបោះពុម្ពក្នុង ១ ក្បាល ១ $ × ៣០០០ ក្បាល = ៣០០០ $

ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨,០៨ ៨៨ ៧៧ ៩៩ ៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេច

ជាស្ថានពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៨៣៣ ទំព័រ ។

**-គម្ពីរសារត្ថសង្គហ:** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថានពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចហើយទាំង ២ ភាគ ដែលមានកម្រាស់រហូតទៅដល់ ៦០០ ទំព័រ ។

**-គម្ពីរអភិធម្មត្ថសង្គហ:** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថានពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦៥០ ទំព័រ ។

**-អភិធម្មត្ថសង្គហ:** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថានពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រ ។

**-គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថានពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច មានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

**-គម្ពីរមិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថានពរហើយ

គឺវាយកុំព្យូទ័ររួចជាស្រេច មានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នាដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៤៨ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ បានចំនួន ១០០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ ខ្ញុំព្រះករុណា អាត្មាភាព

## ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មួយភាគ ១

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ៣

-ប្រជុំកំណាព្យអ្នកកវីល្បីៗ

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

# ម្ចាស់សទ្ធាបរិច្ចាគប្រាក់ ជួយបោះពុម្ពសៀវភៅនេះ

*ដោយឧបាសិកា* **ឱម លក្ខណា** *នៅប្រទេស* **អូស្ត្រាលី** *បោះពុម្ពជីវប្រវត្តិពុទ្ធឧបាសិកា ភាគទី ៣ នេះ* **ចំនួន ៣000 ក្បាល** *ស្មើនឹងទឹកប្រាក់* **៣000 ដុល្លារ** *ជាធម្មទាន ដើម្បីជាការបូជាចំពោះគុណព្រះរតនត្រ័យ ឬឲ្យបានជាឧបនិស្ស័យល្អៗ ដូចជាប្រវត្តិពុទ្ធឧបាសិកាផងដែរ (ឲ្យបានសម្រេចអរិយធម៌) ដូច្នេះសូមឲ្យពុទ្ធបរិស័ទទាំងឡាយ ត្រេកអរនូវចំណែកធម្មទាននេះ ឲ្យបានស្មើៗ គ្នា ។ សូមអនុមោទនាធម្មទាន !!!*

**បោះពុម្ពជាធម្មទាន ៣000 ក្បាល**

**ក្នុងតម្លៃ ៣000 ដុល្លារ**

**រោងពុម្ព រមណី**

TEL : 012597431-088 92 92 334








# បានយល់ស្រុកព្រះ

ជ្រះថ្លាខ្លាំងណាស់ បានយល់ស្រុកព្រះ ជាតិភូមិសាស្តា

១៤ កន្លែង ៦៨ អង្គា បានក្រាបវន្ទា

បូជាគ្រប់ប្រាណ ។

សិរីលង្កា ១៤០ អង្គា ៩ ពុទ្ធស្ថាន

ជ្រះថ្លាខ្លាំងណាស់ ដែលពូកខ្ញុំបាន នមស្ការពុទ្ធស្ថាន

ក្នុងពុទ្ធសករាជ ២៥៥៥ ។

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត